# បទានុក្រមធម្មបទ

## ភាគទី ១

## អ-ឱ

ព្រះគ្រូសិរីសោភ័ណ ភិម តួរ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

រៀបរៀង

បោះពុម្ពលើកទី ៣ ចំនួន ២០០០ ច្បាប់

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៣៨ គ.ស. ១៩៩៤

# សេចក្តីបញ្ជាក់

## ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " បទានុក្រមធម្មបទ " នេះ ត្រូវបានបោះពុម្ពឡើងវិញ ក្នុងឆ្នាំ ១៩៩៤ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូតូស្ស៊ូជប៉ុន Japan Sotoshu Relief Committee (JSRC) និងមូលនិធិនៃតូយ៉ូតា (The Toyota Foundation) ។

គោលបំណងនៃការបោះពុម្ពឡើងវិញ ហើយចែកផ្សាយទូលាយទៅដល់មូលដ្ឋាន គឺសំដៅ :

- ផ្តល់អោយសិស្ស និងគ្រូ មានឧបករណ៍សំរាប់ស្រាវជ្រាវយ៉ាងល្អប្រសើរ ដើម្បីរៀន និងបង្រៀន ពោលគឺ មានមធ្យោបាយបកប្រែបាលីមកជាខ្មែរដោយខ្លួនឯងបានត្រឹមត្រូវ និងឆាប់រហ័ស ។
- រក្សាមរតកវប្បធម៌ អក្សរសាស្ត្រសាសនា អក្សរសាស្ត្រជាតិអោយគង់វង្សឡើងវិញ និងរីកចំរើន ។
- ពង្រីកចំណេះចេះដឹងទូទៅខាងភាសាបាលី ដែលជាចំណែកមួយជួយទ្រទ្រង់ភាសា អក្សរសាស្ត្រ និងការប្រតិបត្តិពុទ្ធសាសនា ក្នុងភាពបរិសុទ្ធត្រឹមត្រូវ ក្នុងចំណោមពុទ្ធមាមកជន ទាំងនៅទីក្រុង ទាំងនៅជនបទ ។

ការបោះពុម្ពក្នុងគ្រាទី ២ នេះ ពុទ្ធសាសនបណ្ឌិត្យ រក្សាអត្ថន័យខ្លឹមសារ ព្រមទាំងអារម្ភកថារបស់អ្នករៀបរៀងទាំងស្រុង ហើយបោះពុម្ពផ្សាយតាមភាគនីមួយៗ ជាបន្តបន្ទាប់ ។

សូមឧទ្ទិសសៀវភៅ " បទានុក្រមធម្មបទ " នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និង លើកស្ទួយអក្សរសាស្ត្រជាតិ ហើយជា

ពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពពិតប្រាកដ លើកម្ពុជា ។

សូមព្រះពុទ្ធសាសនា បានចំរើនរុងរឿងស្ថិតស្ថេរ ជាស្ថាពរ !

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនពេញលេញ ជោគជ័យ វិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និងលើកស្ទួយ ព្រះពុទ្ធសាសនា អោយបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

ដោយអានុភាពនៃកុសលកម្មនេះ សូមអោយវិញ្ញាណក្ខន្ធ របស់ព្រះគ្រូ សិរីសោភ័ណ គីម តួរ បានសំរេចឥដ្ឋមនុញ្ញផលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការជំនួយសូតូស៊ូជប៉ុន និង អង្គការតូយ៉ូតាហ្វោនដេហ្សិន ដែលបានជួយឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តម ដល់ការបោះពុម្ពសៀវភៅនេះ ។

*ភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ព.ស ២៥៣៨ គ.ស ១៩៩៤*

ពុទ្ធសាសនបណ្ឌិត្យ


## ごあいさつ

この本は、

トヨタ財団

からの御寄付により、曹洞宗国際ボランティア会によって印刷されました。

この本が、日本とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee ( JSRC ) with the contribution from

THE TOYOTA FOUNDATION

We pray that this book would contribute to the friendship with Cambodian people and their cultural preservation.

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ដោយមានការឧបត្ថម្ភពី

មូលនិធិ តូយ៉ូតា

យើងអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្ត-ភាពជាមួយប្រជាជនកម្ពុជា និង ថែរក្សាសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

# អារម្ភកថា

មុនដែលរៀបរៀងសៀវភៅនេះ ខ្ញុំមានយោបល់យល់ឃើញថា «នៅកម្ពុជរដ្ឋរបស់យើង ប៉ែកខាងរៀនភាសាបាលី មិនសូវសម្បូរវិធីក្បួនច្បាប់វិសេសប្លែកៗ សម្រាប់រៀន សម្រាប់មើល ដើម្បីឱ្យអ្នកសិក្សាងាយយល់ ងាយចូលចិត្តក្នុងវិធីរៀនភាសាបាលី ឱ្យទាន់សម័យនឹងគេនៅឡើយ», បើទុកជាមានខ្លះ ដូចជាសៀវភៅកច្ចាយនូបត្ថម្ភកជាដើម ក៏នៅតែមិនទាន់ជូនល្មមដល់អ្នកសិក្សាដែលមានក្នុងសម័យសព្វថ្ងៃនេះដែរ ដូច្នេះហើយបានជាលោកអ្នកសិក្សាភាសាបាលីនៅប្រទេសយើង មានដំណើរយឺត ក្រចេះ ក្រយល់ ។ នៅប្រទេសឯទៀតមានប្រទេសថៃជាដើម ថ្វីក៏គេរៀនភាសាបាលី មិនឆាប់ចេះ គឺមកពីប្រទេសគេសម្បូរវិធីក្បួនច្បាប់សម្រាប់មើល ជាជំនួយក្នុងការរៀនភាសាបាលីច្រើនបែប ច្រើនយ៉ាងណាស់ ហេតុនេះគួរឱ្យស្ងើចសរសើរដល់ស្នាដៃ និងសេចក្ដីព្យាយាមរបស់អ្នកប្រាជ្ញប្រទេសគេ ជាទីបំផុត ។

ឧប្បត្តិហេតុដែលបានពណ៌នាមកខាងលើនេះ ទុកដូចជាអាវុធ១ចូលមកប្រហារចាក់ចុចដល់ដួងចិត្តរបស់ខ្ញុំ នាំឱ្យខ្ញុំមានវីរិយភាពដ៏មាំក្នុងការធ្វើសៀវភៅនេះ១ គឺខ្ញុំយល់ឃើញថា «ប្រសិនជាបង្កើតឱ្យមានឡើង នឹងមានប្រយោជន៍យ៉ាងសំខាន់ដ៏ទូលំទូលាយដល់សិក្ខាកាមកុលបុត្រ ដែលត្រូវសិក្សាគម្ពីរធម្មបទជាទីបំផុត » ពិតមែនតែសៀវភៅនេះធ្វើចំពោះត្រឹមគម្ពីរធម្មបទទាំង ៨ ភាគ ក៏គង់មានឧបការៈជាច្រើនដល់គម្ពីរឯទៀតៗ ផងដែរ ។ ហេតុនោះការធ្វើសៀវភៅនេះ, ខ្ញុំបានរើសដកស្រង់ព្យញ្ជនៈពីក្នុងគម្ពីរធម្មបទ មករៀបរៀងទុកតាមលំដាប់អក្សរ ពួកស្រៈតាំងពី អ ដល់ ឱ, ពួកព្យញ្ជនៈតាំងពី ក ដល់ ឡ ; បានសម្មតឈ្មោះសៀវភៅនេះថា « *បទានុក្រមធម្មបទ* » ប្រែថា «បែបសម្រាប់ប្រើរកស័ព្ទផ្សេងៗ តាមលំដាប់បទ ( អក្សរ ឬ ព្យញ្ជនៈ )

ក្នុងគម្ពីរធម្មបទទាំង ៨ ភាគ » គឺជាបែបតម្រាប់អ្នកសិក្សាណា ដែលមានការងឿងឆ្ងល់មិនជាក់លាក់ចំពោះព្យញ្ជនៈណាមួយ មានលិង្គ, ធាតុ, បច្ច័យ, វិគ្គហៈ និងពាក្យប្រែជាដើម ។ អ្នកសិក្សានោះ អាចបើកសៀវភៅនេះមើល រកតាមលំដាប់អក្សរដែលខ្លួនសំដៅនោះ នឹងប្រទះឃើញភ្លាមៗ បានដោយងាយ ។ សៀវភៅនេះ, ខ្ញុំបែកជា ៣ ភាគគឺ ភាគទី ១ ពីអក្សរ អ ដល់ ឱ, ភាគទី ២ ពីអក្សរ ក ដល់ ន, ភាគទី ៣ ពីអក្សរ ប ដល់ ឡ ។ ការបំបែកជា ៣ ភាគ ដូច្នេះ ដើម្បីចៀសវាងកុំអោយសៀវភៅនេះ មានទំហំក្រាស់ពេកផង ឱ្យល្មមដល់កម្លាំងធនធាននៃអ្នកឧបត្ថម្ភក្នុងការបោះពុម្ពផង ទាំងធូរស្រាលដល់សិក្ខាកាមកុលបុត្រ អាចដាក់យកមកទុកមើលជាសម្បត្តិផ្ទាល់ខ្លួនបានផង ។

បទានុក្រមធម្មបទដែលខ្ញុំរៀបរៀងនេះ គឺបានលើកក្នុងគម្ពីរធម្មបទ វៀរលែងតែបទអាខ្យាតកិរិយា និង បទអព្យយស័ព្ទចេញ, ឯបទនាមនាមសុទ្ធតែប្រកបដោយវិភត្តិនាមទាំងអស់ ដូចអាចរិយស័ព្ទ ដែលប្រកបដោយវិភត្តិនាមថា « អាចរិយោ, អាចរិយំ, អាចរិយេហិ » ជាដើម ខ្ញុំរៀបរៀងកាត់វិភត្តិចេញឱ្យនៅត្រឹមតែ « អាចរិយ » ប៉ុណ្ណោះ ហើយប្រាប់លិង្គ, ធាតុ, បច្ច័យ, វាចក, ប្រែស័ព្ទ និងមានចងវិគ្គហៈខ្លះ ដោយអនុមត្តិ ។

ក្នុងឱកាសដែលកំពុងរៀបរៀងសៀវភៅនេះ ខ្ញុំបានយកអដ្ឋកថា និងយោជនាផ្សេងៗ, ពោះនាមអភិធានប្បទីបិកា, អភិធានប្បទីបិកា-សូចិ និង ធាតុប្បទីបិកា ជាដើម មកជាជំនួយផងដែរ ។

វេលាដែលខ្ញុំរៀបរៀងចប់ហើយ បានយកសៀវភៅនេះទៅប្រគេនសម្ដេចព្រះមហា សុ មេ ធា ធិ ប តី ចន្ទ្រនាយកគណៈមហានិកាយ ជ. ណាត វត្តឧណ្ណាលោម សូមឱ្យជួយពិនិត្យផ្ទៀងផ្ទាត់ឱ្យ, សម្ដេចក៏មានព្រះទ័យពេញព្រះទ័យពិនិត្យបានខ្លះ តែមិនចប់សព្វគ្រប់ទេ ដោយខណៈនោះ សម្ដេចកំពុងមានកិច្ចការរវល់ច្រើន ។ លុះដល់ពេលថ្ងៃដែលគេត្រូវការបោះពុម្ព ខ្ញុំបានខ្ចីយកសៀវភៅនេះមកវិញ ហើយបាន

ប្រគេនទៅព្រះទេពសត្ថា សួរ - បាយ, ព្រះមហាឧត្តមវិជ្ជា ប៉ាង - ខាត់ ព្រះគ្រូមុនីសោភ័ណ សេខ - ទាង សុំឱ្យលោកជួយពិនិត្យ ។ លោកទាំង ៣ អង្គនេះ ក៏មានសេចក្ដីខ្នះខ្នែង ជួយពិនិត្យខ្លះដែរ ។ ខ្ញុំមានអំណរគុណដ៏ក្រៃលែងចំពោះព្រះថេរៈទាំង ៣ អង្គនេះ និងអរគុណព្រះមហា ម៉ុ-សាយ ដែលជួយសរសេរចម្លងចេញពីសំណេររបស់ខ្ញុំមកជាអក្សរផ្ចង់ ជរាបដល់ចប់ថែមទៀត ។

បទានុក្រមធម្មបទនេះ ទើបនឹងកើតមានឡើងជាដំបូងបំផុតក្នុងកម្ពុជរដ្ឋ, ខ្ញុំមានសេចក្ដីសង្ឃឹមថា « ចំណេរកាលតទៅអនាគតខាងមុខ, ដោយកម្លាំងព្យាយាម និងការខ្នះខ្នែងអិះអកឫសស័ព្ទនីមួយៗ ក្នុងគម្ពីរធម្មបទរបស់ពួកវេយ្យាករណបណ្ឌិតជាន់ក្រោយ បទានុក្រមធម្មបទនេះ មុខជានឹងបានកើនចំរើនមេពាក្យបន្ថែមចូលមកទៀត ក្រែងនៅមានសល់ខ្លះដែលខ្ញុំដកស្រង់មករៀបរៀងមិនអស់ ព្រមទាំងជួយកែតម្រូវឱ្យមានរបៀប រៀបរយដ៏ត្រឹមត្រូវវិសេសវិសាលជាងនេះឡើងទៀតពុំខាន » ។

ទីបំផុតនៃអារម្ភកថានេះ, ខ្ញុំសូមឧទ្ទិសកុសលដែលកើតអំពីកម្លាំងនៃការព្យាយាមរៀបរៀងសៀវភៅនេះ ជូនចំពោះបុព្វការីទាំងឡាយមានមាតាបិតាជាដើម ដោយអានុភាពនៃកុសលនេះ សូមឱ្យអស់លោកជាបុព្វការីទាំងអម្បាលនោះ បានសំរេចឥដ្ឋមនុញ្ញផលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាត ! សូមឱ្យប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូល បានចំរើនល្អគួរស់ដុះដាលដោយវិជ្ជានិងវិបុលសុខគ្រប់ប្រការ កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ !

បទានុក្រមធម្មបទនេះ ខ្ញុំបានប្រគល់ឱ្យឧបាសក ប៉ោ-ហ៊ាត់ ចាត់ការបោះពុម្ពផ្សាយលើកទី ១ ។

វត្តឧណ្ណាលោម, ថ្ងៃអង្គារ ១០ កើត ខែទុតិយាសាឍ ឆ្នាំខាល ទោស័ក

ព.ស ២៤៨៣ ត្រូវនឹងថ្ងៃទី ៨ ខែសីហា គ.ស ១៩៤០

ព្រះគ្រូសិរីសោភ័ណ **គិម - គូ**

# អក្សរសង្ខេប
## ប្រើក្នុងបទានុក្រមនេះ

| | | |
|---|---|---|
| វិ.ស.អ. | គឺ | វិសេសន . សព្វនាម . អនិយម |
| អ.ស. | . | អព្យយ - សព្វនាម |
| កិ.វិ. | . | កិរិយាវិសេសនៈ |
| ប.សំ. | . | បកតិសំខ្យា |
| បូ.សំ. | . | បូរណសំខ្យា |
| បុំ. | . | បុំលិង្គ |
| ឥ. | . | ឥត្ថីលិង្គ |
| នបុំ. | . | នបុំសកលិង្គ |
| គុ. | . | គុណ ឬ គុណនាម |
| កិ. | . | កិរិយា ឬ កិរិយាស័ព្ទ |
| អ. | . | អព្យយកិរិយា ឬ អព្យយស័ព្ទ |
| វិ.ស.និ. | . | វិសេសន .សព្វនាម.និយម |
| និ. | . | និបាត |
| កា.ស. | . | កាលសត្តមី |
| ឥ.អា. | . | ឥ . អាគម |
| ហ.អា. | . | ហ . អាគម |
| ស.អា. | . | ស . អាគម |
| អា.ឥ. | . | អា . ឥត្ថីលិង្គ |
| ក.ស. | . | ក . សកត្ថ |
| អា.និ. | . | អាលេបននិបាត |

| | | |
|---|---|---|
| សិ.វិ. | គឺ | សិ. វិភត្តិនាម |
| តិ.វ. | . | តិ.វត្តមានា |
| តុ.ប. | . | តុ.បញ្ចមី |
| ឯយ្យ.ស. | . | ឯយ្យ.សត្តមី |
| អ.បរោ | . | អ.បរោក្ខា |
| អា.ហិ. | . | អា.ហិយេត្តនិ |
| ញ្ញ.អជ្ជ. | . | ញ្ញ.អជ្ជត្តនី |
| ស្សតិ.ភ. | . | ស្សតិ.ភវិស្សន្តិ |
| ស្សា.កា. | . | ស្សា.កាលាតិបត្តិ |
| និ.អា. | . | និគ្គហិត.អាគម |
| វិ. | . | វិគ្គហៈ |
| សំ.ស. | . | សំខ្យាសព្វនាម |
| ឧ.ស | . | ឧបសគ្គ |
| យ.អភិ. | . | យោជនាអភិធម្មត្ថវិភាវិនី |
| អ.សុ. | . | អដ្ឋកថាសុត្តន្តបិដក |
| ដី.វិ. | . | ដីកាវិសុទ្ធិមគ្គ |
| ស.និ. | . | ស.និបាត |
| អ.និ. | . | អ.និបាត |
| អ.វិ. | . | អដ្ឋកថាវិន័យ |
| ណិក.ស. | . | ណិក.សកត្ត |
| អ.ត. | . | អព្យយតទ្ធិត |
| អស.ន. | . | អសាធារណនាម |
| ត្ត.ហិ. | . | ត្ត.ហិយត្តនិ |
| អភិ.សុ. | . | អភិធានប្បទីបិកា.សុចិ |
| យ.វិ. | . | យោជនាវិន័យ |

# គ្រឿងសម្គាល់

< នេះសម្គាល់ថា « *មកពី* » ឬ « *កើតមកពី* » ;

> នេះសម្គាល់ថា « *ទៅជា* » ឬ « *កើតទៅជា* » ;

+ នេះសម្គាល់ថា « *និង* » ឬ «*ហើយ និង* » ; ដូចជា *រដ្ឋាភិបាល <រដ្ឋ + អភិបាល* ( មើលថា *រដ្ឋាភិបាល* មកពី *រដ្ឋ និង អភិបាល* ), *រដ្ឋ + អភិបាល > រដ្ឋាភិបាល* ( មើលថា *រដ្ឋ និង អភិបាល ទៅជា រដ្ឋាភិបាល* ) ជាដើម ។

វណ្ណយុត្តិក្រៅពីនេះ មិនបានលើកយកមកពន្យល់ទីនេះទេ ព្រោះធ្លាប់ប្រើថ្មីកមកហើយ ។

**អកណ្ហនេត្ត** គុ. [ អកណ្ហ+នេត្ត ] អ្នកមាននេត្រមានពណ៌ខ្មៅមិនមាន, អ្នកមាននេត្រមិនខ្មៅ, ព្រះរាជាមាននេត្រមិនខ្មៅ ; វិ. **អកណ្ហំ នេត្តំ យស្ស សោ > អកណ្ហនេត្តោ** ។ **នេត្ត** < នី + ត = អវយវៈតែងនាំទៅ ( ភ្នែក ) ; វិ. **នេតីតិ > នេត្តំ** ។

**អកតញ្ញូ** គុ. [ ន>អ+កត+ញា+រូ ] អ្នកមិនដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ; វិ. **ន កតំ ឧបការំ ជានាតីតិ > អកតញ្ញូ** ។ អកត + ញា + រូ = អ្នកដឹងនូវព្រះនិព្វាន ដែលបច្ច័យមិនធ្វើហើយ, វិ. **អកតំ និព្វានំ ជានាតីតិ>អកតញ្ញូ** ។

**អកត** គុ. [ ន+ករ+ត ] គឺ...មិនធ្វើហើយ, វិ. **ន ករីយិត្ថាតិ>អ-កតោ, -តា, -តំ** ។ **-ត្ត** នបុំ. ភាវៈនៃ..ជា ...គឺ...មិនធ្វើហើយ **-បក្ការ** បុំ. ពួកដែល...មិនធ្វើហើយ ។ **-បាបកម្ម** គុ. អ្នកមានបាបកម្មមិនធ្វើហើយ, អ្នកមានអំពើអាក្រក់មិនធ្វើហើយ, វិ. **បាបំ កម្មំ > បាបកម្មំ, អកតំ បាបកម្មំ យេន សោ > អកត-បាបកម្មោ** ។ **-ភាវ** បុំ. ភាវៈនៃ... ជា... គឺ... មិនធ្វើហើយ ។ **-បុញ្ញ** នបុំ. បុណ្យគឺ...មិនធ្វើហើយ, គុ. មានបុណ្យមិនធ្វើហើយ -ល- ។

**អកត្តព្វ** គុ. [ ន+ករ+តព្វ ] គឺ...មិនគប្បីធ្វើ; -មិនត្រូវធ្វើ, -មិនគួរធ្វើ ។ **-យុត្តក** គុ. ដែលគួរតែ...មិនគប្បីធ្វើ ។ **-កម្ម** នបុំ. កម្មគឺ...មិនគប្បីធ្វើ ។ **-រូប** គុ. មានសភាពគឺ... មិនគប្បីធ្វើ ។ល។

**អកត្វា** អ. [ ន+ករ+ត្វា ] មិនធ្វើហើយ, កុំធ្វើឡើយ ។

**អកត្ថ** កិ. [ អ+ករ+អ+ ត្ថ.អជ្ជ. ] បានធ្វើហើយ ។

**អកថន** នបុំ. [ ន+កថ+យុ ] កិ.មិនពោល, កិ.មិននិយាយ, វ. **ន កថយ-តេតិ > អកថនំ** ។

**អកថំកថី** បុំ. [ ន+កថំ+កថំ+ណី ] អ្នកមិនប្រព្រឹត្តទៅយ៉ាងនេះថានេះដូចម្ដេចនេះដូចម្ដេច; វ. **កថមិទំ កថមិទន្តិ ឯវំ នប្បវត្តតីតិ > អកថំកថី** ។ អ្នកមានសេចក្ដីសម្គាល់ថានេះ ដូចម្ដេចនេះដូចម្ដេចមិនមាន; វ. **កថមិទំ កថមិទន្តិ សញ្ញា > កថំកថី, នត្ថិ កថំកថី ឯតស្សាតិ > អកថំកថី** ។ ន័យខ្លះទៀតថា : **អកថំកថី** < ន + កថំ+ កថ + ណី = អ្នកមិនមានវាចាជាហេតុពោលថានេះដូចម្ដេច ឬដោយប្រការដូចម្ដេច ( មិនមានសេចក្ដីសង្ស័យ ); វ. **កថមិទន្តិ កថេតិ ឯតាយាតិ > កថំកថា, កថំកថា ឯតស្ស អត្ថីតិ > កថំកថី, ន កថំកថី > អកថំកថី** ។ អ.សុ. ។

**អកថិត** គុ. [ ន+កថ+ឥ+ត ] គឺ... មិនពោលហើយ, -មិនប្រាប់ហើយ ។



**អកថេតុំ** អ. [ ន+កថ+អ, អ > ឯ+តុំ ] ដើម្បីមិនពោល, កិ.មិនពោល ។

**អកថេត្វា** អ. [ ន+កថ+អ >ឯ+ត្វា ] មិនពោលហើយ, មិនប្រាប់ហើយ ។

**អកនិដ្ឋ** គុ. [ ន+ខុទ្ទក>កន+ឥដ្ឋ ] មានភាវៈនៃភពតូចដោយវិសេសមិនមាន, មិនមានភាវៈនៃភពតូចដោយវិសេស, វ. **អយញ្ច ខុទ្ទកោ អយញ្ច ខុទ្ទកោ អយមិមេសំ វិសេសេន ខុទ្ទកោតិ > កនិដ្ឋោ, កនិដ្ឋស្ស ភាវោ > កនិដ្ឋភាវោ, នត្ថិ ឯតេសំ កនិដ្ឋភាវោតិ > អកនិដ្ឋោ** ។ ( ភពឈ្មោះអកនិដ្ឋ, ឋានសុទ្ធាវាសជាន់ទី៥ ) ។ អ.សុ. ។ **-ព្រហ្មលោក** បុំ. ព្រហ្មលោកជាន់អកនិដ្ឋ, -ឈ្មោះអកនិដ្ឋ ។ **-ភវន** នបុំ. ភពឈ្មោះអកនិដ្ឋ, ឋានជាទីកើតនៃព្រហ្មឈ្មោះអកនិដ្ឋ, ( ភវន < ភូ + យុ ) ។

**អកប្បិយ** គុ. [ ន+កប្ប+ណ្យ+ឥ.អា. ] របស់ដែលបុគ្គលមិនគប្បីសម្រេច, ដែលមិនគួរ, មិនសមគួរ, មិនសមរម្យ ។ **-ភណ្ឌ** នបុំ. ភណ្ឌៈ (ទ្រព្យ, របស់) -ដែលមិនគួរ ។ **-ភោជន** នបុំ. ភោជនមិនគួរ ។ **-ចីវរ** នបុំ. ចីវរមិនសមគួរ ។

**អកម្ប** គុ. [ ន+កម្ប+អ ] ដែលមិនញាប់ញ័រ, មិនកម្រើក ។

**អកម្បិយ** គុ. [ ន+កម្ប+ណ្យ+ឥ.អា. ] គឺ...មិនគប្បីឲ្យញាប់ញ័រ, -មិនគប្បីឲ្យកម្រើក ។ **-ភាវ** បុំ. ភាវៈនៃ...ជាអ្នកគឺ...មិនគប្បីឲ្យញាប់ញ័របាន ។

**អកម្ហ** កិ. [ អ+ករ+អ+ម្ហ..កើ. ] បានធ្វើហើយ ។

**អករណ** នបុ. [ ន + ករ + យុ ] កិ.មិនធ្វើ ( មិនមែនជាអំពើ ); វិ. **ន ករីយតីតិ > អករណំ** ។ - **កម្ម** នបុ. កម្មគឺកិ.មិនធ្វើ ។ -**ដ្ឋាន** នបុ. ទីជាទីមិនធ្វើ, ទីមិនមែនជាទីធ្វើ ។ - **អត្ថ** បុ. ប្រយោជន៍ដល់កិ.មិនធ្វើ, ត្រូវការដល់កិ.មិនធ្វើ ។

**អករម្ហា** កិ. [ អ+ករ+អ+ម្ហា.អជ្ជ. ] បានធ្វើហើយ ។

**អកត្វា** អ. [ ន+ករ+ត.អា+ត្វា ] មិនធ្វើហើយ ។

**អកត្ថ** កិ. [ អ+ករ+ត.អា.+ត្ថ.អជ្ជ. ] បានធ្វើហើយ ។

**អករិស្ស** កិ. [ អ+ករ+ត.អា+ស្សា.កា > ស្ស ] នឹងបានធ្វើហើយ ។

**អករោន្ត** គុ. [ ន+ករ+ឱ+អន្ត ] កាលមិនធ្វើ ។

**អកំសុ** កិ. [ អ+ករ+អ+ឧំ.អជ្ជ.> អំសុ ] បានធ្វើហើយ ។

**អកាតុំ** អ. [ ន+ករ+តុំ ] ដើម្បីមិនធ្វើ, កិ.មិនធ្វើ ។

**អកាមក** បុ. នបុ. [ ន+កម+ណ្វុ>អក ] អ្នកមិនប្រាថ្នា, អ្នកមិនត្រូវការ, អ្នកមិនចង់បាន, វិ. **ន កាមេតីតិ > អកាមកោ** ។ គុ.មានសេចក្ដីប្រាថ្នាមិនមាន, មិនមានសេចក្ដីត្រូវការ, វិ **នត្ថិ កាមោ ឯតស្សាតិ > អកាមកោ** ។

**អការក** បុ, នបុ.[ ន+ករ+ណ្វុ ] អ្នកមិនធ្វើ, មិនមែនអ្នកធ្វើ; វិ. **ន ករោតីតិ > អការកោ** ។ - **ភាវ** បុ. ភាវៈនៃ...ជាអ្នកមិនធ្វើ ។



**អការណ** នបុ. [ ន+ករ+យុ ] កិ.មិនធ្វើ ។ គុ. មិនមែនជាហេតុ, មិនមែនជាការណ៍, មិនមានហេតុ ។

**អការិយ** គុ. [ ន+ករ+ណ្យ+ត.អា. ] ( អំពើ ) ដែល... មិនគប្បីធ្វើ, វិ. **ន កាតព្វន្តិ > អការិយំ** ។

**អការេត្វា** អ. [ ន+ករ+ណេ+ត្វា ] មិនញ៉ាំង... ឲ្យធ្វើហើយ ។

**អកាល** គុ. [ ន + កាល ] មិនមែនជាកាល, សម័យមិនមែនជាកាល, វិ. **ន កាលោ> អកាលោ** ។ បុ. កាលមិនគួរ, វិ.**អយុត្តោ កាលោ> អកាលោ** ។ - **វកុក្កុដជាតក** នបុ. ជាតកគឺបណ្ឌិតកំណត់ហើយដោយមាន់រងាវក្នុងសម័យមិនមែនជាកាល ឬក្នុងកាលមិនគួរ ។

**អកាសិ** កិ. [ អ+ករ+អ+ឦ.អជ្ជ.+ស.អា.] បានធ្វើហើយ ។

**អកិច្ច** គុ. [ ន+ករ+រិច្ច ] (អំពើ) ដែល...មិនគប្បីធ្វើ, (មិនមែនជាកិច្ច); វិ. **ន កត្តព្វន្តិ> អកិច្ចំ** ។ នបុ. កិច្ចមិនគួរ, វិ. **អយុត្តំ កិច្ចំ >អ. កិច្ចំ** ។

**អកិច្ឆ** គុ. [ ន+កិរ+ច្ឆ ] ធម្មជាតិមិនបោះបង់នូវសុខ, (មិនលំបាក, មិនក្រ, មិនត្រដាបត្រដួស); វិ. **កិរតិ សុខន្តិ>កិច្ឆំ, ន កិច្ឆំ>អកិច្ឆំ** ។

**អកិញ្ចន** គុ. [ ន+កិច្ច>កិញ្ច+យុ ] មានកិលេសជាតជាគ្រឿងកង្វល់មិនមាន, មិនមានកិលេសជាតជាគ្រឿងកង្វល់; វិ. **កិញ្ចតិ ឯតេនាតិ** >

កិញ្ចនំ, នត្ថិ កិញ្ចនំ ឯតស្សាតិ> អកិញ្ចនោ ។ មានសេចក្ដីកង្វល់មិនមាន, មិនមានសេចក្ដីកង្វល់; វិ. កិញ្ចយតេតិ > កិញ្ចនំ, នត្ថិ កិញ្ចនំ ឯតស្សាតិ> អកិញ្ចនោ ។

អកិត្តិ ឥ. [ ន+កិត្តិ ] មិនមែនវាចាជាគ្រឿងសរសើរ ឬ មិនមានវាចាជាគ្រឿងសរសើរ (សេចក្ដីតិះដៀល, ជំនៀល); វិ. កិត្តេតិ ឯតាយាតិ> កិត្តិ, ន កិត្តិ> អកិត្តិ, នត្ថិ កិត្តិ ឯតស្សាតិ វា > អកិត្តិ ។ កិត្តិ < កិត+តិ ។

អកិរិយវាទ គុ. [ ន+កិរិយ+វាទ ] អ្នកមានវាទៈថាកម្មដែលបុគ្គលធ្វើហើយ មិនមែនឈ្មោះថាគឺបុគ្គលធ្វើ; វិ. ន កតំ កម្មំ ករិយតីតិ វាទោ អស្សាតិ > អកិរិយវាទោ ។

អកិលមថ នបុំ. [ ន+កិលម+ថុ ] កិ.មិនលំបាក, សេចក្ដីមិនលំបាក, ការមិនឿយហត់; វិ. ន កិលមយតេតិ >អកិលមថំ ។ -ភាវ នបុំ. ភាវៈនៃកិ.មិនលំបាក... ។

អកិលន្ត គុ. [ ន+កិលម+ត>ន្ត ] មិនលំបាកហើយ, មិនឿយហត់ហើយ ។

អកិលមេត្វា អ. [ ន+កិលម+ណេ+ត្វា ] មិនលំបាកហើយ, មិនញុំាង...ឲ្យលំបាកហើយ ។

អកុដិល គុ. [ ន+កុដិល ] ដែលមិនវៀច, មិនកោង ។ -តា ឥ. ភាវៈនៃ...ជា...មិនវៀច ។



អកុទ្ធ គុ. [ ន+កុធ+ត>ទ្ធ ] គឺ... មិនក្រោធហើយ, . មិនខឹងហើយ ។ -មានស គុ. មានចិត្តមិនក្រោធហើយ, មានឆន្ទៈមានក្នុងចិត្តមិនក្រោធហើយ, វិ. អកុទ្ធំ មានសំ យេន សោ> អកុទ្ធមានសោ ។

អកុប្បដ្ឋាន នបុំ. [ អកុប្ប+ឋាន ] ទីមិនកំរើក ។

អកុព្វតោ គុ. [ ន+ករ+ឱ+អន្ត+ស.វិ. ] កាលមិនធ្វើ ។

អកុសល ន. [ ន+កុសល ] អកុសល ។ គុ. មិនមែនជាកុសល, មិនប្រសប់, មិនឈ្លាស, មិនវាងវៃ ។ -កម្ម នបុំ. កម្ម ឬ អំពើជាអកុសល ។ -កម្មបថ បុំ. គន្លង ឬផ្លូវនៃកម្មជាអកុសល ។ -កម្មសង្ខាត គុ. គឺបណ្ឌិតរាប់ព្រមហើយថាកម្មជាអកុសល, គឺបណ្ឌិតពោលថាកម្មជាអកុសល, ពោលគឺកម្មជាអកុសល ។ -កិរិយា ឥ. កិ.ធ្វើនូវកម្មជាអកុសល ។ -ចិត្តុប្បាទ បុំ. កិ.ញុំាងចិត្តជាអកុសលឲ្យកើតឡើង, កិ.កើតឡើងនៃចិត្តជាអកុសល ។ -ចេតនា ឥ. ចេតនាជាអកុសល, ចេតនាប្រកបហើយដោយអកុសល, វិ. អកុសលេន យុត្តា ចេតនា > អកុសលចេតនា ។ -ធម្ម បុំ. ធម៌ជាអកុសល, ធម៌ប្រកបហើយដោយកម្មជាអកុសល ។ -មល នបុំ. មន្ទិលគឺអកុសល ។ -លោភ បុំ. កិ.បាននូវកម្មជាអកុសល ។ -វិតក្ក បុំ. សេចក្ដីត្រិះរិះជាអកុសល ឬក្នុងកម្មជាអកុសល ។ -វិថិ

ឥ. វិធីនៃចិត្តជាអកុសល, ផ្លូវនៃចិត្តជាអកុសល ។ - មូល នពុំ. មូលគល់នៃអកុសល .ល. ។

**អកុសីត** គុ. [ ន+កុ+សទ>សីទ+អ, ផ្លាស់ទ>ត ] អ្នកមិនលិចចុះដោយអាការរើបណ្ដិតឫស្ញើម (មិនខ្ជិលច្រអូស); វិ. ន កុច្ឆិតេន អាការេន សីទតីតិ > អកុសីតោ ។ - តា ឥ. ភាវៈនៃ...ជាអ្នកមិនខ្ជិលច្រអូស ។

**អកោធន** គុ. [ ន+កុធ+យុ ] អ្នកមិនមានសេចក្ដីក្រោធ; វិ. កុជ្ឈិយតេតិ >កោធនំ, នត្ថិ កោធនំ ឯតស្សាតិ>អកោធនោ ។ នពុំ. សេចក្ដីមិនក្រោធ ។

**អកោធ** ពុំ. [ ន+កុធ+ណ ] សេចក្ដីមិនក្រោធ, កិ.មិនខឹង; វិ. អកោធនំ > អកោធោ ។ អ្នកមិនមានសេចក្ដីក្រោធ, វិ. នត្ថិ កោធោ ឯតស្សាតិ > អកោធោ ។ កិ.មិនមាននៃសេចក្ដីក្រោធ, វិ. កោធស្ស អភាវោ > អកោធំ ។

**អកោបេត្វា** ន. [ ន+កុប+ណេ+ត្វា ] មិនញាំង...ឱ្យកំរើកហើយ ។

**អកោបេន្ត** គុ. [ ន+កុប+ណេ+អន្ត ] កាលមិនញាំង...ឱ្យកំរើក ។

**អកក្កស** គុ. [ ន+កក្កស ] អ្នកមិនធ្វើនូវអំពើអគ្រោះ (មិនអាក្រក់, មិនច្រឡោះបោះបោក); វិ. ន កិច្ឆំ ករោតីតិ>អកក្កសោ ។ កក្កស < កិច្ឆ+ករ+អស ។



**អក្កន្ត** គុ. [ អា>អ+កម+ត>ន្ត ] ជាន់ហើយ, ដែល...ជាន់ហើយ ។ - **អល្លចម្ម** នពុំ. ស្បែកស្រស់ដែល... ជាន់ហើយ ។ - **កាល** ពុំ. កាលនៃ...គឺ...ជាន់ហើយ ។ - **អក្កន្តកាល** ពុំ. កាលនៃ...គឺ...ជាន់ហើយៗ ។ - **ដ្ឋាន** នពុំ. ទីនៃ...គឺ... ជាន់ហើយ ។ - **មត្ត** គុ. គ្រាន់តែគឺ...ជាន់ហើយ ។ - **សាខា** ឥ. មែកគឺ...ជាន់ហើយ ។

**អក្កមតិ** កិ. [ អា+កម+អ+តិ.វ. ] ជាន់ ។

**អក្កមន្តុ** កិ. [ អា+កម+អ+អន្តុ.ប. ] ចូរជាន់ ។

**អក្កមន្ត** គុ. [ អា+កម+អន្ត ] កាលជាន់, កំពុងជាន់ ។

**អក្កមិ** កិ. [ អា+កម+អ+ឦ.អជ្ជ.>ឥ ] ជាន់ហើយ ។

**អក្កមិត្វា** អ. [ អា+កម+ឥ.អា+ត្វា ] ជាន់ហើយ ។

**អក្កុជ្ឈិត្វា** អ. [ ន+កុធ+យ+ឥ.អា+ត្វា ] មិនក្រោធហើយ, មិនខឹងហើយ ។

**អក្កុដ្ឋ** គុ. [ អា+កុស+ត>ដ្ឋ ] ជេរហើយ, ដែល...ជេរហើយ ។

**អក្កោច្ឆិ** កិ. [ អ+កុស+អ+ឦ.អជ្ជ.>ឆិ ] បានជេរហើយ ។

**អក្កោសក** ពុំ. [ អា+កុស+ណ្វុ ] អ្នកជេរ; វិ. **អក្កោសតីតិ > អក្កោសកោ** ។ - **បរិភាសក** ពុំ. អ្នកជេរនិងអ្នកប្រទេច ។ - **ភារទ្វាជ** អស.ន ព្រាហ្មណ៍ឈ្មោះភារទ្វាជៈអ្នកជេរ, ព្រាហ្មណ៍ឈ្មោះអក្កោសកភារទ្វាជៈ ។

អក្កោសន នពុំ. [ អា+កុស+យុ ] កិ.ជេរ; វិ. អក្កោសយតេតិ > អក្កោសនំ ។ - បច្ចក្កោសនប្បហរណប្បដិប្បហរណាទិ គុ. មានកិ.ជេរនិងកិ.ជេរតប និងកិ.ប្រហារនិងកិ.ប្រហារតបជាដើម, មានកិ.ជេរតបនូវកិ.ជេរ និងកិ.ប្រហារតបនូវកិ.ប្រហារជាដើម ។ - សទ្ទ ពុំ. សំឡេង ឬ សូរនៃកិ.ជេរ, សំឡេងជាគ្រឿងជេរ ។

អក្កោសន្តិ កិ. [ អា+កុស+អ+អន្តិ.វ. ] ជេរ ។

អក្កោសន្ត គុ. [ អា+កុស+អន្ត ] កាលជេរ, កំពុងជេរ ។

អក្កោស ពុំ. [ អា+កុស+ណ ] កិ.ជេរ, ជាគ្រឿងជេរ ។ - អាទិវត្ថុ នពុំ. មានកិ.ជេរជាដើមជាវត្ថុ ។ - វត្ថុ នពុំ. វត្ថុជាគ្រឿងជេរ ។

អក្កោសិ កិ. [ អា+កុស+អ+ឦ.អជ្ជ. ] ជេរហើយ ។

អក្កោសិតព្វ គុ. [ អា+កុស+ឥ.អា.+តព្វ ] គឺ...គប្បីជេរ ។

អក្កោសិតុំ អ. [ អា+កុស+ឥ.អា.+តុំ ] ដើម្បីជេរ ។

អក្កោសិត្វា អ. [ អា+កុស+ឥ.អា.+ត្វា ] ជេរហើយ ។

អក្កោសិសុ កិ. [ អា+កុស+អ+ឧំ.អជ្ជ.>ឥសុ ] ជេរហើយ ។

អក្ខ ពុំ. ភ្លៅ, ដងកាំបិត ។ - អគ្គនេមិវដ្ដិ ឥ. ចុងនៃភ្លៅនិងកណ្ដាប់ ឬរង្វង់នៃកង់ ។ - ភញ្ជនវណប្បដិច្ឆាទនបុគ្គមំសូបមាវស ពុំ.



អំណាចនៃសេចក្ដីប្រៀបដោយប្រេង(១) សំរាប់លាបនូវភ្លៅ និងសំពត់សំរាប់គ្របនូវដំបៅនិងសាច់នៃកូន ។

អក្ខន្តិ ឥ. [ ន+ខម+តិ ] សេចក្ដីមិនអត់ធន់, មិនមានសេចក្ដីអត់ធន់; វិ. អក្ខមនំ > អក្ខន្តិ, នត្ថិ ខន្តិ ឯតស្សាតិ > អក្ខន្តិ ។

អក្ខរ ពុំ., នពុំ. [ ន+ខិ+អរ ] វណ្ណៈមិនដល់នូវកិ.អស់ទៅ ឬវណ្ណៈមិនរឹង (អក្សរ); វិ. ន ខិយន្តិ ខយំ ន បាបុណន្តីតិ > អក្ខរា, ន ខរន្តីតិ វា > អក្ខរា ។ - បិណ្ឌ ពុំ. កិ.ប្រមូលនៃអក្សរ, ពួកនៃអក្សរ ។ - សមយ ពុំ. លទ្ធិជាគ្រឿងប្រព្រឹត្តទៅព្រមនៃអក្សរ, លទ្ធិនៃអក្សរ ។

អក្ខាត គុ. [ អា+ខា+ត ] គឺ...ពោលហើយ, -ប្រាប់ហើយ ។

អក្ខាយតិ កិ. [ អា+ខា+យ+តិ.វ. ] គឺ...ពោល, ប្រាកដ ។

អក្ខាហិ កិ. [ អា+ខា+អ+ហិ.ប. ] ចូរប្រាប់, ចូរពោល ។

អក្ខិ នពុំ. [ ឥក្ខ>អក្ខ+ឥ ] ធម្មជាតសម្រាប់ឃើញនៃជន (ភ្នែក); វិ. ឥក្ខតិ បស្សតិ ឯតេនាតិ > អក្ខិ ។ - កាណ ពុំ. កិ.ខ្វាក់នៃភ្នែក ។ - កោដិ ឥ. ចុងនៃភ្នែក, ទីបំផុតនៃភ្នែក (កន្ទុយនៃភ្នែក) ។ - រោគ ពុំ. រោគក្នុងភ្នែក, រោគដែលកើតក្នុងភ្នែក ។ - វិនាស ពុំ. សេចក្ដីវិនាសនៃភ្នែក, ការខូចនៃភ្នែក ។

(១) ឬម្យ៉ាង គឺលោះ ។

**អក្ខេម** គុ. [ ន+ខេម ] ដែលមិនក្សេម, មិនមានសេចក្ដីក្សេម; វិ. **នត្ថិ ខេមំ ឯតស្សាតិ > អក្ខេមំ** ។

**អខណ្ឌ** គុ. [ ន+ខណ្ឌ ] មិនដាច់ ។ **-ផុល្ល** គុ. មិនដាច់និងមិនធ្លាយ, មិនដាច់និងមិនផុយរលាស់ ។

**អខមាបេន្ត** គុ. [ ន+ខម+ណាបេ+អន្ត ] កាលមិនញុំាង...ឱ្យអត់, -មិនឱ្យអត់ទោស ។

**អខមាបេត្វា** អ. [ ន+ខម+ណាបេ+ត្វា ] មិនញុំាង...ឱ្យអត់ហើយ, មិនឱ្យអត់ទោសហើយ ។

**អខីណាសវ** គុ. [ ន+ខីណាសវ ] មានអាសវៈមិនទាន់អស់ហើយ; វិ. **អខីណា អាសវា យស្ស សោ > អខីណាសវោ** ។ មិនមែនជាព្រះខីណាស្រព; វិ. **ន ខីណាសវោ>អខីណាសវោ** ។

**អខេបិត** គុ. [ ន+ខិប+ឥ.អា.+ត ] គឺ...មិនញុំាងឱ្យអស់ហើយ, -មិនឱ្យបោះទៅហើយ ។ **-ត្ត** នពុំ. ភាវៈនៃ...ជា...គឺ...មិនឱ្យអស់ទៅហើយ ។

**អគណេត្វា** អ. [ ន+គណ+អ>ឯ+ត្វា ] មិនរាប់ហើយ, មិនអើពើហើយ ។

**អគត** គុ. [ ន+គម+ត ] មិនទៅហើយ, មិនដល់ហើយ ។ **-ការណ** នពុំ. ហេតុនៃ...មិនទៅហើយ ។ **-ទិសសង្ខាត** គុ. ដែលបណ្ឌិតពោលថាទិសគឺ...មិនដែលទៅហើយ។ **-បុព្វ** គុ.ដែលមិនធ្លាប់ទៅហើយ ។ **-បុព្វត្ត** នពុំ. ភាវៈនៃ...ជា...គឺ...មិនធ្លាប់ទៅហើយ ។



**អគតិ** ឥ. [ ន+គម+តិ ] កិ.មិនទៅ, កិ.មិនលុះ, កិ.មិនលំអៀង; វិ. **អគមនំ > អគតិ** ។ **-គមន** នពុំ. កិ.ដល់នូវអគតិ, កិ.លុះនូវគតិមិនគួរ ។

**អគន្តុកាម** គុ. [ អគន្តុំ + កាម ឬ ន+គន្តុកាម ] ចង់ដើម្បីមិនទៅ, មិនចង់ដើម្បីទៅ, មានប្រាថ្នាដើម្បីមិនទៅ (មិនត្រូវការទៅ) ។

**អគន្ធក** គុ. [ ន+គន្ធ+ក ] មានក្លិនមិនមាន, មិនមានក្លិន, ឥតក្លិន; វិ. **នត្ថិ គន្ធោ អស្សាតិ > អគន្ធកំ** ។

**អគមន** នពុំ. [ ន+គម+យុ ] កិ.មិនទៅ។ **-ធម្ម** គុ. មានកិ.មិនទៅជាធម្មតា ។ **-ភាវ** ពុំ. ភាវៈនៃកិ.មិនទៅ ។ **-សីល** គុ. មានកិ.មិនទៅជាប្រក្រតី; វិ. **អគមនំ សីលមស្សាតិ >អគមនសីលោ** ។

**អគរុ** នពុំ. [ ន+គិរ+ឧ.ឥ>អ, គម+ឧ, ម>រ, គរ+ឧ ] សេចក្ដីមិនធ្ងន់, សេចក្ដីមិនធ្ងន់ចិត្ត, (សេចក្ដីមិនចង្អៀតចង្អល់) សេចក្ដីមិនគោរព ។

**អគយ្ហុបគ** គុ. [ ន+គយ្ហ+ឧប+គម+ក្វិ ឬអគយ្ហ+ឧប+គម+ក្វិ ] ធម្មជាតិបុគ្គលមិនគប្បីចូលទៅជិតចាប់យកបាន; វិ. **ន គយ្ហំ ឧបគន្តុញាតិ > អគយ្ហុបគា** ។ ធម្មជាតិបុគ្គលចូលទៅជិតដល់នូវកិ.ចាប់យកមិនបាន; វិ. **អគយ្ហំ ឧបគមិយតេតិ>អគយ្ហុបគា** ។ ធម្មជាតចូលទៅជិតដល់នូវកិ.ចាប់យកមិនបាន; វិ. **អគយ្ហំ ឧបគច្ឆតីតិ > អគយ្ហុបគា** ។

អគ្គហណ ចុំ. [ ន+គហ+យុ ] កិ.មិនកាន់, សេចក្តីមិនប្រកាន់ ។ គុ. មានធម៌ជាគ្រឿងមិនប្រកាន់, មិនមានសេចក្តីប្រកាន់ ។

អគារវ គុ. [ ន+គារវ ] មានភាវៈនៃសេចក្តីគោរពមិនមាន, មិនមានភាវៈនៃសេចក្តីគោរព; វិ. **គរុស្ស ភាវោ> គារវោ, នត្ថិ គារវោ អស្សាតិ > អគារវោ, ន ចា គារវោ យស្ស សោ> អគារវោ** ។ . **ភូត** គុ. ដែលមិនមានភាវៈនៃសេចក្តីគោរពកើតហើយ ។

អគារ ចុំ., នចុំ. ផ្ទះ, រោង ។ . **មជ្ឈ** នចុំ. កណ្តាលនៃផ្ទះ ។

អគារិយ គុ. [ អគារ+ឥយ ] ( កម្ម ) ជាប្រយោជន៍ដល់ផ្ទះ; វិ. **អគារស្ស ហិតំ > អគារិយំ** ។ . **ភូត** គុ. ដែលមានកម្មជាប្រយោជន៍ដល់ផ្ទះកើតហើយ ។

អគុណ ចុំ. [ ន+គុណ ] សភាវៈមិនមែនជាគុណ (ទោស); វិ. **ន គុណោ > អគុណោ** ។

អគោចរ ចុំ. [ ន+គោចរ ] ទីមិនមែនជាគោចរ, ទីមិនគួរត្រេចទៅដូចជាគោ, មិនមែនជាអារម្មណ៍ ។

អគ្គ គុ. [ អជ>អគ+អ ប្ប ] ធម្មជាតដល់នូវភាពដ៏ប្រសើរ, (ប្រសើរ, លើស, កំពូល, ថ្លោង, ខ្ពង់ខ្ពស់, ទីបំផុត, ជាទីបំផុត, ចុង, ជាដើម, ចំណែក, អារម្មណ៍); វិ. **អជតិ គច្ឆតិ សេដ្ឋភាវន្តិ>អគ្គំ** ។



. **អគ្គ** គុ. កំពូលជាទីបំផុត, ចុងនៃកំពូល ។ . **ដ្ឋាន** នចុំ. ទីដ៏លើស, ដំណែងដ៏លើស ។ . **នង្គុដ្ឋ** នចុំ. កន្ទុយជាទីបំផុត, ចុងនៃកន្ទុយ ។ . **ទក្ខិណេយ្យភាវ** ចុំ. ភាវៈនៃ...ជាអ្នកគួរនូវទក្ខិណាដ៏លើស, ភាវៈនៃ...ជាអ្នកគួរនូវទានសម្បត្តិជាគ្រឿងចំរើនដ៏លើស, ភាវៈនៃ...ជាទក្ខិណេយ្យបុគ្គលអ្នកប្រសើរ ។ . **ទណ្ឌក** នចុំ. ដងជាទីបំផុត, ចុងនៃដង ។ . **ទាន** នចុំ. ទានដ៏លើស ។ . **ធម្ម** ចុំ. ធម៌ដ៏លើស ។ . **បណ្ឌិត** ចុំ. បណ្ឌិតអ្នកខ្ពង់ខ្ពស់ ។ . **បាទ** ចុំ. ទីចំផុតនៃជើង, ចុងនៃជើង ។ . **បិណ្ឌ** ចុំ. បិណ្ឌៈដ៏ថ្លោង, ដុំបាយដ៏ថ្លោង ។ . **បុប្ផ** នចុំ. ផ្កាដ៏លើស ។ . **ភត្ត** នចុំ. ភត្តដ៏ថ្លោង ។ . **មហេសិដ្ឋាន** នចុំ. ទីនៃមហេសីដ៏លើស ។ . **យាគុ** ឥ. បបរដ៏លើស ។ . **រស** ចុំ. រសដ៏លើស ។ . **រាជ** ចុំ. ព្រះពុទ្ធជាស្តេចប្រសើរ, ស្តេចប្រសើរ ។ . **សស្សទាន** នចុំ. កិ.ឱ្យនូវសំទូងដ៏លើស ។ . **សាវក** ចុំ. សាវ័កអ្នកលើស ។ . **សាវិកា** ឥ. សាវិកាអ្នកលើស ។ . **សេដ្ឋី** ចុំ. សេដ្ឋីអ្នកលើស . ល . ។

អគ្គិ ចុំ. [ អគ្គ+ឥ ] សភាវៈដល់នូវកិ.កោងកាច (ភ្លើង); វិ. **អគ្គតិ កុដិលំ គច្ឆតីតិ > អគ្គិ** ។ . **ឱភាស** ចុំ. ពន្លឺនៃភ្លើង, រស្មីជាគ្រឿងភ្លឺនៃភ្លើង ។ . **ក្ខន្ធ** ចុំ. គំនរនៃភ្លើង ។ . **ជាលា** ឥ. អណ្តាតនៃភ្លើង ។ . **ទឌ្ឍ** គុ. ដែលភ្លើងឆេះហើយ ។ . **បរិចរណដ្ឋាន** នចុំ. ទីជាទីចំរើនភ្លើង ។ . **បរិចរិយា** ឥ. កិ.ចំរើ

នូវភ្លើង ។ - **វណ្ណ** គុ. មានពណ៌ដូចជាពណ៌នៃភ្លើង, មានពណ៌ដូចជាភ្លើង ។ - **សាលា** ឥ. រោងនៃភ្លើង ។ - **សិខូបម** គុ. មានឧបមាដោយអណ្តាតនៃភ្លើង ។ - **ហុត្ត** គុ. ភ្លើងដែល...បូជា, កិ.បូជានូវភ្លើង (ហុត្ត<ហុ+ត>ត្ត) ។

**អគ្ឃតិ** កិ. [ អគ្ឃ+អ+តិ.វ. ] ថ្លៃ, ដល់ថ្លៃ, គួរថ្លៃ, ។

**អគ្ឃ** គុ. [ អគ្ឃ+អ ] ថ្លៃ, កាត់ថ្លៃ, ដំឡៃ ។ នបុំ. ការបូជា, កិ.បូជា; វិ. **អគ្ឃនំ បូជនំ > អគ្ឃំ** ។

**អគ្ឃិយ** នបុំ. [ អគ្ឃ+ឥយ ] កិ.បូជា, គ្រឿងបូជា; វិ. **អគ្ឃនំ បូជនំ > អគ្ឃិយំ** ។

**អគ្ឃាបេសិ** កិ. [ អគ្ឃ+ណាបេ+ឦ-អជ្ជ.(១)+ស-អា. ] ញុំាង...ឱ្យកាត់ថ្លៃហើយ ។

**អឃាតយំ** គុ.[ ន+ឃាត(២)+ណយ+អន្ត+សិ-វិ, ផ្លាស់សិ-វិ. មិង ន្ត ជាអំ ] កាលមិនញុំាង... ឱ្យសម្លាប់ ឬឱ្យបៀតបៀន ។

**អង្ក** បុំ. [ អង្ក+អ ] គ្រឿងដែលគេសម្រាប់កំណត់, សម្រាប់សម្គាល់ (ចង្កេះ, ភ្លៅ, ថ្នក់, ទំព័រ); វិ. **អង្កិយតេ លក្ខិយតេ អនេនាតិ > អង្កោ** ។

**អង្កុរ** បុំ. [ អង្ក+ឧរ ] សភាវៈដែលគេកំណត់ ឬចំណាំ (ពន្លក, បណ្តូល); វិ. **អង្កិយតិ លក្ខិយតីតិ>អង្កុរោ** ។ - **ទេវបុត្តវត្ថុ** នបុំ. រឿងនៃទេវបុត្រឈ្មោះអង្កុរៈ ។

---
(១) ឦ-អជ្ជ.>ឥ ។ (២) ហន>ឃាត ។



**អង្កុស** បុំ. [ អង្ក>អង្កុ+ស ] គ្រឿងសម្រាប់កំណត់ (កង្វេរ); វិ. **អង្កេតិ អនេនាតិ > អង្កុសោ** ។ - **គ្គាហ** បុំ. អ្នកកាន់នូវកង្វេរ (នាយហត្ថាចារ្យ, ហ្មដំរី) ។

**អង្គណាភាវ** បុំ. [ អង្គណ+អភាវ ] កិ.មិនមាននៃកិលេសដូចជាធូលី, កិ.មិនមាននៃកិលេសជាគ្រឿងរលឹបរល, កិ.មិនមាននៃកិលេស ។

**អង្គប្បច្ចង្គ** នបុំ. [ អង្គ+បច្ចង្គ ] អវយវៈនិងអវយវៈអាស្រ័យ, អវយវៈតូចនិងអវយវៈធំ ។

**អង្គរដ្ឋ** នបុំ. [ អង្គ+រដ្ឋ ] ដែនឈ្មោះអង្គៈ ។

**អង្គវេកល្ល** នបុំ. [ អង្គ+វេកល្ល ] ភាវៈនៃបុគ្គលអ្នកវិកលដោយអវយវៈ, ភាវៈនៃបុគ្គលមានអវយវៈខ្វះខាត, ភាវៈនៃសេចក្តីខ្វះខាតដោយអវយវៈ; វិ. **វិកលស្ស ភាវោ > វេកល្លំ, អង្គេន វេកល្លំ > អង្គវេកល្លំ** ។

**អង្គារ** បុំ. [ អង្គ+អារ ] (សភាវៈ) ដល់នូវសេចក្តីសាបសូន្យ (រងើកភ្លើង, ធ្យូង); វិ. **អង្គតិ ហានិំ គច្ឆតីតិ>អង្គារោ** ។ - **អាវាដ** បុំ. រណ្តៅដីពេញដោយរងើកភ្លើង; វិ. **អង្គារេហិ បូរិតោ អាវាដោ > អង្គារាវាដោ** ។ - **កបល្ល** នបុំ. អំបែងដីពេញដោយរងើកភ្លើង ។ - **កាសុ** ឥ. រណ្តៅដីពេញដោយរងើកភ្លើង ។ - **បច្ឆិ** ឥ. ព្រែងដីពេញដោយធ្យូង, ព្រែងដាក់នូវធ្យូង ។ - **បូរ** គុ. ដីពេញ

ដោយរងើកភ្លើង ឬធ្យូង ។ - **ភាវ** បុំ. ភាវៈនៃ...ជាធ្យូង ។ - **កោដិ** នបុំ. ទីបំផុតនៃរងើកភ្លើង ។ - **មសិមក្ខិត** គុ. ដែលប្រឡាក់ដោយធ្យូងនិងម្រែងភ្លើង, គឺម្រែងនៃធ្យូងប្រឡាក់ហើយ ។ - **រាសិ** បុំ. គំនរនៃធ្យូង ឬរងើកភ្លើង ។

**អង្គីរស** គុ. [ អង្គ+រស+ត្យ.អ. ] មានរស្មីផ្សាយចេញអំពីអវយវៈ, មានអវយវៈជាដែនផ្សាយចេញនៃរស្មី, មានរស្មីរុងរឿងឰដ៏អវយវៈ; វិ. អង្គម្ហិ រសោ រំសិ និច្ឆរេ យស្សាតិ > អង្គីរសោ ។ មានរស្មីឰដ៏អវយវៈ; វិ. អង្គម្ហិ រសោ យស្ស សោ> អង្គីរសោ ។

**អង្គុត្តរាបថ** អស.ន [ អង្គ+ឧត្តរាបថ ] ជនបទឈ្មោះអង្គៈ និងជនបទឈ្មោះឧត្តរាបថៈ ។

**អង្គុលន្តរ** នបុំ. [ អង្គុលិ+អន្តរ ] ចន្លោះនៃម្រាមដៃ, ចង្អៀតនៃម្រាមដៃ ។

**អង្គុលិមុទ្ទិកា** ឥ. [ អង្គុលិ+មុទ្ទិកា ] ចិញ្ចៀនសម្រាប់ពាក់ឰដ៏ម្រាមដៃ, ឬចិញ្ចៀនដែល...ប្រដាប់ឰដ៏ម្រាមដៃ; វិ. អង្គុលិយំ បិលន្ធនំ បិលន្ធិកា វា មុទ្ទិកា > អង្គុលិមុទ្ទិកា ។

**អង្គុលិសញ្ញា** ឥ. [ អង្គុលិ+សញ្ញា ] សេចក្ដីសម្គាល់ដោយម្រាមដៃ ។

**អចក្ខុក** គុ. [ ន+ចក្ខុ+ក ] មានចក្ខុមិនមាន, មិនមានចក្ខុ (ខ្វាក់); វិ. នត្ថិ ចក្ខុ ឯតស្សាតិ > អចក្ខុកោ ។

**អចរិម** គុ. [ ន+ចរិម ] មិនក្រោយ ។



**អចល** គុ. [ ន+ចល+អ ] ដែលមិនកំរើក, មិនករក្រើក, មិនរញ្ជួយ ។ - **តា** ឥ. ភាវៈនៃ...ជា...មិនកំរើក ។ - **ភាវ** បុំ. ភាវៈនៃ...ជា...មិនកំរើក។ - **ចេតិយដ្ឋាន** នបុំ. ទីជាទីតាំងនៃអចលចេតិយ ។ - **សទ្ធា** ឥ. សទ្ធា (សេចក្ដីជឿ) មិនកំរើក ។ - **សទ្ធ** គុ. មានសទ្ធាមិនកំរើក; វិ. អចលា សទ្ធា យស្ស សោ > អចលសទ្ធោ ។

**អចិត្តក** គុ. [ ន+ចិត្ត+ក ] មានចិត្តមិនមាន, មិនមានចិត្ត, ឥតចិត្ត; វិ. នត្ថិ ចិត្តំ ឯតស្សាតិ > អចិត្តកំ ។

**អចិន្តេយ្យ** គុ. [ ន+ចិន្ត+តេយ្យ ] (ហេតុ)ដែល...មិនគប្បីគិត, មិនគួរគិត; វិ. ន ចិន្តេតព្វន្តិ > អចិន្តេយ្យំ ។

**អចិរ** និ., គុ. [ ន+ចិរ ] មិនយូរ, កាលមិនយូរ ។ - **បក្កន្ត** គុ. ដែលជៀសចេញទៅហើយមិនយូរ, ជៀសចេញទៅហើយអស់កាលមិនយូរ ( បក្កន្ត < ប+កម+ត ) ។ - **បព្វជិត** គុ. ដែលបួសហើយអស់កាលមិនយូរ, (ទើបនឹងបួសថ្មី) ។ - **វតីនទីតីរ** នបុំ. ត្រើយ ឬឆ្នេរនៃស្ទឹងឈ្មោះអចិរវតី ។

**អចេតន** គុ. [ ន+ចេតនា ] មានចេតនាមិនមាន, មិនមានចេតនា, ឥតចេតនា; វិ. នត្ថិ ចេតនា ឯតស្សាតិ > អចេតនោ ។

**អចេលក** គុ. [ ន+ចេល+ក ] អ្នកមានសំពត់មិនមាន, មិនមានសំពត់, ឥតសំពត់ (អចេលក៍, បព្វជិតអាក្រាត); វិ. នត្ថិ ចេលំ ឯតស្សាតិ > អចេលកោ ។

**អច្ចគា** គ. [ អតិ+អ+គម+អ+អត.ក ] បានដល់ហើយ, បានកន្លងទៅហើយ ។

**អច្ចន្ត** គុ. [ អតិ+អន្ត ] ទីបំផុតក្រៃពេក, ចំណែកបូរេ ។ - **ទុស្សីល** គុ. មានសីលគឺទោសប្រទូស្តហើយដោយចំណែកបូរេ ។-**ទុស្សីល្យ** នបុ. ភាវៈនៃបុគ្គលទ្រុស្តសីលដោយពិត; វិ. **ទុដ្ឋំ សីលំ យស្ស សោ >ទុស្សីលោ, ទុស្សីលស្ស ភាវោ >ទុស្សីល្យំ, អច្ចន្តំ ទុស្សីល្យំ>អច្ចន្តទុស្សីល្យំ** ។

**អច្ចយ** បុ. [ អតិ+ឥ+ណ ] កាលជាទីប្រព្រឹត្តកន្លង (អំណឹះ, កាលជាអំណឹះ); វិ. **អច្ចយតិ អតិក្កមតិ ឯត្ថាតិ > អច្ចយោ** ។ កិ.ប្រព្រឹត្តកន្លង (ទោស); វិ. **អតិក្កមិត្វា អយនំ>អច្ចយោ** ។

**អច្ចាយិក** គុ. [ អតិ+ឥ+ណិក ] ដែលប្រព្រឹត្តកន្លងនូវប្រមាណ (ដំណើររហ័សរហួន, ប្រញាប់ប្រញាល់); វិ. **បមាណំ អច្ចេតីតិ > អច្ចាយិកំ** ។ ដំណើរប្រព្រឹត្តទៅរួសរាន់ពេក; វិ. **អតិតុរិតំ អយតិ បវត្តតីតិ > អច្ចាយិកំ** ។

**អច្ចារទ្ធវិបស្សក** គុ. [ អច្ចារទ្ធ+វិបស្សក ] ដែលមានវិបស្សនាប្រារព្ធហើយក្រៃពេក, មានប្រាជ្ញាជាគ្រឿងឃើញច្បាស់ប្រារព្ធហើយក្រៃពេក ។

**អច្ចាវទតិ** កិ. [ អតិ+អា+វទ+អ+តិ.វ.] ពោលល្បួង, និយាយថៃថង់ ។

**អច្ចុគ្គត** គុ. [ អតិ+ឧ+គម+ត ] ដែលទៅហើយក្នុងខាងលើក្រៃពេក, ហោះឡើងហើយ, អណ្តែតឡើងហើយ ។

**អច្ចុណ្ហ** គុ. [ អតិ+ឧណ្ហ ] ដែលក្តៅពេក ។



**អច្ចុត** គុ. [ ន+ចុ+ត ] មានកិ.ច្យុតមិនមាន (ដែលមិនច្យុតហើយ(១)); វិ. **ចវិយតេតិ > ចវនំ, ចវនំ > ចុតំ, នត្ថិ ចុតំ ឯតស្សាតិ > អច្ចុតំ** ។

**អច្ចោទក** នបុ. [ អតិ+ឧទក ] ទឹកដ៏ក្រៃលែង (ទឹកច្រើន) ។

**អច្ឆ** [ អស+ឆ ] គុ. ថ្លា; បុ. ខ្លាឃ្មុំ ។

**អច្ឆតិ** កិ. [ អស+ឆ+តិ.វ. ] នៅ; ថ្លា ។

**អច្ឆផន្ទន** បុ. [ អច្ឆ+ផន្ទន ] ខ្លាឃ្មុំនិងដើមពង្រ ។

**អច្ឆម្ភិត** គុ. [ ន+ឆភ+ឥ.អា.+ត ] មិនតក់ស្លុត, មិនរន្ធត់; នបុ. សេចក្តីមិនតក់ស្លុត, សេចក្តីមិនរន្ធត់ ។ - **អត្ថ** បុ. សេចក្តីគឺជាអ្នកមិនតក់ស្លុតហើយ, សេចក្តីថាមិនតក់ស្លុតហើយ ។

**អច្ឆរ** នបុ. [ អស+ឆរ ] ម្រាមដៃ ។ - **គ្គហណមត្ត** គុ. គ្រាន់តែកិ.ចាប់ដោយម្រាមដៃ, គ្រាន់តែកិ.ចឹបដោយម្រាមដៃ ។ - **សទ្ទ** បុ. សូរនៃម្រាមដៃ ។

**អច្ឆរា** ឥ. [ អច្ឆ+រ ] ស្ត្រីមានសម្បុរដ៏ថ្លា (ស្ត្រីអប្សរ); វិ. **អច្ឆោ វណ្ណោ ឯតិស្សា អត្ថីតិ>អច្ឆរា** ។ ស្ត្រីមានមុខដ៏ថ្លា; វិ.**អច្ឆំ បសន្នករំ មុខំ យាយ សា>អច្ឆរា** ។ - **កោដិ** ឥ. កោដិនៃស្ត្រីអប្សរ ។ - **សហស្សបរិវារ** គុ. មានពាន់នៃស្ត្រីអប្សរជាបរិវារ ។

---

(១) ឃ្លៀង, ឃ្លៀងឃាត់ ។

-សហស្សបរិវុត គុ. គឺពាន់នៃស្ត្រីអប្សរចោមរោមហើយ, -ហែហមហើយ ។ -សហស្សមជ្ឈ នពុំ. កណ្ដាលនៃពាន់នៃស្ត្រីអប្សរ។ . សង្ឃ ចុំ. ពួកនៃស្ត្រីអប្សរ, ក្រុមនៃ... ។

**អច្ឆរិយ** គុ. [ អា+ចរ+ណ្យ+ឥ.អា. ] អំពើដែលបុគ្គលគប្បីប្រព្រឹត្តដ៏ក្រៃលែង, ( ដែលអស្ចារ្យ, គួរអស្ចារ្យ; នពុំ. សេចក្ដីអស្ចារ្យ ); វិ. អា ភុសោ ចរិយន្តិ > អច្ឆរិយំ ។ ហេតុដែលគួរដើម្បីប្រហារនូវម្រាមដៃ; វិ. អច្ឆរំ បហរិតុំ យុត្តន្តិ > អច្ឆរិយំ ។ - គុណោ គុ. មានគុណជាអស្ចារ្យ, មានគុណគួរអស្ចារ្យ ។ . អព្ភុតចិត្តជាត គុ. មានចិត្តជាអស្ចារ្យដែលមិនធ្លាប់កើតកើតហើយ; វិ. អច្ឆរិយ-ព្ភុតចិត្តំ ជាតំ ឯតេសន្តិ > អច្ឆរិយព្ភុតចិត្តជាតា ។ -អព្ភុតជាត គុ. មានហេតុជាអស្ចារ្យមិនដែលកើតកើតហើយ; វិ. អច្ឆរិយព្ភុតំ ជាតំ ឯតេសន្តិ > អច្ឆរិយព្ភុតជាតា ។

**អច្ឆាទនដ្ឋាន** នពុំ. [ អច្ឆាទន+ឋាន ] ទីជាទីស្លៀកដណ្ដប់, ទីជាទីបិទបាំង ។ អច្ឆាទន<អា+ឆទ+យុ=វត្ថុសម្រាប់បិទបាំង ឬសម្រាប់ស្លៀកដណ្ដប់ (សំពត់); វិ. អច្ឆាទេតិ ឯតេនាតិ > អច្ឆាទនំ ។

**អច្ឆាទេត្វា** អ. [ អា+ឆទ+ណេ+ត្វា ] ញុំាង...ឱ្យស្លៀកដណ្ដប់ហើយ, ដណ្ដប់ហើយ, បិទបាំងហើយ ។

**អច្ឆិ** កិ. [ អស+ឆ+ត្យ-អជ្ជ.(១) ] នៅហើយ ។

(១) ត្យ-អជ្ជ.>ឥ ។



**អច្ឆិតុំ** អ. [ អស+ឆ+ឥ-អា+តុំ ] ដើម្បីនៅ, កិ.នៅ ។

**អច្ឆិទ្ទវុត្តិ** ឥ. [ អច្ឆិទ្ទ+វុត្តិ ] កិ.ប្រព្រឹត្តមិនដាច់; គុ. មានកិ.ប្រព្រឹត្តមិនដាច់; វិ. អច្ឆិទ្ទា វុត្តិ យស្ស សោ > អច្ឆិទ្ទវុត្តិ ។

**អច្ឆិន្ន** គុ. [ ន+ឆិទ+ណ ] មិនដាច់, មិនធ្លុះ, (<អា+ឆិទ+ណ=ដាច់, ធ្លុះ, ដណ្ដើម) ។

**អច្ឆិន្ទិ** កិ. [ អា+ឆិទ+អ+ត្យ-អជ្ជ., ចុះនិ-អា. ] កាត់ហើយ, ដណ្ដើមយកហើយ ។

**អច្ឆិន្ទិត្វា** អ. [ អា+ឆិទ+ឥ-អា.+ត្វា, ចុះនិ.អា.] ដណ្ដើមយកហើយ ។

**អច្ឆិន្ន** គុ. [ ន+ឆិទ+ត, ត>ឥន្ន ] មិនកាត់ហើយ, កាត់មិនបានហើយ; (<អា+ឆិទ+ត=ដាច់ហើយ, ដណ្ដើមយកហើយ) ។ - លជ្ជិតា ឥ. ភាវៈនៃ...ជាអ្នកមានសេចក្ដីខ្មាសមិនកាត់ហើយ ឬកាត់មិនបានហើយ ។

**អច្ឆិសុ** កិ. [ អស+ឆ+ឧំ-អជ្ជ.(១)] នៅហើយ ។

**អច្ឆេក** គុ. [ ន+ឆេក ] មិនឈ្លាស, មិនវាងវៃ, មិនប្រសប់ ។

**អច្ឆេជ្ជិ** កិ. [ អ+ឆិទ+យ+ត្យ-អជ្ជ. ] បានកាត់ហើយ ។

**អច្ឆេយ្យ** កិ. [ អស+ឆ+ឯយ្យ-ស. ] គប្បីនៅ ។

**អឆុបិត្វា** អ. [ ន+ឆុប+ឥ-អា.+ត្វា) មិនពាល់ត្រូវហើយ, មិនប៉ះពាល់ហើយ ។

**អជគរ** ព. [ អជ+គិល+អ, ឥនៃគិ>អ, ល>រ ] សត្វតែងលេបនូវម្រឹគពពែ

(១) ឧំ-អជ្ជ.>ឥសុ ។

ពពែជាដើម(ពស់ថ្លាន់); វិ. **អជាទយោ គិលតីតិ>អជគរោ** ។

. **ប្រេត** ចុំ. ប្រេតដូចជាពស់ថ្លាន់, ប្រេតមានសរីរៈដូចជាសរីរៈនៃពស់ថ្លាន់, អជគរប្រេត ។

**អជបាល** ចុំ. [ អជ+បាល+អ ] អ្នករក្សាហ្វូងពពែ,អ្នកឃ្វាលហ្វូងពពែ; វិ. **អជេ បាលេតីតិ > អជបាលោ** ។ . **និគ្រោធមូល** នចុំ. ប្រទេសជាទីតាំង (ទីជិត, គល់)នៃដើមជ្រៃជាទីនៅអាស្រ័យនៃជនអ្នករក្សាហ្វូងពពែ, គល់នៃអជបាលនិគ្រោធ ។

**អជរាមរ** គុ. [ អជរ+អមរ ] ទាំងមិនមានសេចក្ដីចាស់ទាំងមិនមានសេចក្ដីស្លាប់, ទាំងមិនចាស់ទាំងមិនស្លាប់ ។

**អជលណ្ឌិក** ចុំ. [ អជ+លណ្ឌិក ] រាចម៍នៃពពែ ។

**អជាគរន្ត** គុ. [ ន+ជាគរ+អន្ត ] កាលមិនភ្ញាក់រឭក ។

**អជាត** គុ. [ ន+ជន(១)+ត ] មិនកើតហើយ ។ . **ត្ត** នចុំ. ភាវៈនៃ....ជាអ្នកមិនកើតហើយ ។ . **សត្តុកុមារ** ចុំ. កុមារឈ្មោះអជាតសត្តុ (អជាតសត្រូវ) ។

**អជានក** ចុំ. [ ន+ញា+ណ្វុ(២) ] អ្នកមិនដឹង, អ្នកមិនចេះ; វិ. **ន ជានាតីតិ > អជានកោ** ។

**អជានន** នចុំ. [ ន+ញា+យុ(៣) ] កិ.មិនដឹង, កិ.មិនចេះ, ជាទីមិនដឹង។ . **កាល** ចុំ. កាលជាទីមិនដឹង ។ . **ដ្ឋាន** នចុំ. ទីជាទីមិនដឹង ។ . **តា** ឥ. ភាវៈ

(១) ជន>ជា ។ (២) ណ្វុ>អានក ។ (៣) យុ>អានន ។



នៃកិ.មិនដឹង ។ . **សិប្ប** នចុំ. សិល្បៈជាគ្រឿងមិនដឹង ។

**អជានាបេត្វា** អ. [ ន+ញា+ណាបេ+ត្វា ] មិនញ៉ាំង....ឱ្យដឹងហើយ ។

**អជានិតព្វ** គុ. [ ន+ញា+នា(១)+តព្វ ] គឺ...មិនគប្បីដឹង ។

**អជាបយំ** គុ. [ ន+ជិ+ណាបយ+អន្ត+សិ.វិ.] កាលមិនញ៉ាំង...ឱ្យឈ្នះ, កាលមិនឱ្យឈ្នះ ។

**អជិកា** ឥ. [ អជ+ណ្វុ+ឥ.អក+អា.ឥ. ] សត្វតែងដើរទៅ (មេពពែ); វិ. **អជតិ គច្ឆតីតិ > អជិកា** ។

**អជិត** គុ. [ ន+ជិ+ត ] គឺ...មិនឈ្នះហើយ ។

**អជិនចម្ម** នចុំ. [ អជិន+ចម្ម ] ស្បែកនៃខ្លា ។

**អជិនសាដិ** ឥ. [ អជិន+សាដិ ] សំពត់សាដកជាវិការៈនៃស្បែកនៃខ្លា; វិ. **អជិនស្ស ចម្មំ > អជិនចម្មំ, អជិនចម្មស្ស វិការោ សាដិ>អជិនសាដិ** ។ សំពត់សាដកដែលជនធ្វើហើយដោយស្បែកនៃខ្លា; វិ. **អជិនចម្មេន កតា សាដិ>អជិនសាដិ** ។

**អជិនិ** កិ. [ អ+ជិ+នា+ឦ.អជ្ជ. ] បានផ្ចាញ់ហើយ, បានឈ្នះហើយ ។

**អជីរណក** គុ. [ ន+ជរ, អនៃជ>ឦ+យុ+ក.ស. ] ដែលមិនគ្រាំគ្រា, មិនចាស់, មិនទ្រុឌទ្រោម, មិនរេចរឹល ។

**អជ្ជ** [ ឥម>អ+ជ្ជ ] ក្នុងថ្ងៃនេះ, ក្នុងកាលនេះ ។

**អជ្ជកាល** ចុំ. [ អជ្ជ+កាល ] កាលក្នុងថ្ងៃនេះ ។

(១) រកៃរោក>ឥ ។

**អជ្ជតគ្គ** គុ. [ អជ្ជ+អគ្គ, ធុះត_អា. ] (កាល) មានថ្ងៃនេះជាដើម; វិ. **អជ្ជ អគ្គោ យស្ស សោ > អជ្ជកគ្គោ** ។

**អជ្ជតន** គុ. [ អជ្ជ+តន ] (ភត្តកិច្ច)មានក្នុងថ្ងៃនេះ (បុញ្ញកោដ្ឋាសៈជាគ្រឿងតទៅក្នុងថ្ងៃនេះ); វិ. **អជ្ជ ភវំ (ភត្តកិច្ចំ) > អជ្ជតនំ** ។

**អជ្ជុនរុក្ខ** ពុ. [ អជ្ជុន+រុក្ខ ] ដើមឈ្លើក, ដើមអង្គ្រង, (អជ្ជុនព្រឹក្ស) ។

**អជ្ឈគា** កិ. [ អធិ>អជ្ឈ+អ+គម+អា_ហី. ] បានដល់ហើយ, បានត្រាស់ដឹងហើយ, បានលុះហើយ ។

**អជ្ឈត្ត** គុ. [ អធិ+អត្ត ] ធម្មជាតប្រព្រឹត្តអាស្រ័យនូវខ្លួន (ខាងក្នុង); វិ. **អត្តានំ អធិកិច្ច បវត្តតីតិ > អជ្ឈត្តំ** ។

**អជ្ឈត្តិក** គុ. [ អជ្ឈត្ត+ណិក ] មានក្នុងខាងក្នុង ឬប្រព្រឹត្តទៅក្នុងខាងក្នុង; វិ. **អជ្ឈត្តំ យស្ស អត្ថីតិ > អជ្ឈត្តិកំ, អជ្ឈត្តេ ចក្កតីតិ ខា > អជ្ឈត្តិកំ** ។ _ **កម្មដ្ឋាន** នថុ. កម្មដ្ឋានដែលប្រព្រឹត្តទៅក្នុងខាងក្នុង ។ _ **ប្បរី** ឥ. ផែនដីមានក្នុងខាងក្នុង ។ _ **ពាហិរ** គុ. ទាំងមានក្នុងខាងក្នុងទាំងមានក្នុងខាងក្រៅ, ទាំងខាងក្នុងទាំងខាងក្រៅ ។

**អជ្ឈាវសេយ្យំ** កិ. [ អធិ+អា+វស+អ+ឯយ្យំ_ស.] គប្បីនៅគ្រប់គ្រង ។

**អជ្ឈាសយ** ពុ. [ អធិ+អា+សី+អ.] ឆន្ទៈជាទីមកដេកនៃចិត្តដ៏ក្រៃលែង (អធ្យាស្រ័យ); វិ. **អាគន្ត្វា សេតិ ឯត្ថាតិ > អាសយោ, អធិកោ អាសយោ > អជ្ឈាសយោ** ។ សភាវៈប្រព្រឹត្តអាស្រ័យនូវអារម្មណ៍; វិ. **អារម្មណំ អធិកិច្ច សយតិ បវត្តតីតិ > អជ្ឈាសយោ** ។



**អជ្ឈិដ្ឋ** គុ. [ អធិ+ឥស+ត ] គឺ...បង្គាប់ហើយ, _អញ្ជើញហើយ, _អារាធនាហើយ ។

**អជ្ឈុប្បត្ត** គុ. [ អធិ+ឧ+បត+ត ] ឆាបហើយ, ឆាបចុះហើយ, ឆ្វៀលធ្លាក់ហើយ ។

**អជ្ឈុបេក្ខន** នថុ. [ អធិ+ឧប+ឥក្ខ+យុ ] កិ.ចូលទៅសំឡឹងដ៏ក្រៃលែង, កិ.ពិនិត្យពិច័យ; វិ. **ឧបេក្ខិយតេតិ > ឧបេក្ខនំ, អធិកំ ឧបេក្ខនំ > អជ្ឈុបេក្ខនំ** ។

**អជ្ឈេសន** នថុ. [ អធិ+ឥស+យុ ] សេចក្តីអញ្ជើញ, ការអារាធនា, កិ.ស្វែងរកដ៏ក្រៃលែង ។

**អជ្ឈោកាស** ពុ. [ អធិ+ឱកាស ] ទីឱកាសដ៏ក្រៃលែង, ទីវាលស្រឡះ ។

**អជ្ឈោគាហេត្វា** អ. [ អធិ+អវ+គហ+ណេ+ត្វា ] ឆាបចុះហើយ, ឆ្វៀលធ្លាក់ហើយ ។

**អជ្ឈោត្ថត** គុ. [ អធិ+អវ+ថរ+ត ] គឺ...គ្របសង្កត់ហើយ, _រួបរឹតហើយ, _សង្កត់ចុះហើយ ។

**អជ្ឈោត្ថរតិ** កិ. [ អធិ+អវ+ថរ+អ+តិ_វ.] គ្របសង្កត់, រួបរឹត, សង្កត់ចុះ, រលំសង្កត់ ។

**អជ្ឈោសាន** នថុ. [ អធិ+អវ+សា+យុ ] ទីបំផុតក្រៃពេក, ទីចប់, សេចក្តីរាយមាយ, សេចក្តីរសាយចិត្ត ។

**អជ្ឈោហរណីយ** គុ. [ អធិ+អវ+ហរ+អនីយ ] (អាហារ) ដែលគេគប្បីលេបចូលទៅ; វិ. **អជ្ឈោហរិតព្វោតិ>អជ្ឈោហរណីយោ** ។ -**មត្ត** គុ. គ្រាន់តែ ឬត្រឹមតែអាហារដែល...គប្បីលេបចូលទៅ ។

**អឈាយន្ត** គុ. [ ន+ឈេ+អន្ត ] កាលមិនញុំាងកិលេសឱ្យឆេះ, កាលមិនដុតនូវកិលេស, កាលមិនសំឡឹង, កាលមិនពិនិត្យ, កាលមិនពិចារណា ។

**អឈាយី** គុ. [ ន+ឈាយី ] មិនមែនអ្នកមានឈាន (មិនមែនអ្នកមានគុណជាតជាគ្រឿងញុំាងកិលេសឱ្យឆេះ, អ្នកមិនពិនិត្យ, អ្នកមិនពិចារណា); វិ. **ឈាយំ យស្ស អត្ថីតិ > ឈាយី, ន ឈាយី > អឈាយី** ។

**អញ្ជន** នបុំ. [ អញ្ជ+យុ ] ថ្នាំសម្រាប់បន្តក់ ឬថ្នាំសម្រាប់លាប (ថ្នាំបន្តក់ភ្នែក); វិ. **អញ្ជតិ សិញ្ចតិ ឯតេនាតិ > អញ្ជនំ, អញ្ជតិ មក្ខតិ ឯតេនាតិ វា > អញ្ជនំ** ។ -**បីសនត្ថ** បុំ. សេចក្ដីត្រូវការដល់កិ.កិននូវថ្នាំសម្រាប់បន្តក់, ប្រយោជន៍ដល់កិ.កិនជាថ្នាំសម្រាប់លាប ។ -**វណ្ណ** គុ. មានពណ៌ដូចជាពណ៌នៃថ្នាំអញ្ជន ។

**អញ្ជលី** បុំ. [ អញ្ជ+អលិ ] ជាគ្រឿងប្រកាស ឬសម្ដែងនូវភក្តី (សេចក្ដីរាប់អាន, សេចក្ដីគោរព) អញ្ជលី, ក្រពុំដៃដ៏រុងរឿងដោយក្រៃលែង, ក្រពុំដៃ ។ -**កម្ម** នបុំ. កិ.ធ្វើនូវអញ្ជលី, អញ្ជលិកម្ម ។ -**ករណមត្ត** គុ. គ្រាន់តែកិ.ធ្វើនូវអញ្ជលី ។

**អញ្ជាបេសិ** គិ. [ អញ្ជ+ណាបេ+ឦ-អជ្ជ.+ស.រក.] ញុំាង...ឱ្យបន្តក់ហើយ, -ឱ្យលាបហើយ, -ឱ្យស្រឡាបហើយ ។



**អញ្ញតរ** វិ.ស.អ. [ អញ្ញ+តរ ] ដទៃជាង, ណាមួយ, មួយរូប, មួយនាក់; (មាននាមនិងគោត្រមិនប្រាកដ) ។ -**វិបក្ខសេវកភិក្ខុវត្ថុ** នបុំ. រឿងនៃភិក្ខុអ្នកសេពគប់នូវបុគ្គលដែលមានពួកខុសគ្នា ឬផ្សេងគ្នាមួយរូប ។

**អញ្ញត្រ** អ.ស.[ អញ្ញ+ត្រ ] ក្នុង...ដទៃ; និ. វៀរលែង, លើកលែង ។

**អញ្ញថត្ត** នបុំ. [ អញ្ញថា+ត្ត ] ភាវៈនៃ...តាំងនៅដោយប្រការដទៃ, ភាវៈនៃប្រការៈដទៃ; វិ. **អញ្ញថា ភាវោ > អញ្ញថត្តំ** ។ **ត្ត**=បើចុះមកជាសកត្ថត្រូវប្រែថា «ប្រការៈដទៃ» **អញ្ញថា ឯវ> អញ្ញថត្តំ** ។

**អញ្ញថា** អ. [ អញ្ញ+ថា ] ប្រការដទៃ, ដោយប្រការដទៃ ។ -**គហណភាវ** បុំ. ភាវៈគឺកិ.កាន់យកដោយប្រការដទៃ ។

**អញ្ញទត្ថុ** និ. ដោយពិត, ប្រាកដ,... ។

**អញ្ញទា** កា.ស. [ អញ្ញ+ទា ] ក្នុងកាលដទៃ, ក្នុងកាលឯទៀត ។

**អញ្ញមញ្ញំ** កិ.វិ. [ អញ្ញំ+អញ្ញំ ] នូវគ្នានឹងគ្នា, ដល់គ្នានឹងគ្នា, ទៅវិញទៅមក ។

**អញ្ញ** វិ.ស.អ. ដទៃ, ឯទៀត ។

**អញ្ញា** បុំ. [ អា+ញា+អ ] គុណវិសេសដែលបុគ្គលគប្បីដឹងទូទៅ (អរហត្តផល) ។

**អញ្ញា** អ. [ អា+ញា+ត្វា, យុចត្វា ] ព្រោះដឹងទូទៅ ឬដឹងសព្វហើយ ។

**អញ្ញាណ** នបុំ. [ ន+ញា+យុ ] មោសជាតមិនមែនជាញាណ, សេចក្ដីមិនដឹង (សេចក្ដីល្ងង់); វិ. **ញាយតេតិ > ញាណំ, ន ញាណំ > អញ្ញាណំ** ។

**អញ្ញាណាភិភូត** គុ. [ អញ្ញាណ+អភិភូត ] គឺទោសជាតមិនមែនជាញាណគ្របសង្កត់ហើយ, គឺសេចក្ដីល្ងង់គ្របសង្កត់ហើយ ។

**អញ្ញាណី** គុ. [ ន+ញាណី ] មិនមែនអ្នកមានញាណ; វិ. **ញាណំ យស្ស អត្ថិ > ញាណី, ន ញាណី > អញ្ញាណី** ។ អ្នកមានគំ. មិនដឹង ឬអ្នកមានគំ.មិនដឹងជាប្រក្រតី; វិ. **អញ្ញាណំ យស្ស អត្ថិ > អញ្ញាណី, អញ្ញាណំ សីលមស្សាតិ វា > អញ្ញាណី** ។

**អញ្ញាតកវេស** ចុំ. [ អញ្ញាតក+វេស ] ភេទនៃខ្លួនគឺបុគ្គលដទៃមិនដឹងហើយ, ភេទនៃខ្លួនគឺអ្នកណានីមួយមិនស្គាល់ហើយ, ភេទមិនប្រាកដ ។

**អញ្ញាតក** គុ. [ ន+ញាតក ] មិនមែនជាជនដែលគេគប្បីស្គាល់, មិនមែនជាញាតិ; វិ. **ញាតព្វោតិ > ញាតោ, ញាតោ ឯវ > ញាតកោ, ន ញាតកោ > អញ្ញាតកោ** ។

**អញ្ញាត** គុ. [ ន+ញា+ត ] ដែល...មិនដឹងហើយ; (<អា+ញា+ត=ដឹងទូទៅហើយ, ដឹងហើយ) ។

**អញ្ញាយ** អ. [ អា+ញា+ត្វា, ត្វា>យ ] ដឹងទូទៅហើយ, ដឹងសព្វហើយ, ដឹងហើយ ។

**អញ្ញាវិហិតក** គុ. [ អញ្ញ+អាវិហិតក ] បញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ,មានចិត្តស្មុងទៅក្នុងអារម្មណ៍ដទៃ ។ (បាលីខ្លះ **អញ្ញាវិហិតក**<អញ្ញ+វិហិត+ក)=មានចិត្តបញ្ជូនទៅក្នុងអារម្មណ៍ដទៃ, មានចិត្តរាយមាយទៅក្នុងអារម្មណ៍ដទៃ; វិ. **អញ្ញស្មិំ អារម្មណេ ចិហិតំ ចិត្តំ យេន វា យស្ស សោ > អញ្ញចិហិតកោ** ។



**អដនី** ឥ. [ អដ+អនិ ] មេព្រៃ ។

**អដវី** ឥ. [ អដ+អវ+ឦ ] ប្រទេសជាទីដើរទៅនៃជន (ព្រៃ, ដងព្រៃ); វិ. **អដតិ គច្ឆតិ ឯត្ថាតិ > អដវី** ។ . **បទេស** ចុំ. ប្រទេសនៃព្រៃ, ប្រទេសមានព្រៃ, ប្រទេសជិតព្រៃ ។ . **ទេវតា** ឥ. ទេវតានៅក្នុងព្រៃ ។.**មជ្ឈ** នចុំ. ទីពាក់កណ្ដាលនៃព្រៃ, កណ្ដាលនៃព្រៃ, ។ . **មុខ** នចុំ. មាត់នៃព្រៃ ។

**អដ្ដក** ចុំ. [ អដ្ដ+ក ] ហាង, រាន, ព្រៃ ។

**អដ្ដ** ចុំ. [ អដ្ដ+អ ] ក្ដី, សេចក្ដី ។

**អដ្ដាលកបរិក្ខា** ឥ. [ អដ្ដាលក+បរិក្ខា ] ប៉មនឹងគូ, ប៉មនឹងស្នាមភ្លោះ ។

**អដ្ដិយមាន** គុ. [ អដ្ដ+ឥ.អា+យ+មាន ] កាលអៀនអន់, គឺ...កាលឱ្យនឿយណាយ ។

**អដ្ឋ** ប.សំ. ប្រាំបី ។ . **អនរិយវោហារ** ចុំ. វោហារមិនប្រសើរ៨យ៉ាង, វោហារនៃបុគ្គលពាលមិនមែនជាព្រះអរិយៈមាន ៨ យ៉ាង ។

**អដ្ឋកថា** ឥ. [ អត្ថ+កថ+អ+អា.ឥ.] វាចាជាគ្រឿងពោលនូវសេចក្ដី; វិ. **អត្ថំ កថេតិ ឯតាយាតិ > អដ្ឋកថា** ។ ផ្លាស់ ត្ថ>ដ្ឋ ។.**វិនិច្ឆយ** ចុំ. គំ.វិនិច្ឆ័យក្នុងអដ្ឋកថា, គំ.កាត់មិនសល់ដោយវិសេសក្នុងអដ្ឋកថា ។

**អដ្ឋកភត្ត** ទចុំ. [ អដ្ឋក+ភត្ត ] ភត្តគឺបុគ្គលគប្បីឱ្យដល់ភិក្ខុមានប្រមាណ៨; វិ. **អដ្ឋ បរិមាណានិ យេសន្តិ > អដ្ឋកា, អដ្ឋកានំ ទាតព្វំ ភត្តំ > អដ្ឋកភត្តំ** ។

**អដ្ឋ** ប.សំ. ប្រាំបី ។ . **ករីសមត្ត** គុ. មានករីស៨ ជាប្រមាណ, ត្រឹមតែករីស៨, ត្រឹមតែ៨ករីស (១ករីស ត្រូវជា ១៧៥ ហត្ថ) ។.**កហាបណទណ្ឌ** ចុំ. ពិន័យដោយកហាបណៈ ៨ ។ . **នវមាសទ្វយ** ចុំ. កាលជាទីប្រព្រឹត្តក្នុងទៅនៃខែ៨ និង ខែ៩, កាលជាទីប្រព្រឹត្តក្នុងទៅអស់ខែ៨ និងខែ៩ ។ . **បញ្ញាសហត្ថុព្វេធ** គុ. មានកំពស់នៃហត្ថ៥៨, មានកំពស់មានហត្ថ៥៨ជាប្រមាណ, មានហត្ថ៥៨ជាចំណែកខ្ពស់ ។ . **អដ្ឋកហាបណៈ** ចុំ. កហាបណៈ៨ៗ, ឬ ៨និង៨ ។ . **យោជនមត្ត** ចុំ. ផ្លូវមានយោជន៍៨ជាប្រមាណ (១យោជន៍ ត្រូវជា៤០០សិន) ។ . **វគ្គិក** គុ. មានវគ្គ៨; វិ. **អដ្ឋ វគ្គានិ យស្សា សា > អដ្ឋវគ្គិកា** ។ . **វិធ** គុ. មានប្រការ៨; វិ. **អដ្ឋ វិធា យស្ស តំ > អដ្ឋវិធំ** ។ . **សដ្ឋីភិក្ខុសតសហស្ស** ទចុំ. សែននៃភិក្ខុ៦៨ (៦៨សែន ឬ៦លាន៨សែន) ។ .**សដ្ឋីយោជនសតសហស្សដ្ឋាន** ទចុំ. ទីមានសែននៃយោជន៍៦៨ជាប្រមាណ ។ .**សដ្ឋីយោជនសតសហស្សុព្វេធ** គុ. មានកំពស់មានសែននៃយោជន៍៦៨ជាប្រមាណ, មានកិ.ខ្ពស់ឡើងអស់ទីមានសែននៃយោជន៍៦៨ជាប្រមាណ(៦៨សែនយោជន៍)។.**សដ្ឋីវស្សសហស្ស** ទចុំ. ពាន់នៃឆ្នាំ៦៨ ( ៦៨ពាន់ឆ្នាំ ឬ៦ហ្មឺន៨ពាន់ឆ្នាំ ) ។ .**សតសហ-**



**ស្សវិភវ** គុ. មានភោគៈគឺបុគ្គលគប្បីប្រើប្រាស់មានសែន៨ ជាប្រមាណ, មានសម្បត្តិមានសែន៨ជាប្រមាណ ។ . **សមាបត្តិក** គុ. អ្នកមានសមាបត្តិ៨, អ្នកប្រកបក្នុងសមាបត្តិ៨ ។ .**សមាបត្តិលាភ** ចុំ. កិ.បាននូវសមាបត្តិ៨ ។ . **សមាបត្តិសមាធិ** ចុំ. សមាធិដ៏សម្បយុត្តដោយសមាបត្តិ៨ ។ . **សមាបត្តិសង្ខាត** គុ. គឺបណ្ឌិតរាប់ព្រមហើយថាសមាបត្តិ៨, ពោលគឺសមាបត្តិ៨ ។. **ហត្ថសាដក** ចុំ. សាដកមានហត្ថ៨ជាប្រមាណ, សាដក៨ហត្ថ ។

**អដ្ឋម** ប្ហ.សំ. [ អដ្ឋ+ម ] ទី៨, គំរប់៨ ។

**អដ្ឋមី** ប្ហ.សំ. [ អដ្ឋ+ម+ឦ ] ទី៨, គំរប់៨; មានតិថីទី៨, តិថីទី៨ ។. **ទិវស** នចុំ., ចុំ. ថ្ងៃទី៨, ថ្ងៃគឺតិថីទី៨ ។

**អដ្ឋង្គសមន្នាគត** គុ. [ អដ្ឋង្គ+សមន្នាគត ] មកតាមព្រមហើយដោយអង្គ៨, ប្រកបហើយដោយអង្គ៨, (**សមន្នាគត**<សំ+អនុ+អា+គម+ត) ។

**អដ្ឋង្គសុសមាគត** គុ. [ អដ្ឋង្គ+សុសមាគត ] មកព្រមល្អហើយដោយអង្គ៨, ប្រកបដោយអង្គ៨ (**សុសមាគត**<សុ+សំ+អា+គម+ត) ។

**អដ្ឋង្គិក** គុ. [ អដ្ឋង្គ+ណិក ] មានអង្គ៨, ប្រកបដោយអង្គ៨; វិ. **អដ្ឋ អង្គានិ > អដ្ឋង្គំ, អដ្ឋង្គំ ឯតស្ស អត្ថីតិ > អដ្ឋង្គិកោ, អដ្ឋង្គេន និយុត្តោ > អដ្ឋង្គិកោ** ។

**អដ្ឋាន** នពុំ. [ ន+ឋាន ] មិនមែនជាហេតុជាទីតាំងនៃផល, មិនមែនជាឋានៈ; វិ. **តិដ្ឋតិ ផលមេត្ថាតិ> ឋានំ, ន ឋានំ> អដ្ឋានំ** ។ ទីមិនគួរ; វិ. **អយុត្តំ ឋានំ > អដ្ឋានំ** ។

**អដ្ឋារស** ប.សំ. [ អដ្ឋ>អដ្ឋា+ទស, ទស>រស ] ១០ក្រៃលែងដោយ៨(១៨); វិ. **អដ្ឋហិ អធិកា ទស> អដ្ឋារស** ។ . **កោដិធន** នពុំ. ទ្រព្យមានកោដិ១៨ជាប្រមាណ ។ . **កោដិសង្ខាត** គុ. គឺ...រាប់ព្រមហើយថាកោដិ១៨, ពោលគឺកោដិ១៨ ។ . **ព្រហ្មកោដិ** ឥ. កោដិនៃព្រហ្ម១៨ ។

**អដ្ឋាសិ** កិ. [ អ+ឋា+អ+ឰ.អដ្ឋ.+ស.អា.] បានឋិតនៅហើយ, បានតាំងនៅហើយ, បានឈរនៅហើយ ។

**អដ្ឋិ** នពុំ. [ អស+ថិ, ថិ>ដ្ឋិ, លុបស ] ធម្មជាតដែលគេតែងបោះចោល (ឆ្អឹង); វិ. **អសិយតិ ខិបិយតីតិ> អដ្ឋិ** ។ . **កល្យាណ** នពុំ. លំអនៃឆ្អឹង; គុ. មានឆ្អឹងជាលំអ ។ . **ចម្មាវសេស** គុ. មានឆ្អឹងនិងស្បែកដ៏សេសចុះ, សល់ត្រឹមតែឆ្អឹងនិងស្បែក, សេសចុះនៃឆ្អឹងនិងស្បែក ។ . **ភេទនិស្សន្ទ** ពុំ. វិបាកជាគ្រឿងហូរចេញគឺកិ.បាក់នៃឆ្អឹង, វិបាកជាគ្រឿងហូរមិនដាច់គឺកិ.បែកធ្លាយនៃឆ្អឹង ( និស្សន្ទ < និ+សន្ទ +អ ) ។ . **មត្តាវសាន** គុ. មានត្រឹមតែឆ្អឹងជាទីបំផុត; នពុំ. ទីបំផុតត្រឹមតែឆ្អឹង។ . **មត្តាវសេស** គុ. មានអវយវៈត្រឹមតែឆ្អឹងដ៏សេសចុះ, ដ៏សេសសល់ត្រឹមតែឆ្អឹង។ . **មិញ្ជ** ពុំ. ខួរក្នុងឆ្អឹង ។ . **សង្ខលិកប្បេតាទិ** គុ. មានប្រេតប្រកបដោយរាងនៃឆ្អឹង ជាដើម, មានរង្គិសង្ខលិកប្រេតជាដើម ។ . **សង្ឃាត** ពុំ. រាងនៃឆ្អឹង, (ការប្រជុំនៃឆ្អឹង) ។



**អដ្ឋត្វា** អ. [ ន+ឋា+ត្វា ] មិនតាំងនៅហើយ, មិនឈរនៅហើយ, មិនឈប់ហើយ, តាំងនៅមិនបានហើយ ។

**អដ្ឋបេត្វា** អ. [ ន+ឋប+ឯ+ត្វា ] មិនតាំងទុកហើយ, មិនដំកល់ទុកហើយ ។

**អដ្ឋិត** គុ. [ ន+ឋា,អានៃឋា>ឥ+ត ] មិនតាំងនៅហើយ, មិនឋិតនៅហើយ, មិនឈប់ហើយ ។ . **ការី** ពុំ. អ្នកមានកិ.ធ្វើនូវ...មិនឈប់ជាប្រក្រតី ។ (អដ្ឋិត<អា+ឋា, អានៃឋា>ឥ+ត=តាំងនៅស៊ប់ហើយ) ។

**អឌ្ឍ, អឌ្ឍ** គុ. [ អឌ្ឍ<អឌ+ឍ; អឌ្ឍ<អឌ+ធ ] កន្លះ, ពាក់កណ្ដាល, មាំ, មាំមួន, រឹងប៉ឹង, ស្ដុកស្ដម្ភ ។ . **ករីសមត្ត** គុ. មានកន្លះនៃករីសជាប្រមាណ, ត្រឹមតែកន្លះនៃករីស ។ . **កុល** នពុំ. ត្រកូលស្ដុកស្ដម្ភ, ត្រកូលមាំមួន។ . **អក្ខិក** នពុំ. កន្លះនៃភ្នែក, ពាក់កណ្ដាលនៃភ្នែក ។ . **អត្ថនិក** គុ. គួរដល់ថ្លៃពាក់កណ្ដាល, គួរដល់ថ្លៃមានកន្លះនៃពាទជាប្រមាណ ។ . **អង្គុល** គុ. មានកន្លះនៃធ្នាប់ជាប្រមាណ, កន្លះនៃធ្នាប់ ។ . **តេយ្យ** គុ. ទីពដោយកន្លះ, គំរប់ពដោយកន្លះ (២កន្លះ); វិ. **អឌ្ឍេន តតិយោ > អឌ្ឍតេយ្យោ** ។ . **តេយ្យសត** នពុំ. រយៈនៃ...ជាគំរប់ពដោយកន្លះ (២៥០) ។ . **តេរសកោដ្ឋិសត** នពុំ. រយនៃជង្រុក១៣ ដោយកន្លះ (១.២៥០ជង្រុក) ។ . **នាឡិមត្ត** គុ. មានកន្លះនៃនាឡិជាប្រមាណ, ត្រឹមតែកន្លះនៃនាឡិ ។

- ភុត្តភោជនបាតិ ឥ. ភាជន៍ដ៏ពេញដោយភោជនដែល...បរិភោគហើយពាក់កណ្ដាល ។ - មាសច្ចយ បុំ. កាលជាទីប្រព្រឹត្តកន្លងទៅកាលជាទីប្រព្រឹត្តទៅអស់កន្លះនៃខែ ។ - មាសមត្ត គុ. ត្រឹមតែកន្លះនៃខែ ។ - មាសាធិក គុ. ដ៏ក្រៃលែងដោយកន្លះនៃខែ, ដ៏លើសដោយកន្លះនៃខែ ។ - មាស បុំ. កន្លះ នៃខែ, កាលជាកន្លះនៃខែ ។ - យោជនប្បមាណ គុ. មានកន្លះនៃយោជន៍ជាប្រមាណ, មានយោជន៍កន្លះជាប្រមាណ ។ - យោជន នបុំ. កន្លះនៃយោជន៍ ។ - យោជនិក គុ. មានកន្លះនៃយោជន៍ជាប្រមាណ; វិ. **យោជនស្ស អឌ្ឍា > អឌ្ឍយោជនំ, អឌ្ឍយោជនំ អស្ស បរិមាណំ > អឌ្ឍយោជនិកោ** ។ ប្រកបដោយកន្លះនៃយោជន៍; វិ. **អឌ្ឍយោជនេន និយុត្តោ > អឌ្ឍយោជនិកោ** ។ - យោជនិកាទិភេទ បុំ. ផ្សេងដោយ អាសនៈមានអាសនៈប្រកបដោយកន្លះនៃយោជន៍ជាដើម; គុ. មានមានអាសនៈប្រកបដោយកន្លះនៃយោជន៍ជាដើមជាប្រភេទ ។ - ឧល្លិក្ខិត គុ. (<អឌ្ឍ+ឧ+លិខ, លិខ>លិក្ខ+ឥ+ត) ដែល...ស្និតស្អាងហើយពាក់កណ្ដាល, ដែលគេចើបនឹងស្និតស្អាងបានពាក់កណ្ដាល ។ - អាឡ្ហកមត្ត គុ. មានកន្លះនៃអាឡ្ហកជាប្រមាណ ។ - ឧឌ្ឍ គុ. ទី៤ដោយកន្លះ, គំរប់៤ដោយកន្លះ (៣កន្លះ); វិ. **អឌ្ឍេន ចតុត្ថោ > អឌ្ឍុឌ្ឍោ** ។

**អណុថូល** គុ. [ អណុ+ថូល ] តូចនិងធំ, ល្អិតនិងគ្រោស, តិចនិងច្រើន ។

**អណុមត្ត** គុ. [ អណុ+មត្ត ] មានប្រមាណដ៏តូច ។



**អណ្ឌ** បុំ., នបុំ. [ អម > អណ+ឌ ] ធម្មជាតជាទីកើតនៃសត្វ (ពង); វិ. **អមន្តិ ឧប្បជ្ជន្តិ ឯត្ថាតិ > អណ្ឌំ** ។

**អណ្ណវកុច្ឆិ** ឥ. [ អណ្ណវ+កុច្ឆិ ] ផ្ទៃនៃសមុទ្រ, ផ្ទៃនៃទន្លេ, ផ្ទៃនៃទឹក ។

**អតជ្ជិត្វា** អ. [ ន+តជ្ជ+ឥ+ត្វា ] មិនគំរាមហើយ, មិនគំទរហើយ, មិនគ្រហឹមហើយ ។

**អតន្ទិត** គុ. [ ន+តន្ទ+ឥ+ត ] មិនខ្ជិលហើយ, មិនកៀចក្រាញហើយ, មិនទម្រន់ទៀត ។

**អតិ** ឧ.ស. ក្រៃលែង, ក្រៃពេក, ច្រើន, កន្លង, លើស, ពេក, ណាស់ ។ - ឧទក នបុំ. ទឹកក្រៃលែង (ទឹកច្រើន) ។ - ឧស្សុរ គុ. (កាល) មានព្រះអាទិត្យក្នុងខាងលើក្រៃពេក (ថ្ងៃត្រង់); វិ. **អតិឧទ្ធំ សូរោ យស្មិំ សោ > អតិឧស្សុរោ** ។ - កិលមេយ្យ កិ. គប្បីលំបាកក្រៃពេក, គប្បីនឿយហត់ក្រៃពេក ។ - ក្កន្តកាល បុំ. កាលនៃ...ឈានកន្លងហើយ, កាលដែលកន្លងទៅហើយ ។ - ក្កន្តមត្ត គុ. គ្រាន់តែឈានកន្លងហើយ ។ - ក្កន្តមានុសិក គុ. មានសោតធាតុជារបស់នៃមនុស្សឈានកន្លងហើយ (ដែលកន្លងហើយនូវសោតធាតុជារបស់នៃមនុស្ស); វិ. **មនុស្សស្ស សន្តកា > មានុសិកា (សោតធាតុ), អតិក្កន្តា មានុសិកា អស្សាតិ > អតិក្កន្តមានុសិកោ** ។ - ក្កន្តវយ គុ. ដែលមានវ័យកន្លងហើយ; វិ. **អតិក្កន្តោ វយោ អស្សាតិ > អតិក្កន្តវយោ** ។ - ក្កន្ត គុ. (<អតិ+កម+ត) ឈានកន្លងហើយ, កន្លងបង់ហើយ ។ - ក្កមន្ត

គុ. (<អតិ+កម+អន្ត) កាលឈានកន្លង។ -**ក្កមន** នបុ. (<អតិ+កម+យុ) ការឈានកន្លង, កិ.ឈានកន្លង ។ -**ក្កម** បុ. កិ.ឈានកន្លង; វិ. **អតិក្កមនំ > អតិក្កមោ** ។ -**ក្កូរ** គុ.ដែលរឹងរូសក្រៃពេក, អាក្រក់ក្រៃពេក, កាចក្រៃពេក ។ -**ខីណ** គុ. (អតិ+ខិ+ត, ត>ណ្ណ) ដែលអស់ហើយក្រៃពេក ។ -**គម្ភីរ** គុ. ដែលជ្រៅពេក, ជ្រៅណាស់ ។ -**គរុក** គុ. ដែលធ្ងន់ក្រៃពេក ។ -**ចណ្ឌ** គុ. ដែលកាចក្រៃពេក, សាហាវក្រៃពេក ។ -**ចរិត្វា** អ. ប្រព្រឹត្តកន្លងហើយ ។ -**ចារិនី** ឥ. (<អតិ+ចរ+ណី+ឥនី) អ្នកប្រព្រឹត្តកន្លង (ស្ត្រីប្រព្រឹត្តក្បត់ចិត្ត); វិ. **អតិចរតិ > អតិចារិនី** ។ -**ចារិនីភាវ** បុ. ភាវៈនៃស្ត្រីជាអ្នកប្រព្រឹត្តកន្លង ។ -**ចារ** បុ. (<អតិ+ចរ+ណ) ការប្រព្រឹត្តកន្លង; វិ. **អតិចរណំ > អតិចារោ** ។ -**ចិរាយន្ត** គុ. (<អតិ+ចិរ+អាយ+អន្ត) កាលប្រព្រឹត្តយូរពេក ។ -**ច្ច** អ. (<អតិ+ឥ+ត្វា, ត្វា>ច្ច, លុប រ) កន្លងហើយ, ប្រព្រឹត្តកន្លង ។ -**ច្ចេថ** កិ. (<អតិ+ឥស+យ+ថ.ប.) ចូរប្រព្រឹត្តកន្លង (ចូរប្រោសសត្វទៅខាងមុខ, សូមនិមន្តប្រោសសត្វទៅខាងមុខទៅ) ។ -**តរុណ** គុ. ក្មេងពេក, នៅក្មេងណាស់, នៅកំលោះពេក, ខ្ចីក្រៃពេក ។ -**ទហរ** គុ. ក្មេងពេក, នៅកំលោះគ្រឡាំង។ -**ទឡ្ហ** គុ. មាំណាស់, មាំក្រៃពេក, ខ្លាំងណាស់ ។ -**ទីឃ** គុ. វែងណាស់, វែងពេក ។ -**ទុក្ករ** នបុ. អំពើដែលបុគ្គលធ្វើបានដោយកម្រណាស់ ។ -**ទុក្ខ** គុ. ដែលលំបាកពេក ។ -**ទុគ្គតភាវ** បុ. ភាវៈនៃ...ជាអ្នកដល់ហើយនូវសេចក្តី



អនេក គុ. [ ន+ឯក>អនេក ] មិនមែនមួយ, មិនមែនតែមួយ (ច្រើន) ។

-កោដិសំខ្យា ឥ. គឺបុគ្គលរាប់ដោយកោដិមិនមែនមួយ ។ -ជាតិ-

សតសហស្សសំខ្យា គ. គឺ...រាប់ដោយសែនរៃជាតិមិនតែមួយ ។ . **ជាតិសង្សារ** ចុំ. សង្សារមានជាតិមិនតែមួយ ។ . **បរិយាយ** ចុំ. សេចក្ដីបរិយាយមិនតែមួយ ។ . **ប្បការ** ចុំ. ប្រការមិនតែមួយ; គុ. មានប្រការមិនតែមួយ ។ . **ប្បភេទ** គុ. មានប្រភេទមិនតែមួយ ។ . **ផល** គុ. មានផលមិនតែមួយ ។ . **ព្យញ្ជន** គុ. មានព្យញ្ជនៈមិនតែមួយ ។ . **ព្រាហ្មណមហាសាល** ចុំ. ព្រាហ្មណ៍មហាសាល ឬ ព្រាហ្មណ៍ជាមហាសាលមិនតែមួយ ។ . **វណ្ណទេវបុត្ត** ចុំ. ទេវបុត្តឈ្មោះអនេកវណ្ណ, ទេវបុត្តមានវណ្ណៈ (សម្បុរ) មិនតែមួយ ។ . **វស្សកោដិសន្និចិត** គុ. គឺ...សន្សំព្រមហើយអស់កោដិនៃឆ្នាំ មិនតែមួយ (សន្និចិត <សំ+និ+ចិ+ត) ។ . **វិហិត** គុ. មានប្រការៈ (មានបែប) មិនតែមួយ ។ . **វិធ** គុ. មានប្រការៈមិនតែមួយ ។ . **សតសហស្ស** គុ. មានសែនមិនតែមួយ ។ . **សតក្ខត្តុំ** និ. ឬ កិ.វិ. វារៈនៃរយមិនតែមួយ, វារៈមានរយមិនតែមួយ ។ . **សហស្សវង្កក** ចុំ. ចាបមានពាន់ដ៏ច្រើន ។ . **សូបព្យញ្ជនវិកតិ** គុ. មានសម្លទឹកនិងសម្លគោកដ៏ប្លែកច្រើនមុខ, មានសូបៈនិងព្យញ្ជនៈគឺបុគ្គលធ្វើឱ្យវិសេសដ៏ច្រើនមុខ; គ. កិ.ធ្វើប្លែកនៃសូបៈនិងព្យញ្ជនៈមិនតែមួយមុខ (**សូប** នចុំ. សម្ល ឬសម្លទឹក, ម្ហូបទឹក; **ព្យញ្ជន** នចុំ. សម្លគោក, ម្ហូបគោក, ម្ហូបក្រៀម) ។

**អនេជ** គុ. [ ន+ឥជ+ណ ] ដែលមិនញាប់ញ័រ ។

**អនេញ្ជ** គុ. [ ន+ឥញ្ជ ] អ្នកមានកិលេសជាគ្រឿងញាប់ញ័រមិនមាន, អ្នកមិនមានកិលេសជាគ្រឿងញាប់ញ័រ; វិ. **ឥញ្ជតិ ឯតេនាតិ > ឥញ្ជោ, នត្ថិ ឥញ្ជោ អស្សាតិ > អនេញ្ជោ** (ឥញ្ជ <ឥជ ឬ ឥញ្ជ+ណ) ។ . **វិហារសមាបត្តិធម្មបរិភោគ** ចុំ. កិ.បរិភោគនូវសមាបត្តិធម៌ (នូវធម៌ដែលប្រកបដោយសមាបត្តិ) ជាទីនៅនៃបុគ្គលអ្នកមិនមានកិលេសជាគ្រឿងញាប់ញ័រ ។

**អនេសន,-នា** នចុំ., គ. [ ន+ឥស+យុ ] កិ.ស្វែងរកមិនគួរ, សេចក្ដីប្រាថ្នាមិនគួរ, កិ.ចង់បានមិនគួរ; វិ. **អយុត្តំ ឯសនំ > អនេសនំ , អយុត្តា វា ឯសនា > អនេសនា** ។

**អនោក** នចុំ. [ ន+ឱក ] កិ.មិនមាននៃទីជាទីនៅ; វិ. **ឱកស្ស អភាវោ > អនោកំ** ; គុ. (និព្វាន) មានអាល័យមិនមាន; វិ. **នត្ថិ ឱកំ ឯតស្សាតិ > អនោកំ** ។

**អនោកាសទិវស** ចុំ., នចុំ. [ អនោកាស+ទិវស ] ថ្ងៃនៃ...មានឱកាសមិនមាន, ថ្ងៃមានឱកាសមិនមាន, ថ្ងៃមិនមានចំនេរ; វិ. **នត្ថិ ឱកាសោ ឯតស្សាតិ > អនោកាសោ** ។

**អនោកាស** ចុំ., គុ. [ ន+ឱកាស ] មិនមែនជាឱកាស, មិនមានឱកាស (មិនចំនេរ) ។

**អនោកចារី** ចុំ. [ អនោក+ចរ+ណី ] អ្នកមានអាល័យមិនមានត្រេចទៅ, អ្នកត្រេចទៅដោយមិនមានអាល័យ ឬដោយកិ.មិនមាននៃទីជាទីនៅ ។ ចូរមើល «**អនិកេតចារី**» ។

**អនោក្កមន្ត** គុ. [ន+អវ+កម+អ+អន្ត] កាលមិនឈានចុះ, កាលមិនចុះស៊ប់ ។

**អនោជ** ចុំ. ននោង ។ - **បុប្ផចង្កោដក** ចុំ. ប្រអប់ សម្រាប់ដាក់ផ្កាន-នោង, ប្រអប់ដ៏ពេញដោយផ្កាននោង ។ - **បុប្ផវណ្ណ** គុ. មានពណ៌ដូចជាផ្កានៃននោង ។

**អនោជាទេវី** ឥ. ទេវីឈ្មោះអនោជា ។

**អនោតត្ត** ចុំ. [ ន+អវ+តប+ត ] ស្រះជាទីមិនក្តៅព្រោះមិនមានកំដៅគីរស្មីនៃព្រះអាទិត្យចាល់ត្រូវហើយ (ស្រះឈ្មោះអនោតត្ត; វិ. **សុរិយរស្មិសមុជ្ជាភាសេន ន អភិតបតិ ឧទកមេត្ថាតិ> អនោតត្តោ** ។ - **ទហបិដ្ឋ** នចុំ. ខ្នងនៃស្រះឈ្មោះអនោតត្ត ។ - **ទហ** ចុំ. ស្រះឈ្មោះអនោតត្ត ។

**អនោតរន្ត** គុ. [ ន+អវ+តរ+អ+អន្ត ] កាលមិនឆ្លងចុះ, កាលមិនចុះឆ្លង, កាលមិនស្លុងទៅ ។

**អនោទក** គុ. [ ន+ឧទក ] មានទឹកមិនមាន, នចុំ. គឺ.មិនមាននៃទឹក (ឥតទឹក) ។

**អនោនត** គុ. [ ន+អវ+នម+ត ] គឺ...មិនឱនចុះហើយ, មិនពន្ទន់ចុះហើយ, មិនទ្រោមចុះហើយ ។

**អនោបម** គុ. [ ន+ឧបមា ] មានឧបមាមិនមាន, មិនមានសេចក្តីប្រៀប; វិ. **នត្ថិ ឧបមា ឯតស្សាតិ> អនោបមា** ។

**អនោម** គុ. [ ន+ឱម ] មិនថោកទាប, មិនថយថោក ។ - **គុណត្ត** នចុំ. ភាវៈនៃ...ជាអ្នកមានគុណមិនថោកទាប ។ - **គុណ** គុ. អ្នកមានគុណមិនថោកទាប ។ - **ត្ថេរ** ចុំ. ព្រះថេរៈឈ្មោះអនោម ។ - **ទស្សី** ចុំ. ព្រះពុទ្ធទ្រង់ព្រះនាមអនោមទស្សី ។ - **បញ្ញ** គុ. អ្នកមានប្រាជ្ញាមិនថោកទាប, អ្នកមានប្រាជ្ញាមិនតិច ។



**អនោមានទីតីរ** នចុំ. [ អនោមានទី+តីរ ] ឆ្នេរ (ត្រើយ) នៃស្ទឹងឈ្មោះអនោមា ។

**អនោរមិត្វា** អ.[ ន+អវ+រម+ឥ.អា.+ត្វា ] មិនវៀរហើយ, មិនបន្ទូរបន្ថយហើយ ។

**អនោលោកេត្វា** អ. [ ន+អវ+លោក+អ, អ>ឯ+ត្វា ] មិនក្រឡេកមើលហើយ, មិនរមិលមើលហើយ ។

**អនោវស្សកដ្ឋាន** នចុំ.[ អនោវស្សក+ឋាន ] ទីមានភ្លៀងធ្លាក់ចុះមិនមាន, ទីមិនមានភ្លៀងបង្អុរចុះ (ទីនៃសម្បាបផ្ទះ) ។

**អនោសក្កិត្វា** អ. [ ន+អវ+សក្ក+យ, យ>ក+ឥ.អា.+ត្វា ] មិនរោយរៀវហើយ, មិនថយហើយ ។

**អនោសជ្ជិត្វា** អ.[ ន+អវ+សជ+យ, យ>ជ+ឥ.អា.+ត្វា ] មិនលះបង់ហើយ, មិនបណ្តោយហើយ ។

**អនោសាទេត្វា** អ.[ ន+អវ+សទ+ណេ+ត្វា ] មិនញ៉ាំង...ឱ្យត្រេកអរហើយ, -ឱ្យត្រេកអរស៊ប់ហើយ, -ឱ្យចូលចិត្តហើយ ។

**អនោសីទិត្វា** អ. [ន+អវ+សទ, សទ>សីទ+ឥ.អា.+ត្វា] មិនលិចចុះហើយ ។

**អន្ន** នចុំ. [ អស ឬអទ+ត ] វត្ថុគឺបុគ្គលគប្បីស៊ី (បាយ, ចំណី); វិ. **អសិតព្វន្តិ > អន្នំ** ។

អន្វឌ្ឍមាស បុ. [ អនុ+អឌ្ឍមាស ] កន្លះនៃខែជាលំដាប់, កាលដ៏កន្លះនៃខែជាលំដាប់; វិ. **មាសស្ស អឌ្ឍោ> អឌ្ឍមាសោ , អនុ អឌ្ឍមាសោ> អន្វឌ្ឍមាសោ** ។

អន្វាគន្ត្វាន អ. [ អនុ+អា+គម+ត្វាន ] មកតាមហើយ, តាមមកហើយ ។

អន្វាយ អ. [ អនុ+ឥ, ឥ>ឯ អយ+ត្វា, លុបត្វា ] ប្រព្រឹត្តទៅតាមហើយ, អាស្រ័យហើយ ។

អន្វាសត្តតា ឥ. [ អន្វាសត្ត+តា ] ភាវៈនៃ...ជា...ជាប់តាមហើយ (អន្វាសត្ត <អនុ+អា+សជ+ត) ។

អន្វេតិ កិ. [ អនុ+ឥ+អ+តិ.វ. ] រមែងទៅតាម, រមែងតាមទៅ, អន្ទោលតាម ។

អន្វេសំ គុ. [ អនុ+ឥស+អន្ត+សិ.វិ., ផ្លាស់ន្ត+សិ.វិ.>អំ ] កាលតាមស្វែងរក, កាលស្វែងរករឿយៗ, កាលស្វែងរកដោយលំដាប់ ។

អន្តកិរិយា ឥ. [ អន្ត+ករ+រិយ+អា.ឥ. ] កិ.ធ្វើនូវទីបំផុត, កិ.ធ្វើនូវព្រះនិព្វានជាទីបំផុត ។

អន្តក បុ. [ អន្ត+ករ+វ. ] សភាវៈធ្វើនូវទីបំផុត ឬសភាវៈធ្វើនូវទីបំផុត គឺ សេចក្តីវិនាស (មច្ចុ); វិ. **អន្តំ ករោតីតិ> អន្តកោ , អន្តំ វិនាសំ ករោតីតិ វា> អន្តកោ** ។

អន្តមសោ និ. [ អន្តម+សោ.វិ. ] ដោយកំណត់មានក្នុងទីបំផុត, ដោយហោចទៅ; វិ. **អន្តេ ភវោ បរិច្ឆេទោ> អន្តមោ** ។

អន្តរឃរ នបុ. [ អន្តរ+ឃរ ] ចន្លោះនៃផ្ទះ, រវាងនៃផ្ទះ, លំដាប់នៃផ្ទះ; វិ. **ឃរស្ស អន្តរំ > អន្តរឃរំ** ។



អន្តរទ្វារ នបុ. [ អន្តរ+ទ្វារ ] ចន្លោះនៃទ្វារ...; វិ. **ទ្វារស្ស អន្តរំ> អន្តរទ្វារំ** ។

អន្តរទីបក នបុ. [ អន្តរ+ទីបក ] ចន្លោះនៃកោះតូច, រវាងនៃកោះតូច, កោះតូចមានក្នុងចន្លោះ, កោះតូចដទៃ ។

អន្តរធាន នបុ. [ អន្តរ+ធា+យុ ] សេចក្តីអន្តរធាន, កិ.បាត់ទៅ, កិ.សូន្យទៅ, មន្តជាគ្រឿងសូន្យទៅ ។

អន្តរធាបេយ្យាម កិ. [ អន្តរ+ធា+ណាបេ+ឯយ្យាម.ស. ] គប្បីញុំាង...ឲ្យបាត់ទៅ, ឲ្យសូន្យទៅ, ឲ្យអន្តរធានទៅ ។

អន្តរធាយមាន គុ. [ អន្តរ+ធា+ណយ+មាន ] កាលបាត់ទៅ, កាលសូន្យទៅ, កាលអន្តរធានទៅ ។

អន្តរន្តរ នបុ. [ អន្តរ+អន្តរ ] ចន្លោះនិងចន្លោះ, រវាងនិងរវាង, ទីដទៃនិងដទៃ ។

អន្តរពាហិរ គុ. [ អន្តរ+ពាហិរ ] ខាងក្នុងនិងខាងក្រៅ, ទាំងខាងក្នុងទាំងខាងក្រៅ, អវយវៈជាខាងក្នុងនិងអវយវៈជាខាងក្រៅ ។

អន្តរវស្ស នបុ. [ អន្តរ+វស្ស ] ចន្លោះនៃកាលភ្លៀង, ខាងក្នុងនៃកាលភ្លៀង, កាលភ្លៀងមានក្នុងចន្លោះ ។

អន្តរវីថិ ឥ. [ អន្តរ+វីថិ ] ចន្លោះនៃថ្នល់; វិ. **វីថិយា អន្តរំ>អន្តរវីថិ** ។

អន្តរសត្ថិ ឥ. [ អន្តរ+សត្ថិ ] ចន្លោះនៃភ្លៅ, ខាងក្នុងនៃដើមភ្លៅ ។

**អន្តលិក្ខ** នថុ. [ អន្តរ+ឥក្ខ–អ, រ>ល ] (ទីឬប្រទេស) សម្រាប់ឃើញនូវការៈនៃវត្ថុផ្សេងៗក្នុងចន្លោះនៃលោក (អាកាស); វិ. **ចក្ខុនមន្តរេ នានត្ថំ ឥក្ខតេ លោកោ ឯតេនាតិ> អន្តលិក្ខំ** ។

**អន្តរហិត** គុ. [ អន្តរ+ធា+ត, ផ្លាស់ធនៃធា>ហ, អា>ឥ ] តាំងនៅក្នុងទីដទៃហើយ, បាត់ទៅហើយ, អន្តរធានហើយ, សូន្យទៅហើយ ។

**អន្តរាបណ** នថុ. [ អន្តរ+អាបណ ] ចន្លោះនៃផ្សារ, ចន្លោះនៃរានផ្សារ ។

**អន្តរាភត្ត** នថុ. [ អន្តរ+ភត្ត ] ចន្លោះនៃភត្ត, រវាងនៃភត្ត ។

**អន្តរាមគ្គ** នថុ. [ អន្តរ+មគ្គ ] ចន្លោះនៃផ្លូវ, រវាងនៃផ្លូវ, កណ្ដាលនៃផ្លូវ ។

**អន្តរាវាស** ថុ. [ អន្តរ+អាវាស ] កិ.នៅអាស្រ័យក្នុងចន្លោះ, ប្រទេសជាទីនៅអាស្រ័យក្នុងចន្លោះ, ចន្លោះនៃអាវាស ។

**អន្ត** ថុ. [ អម ឬអត+ត ] ទីបំផុត, ចំណែក, ជាយ, ចុង, ព្រំដែន, នថុ. ពោះវៀនធំ, គុ. លាមក, ថោកទាប ។

**អន្តិម** គុ. [ អន្ត+ឥម ] មានក្នុងទីបំផុត, កើតក្នុងទីបំផុត, ប្រកបក្នុងទីបំផុត; (បើចង់វិគ្គហៈត្រូវប្រកបដោយស័ព្ទថា «ភវ, ជាត, និយុត្ត» ចូលមកផង) ។ **–សរីរ** គុ. អ្នកមានសរីរៈមានក្នុងទីបំផុត; វិ. **អន្តិមំ សរីរំ យស្ស សោ> អន្តិមសរីរោ** ។

**អន្តេបុរ** នថុ. [ អន្តេ+បុរ ] ខាងក្នុងនៃបុរី (ខាងក្នុងនៃព្រះរាជវាំង) ។ **–បាលក** ថុ. អ្នករក្សានូវខាងក្នុងនៃបុរី, អ្នករក្សានូវបុរីក្នុងខាងក្នុង; វិ. **អន្តេបុរំ បាលេតីតិ> អន្តេបុរបាលកោ** ។

**អន្តេវាសិក** ថុ. [ អន្តេ+វស+ណី+ណិក, ស. ] អ្នកមានកិ.នៅក្នុងទីជិតនៃអាចារ្យជាប្រក្រតី (សិស្ស); វិ. **អាចរិយស្ស អន្តេ សមីបេ វសិតុំ សីលមស្សាតិ> អន្តេវាសី, អន្តេវាសី ឯវ> អន្តេវាសិកោ** ។ **–ត្ថេរ** ថុ. ព្រះថេរៈជាអន្តេវាសិក ។ **–បរិសា** ឥ. បរិស័ទគឺអន្តេវាសិក, អន្តេវាសិកជាបរិស័ទ, បរិស័ទនៃអន្តេ-វាសិក ។ **–វាស** ថុ. កិ.នៅជាអន្តេវាសិក, កិ.នៅដោយអំណាចនៃ...ជាអន្តេវាសិក ។

**អន្តោ** និ. ខាងក្នុង ។ **–អគ្គិ** ថុ. ភ្លើងខាងក្នុង ។ **–អរុណ** នថុ. ខាងក្នុងនៃអរុណ ។ **–អាវដ្ដន** ថុ. ខាងក្នុងនៃ ទីជាទីវិលមក, ខាងក្នុងនៃវង់មូល ។ **–កុច្ឆិ** ឥ. ខាងក្នុងនៃផ្ទៃ ។ **–គព្ភកុដិ** ឥ. ខាងក្នុងនៃគន្ធកុដិ ។ **–គាម** នថុ. ខាងក្នុងនៃស្រុក ។ **–គេហច្ឆទន** នថុ. ដំបូលនៃផ្ទះព្ធដ៏ខាងក្នុង, ខាងក្នុងនៃដំបូលនៃ ផ្ទះ ។ **–គេហប្បវេសន** នថុ. កិ.ចូលទៅកាន់ខាងក្នុងនៃផ្ទះ, កិ.ចូលទៅកាន់ផ្ទះព្ធដ៏ខាងក្នុង ។ **–គេហាភិមុខ** គុ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃផ្ទះ ។ **–គេហ** នថុ. ខាងក្នុងនៃផ្ទះ ។ **–ឃរ** នថុ. ខាងក្នុងនៃផ្ទះ ។ **–ចីវរភោគ** នថុ. ខាងក្នុងនៃផ្នត់នៃចីវរ ។ **–ឆទន** នថុ. ខាងក្នុងនៃដំបូល, ខាងក្នុងនៃទីជាទីប្រក់ ។ **–ជាល** នថុ. ខាងក្នុងនៃបណ្ដាញ (.មង, .សំណាញ់, អួន, លប់, បង្កាត់, ចន្ទឹង) ។ **–ជ្ឈិតមនុស្ស** ថុ. មនុស្សដែលស្ថិតនៅក្នុងខាងក្នុង ។ **–ទេវតា** ឥ. ទេវតាក្នុងខាងក្នុង ។ **–ធាតុនិធាន** នថុ. ខាងក្នុងនៃចេតិយ

ជាទីបញ្ចុះនូវព្រះធាតុ, ចេតិយជាទីបញ្ចុះនូវព្រះធាតុដ៏ខាងក្នុង ។ ‑ **នគរាភិមុខ** គុ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃនគរ ។ ‑ **នគរ** នចុំ. ខាងក្នុងនៃនគរ, ‑នៃក្រុង ។ ‑ **នទី** ឥ. ខាងក្នុងនៃស្ទឹង, ‑នៃទន្លេ ។ ‑ **និវេសន** នចុំ. ខាងក្នុងនៃនិវេសន៍, ខាងក្នុងនៃទីជាទីនៅអាស្រ័យ, ខាងក្នុងនៃផ្ទះ ។ ‑ **បោក្ខរណី** ឥ. ខាងក្នុងនៃស្រះបោក្ខរណី, ខាងក្នុងនៃស្រះមានឈូក ។ ‑ **មហាសមុទ្ទ** នចុំ. ខាងក្នុងនៃសមុទ្រធំ ។ ‑ **វស្សភាវ** ចុំ. ភាវៈនៃកាលជាខាងក្នុងនៃរដូវភ្លៀង, ភាវៈនៃកាលជាខាងក្នុងនៃវស្សា ។ ‑ **វស្ស** នចុំ. ខាងក្នុងនៃវស្សា ។ ‑ **វិហារាភិមុខី** ឥ. មានមុខឆ្ពោះទៅកាន់ខាងក្នុងនៃវិហារ (វត្ត, កុដិ) ។ ‑ **វិហារ** នចុំ. ខាងក្នុងនៃវិហារ ។ ‑ **វីណា** ឥ. ខាងក្នុងនៃពិណ ។ ‑ **សមាបត្តិ** ឥ. ខាងក្នុងនៃសមាបត្តិ ។ ‑ **សាណិ** ឥ. ខាងក្នុងនៃរាំងនន, ខាងក្នុងនៃរនាំង ។

**អន្ធ** គុ. [ អន្ធ+អ ] ងងឹត, ខ្វាក់; វិ. **អន្ធភតិ > អន្ធោ** ។ ‑ **ពាល** គុ. ល្ងង់ដូចជាមនុស្សខ្វាក់; វិ. **អន្ធោ ឥវ ពាលោ> អន្ធពាលោ** ។ ‑ **ភូត** គុ. មានងងឹតកើតហើយ ។

**អបកឌ្ឍន្ត** គុ. [ អប+កឌ្ឍ+អ+អន្ត ] កាលទាញទៅប្រាស, កាលកន្ត្រាក់ចេញ, កាលទាញចេញ ។

**អបកឌ្ឍិត្វា** អ. [ អប+កឌ្ឍ+ឥ.អា.+ត្វា ] ទាញទៅប្រាសហើយ, កន្ត្រាក់ចេញហើយ, ទាញចេញហើយ ។

**អបកតញ្ញូ** គុ. [ អប+កតញ្ញូ ] អ្នកមានកតញ្ញូទៅប្រាសហើយ; វិ. **អបគតោ** 



**កតញ្ញូ យស្មា សោ> អបកតញ្ញូ** ។ អ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើទៅប្រាសហើយ; វិ. **អបគតោ កតញ្ញូ> អបកតញ្ញូ** ។ អ្នកមិនដឹងនូវធម្មវិន័យដែលព្រះមានព្រះភាគធ្វើទុកទៅហើយ; វិ. **ន បកតំ (ធម្មវិនយំ) ជានាតីតិ> អបកតញ្ញូ** ។

**អបក្កម្ម** អ. [ អប+កម+ត្វា ] ឈានទៅប្រាសហើយ, គេចចេញហើយ, ចៀសចេញទៅហើយ ។

**អបក្កមិ** កិ. [ អប+កម+អ+ឦ.អជ្ជ., ឰ.អជ្ជ>ឥ. ] ឈានទៅប្រាសហើយ, គេចចេញហើយ, ចៀសចេញទៅហើយ ។

**អបគច្ឆិ** កិ. [ អប+គម+អ+ឦ.អជ្ជ.] ទៅប្រាសហើយ, គេចចេញហើយ ។

**អបគញ្ឆិ** កិ. [ អប+គម+អ+ឦ.អជ្ជ., ចុះនិ.អា.] ទៅប្រាសហើយ, គេចចេញហើយ ។

**អបគត** គុ. [ អប+គម+ត ] ទៅប្រាសហើយ, ទៅបាត់ហើយ, គេចចេញហើយ, រំងាប់ហើយ ។ ‑ **ឱឡារិកក្កិលេស** គុ. មានកិលេសគ្រោតគ្រាតទៅប្រាសហើយ ។ ‑ **កទ្ទម** គុ. មានភក់ទៅប្រាសហើយ ។ ‑ **ក្កិលេសតា** ឥ. ភាវៈនៃ...ជាអ្នកមានកិលេសទៅប្រាសហើយ ។ ‑ **វិញ្ញាណ** គុ. មានវិញ្ញាណទៅប្រាសហើយ ។

**អបគន្ត្វា** អ. [ អប+គម+ត្វា ] ទៅប្រាសហើយ, គេចចេញហើយ, ទៅបាត់ហើយ ។

**អបគមនកាល** ចុំ. [ អបគមន+កាល ] កាលជាទីទៅប្រាស, កាលជាទីចេញទៅ ។

**អប្បច្ចក្កោសន** នបុំ. [ ន+បតិ+អា+កុស+យុ ] កិ.មិនជេរតប, កិ.មិនជេរត។

**អប្បច្ចវេក្ខិត្វា** អ. [ ន+បតិ+អវ+ឥក្ខ+ឥ.អា.+ត្វា ] មិនឃើញចុះចំពោះហើយ, មិនពិចារណាហើយ ។

**អបចាយមាន** គុ. [ អប+ចិ+មាន ] កាលបូជា, កាលគោរព, កាលកោតក្រែង, កាលប្រព្រឹត្តកោតក្រែង, កាលឱនលំទោន ។

**អប្បច្ចាវត្តន** នបុំ. [ ន+បតិ+អា+វត្ត+យុ ] កិ.មិនត្រឡប់មក, កិ.មិនត្រឡប់មកវិញ ។

**អប្បច្ចាសីសន្ត** គុ. [ ន+បតិ+អា+សិស+អន្ត, ចុះនិ.អា ] កាលមិនប្រាថ្នា, កាលមិនប៉ុនប៉ង, កាលមិនចំណង ។

**អបជិត** គុ. [ អប+ជិ+ត ] ឈ្នះទៅប្រាសហើយ, មានកិ.ឈ្នះទៅប្រាសហើយ, ចាញ់ហើយ ។

**អប្បញ្ញត្ត** គុ. [ ន+ប+ញប+ត ] គឺ...មិនតែងតាំងហើយ, មិនបញ្ញត្តហើយ ។

**អប្បញ្ញ** គុ. [ ន+បញ្ញា ] មានប្រាជ្ញាមិនមាន, មិនមានប្រាជ្ញា; វិ. **នត្ថិ បញ្ញា ឯតស្សាតិ> អប្បញ្ញោ** ។

**អប្បញ្ញាយមាន** គុ. [ ន+ប+ញា+យ+មាន ] គឺ...កាលមិនដឹងទូទៅ, កាលមិនប្រាកដ ។

**អប្បដិក្ខិត្វា** អ. [ ន+បដិ+ខិប+ឥ.អា.+ត្វា ] មិនឃាត់ហើយ, មិនប្រកែកហើយ ។

**អប្បដិច្ឆន្ន** គុ. [ ន+បដិ+ឆទ+ត ] មិនកំបាំងហើយ, មិនបិទបាំងហើយ, គឺ...មិនបិទបាំងហើយ ។



**អប្បដិច្ឆាទន** នបុំ. [ ន+បដិ+ឆទ+យុ ] កិ.មិនបិទបាំង, .មិនទទួល ។

**អប្បដិច្ឆាទេត្វា** អ. [ ន+បដិ+ឆទ+ណេ+ត្វា ] មិនបិទបាំងហើយ, មិនញុំាង...ឱ្យបិទបាំងហើយ, មិនទទួលហើយ, មិនគ្របហើយ ។

**អប្បដិបន្ន** គុ. [ ន+បដិ+បទ+ត ] មិនប្រតិបត្តិហើយ, មិនដើរទៅហើយ ។

**អបណ្ឌិត** គុ. [ ន+បណ្ឌិត ] មិនមែនជាបណ្ឌិត; វិ. **ន បណ្ឌិតោ> អបណ្ឌិតោ** ។

**អប្បណ្ណត្តិកភាវ** បុំ. [ អបណ្ណត្តិក+ភាវ ] ភាវៈនៃ...ជារបស់ដែលបុគ្គលដឹងទូទៅមិនមាន, .ជារបស់មានបញ្ញត្តិមិនមាន (ភាវៈនៃ...ជារបស់សាបសូន្យ); វិ. **បញ្ញាបិយតិ ញាយតីតិ> បញ្ញត្តិ,, បញ្ញត្តិ ឯវ> បណ្ណត្តិ** ; (ផ្លាស់ញ្ញ >ណ្ណ), **នត្ថិ បណ្ណត្តិ ឯតស្សាតិ> អប្បណ្ណត្តិកោ, អប្បណ្ណត្តិកស្ស ភាវោ>អប្បណ្ណត្តិកភាវោ** ។

**អបត្តិក** គុ. [ ន+បត្តិក ] អ្នកមានធម្មជាតជាគ្រឿងដល់មិនមាន, អ្នកមានចំណែកជាគ្រឿងដល់មិនមាន, អ្នកមានចំណែកបុណ្យមិនមាន (មិនមែនអ្នកមានចំណែកបុណ្យ); វិ. **នត្ថិ បត្តិ ឯតស្សាតិ> អបត្តិកោ** ។

**អបតិត្វា** អ. [ ន+បត+ឥ.អា.+ត្វា ] មិនធ្លាក់ចុះហើយ, មិនដួលហើយ, មិនរលំហើយ ។

**អបត្ថិយ** គុ. [ ន+បត្ថ+ណ្យ+ឥ.អា.] គឺ...មិនគប្បីប្រាថ្នា; វិ. **ន បត្ថិតព្វន្តិ**

> **អបគ្គិយំ** ។ ជាវេវចនៈនៃ **អបជ្ជិយំ** ។

**អបត្តេត្វា** អ. [ ន+បត្ត+ឯ+ត្វា ] មិនប្រាថ្នាហើយ, មិនចង់បានហើយ ។

**អបត្តេន្ត** គុ. [ ន+បត្ត+ឯ+អន្ត ] កាលមិនប្រាថ្នា, កាលមិនចង់បាន ។

**អបទ** គុ. [ ន+បទ ] មានស្នាមជើងមិនមាន, មិនមានស្នាមជើង ។

**អបទិសតិ** កិ. [ អប+ទិស+អ+តិ_វ.] សំដែងអាង, អាង, អះអាង ។

**អបទិសន្ត** គុ. [ អប+ទិស+អ+អន្ត ] កាលអាង, ... ។

**អបទិស** ចុំ. [ អប+ទិស+អ ] សេចក្ដីអាង, កិ.អាង ។

**អបទិសិត្វា** អ. [ អប+ទិស+ឥ_អា.+ត្វា ] អាងហើយ, ... ។

**អបទេស** ចុំ. [ អប+ទិស+ណ ] កិ.សម្ដែងអាង, សេចក្ដីអាង, សេចក្ដីអះអាង ។

**អបនីត** គុ. [ អប+នី+ត ] គឺ...នាំប្រាសហើយ, ..នាំចេញហើយ, ..ផ្លាស់ចេញហើយ ។

**អបនុទិត្វា** អ. [ ន+ប ឬអប+នុទ+ឥ_អា.+ត្វា ] មិនបន្ទោបង់ហើយ; មិនច្រានចេញហើយ ។

**អបនេត្វា** អ. [ អប+នី+ត្វា ] នាំប្រាសហើយ, ផ្លាស់ចេញហើយ, នាំចេញហើយ ។

**អបនេន្តិ** កិ. [ អប+នី+អ+អន្តិ_វ.] រមែងនាំប្រាស, ផ្លាស់ចេញ, នាំចេញ ។

**អបព្វជន្ត** គុ. [ ន+ប+វជ+អ+អន្ត ] កាលមិនបួស (កាលមិនវៀរ) ។



**អបព្វជិត** គុ. [ ន+បព្វជិត ] មិនមែនជាបព្វជិត, មិនបួសហើយ ។ .សទិស គុ. ប្រាកដស្មើដោយបុគ្គលមិនបួសហើយ (ប្រហែលនឹងគ្រហស្ថ) ។

**អបព្យាម** គុ. [ អប+ព្យាម ] មានព្យាមទៅប្រាសហើយ, ដែលវៀរចាកចិ មានព្យាមមួយជាប្រមាណ ។

**អបពោធេតិ** កិ. [ អប+ពុធ+ណេ+តិ_វ. ] កំចាត់បង់ (នាំចេញនូវកិ. ទ្រមក់) ។

**អបរិយុបាសន្ត** គុ. [ ន+បរិ+ឧប+អាស+អន្ត, ចុះយ_អា. ] កាលមិនអង្គុយជិត, កាលមិនចូលទៅអង្គុយជិត ។

**អបរក្ខរ** នចុំ ឬចុំ. [ អបរ+អក្ខរ ] អក្សរខាងចុង ។

**អបរជ្ឈតិ** កិ. [ អប+រធ+យ+តិ_វ.] ប្រទូស្ត, បៀតបៀន ( ត្រេកអរប្រាស ) ។

**អបរជ្ឈន្ត** គុ. [ អប+រធ+យ+អ+អន្ត ] កាលប្រទូស្ត, កាលបៀតបៀន ។

**អបរជ្ឈនវស** ចុំ. [ អបរជ្ឈន+វស ] អំណាចនៃកិ.ប្រទូស្ត ។

**អបរទ្ធភាវ** ចុំ. [ អបរទ្ធ+ភាវ ] ភាវៈនៃ...ជាអ្នកប្រទូស្តហើយ, ជា...គឺ...ប្រទូស្តហើយ (**អបរទ្ធ**<អប+រធ+ត) ។

**អបរ** វិស.អ. ដទៃ, ដទៃទៀត, ផ្សេងទៀត; គុ. ខាងចុង, ខាងមុខ, ខាងនាយ ។ . **ភាគ** ចុំ. ចំណែកដទៃទៀត, កាលជាចំណែកដទៃទៀត, កាលជាចំណែកនៅខាងមុខ, កាលជាចំណែកនៅខាងនាយ ។

**អបរាជិត** គុ. [ ន+បរាជិត ] គឺ...មិនចាញ់ហើយ, ទារកឈ្មោះអបរាជិតៈ ។

. គ្គហបតិ ចុំ. គហបតីឈ្មោះអបរាជិតៈ ។

**អបរាធ** ចុំ. [ អប+រធ+ណ ឬអប+រាធ ] សេចក្ដីខុស, កំហុស, ទោស; គុ. មានសេចក្ដីត្រេកអរទៅប្រាសហើយ; វិ. **អបគតោ រាធោ យស្មា សោ> អបរាធោ** ។ . **ការី** ចុំ. អ្នកធ្វើនូវកំហុស ។

**អបរាធានុរូប** គុ. [ អបរាធ+អនុរូប ] មានសភាពដ៏សមគួរដល់កំហុស ឬដល់ទោស ។

**អបរាបរំ** គ.វិ. [ អបរ+អបរ ] ដទៃទៀតៗ, ដទៃទៀតនិងដទៃទៀត, ទៅៗ, មកៗ, ទៅមកៗ ។

**អបរាបរុប្បត្តិក** គុ. [ អបរាបរ+ឧប្បត្តិក ] មានកិ.កើតឡើងក្នុងកាលដទៃទៀតៗ, មានកិ.កើតឡើងតៗគ្នា ។

**អបរិច្ឆិន្ន** គុ. [ ន+បរិ+ឆិទ+ត ] គឺ...កំណត់មិនបានហើយ, .មិនកំណត់ហើយ ។

**អបរិច្ចជិត្វា** អ.[ ន+បរិ+ចជ+ត.អា.+ត្វា ] មិនលះបង់ហើយ, មិនលះស្រឡះហើយ ។

**អបរិចិត** គុ. [ ន+បរិ+ចិ+ត ] មិនសន្សំជុំវិញហើយ, មិនស្និទ្ធស្នាលហើយ ។

. **មនុស្ស** ចុំ. មនុស្សអ្នកមិនស្និទ្ធស្នាល, មនុស្សអ្នកមិនជិតដិត ។

**អបរិញ្ញាតធម្ម** គុ. [ អបរិញ្ញាត+ធម្ម ] មានធម៌មិនកំណត់ដឹងហើយ ឬមិនទាន់កំណត់ដឹងហើយ (**អបរិញ្ញាត**<ន+បរិ+ញា+ត) ។

**អបរិបុណ្ណជ្ឈាសយ** គុ. [ អបរិបុណ្ណ+អជ្ឈាសយ ] មានអធ្យាស្រ័យមិនបរិបូណ៌ហើយ ឬមិនគ្រប់គ្រាន់ហើយ (**អបរិបុណ្ណ**<ន+បរិ+បូរ+ត) ។



**អបរិបូរយមាន** គុ. [ ន+បរិ+បូរ+ណាយ+មាន ] កាលមិនឱ្យពេញជុំវិញ, កាលមិនបំពេញ, កាលមិនញុំាង...ឱ្យពេញគ្រប់គ្រាន់ ឬឱ្យពេញលេញ ។

**អបរិភាសន** នចុំ. [ ន+បរិ+ភាស+យុ ] កិ.មិនផ្ដាសា, កិ.មិនប្រទេច ឬមិនជេរ ។

**អបរិភុញ្ជិត្វា** អ. [ ន+បរិ+ភុជ ឬភុញ្ជ+ត.អា.+ត្វា ] មិនបរិភោគហើយ, មិនប្រើប្រាស់ហើយ ។

**អបរិភោគ** ចុំ. [ ន+បរិ+ភុជ+ណ ] កិ.មិនបរិភោគ, គុ.ជារបស់គឺបុគ្គលប្រើប្រាស់មិនបាន, ឱ្យជារបស់គឺបុគ្គលគប្បីប្រើប្រាស់មិនកើត ។

**អបរិមាណ** គុ. [ ន+បរិមាណ ] មានប្រមាណមិនមាន, មិនមានប្រមាណ, មានប្រមាណមិនបាន; វិ. **នត្ថិ បរិមាណំ ឯតស្សាតិ > អបរិមាណោ** ។ . **សីលក្ខន្ធគោបនធម្មានុធម្មប្បដិបត្តិបូរណាវស** ចុំ. អំណាចនៃកិ.គ្រប់គ្រងនូវសីលក្ខន្ធ (កងនៃសីល) មានប្រមាណមិនមាន និងកិ.បំពេញនូវសេចក្ដីប្រតិបត្តិនូវធម៌តាមធម៌ ឬដ៏សមគួរដល់ធម៌ ។ . **សីលក្ខន្ធគោបនាទិក** គុ. មានកិ.គ្រប់គ្រងនូវកងនៃសីលមានប្រមាណមិនបានជាដើម ។

**អបរិមុត្តត្ត** នចុំ. [ អបរិមុត្ត+ត្ត ] ភាវៈនៃ...គឺ...មិនរួចស្រឡះហើយ ឬមិនផុតស្រឡះហើយ (**អបរិមុត្ត**<ន+បរិ+មុច+ត); វិ. **បរិមុច្ច**-

យុត្តាតិ> បរិមុត្តោ , ន បរិមុត្តោ>អបរិមុត្តោ , កស្ស ភាវោ> អបរិមុត្តត្តំ ។

**អបរិយន្ត** គុ. [ ន+បរិយន្ត ] មានទីបំផុតជុំវិញមិនមាន, មិនមានទីបំផុតជុំវិញ; វិ. នត្ថិ បរិយន្តោ ឯតស្សាតិ> អបរិយន្តំ ។ - **គោចរ** គុ. មានគោចរមានទីបំផុតជុំវិញមិនមាន, មានអារម្មណ៍ជាទីត្រាច់ទៅនៃឥន្ទ្រិយមិនមានទីបំផុតជុំវិញ ។ - **តា** ន. ភាវៈនៃ...ជា...មានទីបំផុតជុំវិញមិនមាន ។ - **ភាវ** ចុំ. ភាវៈនៃ...ជា...មិនមានទីបំផុតជុំវិញ ។

**អបរិយន្តីករ** គុ. [ អបរិយន្ត+ឦ.អា+ករ+អ ] ដែលធ្វើនូវកិលេសឱ្យជារបស់មានទីបំផុតជុំវិញមិនមាន, ធ្វើនូវសេចក្ដីស្រឡាញ់មិនមានទីបំផុតជុំវិញ (ឦ.អាគមនេះចុះមកដើម្បីឱ្យងាយស្រួលដល់ការអានប៉ុណ្ណោះ) ។

**អបរិសុទ្ធ** គុ. [ ន+បរិ+សុធ+ត ] ដែលមិនបរិសុទ្ធ, មិនម៉ត់ចត់, មិនស្អាត ។

**អបលាយន្ត** គុ. [ ន+ប+ឥ ឬអយ, ចុះល.អា.+អន្ត ] កាលមិនរត់ទៅ, កាលមិនហើរទៅ, កាលមិនបោលទៅ ។

**អបលាយនត្ថ** ចុំ. [ អបលាយន+អត្ថ ] ប្រយោជន៍ដល់កិ.មិនរត់ទៅ, ... ។

**អបលាយិត្វា** អ. [ ន+ប+ឥ ឬអយ, ចុះល.អា.+ឥ.អា.+ត្វា ] មិនរត់ទៅហើយ ។

**អបលិពុទ្ធ** គុ. [ ន+បរិ+ពធ+ត, រនៃបរិ>ល ] មិនបៀតបៀនហើយ, មិនព័ទ្ធ



ព័ទ្ធហើយ ។

**អបលោកិត** គុ. [ អប+លោក-ឥ.អា.+ត ] គឺ...លាហើយ, - ប្រកាសហើយ, - ប្រាប់ហើយ ។

**អបលោកេតព្វ** គុ. [ អប+លោក+អ, អ>ឯ+តព្វ ] គឺ...គប្បីលា ឬគប្បីប្រាប់ ។

**អបលោកេត្វា** អ. [ អប+លោក+អ, អ>ឯ+ត្វា ] លាហើយ, ប្រាប់ហើយ ។

**អបវិទ្ធ** គុ. [ អប+វិធ+ត ] គឺ...បោះចោលហើយ, - ប្រមៀលហើយ ។

**អបវិសិត្វា** អ. [ ន-ប-វិស+ឥ.អា.+ត្វា ] មិនចូលទៅហើយ, កុំចូលទៅឡើយ ។

**អបសក្កិត្វា** អ. [ អប+សក្ក+ឥ.អា.+ត្វា ] ថយទៅហើយ, គេចចេញហើយ ។

**អប្បសាទិត** គុ. [ ន+ប+សទ+ឥ.អា.+ត ] គឺ...មិនជ្រះថ្លាហើយ ឬមិនឱ្យជ្រះថ្លាហើយ ។

**អប្បសាទេត្វា** អ. [ ន+ប+សទ+ណេ+ត្វា ] មិនឱ្យជ្រះថ្លាហើយ ។

**អបស្សន្ត** គុ. [ ន+ទិស, ទិស>បស្ស+អន្ត ] កាលមិនឃើញ ។

**អបស្សនភាវ** ចុំ. [ អបស្សន+ភាវ ] ភាវៈនៃ (ឬគឺ) កិ.មិនឃើញ (អបស្សន<ន+ទិស, ទិស>បស្ស+យុ) ។

**អបស្សយ** ចុំ. [ អប+សី+អ ] ភ្នាក់ដៃ, គ្រឿងផ្អែក, បង្អែក ។

**អបស្សំ** គុ. [ ន+ទិស, ទិស>បស្ស+អន្ត+សិ.វិ., ផ្លាស់ន្ត+សិ វិ.>អំ ] កាលមិនឃើញ ។

**អប្បហដភាវ** បុំ. [ អប្បហដ+ភាវ ] ភាវៈនៃ...តី...មិនប្រហារហើយ (**អបហដ**<ន+ប+ហរ+ត) ។

**អបហរតិ** កិ. [ អប+ហរ+អ+តិ.វ.] រមែងនាំព្រាស, នាំចេញ, គេចចេញ ។

**អបហរន្ត** គុ. [ អប+ហរ+ ឬន+ប+ហរ+អ+អន្ត ] កាលនាំព្រាស, កាលមិនប្រហារ ។

**អបហរិត** គុ. [ អប+ហរិត ] មានវត្ថុខៀវទៅព្រាសហើយ, មានវត្ថុមានពណ៌ខៀវទៅព្រាសហើយ; វិ. **អបគតំ ហរិតំ យស្មា តំ> អប.ហរិតំ** ។

**អប្បហិណន្ត** គុ. [ ន+ប+ហិ+ណោ+អន្ត ] កាលមិនបញ្ជូនទៅ, ... ។

**អបាកដ** គុ. [ ន+បាកដ ] មិនប្រាកដ, មិនល្បី (**បាកដ**<ប+កដ+អ; វិ. **ទស្សនំ កដតិ គច្ឆតីតិ> បាកដោ** =សភាវៈដល់នូវកិ.ឃើញ) ។

**អបាកតិក** គុ. [ ន+បាកតិក ] មិនតាំងទៅដោយប្រក្រតី; វិ. **បកតិយា តិដ្ឋតីតិ> បាកតិកំ, ន បាកតិកំ> អបាកតិកំ** ។

**អបានុទិ** កិ. [ អ+ប+អា+នុទ+អ+ឦ.អជ្ជ. ] បានបន្ទោបង់ហើយ ។

**អបាបុណិត្វា** អ. [ ន+ប+អាប+ឧណា+ឥ.អា.+ត្វា ] មិនដល់ហើយ, មិនទាន់ហើយ ។

**អបារ** នបុំ. [ ន+បារ ] មិនមែនត្រើយ, ទីមិនមែនជាត្រើយ ។

**អបាយ** បុំ. [ អប+អាយ ] ភពមានសេចក្តីចំរើនទៅព្រាសហើយ (អបាយ); វិ. **អបគតោ អាយោ យស្មា សោ> អបាយោ** ។ . **លោក** បុំ. លោកគឺអបាយ ។ . **គាមី** បុំ. អ្នកទៅកាន់អបាយ; វិ. **អបាយំ គច្ឆតីតិ > អបាយគាមី** ។ . **ទុក្ខ** នបុំ. ទុក្ខក្នុងអបាយ ។ . **ទ្វារ** នបុំ. ទ្វារនៃអបាយ ។ . **បរាយន** គុ. មានអបាយជាទីប្រព្រឹត្តទៅក្នុងខាងមុខ (**បរាយន**<បរ+អយ ឬឥ+យុ) ។ . **សមុទ្ទ** បុំ. សមុទ្រគឺអបាយ ។ . **សំវត្តនិកកម្ម** នបុំ. កម្មប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីអបាយ ។ . **សំវត្តនិក** គុ. ដែលប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីអបាយ ។ . **ឧបគ** គុ. ដែលចូលទៅដល់នូវអបាយ, កើតក្នុងអបាយ (**ឧបគ**<ឧប+គម+ក្វិ); វិ. **អបាយំ ឧប.គច្ឆតីតិ > អបាយុបគោ** ។ . **ឧប្បត្តិ** ឥ. កិ.កើតក្នុងអបាយ ។



**អបិលន្ធិត្វា** អ. [ ន+បិលន្ធ+ឥ.អា.+ត្វា ចុរ.និ.ភា. ] មិនប្រដាប់ហើយ, មិនពាក់តែងហើយ, មិនពាក់ហើយ ។

**អបិសុណវាចា** ឥ.[ អបិសុណ+វាចា ] វាចាមិនស៊កសៀត, វាចាមិនញុះញង់; គុ. មានវាចាមិនញុះញង់ (**អបិសុណ**<ន+បិសុ+ឧន, ឧន>ឧណ)។

**អបិវនត្ថ** បុំ. [ អបិវន+អត្ថ ] ប្រយោជន៍ ឬត្រូវការដល់កិ.មិនផឹក (**អបិវន**<ន+បា>អបិវ+យុ) ។

**អបុច្ឆិត្វា** អ. [ ន+បុច្ឆ+ឥ.អា.+ត្វា ] មិនសួរហើយ ។

**អបុញ្ញតេជ** បុំ. [ អបុញ្ញ+តេជ ] តេជះនៃបុគ្គលមិនមានបុណ្យ, តេជះនៃកម្ម

មិនមែនជាបុណ្យ ។

**អបុញ្ញលាភ** បុំ. [ អបុញ្ញ+លាភ ] កិ.បាននូវកម្មមិនមែនជាបុណ្យ ។

**អបុញ្ញ** គុ. [ ន+បុញ្ញ ] មានបុណ្យមិនមាន, ឥតបុណ្យ; វិ. **នត្ថិ បុញ្ញំ ឯតស្សាតិ> អបុញ្ញោ** កម្មមិនមែនជាបុណ្យ; វិ. **ន បុញ្ញំ> អបុញ្ញំ** ; កិ.មិនមាននៃបុណ្យ; វិ. **បុញ្ញស្ស អភាវោ> អ.បុញ្ញំ** ។

**អបុដ្ឋការណ** នបុំ. [ អបុដ្ឋ+ការណ ] ហេតុនៃ...គឺ...មិនសួរហើយ (អបុដ្ឋ<ន+បុច្ឆ+ត) ។

**អបុត្តក** គុ. [ ន+បុត្ត+ក ] មានកូនមិនមាន, មិនមានកូន, ឥតកូន; វិ. **នត្ថិ បុត្តោ ឯតស្សាតិ > អបុត្តកោ** ។ **.សេដ្ឋី** បុំ. សេដ្ឋីមានកូនមិនមាន ។ **.សេដ្ឋីវត្ថុ** នបុំ. រឿងនៃសេដ្ឋីអ្នកមិនមានកូន ។ ឥ. អបុត្តិកា ។

**អបុថុជ្ជនសេវិត** គុ. [ អបុថុជ្ជន+សេវិត ] គឺព្រះអរិយៈមិនមែនជាបុថុជ្ជនសេពហើយ (អបុថុជ្ជន<ន+បុថុ+ជន+អ=មិនមែនអ្នកញ៉ាំងកិលេសក្រាស់ឱ្យកើត ឬមិនមែនអ្នកញ៉ាំងកិលេសឱ្យកើតក្រាស់; វិ. **បុថុ កិលេសេ ជនេតីតិ>បុថុជ្ជនោ , ន បុថុជ្ជនោ> អបុថុជ្ជនោ** ; (សេវិត>សេវ+ឥ.អា.+ត) ។

**អបុព្វ** គុ. [ ន+បុព្វ ] មិនមុន, មិនមែនជាខាងដើម ។

**អបូរេត្វា** អ. [ ន+បុរ+ណេ+ត្វា ] មិនញ៉ាំង... ឱ្យពេញហើយ, មិនបំពេញ



ហើយ ។

**អបេក្ខា** ឥ. [ អប+ឥក្ខ+ណេ+អា.ឥ. ] កិ.សម្លឹងប្រាស, កិ.ពិនិត្យ, សេចក្តីអាឡោះអាល័យ; វិ. **អបេក្ខនំ> អបេក្ខា** ។

**អបេត** គុ. [ អប+ឥ+ត ] ទៅប្រាសហើយ, ប្រាសទៅហើយ, វៀរហើយ ។ **.កទ្ទម** គុ. មានភក់ទៅប្រាសហើយ, ដែលប្រាសចាកភក់ ។ **.វិញ្ញាណ** គុ. មានវិញ្ញាណទៅប្រាសហើយ, ដែលប្រាសចាកវិញ្ញាណ

**អបេតិ** កិ. [ អប+ឥ+អ+តិ.វ. ] រមែងទៅប្រាស, ប្រាសទៅ, ចៀសចេញទៅ, វៀរ ។

**អបេថ** កិ. [ អប+ឥ+អ+ថ.ប. ] ចូរទៅប្រាស, ចូរចៀសចេញ, ចូរវៀរ ។

**អប្បគ្ឃ** គុ. [ អប្ប+អគ្ឃ ] មានថ្លៃតិច, មានតម្លៃតិច (ថោក, ថ្លៃថោក) ។

**អប្បញ្ញត្ត** គុ. [ ន+ប+ញប+ត ] គឺ...មិនតាក់តែងហើយ, . មិនតែងតាំងហើយ, . មិនក្រាលហើយ, . មិនបញ្ញត្តហើយ ។

**អប្បញ្ញាយន** នបុំ. [ ន+ប+ញា, ផ្លាស់អាទៃញា>អាយ+យុ ] កិ.មិនដឹងទូទៅ, កិ.មិនប្រាកដ, កិ.មិនជាក់លាក់ ។

**អប្បបញ្ញ** គុ. [ អប្ប+បញ្ញា ] អ្នកមានប្រាជ្ញាតិច ។

**អប្បដិក្ខិត្ត** គុ. [ ន+បដិ+ខិប+ត ] គឺ...មិនហាមហើយ, . មិនប្រកែកហើយ, . មិនឃាត់ហើយ ។

**អប្បដិគ្គហណ** នបុំ. [ ន+បដិ+គហ+យុ ] កិ.មិនកាន់យកចំពោះ, កិ.មិនទទួល ។

អប្បដិច្ឆន្ន គុ. [ ន+បដិ+ឆទ+ត ] គឺបុគ្គលមិនបិទបាំងចំពោះហើយ, . មិនលាក់ទុកហើយ, មិនកំបាំងហើយ ។

អប្បដិជគ្គិតាសន នបុំ. [ អប្បដិជគ្គិត+អាសន ] អាសនៈដែល...មិនសំអាតហើយ, អាសនៈដែល...មិនជម្រះហើយ, . មិនថែទាំហើយ (អប្បដិជគ្គិត<ន+បដិ+ជគ្គ+ឥ.អា.+ត) ។

អប្បដិជគ្គិយ គុ. [ ន+បដិជគ្គិយ ] មិនមែនអ្នកគួរនូវកិ.ជម្រះ, មិនមែនអ្នកគួរនូវកិ.ថែទាំ, មិនគួរដល់នូវកិ.ថែទាំ; វិ. **បដិជគ្គនំ អរហតីតិ> បដិជគ្គិយោ , បដិជគ្គនស្ស អរហតីតិ វា> បដិជគ្គិយោ , ន បដិជគ្គិយោ> អប្បដិជគ្គិយោ** ; (ន+បដិ+ជគ្គ+ណ្យ+ឥ.អា.=គឺ...មិនគប្បីថែទាំ, .មិនគប្បីជម្រះ); **វិ. បដិជគ្គិតព្វន្តិ> បដិជគ្គិយំ , ន បដិជគ្គិយំ> អប្បដិជគ្គិយំ** ។

អប្បដិនិស្សជ្ជ អ. [ ន+បដិ+និ+សជ+ត្វា ] មិនលះបង់ហើយ (មិនសំដែងទោសហើយ, មិនឱ្យអត់ទោសហើយ, មិនសូមទោសហើយ) ។

អប្បដិបុគ្គល គុ. [ ន+បដិបុគ្គល ] មានបុគ្គលប្រៀបមិនមាន, មិនមានបុគ្គលប្រៀប; វិ. **នត្ថិ បដិបុគ្គលោ ឯតស្សាតិ> អប្បដិបុគ្គលោ** ។

អប្បដិពទ្ធចិត្ត គុ. [ អប្បដិពទ្ធ+ចិត្ត ] មានចិត្តមិនជាប់ចំពោះហើយ, មានចិត្តមិនប្រតិព័ទ្ធហើយ ។



អប្បដិពាហិយភាវ ពុំ. [ អប្បដិពាហិយ+ភាវ ] ភាវៈនៃ...ជា...គឺ...មិនគប្បីឃាត់បាន, . មិនគប្បីហាមបាន, . មិនគប្បីការពារបាន ។

អប្បដិភាគ គុ. [ ន+បដិភាគ ] មានចំណែកប្រៀបមិនមាន, មិនមានចំណែកប្រៀប; វិ. **នត្ថិ បដិភាគោ អស្សាតិ> អប្បដិភាគោ** ។

អប្បដិរូបសហាយ ពុំ. [ អប្បដិរូប+សហាយ ] សំឡាញ់មានរូបប្រៀបមិនមាន, សំឡាញ់មិនសមគួរ (អប្បដិរូប<ន+បដិរូប; វិ. **នត្ថិ បដិរូបំ ឯតស្សាតិ> អប្បដិរូបោ**) ។

អប្បដិវិជ្ឈនកមោហ ពុំ. [ អប្បដិវិជ្ឈនក+មោហ ] មោហៈដែលញុំាង...មិនឱ្យចាក់ធ្លុះចំពោះ, មោហៈជាហេតុមិនឱ្យចាក់ធ្លុះចំពោះ, មោហៈជាហេតុមិនឱ្យត្រាស់ដឹង ។

អប្បដិវិជ្ឈន្ត គុ. [ ន+បដិ+វិធ+យ+អន្ត, ផ្លាស់ធ+យ>ជ្ឈ ] កាលមិនចាក់ធ្លុះចំពោះ, កាលមិនត្រាស់ដឹង ។

អប្បដិវិជ្ឈិត្វា អ. [ ន+បដិ+វិធ+យ+ឥ.អា.+ត្វា ] មិនចាក់ធ្លុះចំពោះហើយ, មិនត្រាស់ដឹងហើយ ។

អប្បដិវេក្ខិយ អ. [ ន+បដិ+អវ+ឥក្ខ+ឥ.អា.+ត្វា ] មិនឃើញចុះចំពោះហើយ, មិនពិចារណាហើយ ។

អប្បដិសម គុ. [ ន+បដិសម ] មានបុគ្គលស្មើប្រៀបមិនមាន, មិនមានបុគ្គលប្រៀបស្មើ; វិ. **នត្ថិ បដិសមោ ឯតស្សាតិ> អប្បដិសមោ** ។

អប្បដិឃាតចិត្ត គុ. [ អប្បដិឃាត+ចិត្ត ] មានចិត្តគឺទោសមិនបៀតបៀនចំពោះ

ហើយ, . មិនខ្លាំងខ្ជប់ហើយ (អប្បដិហត<ន+បដិ+ហន+ត); វិ. **អប្បដិហតំ ចិត្តំ យស្ស សោ> អប្បដិហតចិត្តោ** ។

**អប្បដិហតញ្ញាណប្បវេទិត** គុ. [ អប្បដិហតញ្ញាណ+បវេទិត ] ទាំងមានញាណគឺទោសជាតមិនខ្លាំងខ្ជប់ហើយ ទាំងដឹងច្បាស់ហើយ ឬដឹងទូទៅហើយ (បវេទិត<ប+វិទ+ឥ.អ.+ត) ។

**អប្បដិហតពុទ្ធិ** គុ.[ អប្បដិហត+ពុទ្ធិ ] មានប្រាជ្ញាជាគ្រឿងត្រាស់ដឹងគឺ...មិនបៀតបៀនចំពោះហើយ, មានប្រាជ្ញាគឺ...មិនខ្លាំងខ្ជប់ហើយ ។

**អប្បដិប្បហរណ** ចុំ. [ ន+បដិ+ប+ហរ+យុ ] កិ.មិនប្រហារតប, គឺ.មិនវាយតប ។

**អប្បណិហិត** គុ. [ ន+ប+និ, និ>ណ+ធា+ត, ផ្លាស់ធនៃធា>ហ, អា>ឥ ] មិនមានធម្មជាតជាគ្រឿងដំកល់, មិនមានទីជាទីដំកល់; វិមោក្ខឈ្មោះអប្បណិហិតៈ ។

**អប្បតរមូល** គុ. [ អប្បតរ+មូល ] មានមូលតិចជាង, មានតម្លៃតិចជាង ។

**អប្បតិដ្ឋិត** គុ. [ ន+បតិ+ឋា, អានៃឋា>ឥ+ត ] មិនតាំងនៅចំពោះហើយ, មិនដំកល់ស៊ប់ហើយ ។

**អប្បត្ត** គុ. [ ន+បទ+ត ] មិនដល់ហើយ, មិនទាន់ដល់ហើយ ។ . **មានស** គុ. មានសេចក្ដីប្រាថ្នាក្នុងចិត្តមិនទាន់ដល់ហើយ, មានចិត្តមិនទាន់ដល់ហើយ, មានព្រះអរហត្តជាគ្រឿងកំចាត់បង់នូវមានះមិនទាន់ដល់ហើយ ។ . **វិសេស** គុ. មានគុណវិសេសមិនទាន់ដល់ហើយ ។

**អប្បត្វា** អ. [ ន+បទ+ត្វា ] មិនដល់ហើយ, មិនទាន់ដល់ហើយ ។



**អប្បត្ត** គុ. [ ន+បត្ត–អ ] គឺបុគ្គលមិនប្រាថ្នាហើយ, គឺ...ចោលហើយ ។

**អប្បទុដ្ឋ** គុ. [ ន+ប+ទុស–ត ] គឺ...មិនប្រទូស្តហើយ, គឺទោសមិនប្រទូស្តហើយ, មិនប្រទូស្តហើយ ។

**អប្បនាសមាធិ** ចុំ. [ អប្បនា+សមាធិ ] សមាធិជាគ្រឿងចូលទៅអែបនៃបក្នុងអារម្មណ៍; វិ. **អារម្មណេ អប្បេតិ បថិសតិ ឯកាយាតិ>អប្បនា** ។ សមាធិប្រព្រឹត្តទៅក្នុងអប្បនា; វិ. **អប្បនាយំ បវត្តោ សមាធិ > អប្បនាសមាធិ**; (អប្បនា <អប+យុ+អ.ឥ.) ។

**អប្បពុទ្ធិក** គុ. [ អប្ប+ពុទ្ធិ+ក ] មានប្រាជ្ញាតិច; វិ. **អប្បា ពុទ្ធិ យស្ស សោ> អប្បពុទ្ធិកោ** ។

**អប្បភិក្ខុកត្ត** នចុំ. [ អប្បភិក្ខុក+ត្ត ] ភាវៈនៃ...ជា...មានភិក្ខុតិច; វិ. **អប្បា ភិក្ខូ យស្មិន្តិ> អប្បភិក្ខុកោ តស្ស ភាវោ> អប្បភិក្ខុកត្តំ** ។

**អប្បមជ្ជតោ** គុ. [ ន+ប+មទ+យ+អន្ត+ស.វិ., ផ្លាស់ន្ត+ស.វិ.>តោ ] កាលមិនប្រមាទ, កាលមិនធ្វេសប្រហែស ។

**អប្បមញ្ញាភាវនា** ឥ. [ អប្បមញ្ញា+ភាវនា ] ភាវនាប្រព្រឹត្តទៅក្នុងព្រហ្មវិហារឈ្មោះអប្បមញ្ញា ។, ភាវនាមានភាវៈនៃសត្វមិនមានប្រមាណជារអារម្មណ៍ ។

**អប្បមត្តក** គុ. [ អប្ប+មត្ត+ក ] មានប្រមាណតិច, មានចំនួនតិច; វិ. **អប្បំ**

**មក្តំ យស្ស តំ> អប្បមក្កតំ** ។ . **ដ្ឋានត្ថ** ចុំ. ប្រយោជន៍ដល់ទីមានប្រមាណតិច, សេចក្ដីត្រូវការដល់ដំណែងដ៏តូច ។ . **បរិច្ចាគា-នុភាវ** ចុំ. អានុភាពនៃកិ.បរិច្ចាគមានប្រមាណតិច ។ . **សេយ្យ** គុ. ជាគុណប្រសើរជាងមានប្រមាណតិច ។

**អប្បមត្ត** គុ. [ អប្ប+មត្ត ឬន+ប+មទ+ត ] មានប្រមាណតិច; អ្នកមិនប្រមាទ, អ្នកមិនធ្វេសប្រហែស ។ . **វិហារិតា** ឥ. ភាវៈនៃ...ជាអ្នកមានកិ.នៅដោយភាពជាអ្នកមិនធ្វេសប្រហែសជាប្រក្រតី, .នៅជាមួយនឹងបុគ្គលមិនប្រមាទជាប្រក្រតី ។

**អប្បមំសលោហិត** គុ. [ អប្ប+មំសលោហិត ] មានសាច់និងឈាមតិច ។

**អប្បមាណ** គុ.[ ន+បមាណ ] មិនជាប្រមាណ, មានប្រមាណមិនមាន, មិនមានប្រមាណ, កុំយកជាប្រមាណ (**បមាណ**<ប+មា+យុ) ។

**អប្បមាទ** ចុំ. [ ន+បមាទ ] កិ.មិនស្រវឹងទូទៅ, សេចក្ដីមិនប្រមាទ, សេចក្ដីមិនធ្វេសប្រហែស; វិ. **អប្បមជ្ជនំ>អប្បមាទោ** (**បមាទ**<ប+មទ+ណ) ។ . **ប្បដិបទា** ឥ. ការប្រតិបត្តិដោយសេចក្ដីមិនប្រមាទ, សេចក្ដីប្រតិបត្តិដោយអំណាចនៃសេចក្ដីមិនប្រមាទ ។ . **មូលក** គុ. មានសេចក្ដីមិនប្រមាទជាមូល ឬជាឫស, មានសេចក្ដីមិនប្រមាទជាហេតុជាទីតាំង ។ . **រត** គុ. ត្រេកអរហើយក្នុងសេចក្ដីមិនប្រមាទ ។ . **លក្ខណ** នចុំ. លក្ខណៈនៃសេចក្ដីមិនប្រមាទ; គុ. មានសេចក្ដីមិនប្រមាទជាលក្ខណៈ ។ . **វគ្គវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវអប្បមាទវគ្គ ។ . **វិហារិនី** ឥ. មានកិ.នៅដោយ



សេចក្ដីមិនប្រមាទជាប្រក្រតី ។ . **វេគ** ចុំ. កំឡាំងនៃសេចក្ដីមិនប្រមាទ ។ . **សមោសរណ** គុ. ជាទីប្រជុំក្នុងសេចក្ដីមិនប្រមាទ, មានសេចក្ដីមិនប្រមាទជាទីប្រជុំចុះ ។ . **សម្បន្ន** គុ. ដល់ព្រមហើយដោយសេចក្ដីមិនប្រមាទ, មានសេចក្ដីមិនប្រមាទដល់ព្រមហើយ ។ . **អាធិគត** គុ. ដែលដល់ហើយ ឬដល់ក្រៃលែងហើយដោយសេចក្ដីមិនប្រមាទ (**អធិគត**<អធិ+គម+ត=លុះ, ត្រាស់ដឹង, បាន) ។

**អប្បរស** គុ. [ អប្ប+រស ] មានរសតិច, មានទឹកតិច ។

**អប្បលាភ** គុ. [ អប្ប+លាភ ] មានលាភតិច ។

**អប្បវត្តនភាវ** ចុំ. [ អប្បវត្តន+ភាវ ] ភាវៈនៃ (គឺ) កិ.មិនប្រព្រឹត្តទៅ ។

**អប្បវត្តន្ត** គុ. [ ន+ប+វត, វត>វត្ត+អ+អន្ត ] កាលមិនប្រព្រឹត្តទៅ ។

**អប្បវត្ត** គុ. [ ន+ប+វត+ត ] មិនប្រព្រឹត្តទៅហើយ ។

**អប្បវេស** ចុំ. [ ន+ប+វិស+ណ ] កិ.មិនចូលទៅ ។

**អប្បវិដ្ឋ** គុ. [ ន+ប+វិស+ត ] មិនចូលទៅហើយ, មិនចូលមកហើយ ។

**អប្បសត្ថ** គុ. [ អប្ប+សត្ថ ] មានពួកតិច, មានគ្នាតិច ។

**អប្បសន្ន** គុ. [ ន+ប+សទ+ត ] មិនជ្រះថ្លាហើយ, មិនថ្លា ។

**អប្បស្សាទ** គុ.[ អប្ប+អស្សាទ ] មានសេចក្ដីត្រេកអរតិច, (**អស្សាទ**<អា>អ+សទ+ណ) ។

**អប្បស្សុតតា** ឥ. [ អប្បស្សុត+តា ] ភាវៈនៃ...ជាអ្នកមានកិ.ស្ដាប់តិច, . ជា

អ្នកមានពុទ្ធវចនៈតិចស្តាប់ហើយ; វិ. អប្បំ សុតំ យស្ស ទា
យេន សោ> អប្បស្សុតោ, អប្បស្សុតស្ស ភាវោ>
អប្បស្សុតតា ។

**អប្បស្សុតបុរិស** ចុំ. [ អប្បស្សុត+បុរិស ] បុរសមានពុទ្ធវចនៈតិចស្តាប់ហើយ, បុរសមានកិ.ស្តាប់តិច ។

**អប្បហាយ** អ. [ ន+ប+ហា+ត្វា ] មិនលះបង់ហើយ ។

**អប្បហោន្ត** គុ. [ ន+ប+ហុ+អន្ត ] កាលមិនល្មម, កាលមិនគ្រប់គ្រាន់ ។

**អប្បាយុកសំវត្តនិក** គុ. [ អប្បាយុកសំវត្តន៍+ណិក ] ដែលប្រព្រឹត្តទៅព្រមដើម្បីជាអ្នកមានអាយុតិច, ប្រកបក្នុងកិ.ប្រព្រឹត្តទៅព្រមដើម្បីជនដែលមានអាយុតិច ។

**អប្បាយុក** គុ. [ អប្ប+អាយុ+ក ] មានអាយុតិច; វិ. អប្បំ អាយុ យេ.
សំ តេ> អប្បាយុកា ។

**អប្បាហារតា** ឥ. [ អប្បាហារ+តា ] ភាវៈនៃ...ជាអ្នកមានអាហារតិច ។

**អប្បិច្ឆតា** ឥ. [ អប្បិច្ឆ+តា ] ភាវៈនៃ...អ្នកមានសេចក្តីប្រាថ្នាតិច; វិ. អប្បា
ឥច្ឆា យស្ស សោ> អប្បិច្ឆោ កស្ស ភាវោ>
អប្បិច្ឆតា ។

**អប្បិច្ឆតាទិ** គុ. [ អប្បិច្ឆតា+អាទិ ] មានភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម; វិ. អប្បិច្ឆតា អាទិ យស្ស សោ> អប្បិច្ឆ.
តាទិ ។ . **គុណាយុត្ត** គុ. ដែលប្រកបដោយគុណមានភាវៈនៃ



បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម ។ . **ប្បដិសំយុត្ត** គុ. ដែលប្រកបព្រមចំពោះដោយគុណមានភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចជាដើម ។

**អប្បិច្ឆសន្តុដ្ឋភាវគុណ** ចុំ. [ អប្បិច្ឆសន្តុដ្ឋភាវ+គុណ ] គុណគឺភាវៈនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច និងអ្នកត្រេកអរដោយវត្ថុជារបស់នៃខ្លួន (**សន្តុដ្ឋ** <សំ+តុស+ត=ត្រេកអរព្រម, សន្តោស) ។

**អប្បិយ** គុ. [ ន+បិយ ] មិនជាទីស្រឡាញ់ (មិនមែនជាអ្នកគឺបុគ្គលគប្បីស្រឡាញ់); វិ. បិយេតិ កន្តិ> បិយោ, ន បិយោ>
អប្បិយោ ។

**អប្បេកទា** កា.ស. ក្នុងកាលខ្លះ, ក្នុងគ្រាខ្លះ, ក្នុងកាលម្តងៗ, ....។

**អប្បេវនាម** និ. ធ្វើម្តេចហ្ន, តិតដូចម្តេចហ្ន, ធ្វើម្តេចអេះ, ធ្វើយ៉ាងណាអេះ, .... ។

**អប្បេសក្ខ** គុ. [ អប្ប+សក្ខ ] មានស័ក្តិតិច, មានស័ក្តិតូច ។

**អប្បោឋិតមត្ត** គុ. [ អប្បោឋិត+មត្ត ] ត្រឹមតែទះដៃ, អាការគ្រាន់តែទះដៃ (**អប្ផោដិតមត្ត** ក៏មាន) ។

**អប្បោឋេត្វា** អ. [ អា>អ+ចុឋ+ណេ+ត្វា ] ទះហើយ, ទះដៃហើយ (**អប្ផោដេត្វា** ក៏មាន) ។

**អប្បោឋេសិ** កិ. [ អា+ចុឋ+ណេ+ឡ្ហ.អជ្ជ.+ស.អា. ] ទះហើយ, ទះដៃហើយ (**អប្ផោដេសិ** ក៏មាន) ។

**អប្បោទក** គុ. [ អប្ប+ឧទក ] មានទឹកតិច ។ - **មធុបាយាស** បុំ. បាយាសគឺបុគ្គលចំអិនហើយដោយទឹកឃ្មុំមានទឹកតិច, បាយាសដ៏លាយដោយទឹកឃ្មុំមានទឹកតិច, មធុបាយាសមានទឹកតិច ។

**អប្បោស្សុក្ក** គុ. [ អប្ប+ឧស្សុក្ក ] មានសេចក្ដីខ្វល់ខ្វាយតិច ។ - **តា** ឥ., - **ត្ត** នបុំ. ភាវៈនៃបុគ្គលអ្នកមានសេចក្ដីខ្វល់ខ្វាយតិច ។

**អផរុសវាចា** ឥ. [ អផរុស+វាចា ] វាចាមិនអាក្រក់, វាចាមិនទ្រគោះ ។

**អផល** គុ. [ ន+ផល ] មានផលមិនមាន, មិនមានផល, ឥតផល ។

**អផាសុក** នបុំ., គុ. [ ន+ផាសុក ] សេចក្ដីមិនសប្បាយ, សេចក្ដីអផ្សុក ។ - **កាល** បុំ. ភាវៈនៃ.....មិនសប្បាយ, ..មិនមានសេចក្ដីសប្បាយ ។

**អផុសិត** គុ. [ ន+ផុស+ឥ.អា.+ត ] គឺ....មិនពាល់ត្រូវហើយ ។

**អពធិរ** គុ. [ ន+ពធិរ ] មិនមែនថ្លង់, មិនថ្លង់ ។

**អពលទុព្ពលអនទ្ធនិយតាវកាលិកត្ត** បុំ. [ អពល.+អត្ត ] សេចក្ដីថាកាយជារបស់មិនមានកំឡាំងនិងជារបស់មានកំឡាំងថយនិងជារបស់មិនតាំងនៅអស់កាលដ៏វែងនិងជារបស់ប្រកបក្នុងកាលប៉ុណ្ណោះ; អ-ពល<ន+ពល=មានកំឡាំងមិនមាន; វិ. **នត្ថិ ពលំ អស្សាតិ**> **អពលោ**; ទុព្ពល<ទុ+ពល=មានកំឡាំងគឺទោសប្រទូស្តហើយ (មានកំឡាំងខ្សោយ); វិ. **ទុដ្ឋំ ពលំ យស្ស សោ**> **ទុព្ពលោ**; អនទ្ធនិយ<ន+អទ្ធនិយ=មិនតាំងនៅអស់កាលដ៏វែង ឬមិនគួរដល់សេចក្ដីយាំមួន; វិ. **អទ្ធានំ តិដ្ឋតីតិ**> **អទ្ធនិយោ**, **អទ្ធស្ស**



**អរហតីតិ វា**> **អទ្ធនិយោ**, **ន អទ្ធនិយោ**> **អនទ្ធនិយោ**; តាវកាលិក<តាវកាល+ណិក=ប្រកបក្នុងកាលប៉ុណ្ណោះ (ដូចជារបស់ខ្ចីគេ); វិ. **តាវកាលេ និយុត្តោ** > **តាវកាលិកោ** ។

**អពលស្ស** បុំ. [ អពល+អស្ស ] សេះមានកំឡាំងមិនមាន, សេះមិនមានកំឡាំង ។

**អពាធយិត្វា** អ. [ ន+ពាធ+ណយ+ឥ.អា.+ត្វា ] មិនបៀតបៀនហើយ ។

**អពុជ្ឈនក** បុំ. [ ន+ពុធ+យ+ណ្វុ, ណ្វុ>អនក ] អ្នកមិនត្រាស់ដឹង, អ្នកមិនភ្ញាក់; វិ. **ពុជ្ឈតីតិ**>**ពុជ្ឈនកោ** , **ន ពុជ្ឈនកោ**> **អពុជ្ឈនកោ** ។

**អព្យត្ត** គុ. [ ន+ព្យត្ត ] មិនឈ្លាស, មិនប្រសប់, មិនវាងវៃ ។ - **តា** ឥ. ភាវៈនៃ...ជាអ្នកមិនឈ្លាស, ... (ព្យត្ត<វិ>ព្យ+អជ+ត) ។

**អព្វណ** គុ. [ ន+វណ ] មានដំបៅមិនមាន, មិនមានដំបៅ ។

**អព្វត** គុ. [ ន+វត ] មានវត្តមិនមាន, មិនមានវត្ត ។

**អព្វហន** នបុំ. [ អា>អ+វហ+យុ ] កិ.ទាញចេញ, .ដកចេញ; ជាគ្រឿងទាញចេញ, . ដកចេញ ។

**អព្វុឡ្ហ** គុ. [ អា>អ+វហ, អនៃវ>ឧ+ត ] គឺ...ដកឡើងហើយ ។ - **សល្ល** គុ. មានសរដកឡើងហើយ ។

**អព្វុឡ្ហិ** កិ. [ អា+វហ, អនៃវ>ឧ+យ+ឦ.អជ្ជ. ] ដកឡើងហើយ (ប្រើជា «អព្វុហិ» ក៏មាន) ។

**អព្យោកិណ្ណ** គុ. [ ន+វិ+អវ+កិរ+ត ] មិនរាយរាយចុះហើយ, មិនច្រឡូកច្រឡំហើយ ។

**អព្យាកត** គុ. [ ន+វិ+អា+ករ+ត ] គឺ...មិនធ្វើឱ្យជាក់ច្បាស់ហើយ, ..មិនព្យាករហើយ, ..មិនមាញហើយ (អព្យាក្រឹត) ។

**អព្យាបាទ** ចុំ. [ ន+ព្យាបាទ ] (ចេតសិកធម៌) មិនញ៉ាំងប្រយោជន៍និងសេចក្ដីសុខឱ្យវិនាស (គុ.មានព្យាបាទមិនមាន); វិ. **ហិតសុខំ ព្យាបាទយតីតិ> ព្យាបាទោ, ន ព្យាបាទោ> អព្យាបាទោ** ។ កិ.មិនមាននៃព្យាបាទ; វិ. **ព្យាបាទស្ស អភាវោ> អព្យាបាទោ** ។

**អព្រវិ** កិ. [ អ+ព្រូ, ធ.នៃព្រូ>ឱ>អវ+អ+ឦ.អជ្ជ. ] បានពោលហើយ ។

**អព្ភក្ខាន** នចុំ. [ អភិ>អព្ភ+អា, អា>អ+ខា+យុ ] កិ.ពោលបង្កាច់ ។

**អព្ភញ្ញិត្វា** អ. [ អា>អ+ភជ ឬភញ្ជ+ឥ.អា.+ត្វា ] លាបហើយ, ស្រឡាបហើយ ។

**អព្ភន្តរ** គុ. [ អភិ+អន្តរ ] ខាងក្នុង ។

**អព្ភ** នចុំ. [ អវ+ភ ] ពពក, មេឃ, អាកាស ។

**អព្ភាកុដិក** គុ. [ ន+ភាកុដិក ] មិនមានក្រញូវមុខ, មិនមានខ្ញូវមុខ; វិ. **នត្ថិ ភាកុដិកោ អស្សាតិ > អព្ភាកុដិកោ** ។

**អព្ភាចិក្ខនកភិក្ខុ** ចុំ. [ អព្ភាចិក្ខនក+ភិក្ខុ ] ភិក្ខុអ្នកពោលបង្កាច់, ..និយាយបង្កាច់; វិ. **អព្ភាចិក្ខតីតិ> អព្ភាចិក្ខនកោ, អព្ភាចិក្ខនកោ ភិក្ខុ > អព្ភាចិក្ខនកភិក្ខុ** ។



**អព្ភាចិក្ខតិ** កិ. [ អភិ+អា+ចិក្ខ+អ+អន្តិ.វ. ] ពោលបង្កាច់, ប្រាប់បង្កាច់ ។

**អព្ភាចិក្ខិត** គុ. [ អភិ+អា+ចិក្ខ+ឥ.អា.+ត ] គឺ...ពោលបង្កាច់ហើយ, ..ប្រាប់បង្កាច់ហើយ ។

**អព្ភាទិមលវិរហិត** គុ. [ អព្ភាទិមល+វិរហិត ] ដែលប្រាសហើយ (ដែលវៀរហើយ) ចាកមន្ទិលមានពពកជាដើម ។

**អព្ភានុមោទន្ត** គុ. [ អភិ+អនុ+មុទ+អ+អន្ត ] កាលរីករាយតាមចំពោះ, កាលរីករាយតាមក្រៃលែង ។

**អព្ភុគ្គន្ត្វា** អ. [ អភិ+ឧ+គម+ត្វា ] ទៅក្នុងខាងលើហើយក្រៃពេក, ហោះឡើងហើយ, អណ្ដែតឡើងហើយ, ហើរលយទៅហើយ ។

**អព្ភុណ្ហ** គុ. [ អភិ+ឧណ្ហ ] ក្ដៅក្រៃលែង, ក្ដៅណាស់, ក្ដៅពេក ។

**អព្ភូត** គុ. [ ន+ភូត ] មិនធ្លាប់កើតហើយ, មិនធ្លាប់មានហើយ, មិនពិត ។

**អព្ភោកាស** ចុំ. [ អភិ+ឱកាស ] ឱកាសដ៏ក្រៃលែង, ទីវាលស្រឡះ ។

**អភណិ** កិ. [ អ+ភណ+អ+ឦ.អជ្ជ. ] បានពោលហើយ ។

**អភទ្ទក** គុ. [ ន+ភទ្ទក ] មានសេចក្ដីចំរើនមិនមាន, មិនមានសេចក្ដីចំរើន; វិ. **នត្ថិ ភទ្ទោ ឯតស្សាតិ> អភទ្ទកោ** ។

**អភព្វុប្បត្តិក** គុ. [ អភព្វ+ឧប្បត្តិ+ក ] មានកិ.កើតឡើងមិនគួរ, មានហេតុជាគ្រឿងកើតឡើងមិនគួរ; វិ. **អភព្វា ឧប្បត្តិ យស្ស សោ> អភព្វុប្បត្តិកោ** ។

**អភព្វ** គុ. [ ន+ភព្វ ] មិនគួរ, អភ័ព្វ ។

**អភយ** គុ. [ ន+ភយ ] កិ.មិនមាននៃភ័យ; វិ. **ភយស្ស អភាវោ> អភយំ** ; មានសេចក្ដីខ្លាចមិនមាន, មានភ័យមិនមាន; វិ. **នត្ថិ ភយំ ឯតស្សាតិ> អភយោ** ហេតុគឺបុគ្គលមិនគប្បីខ្លាច; វិ. **ភយិតព្វន្តិ> ភយំ, ន ភយំ> អភយំ** ។ . **ទស្សី** បុំ. អ្នកមានកិ.ឃើញនូវហេតុគឺបុគ្គលមិនគួរខ្លាចជាប្រក្រតី ។ . **ភីរុតា** ឥ. ភាវៈនៃ...ជាអ្នកខ្លាចអំពីវត្ថុដែលមិនគួរខ្លាច ។ . **រាជកុមារ** បុំ. ព្រះរាជកុមារឈ្មោះអភ័យ ។

**អភវិស្ស** កិ. [ អ+ភូ+អ+ឥ.អា.+ស្សា.កា.(១) ] នឹងបានមានហើយ, នឹងបាន កើតហើយ ។

**អភស្សិថ** កិ. [ អ+ភស, ភស>ភស្ស+អ+ស្សថ.កា., លុបស្សនៅតែថ ] បានភ្លាត់ធ្លាក់ហើយ, បានរបូតចុះហើយ ។

**អភាជេត្វា** អ. [ ន+ភជ+ណេ+ត្វា ] មិនញុំាង...ឱ្យចែកហើយ, កុំអាលចែកឡើយ ។

**អភាយន្ត** គុ. [ ន+ភី+អ+អន្ត ] កាលមិនខ្លាច ។

**អភាវ** បុំ. [ ន+ភូ+ណ ] កិ.មិនមាន, កិ.មិនកើត; វិ. **ភវនំ> ភាវោ, ន ភាវោ> អភាវោ** ។ . **អត្ថ** បុំ. សេចក្ដីថាកិ.មិនមាន, .កិ.មិនកើត ។

(១) ស្សា.កា.> ស្ស ។



**អភាវិត** គុ. [ ន+ភូ+ឥ+អា.+ត ] គឺ...មិនចំរើនហើយ, .មិនអប់រំហើយ ។

**អភាវេត្វា** អ. [ ន+ភូ+ណេ+ត្វា ] មិនញុំាង...ឱ្យចំរើនហើយ, .ឱ្យមានហើយ, មិនចំរើនហើយ ។

**អភាសន្ត** គុ. [ ន+ភាស+អ+អន្ត ] កាលមិនពោល ។

**អភាសិ** កិ. [ អ+ភាស+អ+ឦ.អជ្ជ. ] បានពោលហើយ ។

**អភិកីរតិ** កិ. [ អភិ+កិរ+អ+តិ.វ. ] រមែងរាយមាយ, ពាចសាច, ជន់លិច ។

**អភិក្កន្ត** គុ. [ អភិ+កម+ត ] ឈានទៅមុខហើយ, ប្រាថ្នាហើយ, ត្រេកអរហើយ, ល្អ,រុងរឿង, ពិរោះ, អស់ហើយ ។

**អភិក្កម** កិ. [ អភិ+កម+អ+ហិ.ប., លុបហិ ] ចូរឈានចំពោះ, ចូរឈានទៅមុខ, ចូរដើរទៅមុខ ។

**អភិក្កមិតព្វ** គុ. [ អភិ+កម+ឥ.អា.+តព្វ ] គឺ...ដើម្បីឈានចំពោះ, .គប្បីឈានទៅមុខ, .គប្បីដើរទៅមុខ ។

**អភិក្ខមថ** កិ. [ អភិ+ខម+អ+ថ.ប. ] ចូរអត់ចំពោះ, ចូរអត់សង្កត់ ។

**អភិគមិស្សសិ** កិ. [ អភិ+គម+អ+ឥ.អា.+ស្សសិ.ភ. ] នឹងដល់ចំពោះ, នឹងបាន ។

**អភិជានាតិ** កិ. [ អភិ+ញា, ញា>ជា+នា+តិ.វ. ] រមែងដឹងចំពោះ, ដឹងច្បាស់ ។

**អភិជានិត្វា** អ. [ អភិ+ញា+នា, អានៃនា>ឥ+ត្វា ] ដឹងចំពោះហើយ, ដឹងច្បាស់ហើយ ។

**អភិជ្ឈិត្វា** អ. [ ន+ភិទ+យ+ត.រក.+ត្វា ] មិនបែកហើយ, មិនអំហោបហើយ ។

**អភិជ្ឈាកាយគន្ថ** ចុំ. [ អភិជ្ឈា+កាយគន្ថ ] កិលេសជាគ្រឿងដោតក្រងក្នុងកាយគឺអភិជ្ឈា, កិលេសជាគ្រឿងដោតក្រងប្រព្រឹត្តទៅក្នុងកាយគឺអភិជ្ឈា, កិលេសជាគ្រឿងដោតក្រងនូវនាមកាយនិងរូបកាយគឺអភិជ្ឈា ។

**អភិជ្ឈាទិ** គុ. [ អភិជ្ឈា+អាទិ ] (មនោទុច្ចរិត) មានអភិជ្ឈាជាដើម ។

**អភិញ្ញា** ឥ. [ អភិ+ញា+អ+អា.ឥ. ] ប្រាជ្ញាជាគ្រឿងដឹងចំពោះ, គុណជាតិគឺបុគ្គលគប្បីដឹងច្បាស់ ។ . **បរិញ្ញាបហានភាវនាសច្ឆិកិរិយាបារគូវស** ចុំ. អំណាចនៃបុគ្គលអ្នកដល់នូវត្រើយគឺគុណជាតិនៃបុគ្គលគប្បីដឹងច្បាស់ និងគុណជាតិជាគ្រឿងកំណត់ដឹង និងគុណជាតិជាគ្រឿងលះបង់នូវទុក្ខ និងគុណជាតិជាគ្រឿងញុំាងមគ្គឱ្យចំរើន និងគុណជាតិជាគ្រឿងធ្វើនូវនិព្វានឱ្យជាក់ច្បាស់; (**បរិញ្ញា**<បរិ+ញា+អ+អា..ឥ.; **បហាន**<ប+ហា+ឃុ; **ភាវនា**<ភូ, ឧ.នៃភូ>ឱ>អវ+យុ+អា.ឥ.; **សច្ឆិកិរិយា**<សច្ឆិ+ករ+រិយ+អា.ឥ.; **បារគូ**<បារ+គម+រូ) ។ . **បាទក** គុ. ជាជើងនៃអភិញ្ញា, ជាទីតាំងនៃអភិញ្ញា (ខ្លះថា មានអភិញ្ញាជាជើង, មានអភិញ្ញាជាទីតាំងប្រព្រឹត្តទៅ) ។ . **បារគាទិវស** ចុំ. អំណាចនៃគុណជាតិមានគុណជាតិជាគ្រឿងដល់នូវត្រើយគឺអភិញ្ញាជាដើម ។

**អភិញ្ញាយ** អ. [ អភិ+ញា+ត្វា ] ដឹងចំពោះហើយ, ដឹងច្បាស់ហើយ ។

**អភិញ្ញេយ្យ** គុ. [ អភិ+ញា+តេយ្យ ] គឺបុគ្គលគប្បីដឹងចំពោះ, ធម្មជាតិគឺបុគ្គលគប្បីដឹងដោយបញ្ញាដ៏ក្រៃលែង ។



**អភិញ្ញេយ្យាទិភេទ** គុ. [ អភិញ្ញេយ្យាទិ+ភេទ ] មានធម៌គឺបុគ្គលគប្បីដឹងច្បាស់ជាដើមជាប្រភេទ, ផ្សេងដោយធម៌មានធម៌គឺបុគ្គលគប្បីដឹងដោយប្រាជ្ញាដ៏ក្រៃលែងជាដើម; វិ. **អភិជានិតព្វោតិ> អភិញ្ញេយ្យោ , អភិញ្ញេយ្យោ អាទិ យស្ស សោ> អភិញ្ញេយ្យាទិ , អភិញ្ញេយ្យាទិ ភេទោ យស្ស សោ> អភិញ្ញេយ្យាទិភេទោ** ។

**អភិណ្ហំ** កិ.វិ. រឿយៗ, ញយ ៗ ។

**អភិត្ថរេថ** កិ. [ អភិ+ថរ+អ+ឯថ.ស. ] គប្បីប្រញាប់ធ្វើ, គប្បីប្រសរាន់ធ្វើ, គប្បីធ្វើរសរាន់ ។

**អភិត្ថវន្ត** គុ. [ អភិ+ថុ, ឧនៃថុ>អវ+អន្ត(១) ] កាលសរសើរ, កាលស្ញើច ។

**អភិត្ថវមាន** គុ. [ អភិ+ថុ+មាន(២) ] កាលសរសើរ, កាលស្ញើច ។

**អភិត្ថុតិ** កិ. [ អភិ+ថុ+អ+ត្យ.អជ្ជ. ] សរសើរហើយ, ស្ញើចហើយ ។

**អភិត្ថុត្វា** អ. [ អភិ+ថុ+ឥ.អា.+ត្វា ] សរសើរហើយ, ស្ញើចហើយ ។

**អភិត្ថុតគុណ** គុ. [ អភិត្ថុត+គុណ ] មានគុណគឺ...សរសើរហើយ ឬស្ញើចហើយ ។

**អភិទា** កិ. [ អ+ភិទ+អ+អា.ហិ. ] បានបំបែកហើយ, បានទំលាយហើយ ។

**អភិធម្មកថា** ឥ. [ អភិធម្ម+កថ+អ+អា.ឥ. ] វាចាជាគ្រឿងសម្ដែងនូវ

(១) (២) ថុ៖អ.បច្ច័យសម្រាប់ពួកធាតុអាខ្យាតមកផងក៏បាន ទេក៏បាន ។

អភិធម្ម, វាចាជាគ្រឿងសម្ដែង (ប្រារព្ធ) នូវអភិធម្ម; វិ. **អភិធម្មំ កថេតិ ឯកាយាតិ> អភិធម្មកថា ។**

**អភិធម្មទេសនា** ឥ. [ អភិធម្ម+ទិស+យុ+អា.ឥ. ] វាចាជាគ្រឿងសម្ដែងនូវអភិធម្ម ។

**អភិធម្មបិដក** នពុំ. [ អភិធម្ម+បិដក ] អភិធម្មបិដក, បិដកគឺអភិធម្ម ។

**អភិធាវតិ** កិ. [ អភិ+ធាវ+អ+តិ.ប. ] ចូរលឿនទៅមុខ, ចូរស្ទុះទៅមុខ ។

**អភិនន្ទន្ត** គុ. [ អភិ+នន្ទ(១)+អន្ត ] កាលត្រេកអរចំពោះ, កាលត្រេកអរក្រៃលែង ។

**អភិនន្ទតិ** កិ. [ អភិ+នន្ទ+អ+តិ.វ. ] រមែងត្រេកអរចំពោះ, ត្រេកអរក្រៃលែង ។

**អភិនន្ទិតា** អ. [ អភិ+នន្ទ+ឥ.អា.+តា ] ត្រេកអរចំពោះហើយ, ត្រេកអរក្រៃលែងហើយ ។

**អភិនវ** គុ. [ អភិ+នវ ] ថ្មីពេក, ថ្មីណាស់, ថ្មីស្រឡាង ។

**អភិនិក្ខមន** នពុំ. [ អភិ+និ+កម, កម>ខម+យុ ] កិ.ចេញទៅចំពោះ, កិ.ចេញទៅដើម្បីគុណដ៏ក្រៃលែង (កិ.ចេញបួស, អភិនិស្ក្រមន៍) ។

**អភិនិក្ខមន្ត** គុ. [ អភិ+និ+កម(២)+អន្ត ] កាលចេញទៅដើម្បីគុណដ៏ក្រៃលែង, (កាលចេញបួស) ។

**អភិនិព្វត្តិ** ឥ. [ អភិ+និ+វត, ផ្លាស់ ប>ព>ព្វ, ទ>ត+តិ ] កិ.កើតចំពោះ ។

---

(១) (២) ចុះអ.បច្ច័យ សម្រាប់ពួកធាតុអាខ្យាតមកផងក៏បាន ទេក៏បាន ។



**អភិនិម្មិតា** អ. [ អភិ+និ+មា+នា+តា; អានៃមា>ឥ, អានៃនា>ឥ ] និម្មិតចំពោះហើយ, តំណែងហើយ ។

**អភិនីហារ** ពុំ. [ អភិ+និ+ហរ+ណ ] អភិនីហារ, ធម៌ជាគ្រឿងនាំចេញដើម្បីគុណដ៏ក្រៃលែង (សេចក្ដីកសាង) ។ . **សម្បន្ន** គុ. អ្នកដល់ព្រមហើយដោយអភិនីហារ, អ្នកមានអភិនីហារដល់ព្រមហើយ ។

**អភិបត្ថយំ** គុ. [ អភិ+បត្ថ+ណាយ+អន្ត+សិ.វិ.ផ្លាស់ន្ត+សិ.វិ>អំ ] កាលប្រាថ្នាចំពោះ ។

**អភិបត្ថិត** គុ. [ អភិ+បត្ថ+ឥ.អា.+ត ] គឺ...ប្រាថ្នាចំពោះហើយ ។

**អភិភវតិ** កិ. [ អភិ+ភូ+អ+តិ.វ. ] រមែងញាំញី, .គ្របសង្កត់ ។

**អភិភវនាទិក** គុ. [ អភិភវន+អាទិ+ក ] មានកិ.គ្របសង្កត់ជាដើម; វិ. **អភិភវនំ អាទិ យស្ស តំ> អភិភវនាទិកំ ។**

**អភិភវន្ត** គុ. [ អភិ+ភូ+អន្ត ] កាលញាំញី, កាលគ្របសង្កត់ ។

**អភិភវិ** កិ. [ អភិ+ភូ+អ+ឦ.អជ្ជ. ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភវិត** គុ. [ អភិ+ភូ+ឥ.អា.+ត ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភវិតា** អ. [ អភិ+ភូ+ឥ.អា.+តា ] ញាំញីហើយ, គ្របសង្កត់ហើយ ។

**អភិភុយ្យ** អ. [ អភិ+ភូ+ត្វា ] គ្របសង្កត់ហើយ ។

**អភិភុយ្យមាន** គុ. [ អភិ+ភូ+យ+មាន ] គឺ...កាលគ្របសង្កត់ ។

**អភិភូត** គុ. [ អភិ+ភូ+ត ] គឺ...គ្របសង្កត់ហើយ, .រួបរឹតហើយ, .ជិះជាន់ហើយ ។

**អភិមង្គលសម្មត** គុ. [ អភិមង្គល+សម្មត ] គឺ...ដឹងដោយល្អហើយថាជាមង្គលក្រៃពេក, . សន្មតហើយថាជាមង្គលដ៏ក្រៃលែង (សម្មត <សំ+មន+ត) ។

**អភិមត្តិ** កិ. [ អភិ+មថ+អ+តិ.វ. ] រមែងញាំញី ។

**អភិមុខ** គុ. [ អភិ+មុខ ] ទីចំពោះមុខ, ទីចំមុខ, ទីមានមុខចំពោះ, ឆ្ពោះមុខទៅ, បែរមុខទៅ, មានមុខតម្រង់ទៅ, មានមុខសំដៅទៅ ។

**អភិយាចិត** គុ. [ អភិ+យាច+ឥ.អា.+ត ] គឺ...អារាធនាហើយ, .សូមហើយ, .អង្វរហើយ, .អញ្ជើញហើយ ។

**អភិយុជ្ឈិតុកាម** គុ. [ អភិយុជ្ឈិតុំ+កម+ណ ] អ្នកចង់ដើម្បីច្បាំងចំពោះ; វិ. **អភិយុជ្ឈិតុំ កាមេតីតិ> អភិយុជ្ឈិតុកាមោ** ។

**អភិរត** គុ. [ អភិ+រម+ត ] ត្រេកអរចំពោះហើយ, ត្រេកអរស៊ប់ហើយ ។

**អភិរតិ** ឥ. [ អភិ+រម+តិ ] សេចក្ដីត្រេកអរចំពោះ, សេចក្ដីត្រេកអរក្រៃ-លែង ។

**អភិរម** កិ. [ អភិ+រម+អ+ហិ.ប., លុបហិ ] ចូរត្រេកអរចំពោះ ។

**អភិរមតិ** កិ. [ អភិ+រម+អ+តិ.វ. ] រមែងត្រេកអរចំពោះ ។

**អភិរមិតុំ** អ. [ អភិ+រម+ឥ.អា.+តុំ ] ដើម្បីត្រេកអរចំពោះ ។

**អភិរមិត្វា** អ. [ អភិ+រម+ឥ.អា.+ត្វា ] ត្រេកអរចំពោះហើយ ។

**អភិរាធយេ** កិ. [ អភិ+រធ+ណយេ+ឯយ្យ.ស. លុប យ្យ ទុក ឯ ] គប្បីញុំាង...ឲ្យត្រេកអរចំពោះ ។



**អភិរុចិត** គុ. [ អភិ+រុច+ឥ.អា.+ត ] ដែល...គាប់ចិត្តចំពោះហើយ ។

**អភិរុយ្ហ** អ. [ អភិ+រុហ+ត្វា ] ឡើងហើយ, ជិះហើយ ។

**អភិរុឡ្ហ** គុ. [ អភិ+រុហ+ត ] ឡើងហើយ, ចំរើនឡើងហើយ, ដុះឡើងហើយ ។

**អភិរូបតរ** គុ. [ អភិរូប+តរ ] មានរូបល្អជាង (មានរូបខ្ពង់ជាង) ។

**អភិរូបតា** ឥ. [ អភិរូប+តា ] ភាវៈនៃ...ជាអ្នកមានរូបល្អ; វិ. **អភិរូបស្ស ភាវោ> អភិរូបតា** ។

**អភិរុហតិ** កិ. [ អភិ+រុហ+អ+តិ.វ.] ឡើង, ចំរើនឡើង, ដុះឡើង, ជិះ ។

**អភិរុហន្តោ** គុ. [ អភិ+រុហ+អន្ត+ស.វិ., ផ្លាស់ន្ត+ស.វិ>តោ ] កាលឡើង, កាលដុះឡើង ។

**អភិរុហណ** នពុំ. [ អភិ+រុហ+យុ ] កិ.ឡើង, កិ.ដុះឡើង ។ . **អត្ថ** ប៉ុ. ប្រយោជន៍ (ត្រូវការ) ដល់កិ.ឡើង, .ដុះឡើង ។ . **មគ្គ** ប៉ុ. ផ្លូវជាទីឡើង ។

**អភិរុហន្តី** គុ. [ អភិ+រុហ+អន្ត+ឦ ] កាលឡើង, កាលដុះឡើង, កាលជិះ ។

**អភិរុហិ** កិ. [ អភិ+រុហ+អ+ឦ.អជ្ជ. ] ឡើងហើយ, ដុះឡើងហើយ, ជិះហើយ ។

**អភិរុហិតុំ** អ. [ អភិ+រុហ+ឥ.អា.+តុំ ] ដើម្បីឡើង, ដុះឡើង, ដើម្បីជិះ ។

**អភិរុហិត្វា** អ. [ អភិ+រុហ+ឥ.អា.+ត្វា ] ឡើងហើយ, ដុះឡើងហើយ, ជិះហើយ ។

**អភិវឌ្ឍតិ** កិ. [ អភិ+វឌ្ឍ+អ+តិ.វ. ] រមែងចំរើនក្រៃលែង ។

**អភិវឌ្ឍន** នបុំ. [ អភិវឌ្ឍ+យុ ] កិ.ចំរើនក្រៃលែង ។

**អភិវាទនសីលតា** ឥ. [ អភិវាទនសីល+តា ] ភាវៈនៃ...អ្នកមានកិ.អភិវាទន៍ជាប្រក្រតី, អ្នកមានកិ.ថ្វាយបង្គំជាប្រក្រតី; វិ. **អភិវាទនំ សីលំ យស្ស សោ> អភិវាទនសីលោ , អភិវាទនសីលស្ស ភាវោ> អភិវាទនសីលតា** ។

**អភិវាទនសីលី** បុំ. [ អភិវាទនសីល+ណី ] អ្នកមានកិ.ថ្វាយបង្គំជាប្រក្រតី; វិ. **អភិវាទនសីលំ យស្ស អត្ថិ> អភិវាទនសីលី** ។

**អភិវាទន** នបុំ. [ អភិ+វទ្ទ ឬវាទ+យុ, លុបទ, ទីឃៈអនៃវ>អា ] កិ.ថ្វាយបង្គំ, កិ.សំពះ, កិ.អភិវាទន៍; វិ. **អភិវាទិយតេតិ> អភិវាទនំ** ។

**អភិវាទនាទិសក្ការករណដ្ឋាន** នបុំ. [ អភិ...ករណ+ឋាន ] ទីជាទីធ្វើនូវសក្ការៈមានកិ.ថ្វាយបង្គំជាដើម ។

**អភិវាទេត្វា** អ. [ អភិ+វទ្ទ ឬវាទ+ណេ+ត្វា ] អភិវាទហើយ, ថ្វាយបង្គំហើយ, សំពះហើយ ។

**អភិវាទេន្តិ** កិ. [ អភិ+វទ្ទ ឬវាទ+ណេ+អន្តិ.វ. ] រមែងអភិវាទ, ថ្វាយបង្គំ, សំពះ ។

**អភិវុដ្ឋ** គុ. [ អភិ+វស្ស+ត, ផ្លាស់អនៃវ>ឧ ] គឺភ្លៀងធ្លាក់ចុះហើយក្រៃពេក, គឺភ្លៀងបង្អុរចុះខ្លាំង ។

**អភិសក្ការ** បុំ. [ អភិ+សក្ការ ] សក្ការៈដ៏ក្រៃលែង, គ្រឿងសក្ការៈដ៏ល្អ ។



**អភិសជ្ជេ** កិ. [ អភិ+សជ+យ+ឯយ្យ.ស., លុប យ្យ ទុក ឯ ] គប្បីជាប់នៅចំពោះ, គប្បីចាត់ចែង ។

**អភិសបិ** កិ. [ អភិ+សប+អ+ឦ.អជ្ជ. ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសបិត** គុ. [ អភិ+សប+ឥ.អា.+ត ] គឺ...ស្បថចំពោះហើយ, . ដាក់សម្បថហើយ, . ផ្តាសាហើយ ។

**អភិសបិត្វា** អ. [ អភិ+សប+ឥ.អា.+ត្វា ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសបិត្ថ** កិ. [ អភិ+សប+អ+ឥ.អា.+ឦ.អជ្ជ., ឦ.អជ្ជ>ត្ថ ] ស្បថចំពោះហើយ, ដាក់សម្បថហើយ, ផ្តាសាហើយ ។

**អភិសមយ** បុំ. [ អភិ+សំ+ឥ, ឥ>ឯ>អយ+ណ ] កិ.ប្រព្រឹត្តទៅព្រមចំពោះ, កិ.ដល់ព្រមហើយ, កិ.ល្មុះ, កិ.បាន, កិ.ត្រាស់ដឹង ។

**អភិសមាចារិក** បុំ. [ អភិសមាចារ+ណិក ] អ្នកប្រកបដោយអភិសមាចារៈ ឬអ្នកមានមារយាទល្អក្រៃលែង; វិ. **អភិសមាចារេន និយុត្តោ> អភិសមាចារិកោ , អភិសមាចារោ យស្ស អត្ថិ វា> អភិសមាចារិកោ**; (អភិសមាចារ>អភិ+សំ+អា+ចរ+ណ) ។

**អភិសមេច្ច** អ. [ អភិ+សំ+ឥ, ឥ>ឯ+ត្វា, ត្វា>ច្ច លុបរ ] ត្រាស់ដឹងហើយ, ពិចារណាហើយ (ដល់ព្រមចំពោះហើយ) ។

**អភិសម្បរាយ** បុំ. [ អភិ+សំ+បរ+ឥ, ឥ>ឯ>អយ+ណ ] ភពគឺសត្វគប្បី

ដល់ព្រមចំពោះក្នុងខាងក្នុង, បរលោក ។

**អភិសម្ពុជ្ឈិត្វា** អ. [ អភិ+សំ+ពុធ+យ+ត.អា.+ត្វា ] ត្រាស់ដឹងព្រមចំពោះហើយ ។

**អភិសម្ពុធាន** គុ. [ អភិ+សំ+ពុធ+យុ ] អ្នកត្រាស់ដឹងព្រមចំពោះ ។

**អភិសង្ខត** គុ. [ អភិ+សំ+ករ, ករ>ខរ+ត, លុបរ ] គឺ...តាក់តែងហើយ, .ប្រុងហើយ, .ជួសជុលហើយ ។

**អភិសង្ខរិត្វា** អ. [ អភិ+សំ+ករ, ករ>ខរ+ត.អា.+ត្វា ] តាក់តែងហើយ, ប្រុងហើយ, ជួសជុលហើយ ។

**អភិសង្ខរោតិ** កិ. [ អភិ+សំ+ករ, ករ>ខរ+ឱ+តិ.វ. ] តាក់តែង, ចាត់ចែង, ប្រុង, ជួសជុល ។

**អភិសង្ខរោន្ត** គុ. [ អភិ+សំ+ករ, ករ>ខរ+ឱ+អន្ត ] កាលតាក់តែង, កាលប្រុង, កាលជួសជុល ។

**អភិសិញ្ចិត្វា** អ. [ អភិ+សិច+ត.អា.+ត្វា, ចុះនិ.អា. ] ស្រោចចំពោះហើយ, អភិសេកហើយ ។

**អភិសិញ្ចិស្សុ** កិ. [ អភិ+សិច+អ+ឧុំ.អជ្ជ., ចុះនិ.អា. ] ស្រោចចំពោះហើយ, អភិសេកហើយ ។

**អភិសិត្ត** គុ. [ អភិ+សិច+ត ] គឺ...ស្រោចចំពោះហើយ, អភិសេកហើយ ។

**អភិសេក** គុ. [ អភិ+សិច+ណ, ច>ក, លុបណ ] ជាទីស្រោចចំពោះ, ជាទីអភិសេក (ការស្រោចទឹក) ។ . **គេហប្បវេសនវិវាហមង្គល** នចុំ. មង្គលជាទីអភិសេកនិងជាទីចូលទៅកាន់ផ្ទះនិងវិវាហៈ, អភិសេកមង្គលនិងគេហប្បវេសនមង្គលនិងវិវាហមង្គល ។ . **មង្គលបោក្ខរណី** ឥ. ស្រះបោក្ខរណី (ស្រះមានឈ្នូក) ជាមង្គលជាទីអភិសេក ។



**អភិហដ** គុ. [ អភិ+ហរ+ត, ត>ដ, លុបរ ] គឺ...នាំទៅចំពោះហើយ, . នាំមកចំពោះហើយ ។ . **បណ្ណាការ** ចុំ. គ្រឿងបណ្ណាការ (ជំនូន, តង្វាយ) ដែលបុគ្គលនាំទៅចំពោះហើយ ។ . **មត្ត** គុ. គ្រាន់តែ ឬត្រឹមតែគឺ...នាំទៅចំពោះហើយ ។ . **សក្ការសម្មាន** គុ. មានគ្រឿងសក្ការៈនិងសេចក្ដីរាប់អាន (គឺ...) នាំទៅចំពោះហើយ, មានសក្ការៈនិងវត្ថុជាគ្រឿងរាប់អាននាំទៅចំពោះហើយ ។

**អភិហនិត្វា** អ. [ អភិ+ហន+ត.អា.+ត្វា ] បៀតបៀនចំពោះហើយ, ដល់ហើយ, ទង្គិចហើយ, ប៉ះហើយ ។

**អភិហរន្តិ** កិ. [ អភិ+ហរ+អ+អន្តិ.វ. ] នាំទៅចំពោះ, នាំមកចំពោះ ។

**អភិហារាបេត្វា** អ. [ អភិ+ហរ+ណាបេ+ត្វា ] ញុំាង...ឱ្យនាំទៅចំពោះហើយ, . ឱ្យនាំទៅហើយ ។

**អភិហរិត្វា** អ. [ អភិ+ហរ+ត.អា.+ត្វា ] នាំទៅចំពោះហើយ, នាំទៅហើយ, នាំមកហើយ ។

**អភុញ្ជន្ត** គុ. [ ន+ភុជ+អន្ត, ចុះនិ.អា. ] កាលមិនបរិភោគ, កាលមិនប្រើប្រាស់ ។

**អភុញ្ជិត្វា** អ. [ ន+ភុជ>អភុញ្ជ+ត.អា.+ត្វា ] មិនបរិភោគហើយ, មិនប្រើប្រាស់ហើយ ។

**អភូតបុព្វ** គុ. [ ន+ភូតបុព្វ ] មិនធ្លាប់កើតហើយ, មិនធ្លាប់មានហើយ ។

**អភូត** គុ. [ ន+ភូត ] មិនដែលកើតហើយ; មិនមានហើយ; មិនពិត, ពាក្យមិនពិត ។ **-ពួក្ខានទោស** ចុំ. ទោសគឺកិ.ពោលបង្កាច់ដោយពាក្យមិនពិត ។ **-វាទី** ចុំ. អ្នកពោលនូវពាក្យមិនពិត, អ្នកមានកិ.ពោលនូវពាក្យមិនពិតជាប្រក្រតី; វិ. **អភូតំ វទតីតិ> អភូតវាទី**, **អភូតំ វទិតុំ សីលមស្សាតិ> អភូតវាទី** ។

**អមគ្គ** គុ. [ ន+មគ្គ ] មិនមែនជាមគ្គ, មិនមែនជាផ្លូវ ។

**អមច្ច** ចុំ. [ អមា+ច្ច ] អ្នកកើតជាមួយ, អ្នកកើតរួមជាមួយនឹងស្ដេច ឬមន្ត្រីក្នុងកិច្ចទាំងពួង (អមាត្យ); វិ. **សព្វកិច្ចេសុ រញ្ញា សទ្ធឹ អមា សហ ភវតីតិ> អមច្ចោ** ។ **-កុល** នចុំ. ត្រកូលនៃអមាត្យ ។ **-បុត្ត** ចុំ. កូននៃអមាត្យ ។ **-សហស្សបរិវុត** គុ. គឺពាន់នៃអមាត្យចោមរោមហើយ, -ហែហមហើយ ។ **-បុត្តភាវ** ចុំ. ភាវៈនៃ...ជាបុត្រនៃអមាត្យ ។

**អមជ្ជប** ចុំ. [ ន+មជ្ជ+បា+អ ] អ្នកមិនផឹកនូវទឹកស្រវឹង; វិ. **មជ្ជំ បិវតីតិ> មជ្ជបោ, ន មជ្ជបោ> អមជ្ជបោ** ។

**អមញ្ញិស្សុ** កិ. [ អ+មន+យ+ឧំ.អជ្ជ. ] បានដឹងហើយ, បានសំគាល់ហើយ, បានស្មានហើយ ។

**អមត** គុ. [ ន+មត ] មិនស្លាប់, មិនស្លាប់ហើយ, និព្វានឈ្មោះអមតៈ ។ ទីមិនមានសេចក្ដីស្លាប់; វិ. **នត្ថិ ឯត្ថ មតំ មរណន្តិ> អមតំ** ។



**-ដ្ឋាន** នចុំ. ទីមិនមានសេចក្ដីស្លាប់, ទីនៃបុគ្គលមិនស្លាប់ហើយ ឬមិនដែលស្លាប់ហើយ ។ **-និព្វាន** នចុំ. និព្វានឈ្មោះអមតៈ ។ **-បរិយោសាន** គុ. មាននិព្វានឈ្មោះអមតៈជាទីបំផុត ។ **-បទ** នចុំ. ធម្មជាតជាគ្រឿងដល់នូវនិព្វានឈ្មោះអមតៈ; វិ. **អមតំ បជ្ជន្តិ ឯតេនាតិ> អមតបទំ**; ជាផ្លូវនៃនិព្វានឈ្មោះអមតៈ, ឬទីជាហេតុដល់នូវនិព្វានឈ្មោះអមតៈ; វិ. **អមតស្ស បទំ> អមតំបទំ** ។ **-បាន** នចុំ. ទឹកគឺបុគ្គលគប្បីផឹកឈ្មោះអមតៈ, ទឹកអម្រឹត ។ **-បុព្វ** គុ. ដែល...មិនធ្លាប់ស្លាប់ហើយ ។ **-ផល** គុ. មានផលឈ្មោះអមតៈ ។ **-ភាវ** ចុំ. ភាវៈនៃ...ជា...មិនស្លាប់ហើយ ។ **-មគ្គទេសក** ចុំ. អ្នកសំដែងនូវផ្លូវនៃនិព្វានឈ្មោះអមតៈ ។ **-មហានិព្វាន-សម្បត្តិ** ឥ. សម្បត្តិគឺមហានិព្វានឈ្មោះអមតៈ, កិ.ដល់ព្រមនូវមហានិព្វានឈ្មោះអមតៈ ។ **-មហានិព្វានសម្បាបកត្ត** នចុំ. ភាវៈនៃ... ជា... ញុំាងសត្វឱ្យដល់ព្រមនូវមហានិព្វានឈ្មោះអមតៈ ។ **-រស្ស** នចុំ. ភ្លៀងគឺធម៌ឈ្មោះអមតៈ, ភ្លៀងគឺនិព្វានឈ្មោះអមតៈ ។

**អមតាធិគត** គុ. [ អមត+អធិ+គម+ត ] ដែលដល់នូវនិព្វានឈ្មោះអមតៈ, ដែលបាន (លុះ) នូវនិព្វានឈ្មោះអមតៈ ។

**អមតោគធ** គុ. [ អមត+អវ++គាធ+អ ] ដែលចុះស៊ប់ក្នុងនិព្វានឈ្មោះអមតៈ, (ដែលតាំងស៊ប់ក្នុងធម៌ឈ្មោះអមតៈ, ដែលឈានចុះកាន់

និព្វានឈ្មោះអមតៈ); វិ. **អមតោ និព្វានំ អមតាធិគតិកំ> អមតោគធំ** ។

**អមត្តញ្ញូ** គុ. [ ន+មត្ត+ញា+រូ ] អ្នកមិនស្គាល់នូវប្រមាណ, អ្នកមិនដឹងនូវប្រមាណ; វិ. **មត្តំ ជានាតីតិ> មត្តញ្ញូ , ន មត្តញ្ញូ> អមត្តញ្ញូ** ។

**អមត្តញ្ញុតាបដិក្ខេប** ចុំ. [ អមត្តញ្ញុតា+បដិក្ខេប ] កិ..ហាមឃាត់ដោយភាវៈនៃបុគ្គលអ្នកមិនដឹងនូវប្រមាណ, អាការឃាត់នូវភាវៈនៃបុគ្គលអ្នកមិនដឹងនូវប្រមាណ (**បដិក្ខេប**<បដិ+ខិប+ណ) ។

**អមនសិកត្វា** អ. [ ន+មនសិ+ករ+ត្វា ] មិនធ្វើទុកក្នុងចិត្តហើយ, មិនចាប់ភ្លឹកហើយ ។

**អមនសិការ** ចុំ. [ ន+មនសិ+ករ+ណ ] កិ.មិនធ្វើទុកក្នុងចិត្ត; វិ. **មនសិការណំ> មនសិការោ , ន មនសិការោ> អមនសិការោ** ។

**អមនាប** គុ. [ ន+មនាប ] ដែលមិនជាទីគាប់ចិត្ត, ដែលមិនជាទីពេញចិត្ត, មិនមានសេចក្តីគាប់ចិត្ត ។

**អមនុស្ស** គុ. [ ន+មនុស្ស ] មិនមែនជាមនុស្ស (មានភូតនិងបិសាចជាដើម) ។ - **គ្គហិត** គុ. គឺអមនុស្សចាប់ហើយ ។ - **បរិគ្គហិត** គុ. គឺអមនុស្សហួងហែងហើយ, គឺអមនុស្សកំណត់ហើយ ។ - **ពហុល** គុ. មានអមនុស្សច្រើន, ច្រើនដោយអមនុស្ស ។ - **ភយ** នចុំ. ភ័យអំពីអមនុស្ស, ភ័យកើតអំពីអមនុស្ស ។ - **សទ្ទ** ចុំ. សំឡេងឬសូរនៃអមនុស្ស ។



**អមនុស្សុបទ្ទវ** ចុំ. [ អមនុស្ស+ឧបទ្ទវ ] អន្តរាយអំពីអមនុស្ស, ឬឧបទ្រពដែលកើតអំពីអមនុស្ស; វិ. **អមនុស្សេហិ ជាតោ ឧបទ្ទវោ> អមនុស្សុបទ្ទវោ** ។

**អមនុស្សុបទ្ទុត** គុ. [ អមនុស្ស+ឧបទ្ទុត ] គឺអមនុស្សចូលទៅបៀតបៀនហើយ, គឺអមនុស្សប្រទូស្តហើយ; វិ. **អមនុស្សេហិ ឧបទ្ទុ-តោ> អមនុស្សុបទ្ទុតោ** ។

**អមរណកសត្ត** ចុំ. [ អមរណក+សត្ត ] សត្វអ្នកមិនស្លាប់, សត្វដែលមិនស្លាប់ ។

**អមរវតីនគរ** នចុំ. [ អមរវតី+នគរ ] ក្រុងឈ្មោះអមរវតី ។

**អមហប្ផលភាវ** ចុំ. [ អមហប្ផល+ភាវ ] ភាវៈនៃ...ជា...មិនមានផលធំ; វិ. **មហន្តំ ផលំ> មហប្ផលំ , នត្ថិ មហប្ផលំ ឯតស្សាតិ> អមហប្ផលំ តស្ស ភាវោ> អមហប្ផលភាវោ** ។

**អមាតរ** គុ. [ ន+មាតុ ] ស្ត្រីមិនមែនជាមាតា ។

**អមាតាបិតុសំវឌ្ឍ** គុ. [ អមាតាបិតុ+សំវឌ្ឍ ] ដែលចំរើនព្រមហើយក្នុងបុគ្គលមិនមែនជាមាតានិងបិតា, ចំរើនល្អហើយក្នុងសំណាក់នៃបុគ្គលមិនមែនជាមាតានិងបិតា ។

**អមានុសី** គុ. [ ន+មានុសី ] មិនមែនជារបស់នៃមនុស្ស; វិ. **មនុស្សស្ស**

សន្តកោ> មានុសំ, ន មានុសំ> អមានុសំ ។

**អមាមក** គុ. [ ន+មម+ណក ] អ្នកមិនរាប់អាន, មិនរាប់រក, មិនស្រឡាញ់ ។

**អមាយាវី** គុ. [ ន+មាយាវី ] មិនមែនអ្នកមានមាយា, អ្នកមិនមានពុតត្បុត (មិនមែនអ្នកលាក់ពុត); វិ. មាយា យស្ស អត្ថីតិ> មាយាវី, ន មាយាវី> អមាយាវី ។

**អមាយ** គុ. [ ន+មាយា ] អ្នកមានមាយាមិនមាន, អ្នកមិនមានមាយា; វិ. នត្ថិ តស្ស មាយាតិ> អមាយោ ។

**អមារិតត្ត** នថុំ. [ អមារិត+ត្ត ] ភាវៈនៃ...ជាអ្នកតី...មិនឱ្យស្លាប់ហើយ, -មិនសម្លាប់ហើយ ។

**អមារេត្វា** អ. [ ន+មរ+ណេ+ត្វា ] មិនឱ្យស្លាប់ហើយ, មិនញុំាង...ឱ្យស្លាប់ហើយ, មិនសម្លាប់ហើយ ។

**អមិតភោគ** គុ. [ អមិត+ភោគ ] មានភោគៈរាប់មិនបានហើយ, មានភោគៈគឺពុគ្គលរាប់មិនបានហើយ; វិ. អមិតា ភោគា យេន ចា យស្ស សោ> អមិតភោគោ; (អមិត<ន+មា, អានៃមា> ឥ+ត) ។

**អមិត្ត** គុ. [ ន+មិត្ត ] មិនមែនជាមិត្រ (សត្រូវ); វិ. ន មិត្តោ> អមិត្តោ ។ -ភូត គុ. ដែលមិនមែនជាមិត្រ, មិនមែនជាមិត្រកើតហើយ (ភូត.ស័ព្ទដែលចុះខាងចុងស័ព្ទដូច្នេះជាដើមប្រែក៏បាន ទេក៏បាន) ។ -មទ្ទន នថុំ. កិ.ញុំាញីនូវបុគ្គលមិនមែនជាមិត្រ, កិ.កាច់កិននូវសត្រូវ ។ -វស បុំ. អំណាចនៃសត្រូវ ។



**អមិលាត** គុ. [ ន+មិលា+ត ] មិនស្វិតហើយ, មិនស្រពោនហើយ, មិនរញួមហើយ ។

**អមុច្ចមាន** គុ. [ ន+មុច+យ+មាន ] តី...កាលមិនរួច, - កាលមិនលែង ។

**អមុញ្ចិត្វា** អ. [ ន+មុច+ឥ_អា.+ត្វា, ចុះនិ_អា. ] មិនរួចហើយ, មិនលែងហើយ ។

**អមុត្ត** គុ. [ ន+មុច+ត ] មិនរួចហើយ, មិនផុតហើយ ។

**អមុសាវាទ** បុំ. [ ន+មុសា+វទ+ណ ] កិ.មិនពោលនូវពាក្យកុហក; គុ. អ្នកមិនមានមុសាវាទ ។

**អមូគ** គុ. [ ន+មូគ ] មិនមែនគរ, មិនគរ ។

**អមោឃ** គុ. [ ន+មោឃ ] មិនទទេ, មិនសូន្យ, មិនឥតអំពើ ។

**អមោឃភាវ** បុំ. [ អមោឃ+ភាវ ] ភាវៈនៃ...ជា...មិនមែនក្លោក ។

**អម្ហ** កិ. [ អស+អ+ម_វ., ម_វ.>ម្ហ ] មាន, ជា... ។

**អម្ហមយ** គុ. [ អម្ហ+មយ ] ជាវិការៈនៃថ្ម, ដែលកើតអំពីថ្ម ។

**អម្ហយ** គុ. [ អម្ហ+មយ ] ជាវិការៈនៃថ្ម, ដែលកើតអំពីថ្ម ។

**អម្ហាទិស** គុ. [ អម្ហ+ទិស+ក្វិ ] ប្រាកដដូចជាយើង, ដូចជាយើង; វិ. អហំ ឥវ ទិស្សតីតិ> អម្ហាទិសោ ។

**អម្ពដ្ឋិ** នបុំ. [ អម្ព+អដ្ឋិ ] គ្រាប់ (ឆ្អឹង) នៃស្វាយ ។

**អម្ពណក** នបុំ. [ អម្ព+អណក ] ស្នូក (ភាជនៈដែលគេធ្វើអំពីស្វាយ) ។

អម្ពបក្ក គុ. [ អម្ព+បក្ក ] ស្វាយទុំ, ផ្លែនៃស្វាយទុំហើយ ។

អម្ពបានក នថុំ. [ អម្ព+បានក ] ទឹកគឺបុគ្គលគប្បីផឹកដែលបុគ្គលធ្វើដោយផ្លែនៃស្វាយ, ទឹកបានដែលបុគ្គលធ្វើដោយផ្លែនៃស្វាយ; វិ. **អម្ពេហិ កតំ បានកំ> អម្ពបានកំ** ។

អម្ពបោតក ថុំ. [ អម្ព+បោតក ] កូននៃស្វាយ ។

អម្ពរុក្ខមូល នថុំ. [ អម្ពរុក្ខ+មូល ] ប្រទេសជាទីតាំងនៃដើមស្វាយ, គល់នៃដើមស្វាយ, ទីជិតនៃដើមស្វាយ ។

អម្ពវន នថុំ. [ អម្ព+វន ] ព្រៃនៃស្វាយ, ព្រៃដ៏ដេរដាសដោយដើមស្វាយ, វិហារឈ្មោះអម្ពវន; វិ. **អម្ពានំ វនំ> អម្ពវនំ , អម្ពេហិ សញ្ឆន្នំ វនំ> អម្ពវនំ** ។

អម្ពាដកវន នថុំ. [ អម្ពាដក+វន ] ព្រៃនៃដើមម្កាក់, ព្រៃដ៏ដេរដាសដោយដើមម្កាក់ (អម្ពាដក<អម្ព+អដ+កស) ។

អម្ពិល នថុំ. [ អម្ព+ឥល ] វត្ថុជាគ្រឿងធ្វើនូវសំឡេងនៃជន (ជូរ, រសជូរ, ហានរសជូរ); វិ. **អម្ពតិ សទ្ទំ ករោតិ ឯតេនាតិ> អម្ពិលំ** ។ . ភាជន នថុំ. ភាជនះសម្រាប់ដាក់នូវវត្ថុជូរ ។

អម្ពោ អា.និ. នែអ្នកដ៏ចំរើនទ., វ៉ុយ (ប្រើបានទាំងពីរវចនះចំពោះតែខាងបុរស) ។

អម្ម អា.និ. បពិត្រម៉ែ, ម្នាលនាង . ល . ។ (សម្រាប់ប្រើបានចំពោះតែខាងស្ត្រី) ។



អម្មតាត អា.និ. បពិត្រម៉ែនិងឪពុកទ., ម្នាលនាងនិងអ្នកទ. . ល . ។

អយ ថុំ. [ អយ+អ ] (សភាវះ) ដល់នូវកិ.ប្រកបក្នុងកិច្ចរបស់ជាងផ្សេងៗ (ដែក); វិ. **អយតិ នានាកម្មារកិច្ចេសុ យោគំ គច្ឆតីតិ> អយោ** ។ . កូដសហស្ស ថុំ. ពាន់នៃញញួរជាវិការះនៃដែក ។ . នង្គល នថុំ. នង្គ័លជាវិការះនៃដែក ។ . បថវី ឥ. ផែនដីជាវិការះនៃដែក ។ . កបល្ល នថុំ. អំបែងជាវិការះនៃដែក, គ្រឿងជាវិការះនៃដែក ។ . សលាកា ឥ. ស្នូលជាវិការះនៃដែក, បន្ទះនៃដែក ។ . សំខលិកសង្ឃាត គុ. គឺបណ្ដឹតរាប់ព្រមហើយជាច្រវាក់ជាវិការះនៃដែក, ពោលគឺច្រវាក់ជាវិការះនៃដែក ។ . សិឃាដក នថុំ. ក្រចាប់ជាវិការះនៃដែក, កង្វាមានសណ្ឋានដូចជាច្រវាក់ជាវិការះនៃដែក ។ . សូល នថុំ. ឈើអណ្ដោតជាវិការះនៃដែក, គ្រឿងសំរួចជាវិការះនៃដែក ។

អយស គុ. [ អយ+ស ] ដែលកើតអំពីដែក; វិ. **អយសោ ជាតំ> អយសំ** ។

អយស គុ. [ ន+យស ] មិនមែនជាយស (ទោស) ។

អយោសា ថុំ. [ អយ+ទា.វិ.>អា ចុះស.អា. ] អំពីដែក ។

អយាចិត្វា អ. [ ន+យាច+ឥ.អា.+ត្វា ] មិនសូមហើយ... ។

អយុញ្ជិតព្វ គុ. [ ន+យុជ>អយុញ្ជ+ឥ.អា.+តព្វ ] គឺ...មិនគប្បីប្រកប ។

**អយុត្ត** គុ. [ ន+យុជ+ត ] មិនគួរ, មិនគួរហើយ ។ - **ដ្ឋាន** នបុំ. ទីដែលមិនគួរ, ទីដែលមិនត្រូវ ។

**អយោគ** បុំ. [ ន+យុជ+ណ ] កិ.មិនប្រកប, មិនមានព្យាយាមជាគ្រឿងប្រកប ។

**អយោគុឡ** បុំ. [ អយ+គុឡ ] ដុំនៃដែក ។

**អយោជយំ** គុ. [ ន+យុជ+ណយ+អន្ត+សិ.វិ. ] កាលមិនប្រកប ។

**អយោជេន្ត** គុ. [ ន+យុជ+ណេ+អន្ត ] កាលមិនប្រកប ។

**អយោនិសោ** អ. [ ន+យោនិសោ ] ដោយមិនមែនជាឧបាយ, ដោយមិនមែនជាឧបាយនៃប្រាជ្ញា, ដោយឧបាយមិនមែនជាប្រាជ្ញា ។ - **មនសិការ** បុំ. ការធ្វើទុកក្នុងចិត្តដោយមិនមែនជាឧបាយនៃប្រាជ្ញា, ... ។

**អយ្យក** បុំ. [ អរហ+ណ្វុ, រហ>យ>យ្យ, ណ្វុ>អក ] អ្នកដែលគេគប្បីបូជា (តា ឬជីតា); វិ. **អរហិតព្វោ បូជេតព្វោតិ> អយ្យកោ;** (អយ+ណ្វុ ក៏មាន) ។ - **កុល** នបុំ. ត្រកូលនៃជីតា ។ - **សេដ្ឋី** បុំ. សេដ្ឋីជាជីតា ។ ឥ. អយ្យិកា=យាយ ឬជីដូន ។

**អយ្យ** គុ. [ អយ+ណ្យ ] អ្នកដែលគេគប្បីចូលទៅជិត (ម្ចាស់, លោកម្ចាស់, ចៅហ្វាយនាយ); វិ. **អយិតព្វោ ឧបគន្តព្វោតិ> អយ្យោ** ។ - **បុត្ត** បុំ. បុត្រនៃម្ចាស់ (ព្រះអង្គម្ចាស់) ។

**អរក្ខិតព្វដ្ឋាន** នបុំ. [ អរក្ខិតព្វ+ឋាន ] ទីនៃ...គឺ...មិនគប្បីរក្សា ។

**អរជន្ត** គុ. [ ន+រជ+អន្ត ] កាលមិនត្រេកអរ, កាលមិនរីករាយ ។



**អរញ្ញកវិហារ** បុំ. [ អរញ្ញក+វិហារ ] វិហារ (វត្ត) ដ៏តាំងនៅក្នុងព្រៃ, វិហារមាននៅក្នុងព្រៃ ។

**អរញ្ញកាទិគុណយុត្ត** គុ. [ អរញ្ញកាទិគុណ+យុត្ត ] ដែលប្រកបហើយដោយគុណមានអរញ្ញកធុតង្គ ឬអរញ្ញកគុណជាដើម ។

**អរញ្ញកធុតង្គសមាទានវស** បុំ. [ អរញ្ញកធុតង្គសមាទាន+វស ] អំណាចនៃកិ.កាន់យកព្រមនូវអរញ្ញកធុតង្គ, អំណាចនៃការសមាទាននូវ...; (ធុតង្គ នបុំ. <ធុត+អង្គ=អង្គនៃធមិជាគ្រឿងកំចាត់បង់នូវកិលេស; វិ. **កិលេសេ ធុនាតិ ឯតេនាតិ> ធុតោ, ធុតស្ស អង្គំ> ធុតង្គំ** ។

**អរញ្ញិក,អរញ្ញក** គុ. [ អរញ្ញ+ណិក ] អ្នកមានកិ.នៅក្នុងព្រៃជាប្រក្រតី; វិ. **អរញ្ញេ ចារោ សីលមស្សាតិ> អរញ្ញកោ** (១); អ្នកមានកិ.នៅក្នុងព្រៃជាវត្ត; វិ. **អរញ្ញេ ចារោ វត្តមស្សាតិ> អរញ្ញិកោ**(១) ។ **អរញ្ញក** <អរញ្ញ +ណក; (ចង់វិគ្គហៈប្រែផ្សេងពីខាងលើថា «មានក្នុងព្រៃ, តាំងនៅក្នុងព្រៃ» ក៏បាន) ។

**អរញ្ញ** នបុំ. [ អរ+ញ ] ទីដែលជនតែងទៅ (ព្រៃ); វិ. **អរិយតេ គច្ឆ. តេតិ> អរញ្ញំ** ។ - **គត** គុ. ទៅហើយកាន់ព្រៃ, ទៅហើយក្នុងព្រៃ, នៅក្នុងព្រៃ ។ - **គមនវេលា** ឥ. វេលាជាទីទៅកាន់ព្រៃ ។ - **វាស** បុំ. កិ.នៅក្នុងព្រៃ ។

---

(១) ដោយអំណាច «ណិកប្បច្ច័យ» ត្រូវទីឃៈទៅជា«អារញ្ញិក» ។

**អរញ្ញាយតន** នថុំ. [ អរញ្ញ+អាយតន ] ព្រៃ (ខ្លះប្រែថាព្រៃរហោង, ព្រៃធំ); អាយតន_ស័ព្ទនេះ ចុះមកជាបទប្ដូរណៈ ឬជាសកត្ថៈ ដូច «កម្មាយតន» ដែរ ។

**អរហត្ត** នថុំ. [ អរហន្ត+ត្ត ] ភាវៈនៃបុគ្គលជាព្រះអរហន្ត; វិ. **អរហតោ ភាវោ> អរហត្តំ** ។ _ **ផលសង្ខាត** គុ. គឺបណ្ឌិតរាប់ព្រម ហើយថាអរហត្តផល, គឺបណ្ឌិតពោលថាអរហត្តផល ។ _ **មគ្គញ្ញាណជុតិ** ឥ. សេចក្ដីរុងរឿងនៃញាណដ៏សម្បយុត្តដោយអរហត្តមគ្គ (ជុតិ<ជុត+តិ=ពន្លឺ, រស្មី) ។ . **មគ្គញ្ញាណាសិ** ពុំ. ដាវគឺញាណដ៏សម្បយុត្តដោយអរហត្តមគ្គ ។ _ **មគ្គដ្ឋ** គុ. បុគ្គលអ្នកតាំងនៅក្នុងអរហត្តមគ្គ ។ _ **មគ្គ** ពុំ. មគ្គជាទីមកនៃព្រះអរហត្ត, អរហត្តមគ្គ ។ . **ឧបនិស្សយការណ** នថុំ. ហេតុនៃឧបនិស្ស័យនៃភាវៈនៃបុគ្គលជាព្រះអរហន្ត ។ _ **ឧបនិស្សយសម្បន្ន** គុ. ដែលដល់ព្រមហើយដោយឧបនិស្ស័យនៃព្រះអរហត្ត, មានឧបនិស្ស័យនៃព្រះអរហត្តដល់ព្រមហើយ ។ _ **គ្គហណ** នថុំ. កិ.កាន់យកនូវព្រះអរហត្ត ។ _**ត្ថ** ពុំ. ប្រយោជន៍ដល់ព្រះអរហត្ត, សេចក្ដីត្រូវការដល់ព្រះអរហត្ត ។ . **និកូដ** ពុំ. កំពូលនៃព្រះអរហត្ត, កំពូលគឺព្រះអរហត្ត ។ . **បរិយោសាន** គុ. មានព្រះអរហត្តជាទីបំផុត (មានព្រះអរហត្តជាទីបំផុតចុះដូរិញ) ។ _ **បាបនសង្ខាត** គុ. គឺបណ្ឌិតពោលថាកិ.ដល់នូវព្រះអរហត្ត, ពោលគឺកិ.ញ៉ាំង...ឱ្យដល់នូវព្រះអរហត្ត ។ . **បត្តក្ខណ** ពុំ. ខណៈនៃ...ដល់ហើយនូវភាវៈនៃខ្លួនជាព្រះអរហន្ត ។



. **បត្ត** គុ. ដែលដល់ហើយនូវព្រះអរហត្ត ។ . **ទីប** នថុំ. ទីពឹងគឺព្រះអរហត្ត, ទីពឹងដូចជាកោះគឺព្រះអរហត្ត ។

**អរហន្ត** ពុំ. [ អរហ+ន្ត ] អ្នកឆ្ងាយចាកកិលេស . ល . (ព្រះអរហន្ត) ។ . **វត្តវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវអរហន្តវត្ត ។ . **វាទប្បដិសំយុត្ត** គុ. ប្រកបព្រមចំពោះហើយដោយកិ.ពោលថាព្រះអរហន្ត, . ដោយអរហន្តវាទ ។ . **វាទ** ពុំ. កិ.ពោលថាព្រះអរហន្ត, ពាក្យពោលថាជាព្រះអរហន្ត ។ . **សញ្ញី** គុ. អ្នកមានសេចក្ដីសំគាល់ថាខ្លួនជាព្រះអរហន្ត ។

**អរណីសហិត** គុ. [ អរណី+សហិត ] វត្ថុដែលប្រព្រឹត្តទៅមួយអន្លើដោយដែកភ្លើង ឬដោយពំនួតភ្លើង (ឈើពំនួត) ។

**អរតី** ឥ. [ ន+រតី ] មិនមានសេចក្ដីត្រេកអរ ឬអ្នកធ្វើនូវសេចក្ដីមិនត្រេកអរក្នុងកុសលធម៌នៃជនដទៃ (មារធីតាឈ្មោះអរតី); វិ. **នត្ថិ រតិ ឯតិស្សាតិ> អរតិ , ឋបេសុ កុសលធម្មេ អរតិ ករោតីតិ វា> អរតិ** ។

**អរមណដ្ឋាន** នថុំ. [ អរមណ+ឋាន ] ទីជាទីមិនត្រេកអរ, ទីមិនសមនជាទីត្រេកអរ, ទីគឺបុគ្គលមិនគប្បីត្រេកអរ ។

**អរហតិ** កិ. [ អរហ+អ+តិ.៍ ] គួរ, រមែងគួរ ។

**អរហ** ពុំ. [ អរហ+អ ] អ្នកឆ្ងាយចាកកិលេស, អ្នកគួរដើម្បីទទួលនូវបូជាវិសេស (ព្រះអរហន្ត) ។

**អរិយ** ចុំ. [ អរ+ណ្យ+ឥ.អា. ] អ្នកសម្លាប់នូវសត្រូវគឺកិលេស (ព្រះអរិយៈ; គុ. ប្រសើរ, អ្នកប្រសើរ); វិ. **កិលេសារយោ ហន្តីតិ> អរហោ , សោ ឯវ> អរិយោ;** អ្នកឆ្ងាយចាកកិលេស; វិ. **កិលេសេហិ អារកាតិ> អរិយោ;** (ផ្លាស់អារក>អរិយ) ។ **- ដ្ឋង្គិក** គុ. ប្រកបដោយអង្គ៨ដ៏ប្រសើរ, មានអង្គ៨ជារបស់នៃព្រះអរិយៈ, មានអង្គ៨ដ៏ប្រសើរ ។ **- ធន** នចុំ. ទ្រព្យជារបស់នៃព្រះអរិយៈ, ទ្រព្យដ៏ប្រសើរ, អរិយទ្រព្យ ។ **- បុគ្គល** ចុំ. បុគ្គលជាព្រះអរិយៈ, អរិយបុគ្គល ។ **- ប្បវេទិត** គុ. ដែលព្រះអរិយៈឱ្យដឹងនូវទៅហើយ, - ប្រកាសហើយ, - សំដែងហើយ ។ **- ផល** នចុំ. ផលដ៏ប្រសើរ, អរិយផល ។ **- ពាលិសិកវត្ថុ** នចុំ. រឿងនៃ បុគ្គលអ្នកចាប់នូវត្រីដោយសន្ទូចឈ្មោះអរិយៈ (ពាលិសិក<ពលិស+ណិក; វិ. **ពលិសេន គណ្ហាតីតិ> ពាលិសិកោ**) ។ **- ភូមិ** ឥ. ភូមិនៃព្រះអរិយៈ, អរិយភូមិ ។ **- មគ្គញាណគ្គិ** ចុំ. ភ្លើងគឺញាណដ៏សម្បយុត្តដោយអរិយមគ្គ, ភ្លើងគឺអរិយមគ្គញាណ ។ **- មគ្គភាវនា** ឥ. កិ.ចំរើននូវអរិយមគ្គ, កិ.ញុំាងអរិមគ្គឱ្យកើត ។ **- មគ្គមយ** គុ. ជាវិការៈនៃអរិយមគ្គ, សម្រេចដោយអរិយមគ្គ ។ **- មគ្គ** ចុំ. ផ្លូវជារបស់នៃព្រះអរិយៈ, មគ្គដ៏ប្រសើរ, អរិយមគ្គ ។ **- វំសប្បដិបទា** ឥ. សេចក្ដីប្រតិបត្តិជាវង្សនៃព្រះអរិយៈ, -ដោយវង្សនៃព្រះអរិយៈ, - ជាប់មកអំពីវង្សនៃព្រះអរិយៈ ។ **- សច្ច** នចុំ. សេចក្ដីពិតរបស់ព្រះអរិយៈ, សេចក្ដីពិតដ៏ប្រសើរ, អរិយសច្ច ។ **- សាវកកោដិ** ឥ. កោដិនៃអរិយសាវក ។ **- សាវក** ចុំ. សាវកជាព្រះអរិយៈ, សាវកអ្នកប្រសើរ ។



**អរុ** នចុំ. [ អរ+ឧ ] រោគជាតទៅក្នុងខាងលើដោយភាពជារបស់ស្អុយ (ដំបៅ); វិ. **អរតិ បូតិភាវេន ឧទ្ធំ គច្ឆតីតិ> អរុ** ។ **- កាយ** ចុំ. កាយប្រព្រឹត្តទៅដោយដំបៅ, កាយមានដំបៅ; គុ. មានកាយជាដំបៅ ។

**អរុចិ** ឥ. [ ន+រុចិ ] សេចក្ដីមិនគាប់ចិត្ត, សេចក្ដីមិនរុងរឿង ។

**អរុច្ចនក** គុ. [ ន+រុច+យ+ណ្វុ, ណ្វុ>អនក ] មិនជាទីគាប់ចិត្ត, ដែលមិនគាប់ចិត្ត ។

**អរុណ** ចុំ. [ អរ+ឧណ ] សភាវៈតែងទៅ ឬសភាវៈប្រព្រឹត្តទៅដោយភាពដូចជាមាស (អរុណ); វិ. **អរតិ គច្ឆតីតិ> អរុណោ , អរតិ គច្ឆតិ សុវណ្ណភាវេន ឧបក្កមតីតិ វា> អរុណោ** ។ **- វណ្ណមត្តិកា** ឥ. ដីមានពណ៌ដូចជាពណ៌នៃអរុណ ។ **- ឧគ្គមនឧតុ** នចុំ. រដូវជាទីរះនៃអរុណ, រដូវជាទីទៅក្នុងខាងលើនៃអរុណ ។ **- ឧគ្គមនវេលា** ឥ. វេលាជាទីរះនៃអរុណ ។

**អរុភូតកាយ** ចុំ. [ អរុភូត+កាយ ] កាយមានដំបៅកើតហើយ, កាយគឺភូតរូបមានដំបៅ, កាយជាទីកើតនៃដំបៅ ។

**អរូប** គុ. [ ន+រូប ] មានរូបមិនមាន, មិនមានរូប ។ **- ធម្ម** ចុំ. អរូបធម៌, ធម៌មិនមានរូប ។ **- ព្រហ្ម** ចុំ. អរូបព្រហ្ម, ព្រហ្មមិនមានរូប ។

**អរូបី** ចុំ. [ន+រូបី] មិនមែនធម៌មានរូប; វិ. **រូបំ យស្ស អត្ថីតិ> រូបី, ន រូបី> អរូបី** ។

**អរេ** អា.និ, នែមនុស្សចង្រៃ, នែអាចង្រៃ, នែមេចង្រៃ, ... ។

**អរោគ** គុ. [ន+រោគ] មានរោគមិនមាន, មិនមានរោគ, ឥតរោគ; វិ. **នត្ថិ រោគោ អស្សាតិ> អរោគោ** ។ -**ករណភាវ** ចុំ. ភាវៈនៃកិ.ធ្វើឱ្យជាអ្នកមិនមានរោគ ។ -**កាល** ចុំ. កាលនៃ...មានរោគមិនមាន ។ -**និត្ត** គុ. មានចៅមិនមានរោគ ។ -**បុត្ត** គុ. មានកូនមិនមានរោគ ។ -**ភាវបរម** គុ. មានភាវៈនៃបុគ្គលមិនមានរោគយ៉ាងក្រៃលែង ។ -**ភាវ** ចុំ. ភាវៈនៃ...ជាអ្នកមិនមានរោគ (ភាវៈនៃ...មិនសាបសូន្យ) ។

**អលក្ខិក** គុ. [ន+លក្ខិក] អ្នកមិនមានសិរីជាគ្រឿងកំណត់ (អ្នកមិនមានបុណ្យ) ។

**អលង្កត** គុ. [អលំ+ករ+ត] របស់ដែលគេធ្វើប្រដាប់, (ប្រដាប់, តាក់តែង); វិ. **អលំ វិភូសណំ ករិយតេតិ> អលង្កតោ, -តា, -តំ** ។ -**កាល** ចុំ. កាលនៃ...គឺ...ធ្វើប្រដាប់ហើយ ។ -**ធម្មាសន** នចុំ. ធម្មាសនៈដែលបុគ្គលធ្វើប្រដាប់ហើយ ។ -**បដិយត្ត** គុ. ទាំងដែលគេធ្វើប្រដាប់ហើយ ទាំងដែលគេតាក់តែងហើយ (បដិយត្ត<បដិ+យត+ត) ។ -**មណ្ឌបមជ្ឈ** នចុំ. កណ្ដាលនៃមណ្ឌប (បារាំ) ដែលគេធ្វើប្រដាប់ហើយ ។ -**មណ្ឌលមាលមជ្ឈ** នចុំ. កណ្ដាលនៃរោងមានមណ្ឌលដែលគេធ្វើប្រដាប់ហើយ ។



-**សីស** នចុំ. ក្បាលដែលគេធ្វើប្រដាប់ហើយ, ក្បាលដែលបុគ្គលប្រដាប់ហើយ ។

**អលង្ករិត្វា** អ. [អលំ+ករ+ឥ.អា.+ត្វា] ធ្វើប្រដាប់ហើយ, ធ្វើឱ្យល្អហើយ, ប្រដាប់ហើយ, តាក់តែងហើយ ។

**អលង្ការ** ចុំ. [អលំ+ករ+ណ] កិ.ធ្វើប្រដាប់ (គ្រឿងអលង្ការ); វិ. **អលំ វិភូសណំ ករោតីតិ> អលង្ករណំ, អលង្ករណំ> អលង្ការោ** ។ -**ភណ្ឌ** នចុំ. ភណ្ឌៈគឺគ្រឿងអលង្ការ ។

**អលង្ការាបេត្វា** អ. [អលំ+ករ+ណាបេ+ត្វា] ញុំាង...ធ្វើឱ្យប្រដាប់ហើយ, -ឱ្យប្រដាប់ហើយ ។

**អលគទ្ទ** បុំ. [អរ>អល+គម, គម>គទ+អ] សត្វទៅរហ័ស (ពស់); វិ. **អរំ សីឃំ គច្ឆតីតិ> អលគទ្ទោ** ។ ម្យ៉ាងទៀត សត្វមានពិសដ៏បរិបូណ៌ (ពស់); វិ. **គោ វុច្ចតិ ទុគ្ធំ, តំ ទេតីតិ> គទោ វិសំ; អលំ បរិបុណ្ណំ គទំ អស្សាតិ> អលគទ្ទោ** ។

**អលគ្គ** គុ. [ន+លគ្គ+អ] មិនជាប់, មិនជំពាក់ ។ -**តា** ឥ. ភាវៈនៃ...ជា...មិនជាប់នៅ ។ -**មាន** គុ. កាលមិនជាប់, កាលមិនជំពាក់ ។

**អលជ្ជតា** ឥ. [អលជ្ជ+តា] ភាវៈនៃ...អ្នកមិនមានសេចក្ដីខ្មាស; វិ. **នត្ថិ លជ្ជា អស្សាតិ> អលជ្ជោ, តស្ស ភាវោ> អលជ្ជតា** ។

**អលជ្ជមាន** គុ. [ន+លជ្ជ+មាន] កាលមិនខ្មាស, កាលមិនអៀន ។

**អលជ្ជិតព្វ** គុ. [ន+លជ្ជ+ឥ.អា.+តព្វ] (វត្ថុ) ដែលបុគ្គលមិនគប្បីខ្មាស ។

**អលជ្ជី** បុ. [ ន+លជ្ជី ] អ្នកមិនមានសេចក្ដីខ្មាស; វិ. **លជ្ជា យស្ស អត្ថីតិ> លជ្ជី , ន លជ្ជី> អលជ្ជី** ។

**អលត្តក** បុ. [ អា>អ+រត្ត, រ>ល+ករ+ក្វិ ] សភាវៈធ្វើនូវពណ៌ក្រហមក្រៃលែង (ល័ក្ត); វិ. **អា ភុសោ រត្តំ ករោតីតិ> អលត្តកោ** ។ -**កត** គុ. គឺបុគ្គលធ្វើហើយឱ្យជារបស់មានពណ៌ដូចល័ក្ត ។ -**រស-រញ្ជិត** គុ. ដែលបុគ្គលជ្រលក់ហើយដោយទឹកនៃល័ក្ត ។ -**វណ្ណ** គុ. មានពណ៌ដូចជាពណ៌នៃល័ក្ត; វិ. **អលត្តកស្ស វណ្ណោ> អលត្តកវណ្ណោ , អលត្តកវណ្ណោ ឥវ វណ្ណោ អស្សាតិ> អលត្តកវណ្ណោ** ។

**អលត្ថ** កិ. [ អ+លភ+អ+ត្ថ-អដ្ឋ. ] បានបានហើយ ។

**អលទ្ធ** គុ. [ ន+លភ+ត ] គឺ...មិនបានហើយ; វិ. **លភិយិត្ថាតិ> លទ្ធោ ន លទ្ធោ> អលទ្ធោ** ។ -**បុព្វ** គុ. គឺ... មិនធ្លាប់បានហើយ ។

**អលទ្ធា** ន. [ ន+លភ+ត្វា ] មិនបានហើយ ។

**អលភនាការ** បុ. [ អលភន+អាការ ] អាការគឺកិ.មិនបាន ។

**អលភន្ត** គុ. [ ន+លភ+អន្ត ] កាលមិនបាន ។

**អលភិតព្វដ្ឋាន** នបុ. [ អលភិតព្វ+ឋាន ] ទីគឺ...មិនគប្បីបាន, ទីនៃ...គឺ... មិនគប្បីបាន ។

**អលភិត្វា** អ. [ អ+លភ+ឥ-អា.+ត្វា ] មិនបានហើយ ។

**អលភិស្ស** កិ. [ អ+លភ+អ+ឥ-អា.+ស្សា-កា. ] នឹងបានបានហើយ ។





**អលស** បុ. [ ន+លស+អ ] អ្នកមិនព្រេកអរ (ខ្ជិល); វិ. **ន លសតិ កីឡ្យតីតិ> អលសោ** ។ -**ជាតិកា** គុ. មានជាតិនៃស្ត្រីខ្ជិល, ប្រកបដោយជាតិនៃបុគ្គលអ្នកខ្ជិល, មានជាតិជាមនុស្សខ្ជិល ។ -**ថេរ** បុ. ព្រះថេរអ្នកខ្ជិល, -មានសេចក្ដីខ្ជិល ។ -**ភាវ** បុ. ភាវៈនៃ...ជាអ្នកខ្ជិល, -ជាអ្នកមានសេចក្ដីខ្ជិល ។

**អលំ** និ. ល្មម, អាច, គួរ, មិនគួរ, កុំឡើយ, ប៉ុណ្ណឹងហើយ ។

**អលង្ឃិត្វា** អ. [ ន+លឃ, លឃ>លង្ឃ+ឥ-អា.+ត្វា ] មិនហោះហើយ, មិនផ្លោះហើយ, មិនផ្លោះរំលងហើយ ។

**អលាពុ** នបុ. [ អា>អ+លម្ព, លម្ព>លាព+ឧ ] វត្ថុដែលប្រពោង ឬសំយុងចុះ (ឃ្លោក); វិ. **លម្ពតិ អធោសំសតីតិ> អលាពុ** ។

**អលាភ** គុ. [ ន+លាភ ] មិនមែនជាលាភ, កិ.មិនបាន; វិ. **លភិយតេតិ> លភនំ, លភនំ> លាភោ , ន លាភោ> អលាភោ** ។

**អលាភេសិ** កិ. [ អ+លភ+ណេ++ឦ-អដ្ឋ.+ស-អា. ] ញុំាង...ឱ្យបានបានហើយ ។

**អលិក** នបុ. [ អល+ណិក ] ពាក្យជាគ្រឿងចងនៃជន (ពាក្យឡេះឡោះ, ពាក្យមិនពិត); វិ. **អលតិ ពន្ធតិ ឯតេនាតិ> អលិកំ** ។ -**វាទី** បុ. អ្នកពោលនូវពាក្យឡេះឡោះដោយប្រក្រតី ឬ អ្នកមានកិ.ពោលនូវពាក្យឡេះឡោះជាប្រក្រតី; វិ. **អលិកំ វទតិ សីលេនាតិ> អលិកវាទី , អលិកំ វទិតុំ សីលមស្សាតិ> អលិកវាទី** ។

**អលីន** គុ. [ ន+លិ+យុ ] មិនរួញរា, មិនចំរន់ ។ - **ចិត្តជាតក** នចុំ. ជាតកគឺបណ្ឌិតកំណត់ហើយដោយកុមារឈ្មោះអលីនចិត្ត ។ - **ចិត្ត** គុ. មានចិត្តមិនរួញរា (កុមារឈ្មោះអលីនចិត្ត) ។

**អលោណ** គុ. [ ន+លោណ ] មានរសប្រៃមិនមាន, មិនមានរសប្រៃ (សាប); **វិ. នត្ថិ លោណំ អស្សាតិ> អលោណំ ។**

**អលោណិក** គុ. [ អលោណ+ណិក ] មិនមែនជារបស់មានរសប្រៃ; **វិ. លោណំ យស្ស អត្ថីតិ> លោណិកំ , ន លោណិកំ> អលោណិកំ ។**

**អល្ល** គុ. [ អល+ល ] ស្រស់, ទទឹក, សើម ។ - **កប្បរដ្ឋ** នចុំ. ដែនឈ្មោះអល្លកប្បៈ ។ - **កប្បរាជ** ចុំ. ស្តេចឈ្មោះអល្លកប្បៈ ។ - **កេស** គុ. មានសក់ទទឹក, មានសក់ស្រស់, មានសក់សើម ។ - **គោមយ** គុ. គោម័យដ៏ស្រស់, ករីសដែលគោធ្វើហើយដ៏ស្រស់, អាចម៍គោស្រស់ ។ - **ចីវរ** គុ. មានចីវរទទឹក, មានចីវរសើម ។ - **មធុ** នចុំ. ឃ្មុំដ៏ស្រស់, ទឹកឃ្មុំដ៏ស្រស់ ។ - **មំសសរីរ** គុ. មានសាច់ដ៏ស្រស់ក្នុងសរីរៈ, មានសាច់ក្នុងសរីរៈដ៏ស្រស់, មានសាច់និងសរីរៈដ៏ស្រស់ ។ - **រសមុទិកបានកបីតាវសេស** គុ. ជាចំណែកដ៏សេសចុះចាកទឹកគឺបុគ្គលគប្បីផឹកដែលបុគ្គលធ្វើហើយដោយផ្លែចន្ទន៍មានរសដ៏ស្រស់គឺ...ផឹកហើយ ។ - **វត្ថ** គុ. មានសំពត់ដ៏សើម, មានសំពត់ទទឹក ។

**អល្លយីសុ** កិ. [ អល>អល្ល+ណាយ ឬ យ+ឧំ.អជ្ជ. ] ជាប់គ្នាហើយ, ស្អិតជាប់គ្នាហើយ ។



**អល្លាប** ចុំ. [ អា>អ+លប+ណ ] កិ.ពោលមុន, កិ.និយាយរកមុន, កិ.ហៅរកមុន, កិ.ចរចាមុន ។ - **មត្ត** គុ. ពាក្យគ្រាន់តែកិ.ពោលមុន, គ្រាន់តែពាក្យជាគ្រឿងចរចាមុន ។ - **សល្លាប** ចុំ. កិ.ពោលមុននិងកិ.ពោលក្រោយ, កិ.ចរចារកមុននិងកិ.ចរចារកក្រោយ (ការនិយាយឆ្លើយឆ្លង, ការនិយាយតគ្នាទៅវិញទៅមក) ។

**អវកង្ខន្តិ** កិ. [ អវ+កង្ខ+អ+អន្តិ.វ. ] ប៉ុនប៉ង, នឹកស្តាយ, អាឡោះអាល័យ ។

**អវកឌ្ឍិត** គុ. [ អវ+កឌ្ឍ+ឥ.អា.+ត ] គឺ....ទាញចុះហើយ, - សង្កត់ចុះហើយ, - ទាញផ្កុបហើយ ។

**អវក្ការបាតិ** ឥ. [ អវក្ការ+បាតិ ] ភាជនៈសម្រាប់ដាក់នូវវត្ថុជាទីធ្វើចុះ, ភាជនៈសម្រាប់ដាក់នូវវត្ថុជារបស់ដែល, ភាជនៈសម្រាប់ផ្តេរ (**អវក្ការ**<អវ+ករ+ណ) ។

**អវច** កិ. [ អ+វច+អ+អា.ហី., អា.ហី.>អ ] បានពោលហើយ, ... ។

**អវចំ** កិ. [ អ+វច+អ+អំ.ហី. ] បានពោលហើយ ។

**អវចុត្ថ** កិ. [ អ+វច+អ+ត្ថ.អជ្ជ., ត្ថ.អជ្ជ.>ត្ថ, យកអនៃវច>ឧ ] បានពោលហើយ, ... ។

**អវជាតបុត្ត** ចុំ. [ អវជាត+បុត្ត ] អវជាតបុត្រ, កូនមានគុណដ៏ទាបកើតហើយ, កូនកើតហើយដោយអំណាចនៃគុណដ៏ទាប (កូនថោកទាប) ។

**អវជានេយ្យ** កិ. [ អវ+ញា+នា+ឯយ្យ.ស ] គប្បីមើលងាយ ។

**អវជិយតិ** កិ. [ អវ+ជិ+យ+តិ.វ. ] គឺ...ត្រឡប់ឈ្នះបានវិញ, -ចាញ់វិញ ។

**អវជ្ជ** គុ. [ ន+វជ្ជ ] មានកម្មគឺ...គប្បីវៀរមិនមាន, កម្មមានទោសគឺបណ្ឌិតគប្បីវៀរមិនមាន (មិនមានទោស); វិ. **វជ្ជេតព្វន្តិ> វជ្ជំ , នត្ថិ វជ្ជំ ឯតស្សាតិ> អវជ្ជំ** ។ - **ទស្សី** ថុំ. អ្នកមានកិ.ឃើញនូវកម្មគឺបណ្ឌិតគប្បីវៀរមិនមានជាប្រក្រតី, អ្នកមានកិ.ឃើញនូវកម្មមានទោសមិនមានជាប្រក្រតី; វិ. **អវជ្ជំ បស្សិតុំ សីលម-ស្សាតិ> អវជ្ជទស្សី** ។

**អវឈាយន្តិ** កិ. [ អវ+ឈេ+អ+អន្តិ.វ. ] រមែងសញ្ជប់សញ្ជឹង, សុបសៅ, ក្រៀមក្រំ, សំកុកនៅ ។

**អវឌ្ឍេត្វា** អ. [ ន+វឌ្ឍ+ណេ+ត្វា ] មិនញ៉ាំង...ឱ្យចំរើនហើយ, មិនចំរើនហើយ ។

**អវណ្ណ** គុ. [ ន+វណ្ណ ] សភាវៈមិនមែនជាគុណគឺបុគ្គលគប្បីពណ៌នា, - គប្បីប្រកាស (ទោស); វិ. **វណ្ណេតព្វោតិ> វណ្ណោ, ន វណ្ណោ > អវណ្ណោ** (វណ្ណ<វណ្ណ+អ) ។

**អវត្វា** អ. [ ន+វទ+ត្វា ] មិនពោលហើយ ។

**អវត្តព្វតា** ឥ. [ អវត្តព្វ+តា ] ភាវៈនៃ...ជា...គឺ...មិនគប្បីពោល ។

**អវត្តិត្វា** អ. [ ន+វត្ត>អវត្ត+ឥ.អា.+ត្វា ] មិនប្រព្រឹត្តហើយ ។

**អវត្ថដ** គុ. [ អវ+ថរ+ត, ត>ដ ] គឺ...គ្របសង្កត់ហើយ, សង្កត់ចុះហើយ, រលំសង្កត់ហើយ, រួបរឹតហើយ, លាតចុះហើយ ។





**អវត្ថរន្ត** គុ. [ អវ+ថរ+អន្ត ] កាល..., (ប្រែដូច«អវត្ថដ») ។

**អវត្ថរិត** គុ. [ អវ+ថរ+ឥ.អា.+ត ] គឺ..., (ប្រែដូច«អវត្ថដ») ។

**អវត្ថរិត្វា** អ. [ អវ+ថរ+ឥ.អា.+ត្វា ] (ប្រែដូច«អវត្ថដ») ។

**អវត្ថិត** គុ. [ អវ+ឋា, យកអានៃឋា>ឥ+ត ] តាំងចុះហើយ, តាំងស៊ប់ហើយ, ដំកល់មាំហើយ, ដំកល់ស៊ប់ហើយ ។ - **ត្ត** នថុំ. ភាវៈនៃ...ជា... តាំងចុះហើយ, - តាំងស៊ប់ហើយ ។ - **សមាទាន** គុ. មានកិ. សមាទានតាំងមាំហើយ, មានកិ.កាន់យកព្រមតាំងស៊ប់ហើយ ។

**អវទន** នថុំ. [ ន+វទ+យុ ] កិ.មិនពោល ។ - **តា** ឥ. ភាវៈនៃកិ.មិនពោល ។

**អវធិ** កិ. [ អ+ហន, ហន>វធ+អ+ឦ.អជ្ជ. ] បានសម្លាប់ហើយ, បានវាយហើយ ។

**អវធិបរិច្ឆេទនត្ថ** ថុំ. [ អវធិបរិច្ឆេទន+អត្ថ ] អត្ថគឺកិ.កំណត់នូវដែន, អត្ថជាគ្រឿងកំណត់នូវដែន (**អវធិ**<អវ+ធា+ឥ=កិ.ទ្រទ្រង់ចុះ«ដែន, ព្រំដែន»; **បរិច្ឆេទន**<បរិ+ឆិទ+យុ=កិ.កាត់ជុំវិញ «កំណត់») ។

**អវន្តិ** ឥ., គុ. ជនបទឈ្មោះអវន្តិ, អ្នកនៅក្នុងជនបទឈ្មោះអវន្តិ ។ - **បច្ចន្ត-ជនបទ** ថុំ. ជនបទជាទីបំផុតនៃដែនឈ្មោះអវន្តិ, ជនបទត្រង់ប្រទល់ដែនឈ្មោះអវន្តិ ។

**អវន្ទិត្វា** អ. [ ន+វន្ទ+ឥ.អា.+ត្វា ] មិនថ្វាយបង្គំហើយ, មិនសំពះហើយ ។

**អវមង្គល** នថុំ. [ អវ+មង្គល ] មង្គលដ៏ថោកទាប, អពមង្គល ។

**អវមញ្ញន្ត** គុ. [ អវ+មន+យ+អន្ត ] កាលមើលងាយ, កាលស្មាន ។

**អវមញ្ញិ** កិ. [ អវ+មន+យ+ញ្ញ.អជ្ជ. ] មើលងាយហើយ ។

**អវមញ្ញិតព្វ** គុ. [ អវ+មន+យ+ឥ.អា.+តព្វ ] គឺ...គប្បីមើលងាយ, .គប្បីស្អប់ ។

**អវមានប្បត្ត** គុ. [ អវមាន+បត្ត ] ដល់ហើយនូវកិ.មើលងាយ, ដល់ហើយនូវកិ.ស្អប់ (អវមាន<អវ+មន+ណ) ។

**អវរុទ្ធក** អស.ន ឈ្មោះអវរុទ្ធកៈ ។

**អវរោជ** អសុ.ន. ឈ្មោះអវរោជៈ ។

**អវលញ្ជ** គុ. [ ន+វលញ្ជ+អ ] គឺបុគ្គលគប្បីប្រើប្រាស់មិនបាន, គឺបុគ្គលមិនគប្បីប្រើប្រាស់; វិ. **ន ចលព្យ៉ាកព្យាក> អចលព្យា** ។ មានស្នាមមិនមាន ។

**អវសន្ន** គុ. [ អវ+សទ+ត ] លិចចុះហើយ ។ - **សង្កប្បចិត្ត** គុ. មានចិត្តជាគ្រឿងត្រិះរិះលិចចុះហើយ ។ - **សង្កប្ប** គុ. មានសេចក្ដីត្រិះរិះលិចចុះហើយ, មានតម្រិះលិចចុះហើយ ។

**អវសរិ** កិ. [ អវ+សរ+អ+ឦ.អជ្ជ. ] ត្រេចទៅហើយ, សំដៅទៅហើយ ។

**អវសវត្តនត្ត** ថុំ. [ អវសវត្តន+អត្ត ] សេចក្ដីគឺកិ.មិនប្រព្រឹត្តទៅក្នុងអំណាច, សេចក្ដីជាកិ.មិនប្រព្រឹត្តទៅក្នុងអំណាច ។

**អវសាន** នថុំ. [ អវ+សា+យុ ] ទីបំផុត, កាលជាទីបំផុត, កាលជាទីចប់, កាលជាទីហើយស្រេច, អវសាន ។

**អវសិដ្ឋ** គុ. [ អវ+សិស+ត ] ដែលសល់ចុះហើយ ។ - **មត្តិកា** ឥ. ដី



(ឬដីស្អិត) ដែលសល់ចុះហើយ ។

**អវសិត្វា** អ. [ ន+វស+ឥ.អា.+ត្វា ] មិនរនៅហើយ, មិនរក្សាហើយ ។

**អវសិរ** គុ. [ អវ+សិរ ] មានក្បាលក្នុងខាងទាប, មានក្បាលសំយុងចុះ (អវំសិរ ក៏មាន) ។

**អវសីសុ** កិ. [ អវ+សិស+អ+ឧំ.អជ្ជ. ] សល់ចុះហើយ, សល់នៅហើយ ។

**អវសេស** គុ. [ អវ+សិស+ណ ] ដ៏សេសចុះ, សល់ចុះ, សេសសល់, សំណល់ ។ - **ចោរ** ពុំ. ចោរដ៏សេសចុះ ។ - **សុរា** ឥ. សុរាដ៏សេសចុះ, សុរាដែលសល់ ។

**អវស្សន្ត** គុ. [ ន+វស្ស+អន្ត ] កាលមិនធ្លាក់ចុះ, កាលមិនបង្អុរចុះ, កាលមិនភ្លៀង ។

**អវស្សយ** គុ. [ អវ+សី+ណ ] ជាទីអាស្រ័យ, ជាទីពឹង, ជាទីពំនាក់ ។

**អវស្សំ** និ. ពិត, ដោយពិត, មែន,... ។

**អវស្សិក** គុ. [ ន+វស្សិក ] មានវស្សាមិនមាន, មិនមានវស្សា, មិនប្រកបដោយវស្សា, មិនប្រព្រឹត្តទៅក្នុងកាលភ្លៀង (វស្សិក<វស្ស+ណិក) ។

**អវហដ** គុ. [ អវ+ហរ+ត, ត>ដ ] គឺ...នាំចុះហើយ, .លួចយកហើយ ។

**អវហរតិ** កិ. [ អវ+ហរ+តិ.វ. ] រមែងនាំចុះ, រមែងលួច ។

**អវាយាមន្ត** គុ. [ ន+វាយាម+អន្ត ] កាលមិនព្យាយម, ... ។

**អវារិត** គុ. [ ន+វរ+ឥ.អា.+ត ] គឺ...មិនហាមហើយ, .មិនឃាត់ហើយ ។

**អវិក្កីណន្ត** គុ. [ ន+វិ+កី+ណា+អន្ត ] កាលមិនលេក ។

**អវិក្ខិត្ត** គុ. [ ន+វិ+ខិប+ត ] គឺ...មិនបោះទៅផ្សេងៗហើយ, ‑ មិនរាយមាយហើយ ។

**អវិគត** គុ. [ ន+វិ+គម+ត ] មិនទៅប្រាសហើយ, មិនរាំងហើយ ។ ‑ **គន្ធ** គុ. មានក្លិនមិនទៅប្រាសហើយ ។

**អវិចរិត្វា** អ. [ ន+វិ+ចរ+ឥ.អា.+ត្វា ] មិនត្រេចទៅហើយ, មិនប្រព្រឹត្តហើយ ។

**អវិជហិត** គុ. [ ន+វិ+ហា.ហា, ផ្លាស់ហាទៃអព្ភាសៈ>ជ, ផ្លាស់អានៃហា.ធាតុ>ឥ+ត ] គឺ...មិនលះហើយ, ‑ មិនលះបង់ហើយ ។

**អវិជាត** គុ. [ ន+វិ+ជន, ជន>ជា+ត ] មិនកើតវិសេសហើយ, មិនទាន់សម្រាលហើយ ។

**អវិជានន្ត** គុ. [ ន+វិ+ញា, ញា>ជា+នា, នា>ន+អន្ត ] កាលមិនដឹងច្បាស់ ។

**អវិជាយិត្វា** អ. [ ន+វិ+ជន, ជន>ជា, ផ្លាស់អានៃជា>អាយ+ឥ.អា.+ត្វា ] មិនទាន់កើតហើយ, មិនទាន់សម្រាលហើយ ។

**អវិជ្ជន្ធការ** ប៉ុ. [ អវិជ្ជា+អន្ធការ ] សភាវៈជាគ្រឿងធ្វើនូវងងឹតគឺអវិជ្ជា(១), ងងឹតគឺអវិជ្ជា (អន្ធការ<អន្ធ+ករ+ណ); វិ. **អន្ធំ ករោតិ ឯតេនាតិ> អន្ធការោ** (២); **អវិជ្ជា ឯវ អន្ធការោ> អវិជ្ជន្ធការោ** ។

(១) (២) ចង់ប្រែស័ព្ទនិងវិគ្គហៈជាកត្តុរូប_កត្តុសាធនៈវិញ ក៏បាន ។



**អវិជ្ជមាន** គុ. [ ន+វិទ+យ, ផ្លាស់ទនិងយ>ជ្ជ+មាន ] កាលមិនមាន, កាលមិនដឹង, កាលមិនបាន ។

**អវិជ្ជាខន្ធ** ប៉ុ. [ អវិជ្ជា+ខន្ធ ] កងនៃអវិជ្ជា, គំនរនៃអវិជ្ជា ។

**អវិជ្ជាសង្ខាត** គុ. [ អវិជ្ជា+សង្ខាត ] គឺបណ្ឌិតរាប់ព្រមហើយថាអវិជ្ជា, ពោលគឺអវិជ្ជា ។

**អវិញ្ញូ** គុ. [ ន+វិញ្ញូ ] អ្នកមិនដឹងច្បាស់, ឬមិនមែនអ្នកដឹងច្បាស់ដោយប្រក្រតី (មិនមែនអ្នកប្រាជ្ញ); វិ. **វិជានាតីតិ> វិញ្ញូ** , **វិជានាតិ សីលេនាតិ> វិញ្ញូ** , **ន វិញ្ញូ> អវិញ្ញូ** ។

**អវិតិណ្ណកង្ខ** គុ. [ អវិតិណ្ណ+កង្ខា ] មានសេចក្ដីសង្ស័យមិនទាន់ឆ្លងផុតហើយ (អវិតិណ្ណ<ន+វិ+តរ+ត, ត>ឥណ្ណ); វិ. **អវិតិណ្ណា កង្ខា យស្ស សោ> អវិតិណ្ណកង្ខោ** ។

**អវិតិណ្ណភាវ** ប៉ុ. [ អវិតិណ្ណ+ភាវ ] ភាវៈនៃ...ជា...មិនទាន់ឆ្លងផុតហើយ ។

**អវិទិត** គុ. [ ន+វិទ+ឥ.អា.+ត ] គឺ...មិនដឹងហើយ, ‑មិនប្រាកដហើយ ។

**អវិទូរ** គុ. [ ន+វិទូរ ] ទីមិនឆ្ងាយ (ទីជិត, ជិត) ។ ‑ **ដ្ឋាន** នប៉ុ. ទីមិនឆ្ងាយ ទីជិត ។ ‑ **វិហារ** ប៉ុ. វិហារមិនឆ្ងាយ, វិហារជិត ។

**អវិទ្ទសុ** ប៉ុ. [ ន+វិទ+ទសុ ] អ្នកមិនដឹង, អ្នកមិនចេះ; វិ. **វិទតិ ជានាតីតិ> វិទ្ទសុ** , **ន វិទ្ទសុ> អវិទ្ទសុ** ។

**អវិធេយ្យ** គុ. [ ន+វិធិ+ឯយ្យ ] អវយវៈមិនគួរដើម្បីធ្វើនូវវិធី, ‑ នូវបែបយ៉ាង; វិ. **ន វិធី (កាតុំ) អរហតីតិ> អវិធេយ្យោ** ។

អវយវៈមិនគួរដល់វិធី; ឧ. **ន វិជិស្ស អរហតីតិ> អវិជេយ្យោ** ។

អវិនស្សមាន គុ. [ ន+វិ+នស+យ+មាន ] កាលមិនវិនាស, កាលមិនខូច, កាលមិនបាត់ ។

អវិនាសេន្ត គុ. [ ន+វិ+នស+ណេ+អន្ត ] កាលមិនញ៉ាំង...ឲ្យវិនាស, ... ។

អវិនោទេត្វា អ. [ ន+វិ+នុទ+ណេ+ត្វា ] មិនបន្ទោបង់ហើយ, បន្ទោបង់មិនបានហើយ ។

អវិន្ទន្ត គុ. [ ន+វិន្ទ+អន្ត ] កាលមិនបាន, កាលមិនប្រសព្វ, កាលមិនជួប ។

អវិប្បវាស បុំ. [ ន+វិ+ប+វស+ណ ] កិ.មិននៅប្រាស, ការមិនព្រាត់ប្រាស ។

អវិប្បវុត្តស្សតិ គុ. [ អវិប្បវុត្ត+សតិ ] អ្នកមានសតិមិននៅប្រាសហើយ (មិនប្រាសចាកសតិ); ឧ. **អវិប្បវុត្ថា សតិ យេន សោ> អវិប្បវុត្ថស្សតិ** ។

អវិមំសិត្វា អ. [ ន+មា.មាន+ស+ឥ.អា.+ត្វា(១) ] មិនពិចារណាហើយ, មិន ល្បងហើយ ។

អវិរុជ្ឈិត្វា អ. [ ន+វិ+រុធ+យ+ឥ.អា.+ត្វា ] មិនខុសហើយ, មិនភ្លាត់ហើយ ។

អវិរុទ្ធ គុ. [ ន+វិ+រុធ+ត ] មិនពិរុធហើយ, មិនខុសហើយ, មិនភ្លាត់

---

(១) រូបសិទ្ធិនេះ ចូរមើលបទានុក្រមធម្មបទ ភាគទី៣ ត្រង់អក្សរ " វិ ឬ វី " ។





ហើយ ។ -ត្តា នបុំ. ភាវៈនៃ...ជា...មិនខុសហើយ, -មិនភ្លាត់ហើយ ។

អវិរូឡ្ហធម្ម គុ. [ អវិរូឡ្ហ+ធម្ម ] មានធម៌មិនដុះហើយ, មានធម៌មិនចំរើនហើយ ។

អវិរូហន្ត គុ. [ ន+វិ+រុហ+អន្ត ] កាលមិនដុះ, កាលមិនចំរើន ។

អវិលិត្ត គុ. [ ន+វិ+លិប+ត ] គឺ...មិនប្រឡាក់ហើយ, -មិនជិតហើយ, -មិនជិតជាប់ហើយ, -មិនលាបហើយ ។

អវិវរ គុ. [ ន+វិវរ ] មានប្រហោងមិនមាន, មានចន្លោះមិនមាន ។

អវិវិត្ត គុ. [ ន+វិ+វិច+ត ] មិនស្ងាត់ហើយ ។

អវិស្សជ្ជេត្វា អ. [ ន+វិ+សជ្ជ+ណេ+ត្វា ] មិនចាត់ចែងហើយ, មិនលះបង់ហើយ, មិនចំណាយហើយ, មិនលែងហើយ, ... ។

អវិស្សដ្ឋ គុ. [ ន+វិ+សជ+ត ] គឺ...មិនលះបង់ហើយ ។ - កម្មដ្ឋានតា ឥ. ភាវៈនៃ...ជាអ្នកមានកម្មដ្ឋានមិនលះបង់ហើយ ។

អវិសមិត្វា អ. [ ន+វិ+សម+ឥ.អា.+ត្វា ] មិនរំងាប់ហើយ, មិនសម្រាកហើយ ។

អវិសយ គុ. [ ន+វិសយ ] មិនមែនជាវិស័យ (មិនមែនជាអារម្មណ៍) ។

អវិសយ្ហ គុ. [ ន+វិ+សហ+ណ្យ ] គឺ...គប្បីកំហែងមិនបាន, - មិនគប្បីកំហែងបាន, - មិនគប្បីគំរាមបាន ។

អវិសហន្តី គុ. [ ន+វិ+សហ+អន្ត+ឦ ] កាលមិនអាច, កាលមិនហ៊ាន ។

អវិសហន្ត គុ. [ ន+វិ+សហ+អន្ត ] កាលមិនអាច, កាលមិនហ៊ាន ។

**អវិសារទតា** ឥ. [ អវិសារទ+តា ] ភាវៈនៃ...អ្នកមិនមានសេចក្ដីខ្លាចទៅប្រាសហើយ, . អ្នកមិនមានសេចក្ដីក្លៀវក្លា, . អ្នកមិនមានសេចក្ដីអង់អាច; វិ. **វិគតោ សារទោ ឯតស្មាតិ> វិសារទោ , នត្ថិ វិសារទោ ឯតស្សាតិ> អវិសារទោ, តស្ស ភាវោ> អវិសារទតា** ។ **សារទ**<សំ+រទ+អ, លុបនិគ្គហិតទីឃៈអនៃស>អា=សេចក្ដីខ្លាច ។

**អវិសេស** គុ. [ ន+វិសេស ] មិនវិសេស, មិនប្លែកគ្នា ។

**អវិស្សាសនីយដ្ឋាន** នបុំ. [ អវិស្សាសនីយ+ឋាន ] ទីមិនមែនជាទីតាំងនៃសេចក្ដីស្និទ្ធស្នាល; ទីគឺ...មិនគប្បីស្និទ្ធស្នាល; វិ. **ន វិស្សាសិកព្វន្តិ> អវិស្សាសនីយំ , អវិស្សាសនីយំ ឋានំ> អវិស្សាសនីយដ្ឋានំ** ។

**អវិហញ្ញន្ត** គុ. ( ន+វិ+ហន+យ+អន្ត ) កាលមិនបៀតបៀន, កាលមិនលំបាក, កាលមិនក្ដៅក្រហាយ ។

**អវិហឹសនភាវ** បុំ. [ អវិហឹសន+ភាវ ] ភាវៈគឺកិ.មិនបៀតបៀន, ភាវៈនៃកិ.មិនបៀតបៀន (**អវិហឹសន**<ន+វិ+ហិស+យុ, ចុះនិ.អា.) ។

**អវិហេឋេត្វា** អ. [ ន+វិ+ហេឋ+ណេ+ត្វា ] មិនញុំាង...ឱ្យលំបាកហើយ, មិនបៀតបៀនហើយ ។

**អវិហា** អស.ន ព្រហ្មលោកឈ្មោះអវិហា, ទេវតានៅក្នុងព្រហ្មលោកឈ្មោះអវិហា ។

**អវីចិ** ឥ. ឬ នបុំ. [ ន+វីចិ ] ទីមានសេចក្ដីសុខមិនមាន (នរកឈ្មោះអវីចិ);



វិ. **នត្ថិ សុខំ : វីចិ មេត្ថាតិ> អវីចិ**; (ឈ្មោះរណ្ដៅនរកធំមួយក្នុងពួកនរកទាំង៨រណ្ដៅ) ។ . **បរាយន** គុ. មាននរកឈ្មោះអវីចិជាទីប្រព្រឹត្តទៅក្នុងខាងក្នុង ។ . **មហានិរយសន្តាប** បុំ. កិ.ក្ដៅព្រមនៃនរកធំឈ្មោះអវីចិ, កំដៅនៃនរកធំឈ្មោះអវីចិ ។ . **មហានិរយ** នបុំ. នរកធំឈ្មោះអវីចិ ។ . **សន្តាប** បុំ. សេចក្ដីក្ដៅព្រមនៃនរកឈ្មោះអវីចិ, កំដៅនៃ... ។ **សន្តាប**>សំ+តប+ណ ។

**អវីតរាគ** គុ. [ អវីត+រាគ ] អ្នកមានរាគៈមិនទៅប្រាសហើយ ។

**អវុឌ្ឍិមុខ** នបុំ. [ អវុឌ្ឍិ+មុខ ] មាត់នៃសេចក្ដីមិនចំរើន, ប្រធាននៃសេចក្ដីមិនចំរើន, ប្រធាននៃសេចក្ដីវិនាស ។

**អវេកល្លក្ខណ** បុំ. [ អវេកល្ល+ខណ ] ខណៈគឺ... (នៃ)ភាវៈនៃបុគ្គលមិនវិកល, ខណៈគឺភាវៈនៃសេចក្ដីមិនខ្វះខាត, ខណៈគឺភាវៈនៃបុគ្គលមានអវយវៈមិនខ្វះខាត (**អវេកល្ល**<ន+វេកល្ល); វិ. **វិកលស្ស ភាវោ> វេកល្លំ , នត្ថិ វេកល្លំ អស្សាតិ> អវេកល្លោ** ។

**អវេក្ខតិ** កិ. [ អវ+ឥក្ខ+អ+តិ_វ. ] ក្រឡេកមើល, ពិចារណា ។

**អវេក្ខន្ត** គុ. [ អវ+ឥក្ខ+អន្ត ] កាលក្រឡេកមើល, កាលពិចារណា ។

**អវេច្ចប្បសន្ន** គុ. [ អវេច្ច+បសន្ន ] ពិចារណាហើយទើបជ្រះថ្លា, ជ្រះថ្លាហើយព្រោះពិចារណា (**អវេច្ច**<អវ+ឥ, ឥ>ឯ+ត្វា ,ត្វា>រច្ច, លុបរ=ពិនិត្យ, ពិចារណា, ត្រួតត្រា; **បសន្ន**<ប+សទ+ត, ត>ន្ន=ជ្រះថ្លា, ថ្លា) ។

**អវេច្ចប្បសាទសង្ខាត** គុ. [អវេច្ចប្បសាទ+សង្ខាត] ពោលគឺកិ.ពិចារណាហើយទើបជ្រះថ្លា, ពោលគឺសេចក្ដីជ្រះថ្លាព្រោះពិចារណា ។

**អវេរី** គុ. [ន+វេរី] មិនមែនអ្នកមានពៀរ, អ្នកមិនមានពៀរ; វិ. **វេរំ យស្ស អត្ថីតិ> វេរី , ន វេរី> អវេរី** ។

**អវេរ** គុ. [ន+វេរ] មានពៀរមិនមាន; វិ. **នត្ថិ វេរំ អស្សាតិ> អវេរោ** ។ កិ.មិនមាននៃពៀរ; វិ. **វេរស្ស អភាវោ> អវេរំ** ។

**អវេលា** ឥ. [ន+វេលា] មិនមែនជាវេលា; វិ. **ន វេលា>អវេលា** ។ វេលាមិនគួរ; វិ. **អយុត្តា វេលា> អវេលា** ។

**អវោច** កិ. [អ+វច+អ+អា_ហី, យកអនៃវ>ឱ] បានពោលហើយ ។

**អវោចុំ** កិ. [អ+វច+អ+ឧំ.អជ្ជ.យកអនៃវ>ឱ] បានពោលហើយ ។

**អវ្ហាន** នចុំ. [អា>អ+ហុ ឬ វេហ+យុ] ពាក្យសម្រាប់ហៅ ឬសម្រាប់ស្រែកហៅ (ឈ្មោះ); វិ. **អវ្ហាយតិ ឯតេនាតិ> អវ្ហានំ** ។ កិ.ស្រែកហៅ (ឈ្មោះ); វិ. **អវ្ហាយតេតិ> អវ្ហានំ** ។

**អសក្កច្ចំ** កិវិ. [ន+សក្កច្ច] កិ.មិនអើពើ, កិ.មិនធ្វើ (មិនគោរព, មិនយកចិត្តទុកដាក់, មិនត្រឹមត្រូវ; សក្កច្ច<ស_និ+ករ+ត, ត>ច្ច, ក>ក្កលុប; វិ. **អាទរំ ករណំ> សក្កច្ចំ , ន សក្កច្ចំ> អសក្កច្ចំ** ។

**អសក្ការ** ចុំ. [ន+ស+ករ+ណ] កិ.មិនធ្វើដោយប្រពៃ; វិ. **ន សំ: សម្មា ករយតេតិ> អសក្ការណំ , អសក្ការណំ> អសក្ការោ** ។ គុ. មិនមែនជាគ្រឿងសក្ការៈ, មិនមានគ្រឿងសក្ការៈ ។



**អសក្កុណិត្វា** អ. [ន+សក+ឧណា, អានៃឧណា>ឥ+ត្វា] មិនអាចហើយ ។

**អសក្កោន្ត** គុ. [ន+សក+ឧ+អន្ត] កាលមិនអាច (ឥ.ចុះឮ>អសក្កោន្តី) ។

**អសក្ខរ** គុ. [ន+សក្ខរ] មានក្រួសមិនមាន, មិនមានក្រួស, មិនមានស្ករ, មិនមែនស្ករ ។

**អសក្ខិ** កិ. [អ+សក+អ+ឦ.អជ្ជ, ផ្លាស់ ក>ខ, តម្រួត ក លើ ខ] បានអាចហើយ ។

**អសច្ឆិកត** គុ. [ន+សច្ឆិ+ករ+ត] គឺ...មិនធ្វើឱ្យជាក់ច្បាស់ហើយ ។

**អសជ្ជន្ត** គុ. [ន+សជ្ជ+អន្ត] កាលមិនជាប់, កាលមិនទើសទាក់, កាលមិនចាត់ចែង ។

**អសជ្ឈាយករណ** នចុំ. [ន+សជ្ឈាយ+ករ+យុ] កិ.មិនធ្វើនូវសេចក្ដីស្វាធ្យាយ, កិ.មិនធ្វើនូវការសិក្សា ។

**អសជ្ឈាយន្ត** គុ. [ន+សំ+អធិ, អធិ>អជ្ឈ+ឥ, ឥ>អាយ+អន្ត] កាលមិនស្វាធ្យាយ, កាលមិនសិក្សា, កាលមិនរៀន ។

**អសជ្ឈាយមល** គុ. [អសជ្ឈាយ+មល] មានកិ.មិនស្វាធ្យាយជាមន្ទិល; វិ. **អសជ្ឈាយោ មលំ យស្ស សោ> អសជ្ឈាយ-មលោ** ។

**អសញ្ចិច្ច** អ. [ន+សំ+ចិត+ត្វា, ត្វា>ច្ច, លុបនិងទីបំផុតធាតុ] មិនគិតព្រមហើយ, មិនក្លែងហើយ, មិនល្មើសហើយ ។

**អសញ្ចេតនិក** គុ. [ ន+សញ្ចេតនិក ] មិនមែនអ្នកប្រព្រឹត្តទៅមួយអន្លើដោយចេតនា, មិនប្រកបដោយសេចក្ដីក្លែង, - សេចក្ដីល្មើស, មិនមែនអ្នកក្លែង (សញ្ចេតនិក<សញ្ចេតនា+ណិក) ។

**អសញ្ញានន្ត** គុ. [ ន+សំ+ញា+នា+អន្ត ] កាលមិនដឹងព្រម, កាលចាំមិនបាន, កាលមិនដឹងច្បាស់, កាលមិនស្គាល់ជាក់ ។

**អសញ្ញត** គុ. [ ន+សំ+យម+ត, ផ្លាស់និគ្គហិតនិងយ>ញ្ញ>ញ្ញ, លុបមីចុងធាតុ ] គឺ...មិនសង្រួមហើយ, -មិនប្រុងប្រយ័ត្នហើយ, -មិនទុកដាក់ហើយ។ - **បរិក្ខារវត្ត** ទចុំ. រឿងនៃភិក្ខុអ្នកមានបរិក្ខារមិនចេះទុកដាក់ហើយ, -មិនប្រុងប្រយ័ត្នហើយ ។

**អសណ្ឋហន្ត** គុ. [ ន+សំ+ឋា+អន្ត, ចុះហ.អា ] កាលមិនតាំងទុកព្រម, កាលមិនតាំងនៅដោយល្អ, កាលតាំងនៅមិនបាន, កាលមិនទុកដាក់ ។

**អសតំ** ចុំ. [ អសន្ត+នំ.វិ., ផ្លាស់ ន្ត+នំ>តំ ] នៃអសប្បុរសទាំងឡាយ, នៃបុគ្គលអ្នកមិនស្ងប់ទាំងឡាយ ។

**អសតិ** គុ. [ ន+អស+អន្ត+ស្មិំ.វិ., ផ្លាស់ន្ត+ស្មិំ.វិ>តិ ] កាលមិនមាន ។

**អសតិ** គុ., ឥ. [ សតិ+អភាវ ឬន+សតិ ] កិ.មិនមាននៃសតិ, មិនមានសតិ; វិ. **សតិយា អភាវោ> អសតិ , នត្ថិ សតិ ឯតស្សាតិ> អសតិ** ។ - **អមនសិការវស** ចុំ. អំណាចនៃកិ.មិនធ្វើទុកក្នុងចិត្តព្រោះកិ.មិនមាននៃសតិ ។

**អសត្តឃាដក** ចុំ. [ ន+សត្ត+ហន, ហន>ឃាដ+ណ្វុ ] អ្នកមិនសម្លាប់នូវសត្វ, មិនមែនអ្នកសម្លាប់នូវសត្វ; វិ. **សត្តេ ហនតីតិ> សត្តឃាដកោ , ន សត្តឃាដកោ> អសត្តឃាដកោ** ។



**អសត្ត** គុ. [ ន+សត្ត ឬសជ+ត ] មិនមែនជាសត្វ, អ្នកមិនជាប់ជំពាក់ ។

**អសឋ** ចុំ. [ ន+សឋ+អ ] អ្នកមិនអួត, មិនកោង, មិនល្បួង; វិ. **ន សឋេតីតិ> អសឋោ**; គុ. មិនមែនអ្នកអួតអាង, មិនមែនអ្នកបៀតបៀន, អ្នកមិនមានអំនួត, អ្នកមិនអែបអប ។

**អសទិស** គុ. [ ន+សទិស ] មិនប្រាដកស្មើ, មិនដូចគ្នា, មិនប្រហែលគ្នា, មិនស្រដៀងគ្នា (សទិស<សមាន>ស+ទិស+ក្វិ; វិ. **សមានោ ឋិយ សោ ធិស្សតីតិ> សធិសោ , សមានំ ភត្វា នំ បស្សតីតិ ចា> សធិសោ , ន សធិសោ> អសធិសោ**) ។ - **ទាន** នចុំ. ទានមានទានដទៃប្រាកដស្មើមិនមាន ។ - **រូប** នចុំ. រូបមានរូបដទៃប្រាកដស្មើមិនមាន, មានរូបមិនដូចគ្នា, មានរូបមិនប្រហែលគ្នា, មានរូបមិនស្រដៀងគ្នា ។ - **ទានវត្ថុ** នចុំ. រឿងនៃអសទិសទាន, រឿងនៃទានមានទានដទៃទៀតប្រាកដស្មើមិនមាន ។

**អសទ្ទហន្ត** គុ. [ ន+សំ+ធា+អន្ត ] កាលមិនជឿ ។

**អសទ្ទហិត្វា** [ ន+សំ+ធា+ឥ.អា.+ត្វា ] មិនជឿហើយ ។

**អសទ្ធម្ម** ចុំ. [ អសន្ត+ធម្ម ] ធម៌នៃអសប្បុរស, ធម៌នៃបុគ្គលអ្នកមិនស្ងប់ ឬមិនមែនជាធម៌របស់សប្បុរស (អសទ្ធម្ម); វិ. **អសតំ ធម្មោ> អសទ្ធម្មោ , សតំ ចា ធម្មោ> សទ្ធម្មោ, ន សទ្ធម្មោ> អសទ្ធម្មោ** ។ - **សន្ថវ** ចុំ. សេចក្ដីរាក់រាយគ្រមដោយ

អំណាចនៃអសទ្ធម្ម, សេចក្តីរីករាយព្រមដោយធម៌នៃអសប្បុរស (សន្តរ<សំ+ចុ+ណ) ។

**អស្សទ្ធ** គុ. [ ន+សទ្ធា ] មានសទ្ធាមិនមាន, មិនមានសទ្ធា; វិ. **សទ្ធា យស្ស អត្ថិ តិ> សទ្ធោ , ន សទ្ធោ> អស្សទ្ធោ** (កិ.មិនមាន នៃសទ្ធា, មានសទ្ធាដ៏ធំរើន) ។

**អសនិ** ពុំ.,ឥ. [ អស+អនិ ] សភាវៈ ឬធម្មជាតិដែលទេវតាបាញ់ទៅដើម្បីប្រយោជន៍ដល់រណ្ណះ, រន្ទះ (អាវុធរបស់ព្រះឥន្ទ្រ); វិ. **ភណ្ឌក្ខាយ អស្សតេ ខិបិយតេ ឆេទេហិតិ> អសនិ** ។ - **អគ្គិ** ចុំ. ភ្លើងគឺរន្ទះ, ភ្លើងនៃរន្ទះ ។ - **បាតសទ្ទ** ចុំ. សំឡេងជាទីធ្លាក់ចុះនៃរន្ទះ, សំឡេងគឺរន្ទះធ្លាក់ចុះហើយ ។ - **សទ្ទ** ចុំ. សំឡេងនៃរន្ទះ, សូរនៃរន្ទះ ។

**អសន្តុសក** គុ. [ ន+សំ+តុស+ណ្ហុ ] អ្នកមិនតក់ស្លុតព្រម, មិនមែនអ្នកតក់ស្លុត ។

**អសន្ត** គុ. [ ន+អស+អន្ត ] កាលមិនអាន ។

**អសន្ត** ចុំ. [ ន+សម+ត, ត>ន្ត, លុបទីចំផុតធាតុ ] អ្នកមិនស្ងប់, អ្នកមិនរំងាប់ (អសប្បុរស); គុ. មិនរំងាប់ហើយ, មិនស្ងប់ហើយ ។

**អសន្តុដ្ឋ** គុ. [ ន+សំ+តុស+ត, ត>ដ្ឋ ] មិនត្រេកអរព្រមហើយ, មិនត្រេកអរហើយដោយវត្ថុជារបស់នៃខ្លួន, មិនសន្តោស ។

**អសន្ថុត** គុ. [ ន+សំ+ថុ+ត ] គឺ...មិនត្រេកអរព្រមហើយ, - មិនធ្លាប់រីករាយ



ព្រមហើយ, - មិនសរសើរព្រមហើយ, - មិនធ្លាប់ជិតដិតហើយ, មិនធ្លាប់ម្ហូលមិត្រហើយ ។

**អសប្បាយ** គុ. [ ន+សប្បាយ ] មិនមែនជាសេចក្តីសប្បាយ, មិនជាទីសប្បាយ, មិនមានសេចក្តីសប្បាយ ។

**អសព្ភ** គុ. [ ន+សភា ] មិនមែនវាចាគឺបុគ្គលគប្បីពោលក្នុងទីប្រជុំ, មិនមែនវាចាជាគ្រឿងពោលនៃជនអ្នករំងាប់ (អសប្បុរស, អកុសលធម៌, ធម៌ជាអកុសល) ។

**អសព្ភិវាចា** ឥ. [ អសព្ភិ+វាចា ] វាចាជារបស់នៃអសប្បុរស, វាចារបស់បុគ្គលមិនមែនជាសប្បុរស, វាចានៃអសប្បុរស ។

**អសមត្ថ** គុ. [ ន+សមត្ថ+អ ] អ្នកមិនអាច; វិ. **ន សមត្ថោតិ>អស. មត្ថោ** ។ - **តា** ឥ. ភាវៈនៃ...ជាអ្នកមិនអាច ។ - **ភាវ** ចុំ. ភាវៈនៃ...ជាអ្នកមិនអាច ។ - **ភាវសង្ខាត** គុ. គឺបណ្ឌិតពោលថាភាវៈនៃ...ជា...មិនអាច, ពោលគឺភាវៈនៃ... ។

**អសម** គុ. [ ន+សម ] មានបុគ្គលស្មើមិនមាន, មិនមានបុគ្គលស្មើ (មិនស្មើ); វិ. **នត្ថិ សមោ ឯតស្សាតិ> អសមោ** ។

**អសមធុរ** គុ. [ អសម+ធុរ ] មានធុរៈមានបុគ្គលស្មើមិនមាន; នចុំ. ធុរៈនៃព្រះពុទ្ធមិនមានបុគ្គលស្មើ; វិ. **នត្ថិ ឥតស្ស សមោតិ > អសមោ, អសមំ ធុរំ យស្ស សោ > អសមធុរោ , អសមស្ស ធុរំ> អសមធុរំ** ។

**អសមន្នាហរិត្វា** អ. [ ន+សំ+អនុ+អា.+ហរ+ឥ_អា.+ត្វា ] មិននាំ

មកតាមព្រមហើយ, មិនប្រមូលហើយ, មិនប្រមូលទុកហើយ ។

**អសមបេក្ខន** នបុំ. [ អសម+អបេក្ខន ] កិ.សម្លឹងនូវអារម្មណ៍មិនស្មើ, កិ.មិនសម្លឹងស្មើ (អបេក្ខន<អប+ឥក្ខ+យុ) ។

**អសមសម** គុ. [ អសម+សម ] ស្មើដោយព្រះពុទ្ធមានបុគ្គលស្មើមិនមាន, ស្មើដោយព្រះពុទ្ធមិនមានបុគ្គលស្មើ; វិ. **នត្ថិ សមោ ឯតស្សាតិ> អសមោ, អសមេន សមោ> អសមសមោ** ។

**អសមាចរន្ត** គុ. [ ន+សំ+អា+ចរ+អន្ត ] កាលមិនប្រព្រឹត្តតាម, កាលមិនប្រព្រឹត្តទូទៅព្រម, កាលមិនប្រព្រឹត្តដោយប្រពៃ ។

**អសមាហិត** គុ. [ ន+សមាហិត ] មិនតាំងមាំហើយ, មិនដំកល់ខ្ជាប់ហើយ, មិនមែនអ្នកមានចិត្តដំកល់មាំ, មានចិត្តមិនដំកល់ខ្ជាប់ហើយ (សមាហិត<សំ+អា+ធា+ត) ។

**អសមុច្ឆិន្ន** គុ. [ ន+សំ+ឧ+ឆិទ+ត ] គឺ...មិនកាត់ឡើងព្រមហើយ, . មិនកាត់ផ្តាច់ហើយ, . មិនដកឡើងហើយ ។ . **វដ្តពីជ** គុ. មានពូជនៃវដ្តៈមិនកាត់ឡើងព្រមហើយ, . មិនផ្តាច់ចង់ហើយ ។

**អសមុដ្ឋាបេន្ត** គុ. [ ន+សំ+ឧ+ឋា+ណាបេ+អន្ត ] កាលមិនញុំាង...ឱ្យតាំងឡើងព្រម, . ឱ្យកើត ។

**អសមុទាចរណ** នបុំ. [ ន+សំ+ឧ+ទ.អា.+អា+ចរ+យុ ] កិ.មិនប្រព្រឹត្តទូទៅក្នុងខាងលើព្រម, កិ.មិនស្រែកហៅ ឬមិនហៅរក, កិ.មិនកំរើក, កិ.មិនពុះពោរឡើង ឬមិនដាលឡើង, កិ.មិនប្រាលឡើង ។

**អសមុទាចរ** បុំ. [ ន+សំ+ឧ+ទ.អា.+អា+ចរ+ណ ] (ប្រែដូច «អសមុទាចរណ») ។



**អស្មិមាន** បុំ. [ អស្មិ+មាន ] មានះប្រព្រឹត្តទៅដោយអាការថាអញមាន, ឬសេចក្តីប្រកាន់ថាអញមាន, មានះថាអញមាន (អស្មិមានះ); វិ. **អស្មីតិ អាការេន បវត្តោ មានោ> អស្មិមានោ, អស្មីតិ ចា មានោ> អស្មិមានោ** ។ . **មត្ត** គុ. អាការគ្រាន់តែ ឬត្រឹមតែអស្មិមានះ ។

**អសម្បដិច្ឆន្ត** គុ. [ ន+សំ+បដិ+ឥស+អន្ត ] កាលមិនទទួលព្រម, កាលមិនប្រាថ្នាព្រមចំពោះ ។

**អសម្បត្ត** គុ. [ ន+សំ+បទ+ត ] មិនដល់ព្រមហើយ, មិនទាន់ហើយ ។

**អសម្ពន្ធ** គុ. [ ន+សំ+ពន្ធ+អ ] មិនចងព្រមហើយ, មិនជាប់ព្រមហើយ, មិនទាក់ទងហើយ ។

**អសម្ភិន្ន** គុ. [ ន+សំ+ភិទ+ត ] មិនបែកព្រមហើយ, មិនធ្លាយព្រមហើយ, មិនច្រឡូកច្រឡំហើយ (សុទ្ធ) ។ . **ខីរបាយាស** បុំ. បាយបាយាសគឺបុគ្គលចំអិនដោយទឹកដោះស្រស់សុទ្ធ, បាយបាយាសដ៏លាយដោយទឹកដោះស្រស់សុទ្ធ (បាយបាយាសគឺបុគ្គលចំអិនហើយដោយទឹកដោះស្រស់មិនលាយដោយទឹក) ។

**អសម្មជ្ជិតា** ឥ. [ ន+សំ+មជ្ជ+ឥ.អា.+តា ] មិនសំអាតហើយ, មិនបោសហើយ, មិនជំរះហើយ ។

**អសម្មិស្ស** គុ. [ ន+សំ+មិស+អ ] មិនច្រឡំគ្នា, មិនច្រឡំព្រម, មិនលាយឡំ, មិនច្របូកច្របល់ ។

**អសម្មោហសម្បជញ្ញ** នប៉ុ. [ អសម្មោហ+សម្បជញ្ញ ] ភាវៈនៃសេចក្ដីដឹងខ្លួនទៅគ្រប់ដោយសេចក្ដីមិនវង្វេងព្រម(១) ឬសេចក្ដីដឹងច្បាស់ដោយសេចក្ដីមិនវង្វេង(២) (អសម្មោហ<ន+សំ+មុហ+ណ=វិ. **អសម្មុយ្ហនំ**> **អសម្មោហោ** , សម្បជញ្ញ<សម្បជាន+ណ្យ=វិ. **សម្បជានាតីតិ**> **សម្បជានំ** , **តស្ស ភាវោ**> **សម្បជញ្ញំ** , **សម្បជានំ ឯវ វា**> **សម្បជញ្ញំ**) ។

**អសរណភាវ** ប៉ុ. [ អសរណ+ភាវ ] ភាវៈនៃ...ជាអ្នកមិនមានសេចក្ដីទីពឹង, ភាវៈនៃកិ.រឭកមិនបាន, ភាវៈគឺកិ.នឹកមិនឃើញ ។

**អសរីរ** គុ. [ ន+សរីរ ] មានសរីរៈមិនមាន, មិនមានសរីរៈ ។

**អសល្លក្ខណាការ** ប៉ុ. [ អសល្លក្ខណ+អាការ ] អាការគឺកិ.មិនកំណត់ព្រម, អាការគឺកិ.កំណត់មិនបាន, (អសល្លក្ខណ<ន+សំ+លក្ខ+យុ) ។

**អសល្លក្ខេត្វា** អ. [ ន+សំ+លក្ខ+ឯ+ត្វា ] កំណត់ព្រមមិនបានហើយ, មិនកំណត់ព្រមហើយ ។

**អសហន្ត** គុ. [ ន+សហ+អន្ត ] កាលមិនអត់ធន់, កាលអត់ទ្រាំមិនបាន, កាលមិនអត់សង្កត់ ។

**អសង្ខត** គុ. [ ន+សំ+ករ, ករ>ខរ+ត, លុបរ ] គឺបច្ច័យមិនធ្វើព្រមហើយ, គឺ...មិនតាក់តែងហើយ ។

**អសង្ខេយ្យ** នប៉ុ. [ ន+សំ+ខា+ឯយ្យ ] គឺបុគ្គលមិនគប្បីរាប់បាន, កាល

(១) (២) ប្រែជា ខ្ទង់សមាស វិញក៏បាន ។



គឺបុគ្គលមិនគប្បីអាចដើម្បីរាប់បាន, អសង្ខេយ្យ (លេខ ១ មានសូន្យ ១៤០; ខ្លះថា ១៤៥) អភិ..សុចិ ។

**អសំវរ** ប៉ុ. [ ន+សំ+វរ+អ ] កិ.មិនសង្រួម, សេចក្ដីមិនសង្រួម, ការមិនរាំង ។ - ទ្វារ នប៉ុ. ទ្វារមិនជាទីសង្រួម, ទ្វារគឺបុគ្គលមិនគប្បីសង្រួម; គុ. មានទ្វារមិនសង្រួម ។

**អសំវុត** គុ. [ ន+សំ+វុ+ត ] គឺបុគ្គលមិនសង្រួមហើយ, - មិនរាំងហើយ, - មិនបិទហើយ ។

**អសំសដ្ឋ** គុ. [ ន+សំ+សជ+ត ] មិនលាយហើយ, មិនច្រឡូកច្រឡំហើយ ។

**អសំហារិយ** គុ. [ ន+សំ+ហរ+ណ្យ+ឥ.អា. ] គឺបុគ្គលមិនគប្បីនាំទៅព្រម, គឺ...មិនគប្បីជញ្ជូនទៅបាន ។

**អសាទុ** គុ. [ ន+សទ+ណុ ] គឺបុគ្គលមិនគប្បីត្រេកអរ, មានរសគឺបុគ្គលមិនគប្បីត្រេកអរ, មិនជាទីត្រេកអរ, មានរសមិនឆ្ងាញ់ ។

**អសាធារណ** គុ. [ ន+សហ+ធារណ ឬន+សម, សម>ស+អា+ធរ+យុ ] ធម្មជាតមិនប្រព្រឹត្តទៅមួយអន្លើដោយកិ.ទ្រទ្រង់ ឬសភាវៈជាទីដែលគេមិនទ្រទ្រង់ទូទៅស្មើ (មិនសាធារណ, មិនទូទៅ); វិ. **ន សហ ធារណេន បក្កតីតិ**> **អសាធារណំ** , **ន សមំ អាធារិយន្តិ តស្មិន្តិ វា**> **អសាធារណោ** ។

**អសាធុ** ប៉ុ. [ ន+សាធ+ឧ ] អ្នកមិនញុំាងប្រយោជន៍ឱ្យសម្រេច (អសប្បុរស, មនុស្សមិនល្អ); វិ. **ន អត្ថំ សាធេតីតិ**> **អសាធុ** ; នប៉ុ.

កម្មមិនញុាំងប្រយោជន៍ឱ្យសម្រេច, កម្មមិនល្អ, មិនប្រពៃ ។

**អសារក** គុ. [ ន+សារ+ក ] មានសារៈមិនមាន, មានខ្លឹមមិនមាន, មិនមានខ្លឹម; វិ. **នត្ថិ សារោ អស្សាតិ> អសារកោ** ។

**អសារ** គុ. [ ន+សារ ] ធម៌មានសារៈ (ខ្លឹម) មិនមាន ។ **- ទស្សី** ចុំ. អ្នកមានកិ.ឃើញនូវធម៌មិនមានសារៈជាប្រក្រតី ។

**អសារុប្ប** គុ. [ ន+សារុប្ប ] មានភាវៈនៃកម្មប្រព្រឹត្តទៅមួយអន្លើដោយរូបមិនមាន, មិនមានភាវៈនៃកម្មដ៏សមគួរ (មិនសមគួរ, សេចក្តីមិនសមគួរ); វិ. **សហ រូបេន ចត្តតីតិ> សរូបំ,តស្ស ភាវោ> សារុប្បំ , នត្ថិ សារុប្បំ ឯតស្សាតិ> អសារុប្បំ** ។

**អសាហស** នចុំ. [ ន+សាហស ] មិនប្រញាប់ប្រញាល់, មិនរហ័ស, មិនរួសរាន់, មិនមានអាជ្ញា, មិនមានសេចក្តីកំហែង ។

**អសិ** ចុំ. [ អស+ឥ ] គ្រឿងប្រហារដែលជនគ្រវែងទៅ (ដាវ); វិ. **អស្សតេ ខិបិយតេតិ> អសិ** ។ **- អាទិ** គុ. (អាវុធ) មានដាវជាដើម ។ **- ធារា** ឥ. មុខនៃដាវ ។ **- ថរុ** ចុំ. ដងនៃដាវ ។ **- សត្តិតោមរាទិ** គុ. មានដាវនិងលំពែង និងលំពែងស្នែងក្របីជាដើម ។ **- ហត្ថ** គុ. មានដាវក្នុងដៃ ។

**អសិក្ខិត** គុ. [ ន+សិក្ខ+ឥ.អា.+ត ] គឺ...មិនសិក្សាហើយ, មិនមែនអ្នកសិក្សាហើយ, អ្នកមិនធ្លាប់បានសិក្សាហើយ ។

**អសីតិ** ប.សំ. ប៉ែតសិប (៨០) ។ **- កប្ប** នចុំ. កប្ប ៨០ ។ **- កោដិធន** នចុំ. ទ្រព្យមានកោដិ ៨០ជាប្រមាណ (ទ្រព្យ៨០កោដិ) ។ **- កោដិវិភវ** គុ. មានភោគៈគឺបុគ្គលគប្បីប្រើប្រាស់មានកោដិ៨០ជាប្រមាណ, មានសម្បត្តិ ៨០កោដិ ។ **- កោដិសហស្ស** នចុំ. ពាន់នៃកោដិ ៨០ (ប្រាំបីម៉ឺនកោដិ) ។ **- មហាថេរ** ចុំ. ព្រះថេរៈទាំង៨០ ។ **- មហាសាវកបរិវុត** គុ. គឺសាវកធំ៨០ ចោមរោមហើយ, - ហែហមហើយ ។ **- វស្សសហស្ស** នចុំ. ពាន់នៃឆ្នាំ ៨០ ។ **- សកដមត្ត** គុ. មានរទេះ៨០ជាប្រមាណ ។ **- សហស្សបុត្ត** ចុំ. កូនមានពាន់៨០ ជាប្រមាណ ។ **- ហត្ថុព្វេធ** គុ. មានកំពស់នៃហត្ថ៨០, មានកិ.ខ្ពស់ឡើងរស់ទីមានហត្ថ៨០ ជាប្រមាណ, មានចំណែកខ្ពស់មានហត្ថ៨០ ជាប្រមាណ (កំពស់៨០ហត្ថ) ។



**អសីត្យានុព្យញ្ជនសិរីសោភគ្គ** គុ. មានភាវៈនៃចំណែកដ៏ល្អនៃសិរីគឺអនុព្យញ្ជន៨០ (សោភគ្គ<សុភាគ+ណ្យ; វិ. **សុភាគស្ស ភាវោ> សោភគ្គំ**) ។

**អសីលិយ** នចុំ. [ អសីល+ឥយ ] ភាវៈនៃបុគ្គលមិនមានសីល; វិ. **នត្ថិ សីលំ ឯតស្សាតិ> អសីលោ, តស្ស ភាវោ> អសីលិយំ** ។

**អសុក** វិ.ស.និ. [ អមុ>អសុ+ក ] ឯនោះ, ឯណោះ ។ **- ឥរិយាបថ** ចុំ. ឥរិយាបថឯណោះ ។ **- កាល** ចុំ. កាលឯណោះ ។ **- គាមគមនដ្ឋាន** នចុំ. ទីជាទីទៅកាន់ស្រុកឯណោះ ។ **- កីឡា** ឥ. ទីជាទីលេងឯនោះ ។ **- កុល** នចុំ. ត្រកូលឯនោះ ។ **- ដ្ឋាន** នចុំ. ទីឯនោះ ។

- **រោគ** បុំ. រោគឯណោះ ។ - **វិថិ** ឥ. ថ្នល់ឯនោះ ។ - **វេលា** ឥ. វេលាឯនោះ ។ ល ។

**អសុចិ** គុ., បុំ. [ ន+សុចិ ] មិនស្អាត, សេចក្តីមិនស្អាត ។ - **ខាទក** បុំ. អ្នកទំពាស៊ីនូវវត្ថុមិនស្អាត (ខាទក<ខាទ+ណ្វុ); វិ. **អសុចឹ ខាទតីតិ> អសុចិខាទកោ** ។ - **ឃដ** បុំ. ក្អមពេញដោយវត្ថុមិនស្អាត; វិ. **អសុចីហិ បូរោ ឃដោ> អសុចិឃដោ** ។ - **ជេគុច្ឆបដិកូល** គុ. ជារបស់មិនស្អាតនិងជារបស់គួរខ្ពើមនិងជារបស់បដិកូល, ជារបស់មិនស្អាតនិងជារបស់បដិកូលគួរខ្ពើម ។ - **មក្ខិត** គុ. គឺអសុចិប្រឡាក់ហើយ, ដែលប្រឡាក់ហើយដោយវត្ថុមិនស្អាត ។

**អស្សុណន្តិ** គុ. [ ន+សុ+ណា+អន្ត+ឦ ] កាលមិនស្តាប់, កាលមិនឮ ។

**អស្សុណិត្វា** អ. [ ន+សុ+ណា+ត្វា ] មិនស្តាប់ហើយ, មិនឮហើយ ។

**អស្សុត** គុ. [ ន+សុ+ត ] គឺ...មិនស្តាប់ហើយ, - មិនឮហើយ ។ - **បុព្វ** គុ. គឺ...មិនធ្លាប់ឮហើយ ។ - **បុព្វត្ត** នបុំ ភាវៈនៃ...ជា... គឺ...មិនធ្លាប់ស្តាប់ហើយ, - មិនធ្លាប់ឮហើយ ។

**អសុត្តមយ** គុ. [ ន+សុត្តមយ ] មិនមែនជារបស់សម្រេចហើយដោយអំបោះ ឬមិនមែនជាវិការៈនៃអំបោះ; វិ. **សុត្តេន និព្វត្តោ> សុត្តមយោ , សុត្តស្ស វិការោ វា> សុត្តមយោ , ន សុត្តមយោ> អសុត្តមយោ** ។

**អស្សុត្វា** អ. [ ន+សុ+ត្វា ] មិនស្តាប់ហើយ, មិនឮហើយ ។



**អសុទ្ធតរ** គុ. [ ន+សុទ្ធតរ ] មិនស្អាតជាង, មិនស្អាតដោយវិសេស, មិនម៉ត់ចត់ជាង, មិនម៉ត់ចត់ដោយវិសេស ។

**អសុទ្ធត្ត** នបុំ. [ អសុទ្ធ+ត្ត ] ភាវៈនៃ...ជា...មិនស្អាត ។

**អសុទ្ធិ** ឥ. [ ន+សុទ្ធិ ] សេចក្តីមិនស្អាត, សេចក្តីមិនបរិសុទ្ធ ។

**អសុភ** គុ. [ ន+សុភ ] មិនល្អ (អសុភ) ។ - **កម្មដ្ឋាន** នបុំ. កម្មដ្ឋានមានអសុភជាអារម្មណ៍ ។ - **ជ្ឈាន** នបុំ. ឈានមានអសុភជាអារម្មណ៍ ។ - **បដិកូលកម្មដ្ឋាន** នបុំ. កម្មដ្ឋានមានអសុភជារបស់បដិកូលជាអារម្មណ៍ ។ - **សញ្ញា** ឥ. សញ្ញា (សេចក្តីសំគាល់) ថាអារម្មណ៍មិនល្អ, សេចក្តីសំគាល់ថាមិនល្អ ។

**អសុភានុបស្សី** បុំ. [ អសុភ+អនុ+ទិស, ទិស>បស្ស+ណី ] អ្នកមានកិ. ឃើញរឿយៗនូវអារម្មណ៍មិនល្អជាប្រក្រតី (អ្នកឃើញតាមនូវអារម្មណ៍ថាមិនល្អ); វិ. **អសុភំ អនុបស្សិតុំ សីលមស្សាតិ> អសុភានុបស្សី** ។

**អសុរ** បុំ. [ ន+សុរ ] អ្នកមិនមែនជាទេវតា (អសុរ) ។ - **កញ្ញា** ឥ. នាងកញ្ញានៃអសុរ ។ - **ជេដ្ឋក** បុំ. អសុរជាធំជាង, អសុរជាធំបំផុត, អសុរជាច្បង ។ - **បុរ** នបុំ. បុរីនៃអសុរ ។ - **ពល** នបុំ. កំឡាំងនៃអសុរ, ពលនៃ... ។ - **ភវន** នបុំ. ភពនៃអសុរ, ប្រទេសជាទីកើតនៃអសុរ, លំនៅនៃអសុរ ។

**អសុរិន្ទ** [ អសុរ+ឥន្ទ ] បុំ. អសុរជាធំ; គុ. មានអសុរជាធំ, ជាធំជាងអសុរ ។

**អសុសិរ** គុ. [ ន+សុសិរ ] មិនមានប្រហោង, មិនមានរន្ធ; វិ. សុសិ យស្ស អត្ថីតិ> សុសិរោ, ន សុសិរោ> អសុសិរោ ។

**អសេក្ខមុនិ** ចុំ. [ អសេក្ខ+មុនិ ] មុនីមិនមែនអ្នកមានសេចក្ដីសិក្សា, មុនីអ្នកមិនមានការសិក្សា, មុនីជាអសេក្ខៈ, អសេក្ខមុនី (អ្នកប្រាជ្ញមានការសិក្សាដ៏ចំរើន) ។

**អសេវិត** គុ. [ ន+សេវ៍+ឥ+ត ] គឺ...មិនសេពហើយ, .មិនសេពគប់ហើយ, .សេពគប់មិនបានហើយ ។

**អសេសេត្វា** អ. [ ន+សិស+ណេ+ត្វា ] មិនញ៉ាំង...ឱ្យសល់ហើយ, មិនឱ្យសេសសល់ហើយ ។

**អសោក** គុ. [ ន+សោក ] អ្នកមានសេចក្ដីសោកមិនមាន, អ្នកមិនមានសេចក្ដីសោក; វិ. នត្ថិ សោកោ ឯតស្សាតិ> អសោកោ ។

**អសោចន្ត** គុ. [ ន+សុច+អន្ត ] កាលមិនសោយសោក, កាលមិនសោកស្ដាយ ។

**អសោចំ** គុ. [ ន+សុច+អន្ត+សិ.វិ., ផ្លាស់ន្ត+សិ.វិ.>អំ ] កាលមិនសោក, កាលមិនសោកខ្លួនឯង ។

**អសោចាបយំ** គុ. [ ន+សុច+ណាបយ+អន្ត+សិ.វិ. ] កាលមិនញ៉ាំង...ឱ្យសោក, .ឱ្យសោកស្ដាយ ។ រូបសិទ្ធិដូច អសោចំ ។

**អសោធេត្វា** អ. [ ន+សុធ+ណេ+ត្វា ] មិនញ៉ាំង...ឱ្យម៉ត់ចត់ហើយ, .ឱ្យស្អាតហើយ, មិនជំរះហើយ ។

**អសោភណ** គុ. [ ន+សុភ+យុ ] មិនល្អ ។



**អស្ស** កិ. [ អស+អ+ឯយ្យ ] គប្បីមាន, គប្បីជា, ... ។

**អស្ស** ចុំ. [ អស+អ ឬន+សិ+អ ] សត្វតែងស៊ី ឬសត្វមិនដេក (សេះ); វិ. អសតិ ភក្ខតីតិ> អស្សោ, ន សយតីតិ វា> អស្សោ ។ .ជាតិ ឥ. ជាតិនៃសេះ ។ .តរ ត្តុំ. សេះកន្លងនូវសេះ (សេះអស្សតរ); វិ. អស្សំ តរតីតិ> អស្សតរោ ។ .តរី ឥ. មេសេះអស្សតរ ។ .បិដ្ឋ នចុំ. ខ្នងនៃសេះ ។ .ពន្ធាទិ គុ. មានជនអ្នកចងនូវសេះជាដើម ។ .រក្ខណាទិ គុ. (កិច្ច) មានកិ.រក្សានូវសេះជាដើម ។ .រូបក នចុំ. រូបនៃសេះ ឬរូបប្រៀបនៃសេះ ។ .លណ្ឌ នចុំ. គូថនៃសេះ ឬអាចម៍នៃសេះ ។ .វាណិជក ចុំ. ជនអ្នកជួញនូវសេះ, ឈ្មួញនៃសេះ ។ .វាណិជគេហ នចុំ. ផ្ទះនៃជនអ្នកជួញនូវសេះ ។ .វាហនៈ នចុំ. វាហនៈគឺសេះ ។ .សត នចុំ. រយនៃសេះ ។ .ទម្មសារថិ ចុំ. សារថីអ្នកទូន្មាននូវសេះ ។

**អស្សាជានិយ** ចុំ. [ អស្ស+អាជានិយ ] សេះដឹងនូវហេតុនិងមិនមែនហេតុទូទៅ ឬដោយរហ័សរហួន, សេះអាជានេយ្យ (អាជានិយ<អា+ញា, ញា>ជា+អានិយ ឬណ្យ= វិ. អា ភុសោ ការណាការណំ ជានាតីតិ> អាជានិយោ ។ ន័យខ្លះ អាជានេយ្យ សេះអាចក្នុងកិ.ដឹងនូវហេតុដ៏រហ័ស ។ ឯយ្យបច្ច័យ ) ។

**អស្សមណ** ចុំ. [ ន+សម+យុ ឬន+សមណ ] អ្នកមិនរំងាប់, អ្នកមិនស្ងប់, អ្នកមិនមែនជាសមណៈ; វិ. សមេតីតិ> សមណោ, ន

**សមណោ> អស្សមណោ** ។

**អស្សម** ចុំ. [ អា+សម+ណ ] ប្រទេសជាទីរងាប់ទូទៅ ឬប្រទេសជាទីញ៉ាំងរាគាទិក្កិលេសឱ្យរម្ងាប់ដោយក្រៃលែង (អាស្រម); វិ. **អាសមេតិ ឯត្ថាតិ> អស្សមោ, អា ភុសោ សមេន្តិ ឯត្ថ រាគាទយោតិ វា> អស្សមោ** ។ - **បទ** នចុំ. ទីជាទីដល់គឺអាស្រម, អាស្រមបទ ។

**អស្សាទេតិ** កិ. [ អា+សទ+ណេ+តិ.វ. ] ត្រេកអរ, ញ៉ាំង...ឱ្យត្រេកអរ ។

**អស្សាទេន្ត** គុ. [ អា+សទ+ណេ+អន្ត ] កាលត្រេកអរ, កាលញ៉ាំង...ឱ្យត្រេកអរ ។

**អស្សាមិក** គុ. [ ន+សាមិក ] មានស្វាមីមិនមាន, មានម្ចាស់មិនមាន, ឥតម្ចាស់; វិ. **នត្ថិ សាមិកោ អស្សាតិ> អស្សាមិកោ** ។ ឥ. អស្សាមិកា ។ មិនមែនជាម្ចាស់; វិ. **នសាមិកោ> អស្សាមិកោ** ។ - **ភាវ** ចុំ. ភាវៈនៃ...ជាអ្នកមានស្វាមីមិនមាន ។

**អស្សារោហ** ចុំ. [ អស្ស+អា+រុហ+ណ ] អ្នកឡើងកាន់សេះ, អ្នកជិះនូវសេះ; វិ. **អស្សំ អារុហតីតិ> អស្សារោហោ** ។

**អស្សាសតរ** គុ. [ អស្សាស+តរ ] កិ.ដកដង្ហើមស្រួលជាង, កិ.ត្រេកអរជាង, មានសេចក្តីធូរចិត្ត (**អស្សាស**<អា+សស+អ) ។

**អស្សាសថ** កិ. [ អា+សស+អ+ថ.ប. ] ចូរដកដង្ហើមចេញ, ចូរត្រេកអរ, ចូរល្ហើងលោម ។



**អស្សាសិយមាន** គុ. [ អា+សស+ឥ.អា+យ+មាន ] គឺ...កាលឱ្យដកដង្ហើមចេញ, -កាលឱ្យត្រេកអរ, -កាលល្ហើងលោម, -កាលឱ្យធូរចិត្ត ។

**អស្សាសេត្វា** អ. [ អា+សស+ណេ+ត្វា ] ញ៉ាំង...ឱ្យដកដង្ហើមចេញហើយ, -ឱ្យត្រេកអរហើយ, ល្ហើងលោមហើយ, ឱ្យធូរចិត្តហើយ ។

**ឥតោ** អ.ស. [ ឥម+តោ>ឥតោ ] អំពី...នេះ, ខាងនេះ, ក្នុងនេះ ។

**ឥត្ថំ** គុ. [ ឥម+ថំ ] ប្រការនេះ, ដោយប្រការនេះ ។ល។; វិ. អយំ បការោ> ឥត្ថំ ។ល។ - នាម គុ. មានប្រការនេះជាឈ្មោះ, មានឈ្មោះដោយប្រការៈនេះ ។ - តា ឥ. ភាវៈនៃ...ជា...ដោយប្រការនេះ, ភាវៈនៃប្រការនេះ ។

**ឥត្ថាគារ** ទចុំ. [ ឥត្ថិ+អគារ ] ផ្ទះនៃស្ត្រី, ផ្ទះជាទីនៅនៃស្ត្រី, ផ្ទះដែលច្រឡូកច្រឡំដោយស្ត្រី, ស្ត្រីស្នំ ។

**ឥត្ថី** ឥ. [ ឥស+ត្ថី ] (នារី) ដែលបុរសតែងប្រាថ្នា ឬ ដែលបុរសគប្បីប្រាថ្នា

(ស្ត្រី); វិ. ឥច្ឆិយតីតិ> ឥត្ថី, ឥច្ឆិតព្វា ឋា> ឥត្ថី ។ - កុត្ត នចុំ. លំនាំជាទីធ្វើនូវកិ.រាំនៃស្ត្រី, លំនាំជាទីធ្វើនូវកិ. កែក្រាយនៃស្ត្រី, មាយានៃស្ត្រី ។ - **បុរិសគោមហិសកុក្កុដាទិ** គុ. មានស្ត្រីនិងបុរសនិងគោនិងក្របីនិងមាន់ជាដើម ។ - **បុរិសសទ្ទាទិ** គុ. មានសំឡេងនៃស្ត្រីនិងបុរសជាដើម ។ - **ភាវ** ចុំ. ភាពនៃស្ត្រី, ភាវៈនៃ...ជាស្ត្រី ។ - **រតន** នចុំ. កែវគឺស្ត្រី, ស្ត្រីដូចជាកែវ ។ - **មាយា** ឥ. មាយានៃស្ត្រី, ពុតនៃស្ត្រី ។ - **លិង្គ** នចុំ. ភេទនៃស្ត្រី ។ - **រូប** នចុំ. រូបនៃស្ត្រី ។ - **លីឡា** ឥ. លីលានៃស្ត្រី, លំនាំនៃស្ត្រី, កិ.កែក្រាយនៃស្ត្រី ។ - **សធ** នចុំ. រយនៃស្ត្រី ។ - **សមីប** គុ. ទីជិតនៃស្ត្រី ។

**ឥទានិ** កា.ស. [ ឥម+ទានិ ] ក្នុងកាលនេះ, ក្នុងពេលនេះ, ក្នុងកាលឥឡូវនេះ, ក្នុងកាលអម្បាញ់មិញ ។

**ឥទ្ធ** គុ. [ ឥធ+ត ប្ច. ] សម្រេច, ដែលសម្រេច, ស្តុកស្តម្ភ, មាំមួន ។

**ឥទ្ធានុភាវ** ចុំ. [ ឥទ្ធិ+អានុភាវ ] អានុភាពនៃ ឫទ្ធិ ។

**ឥទ្ធិ** ឥ. [ ឥធ+តិ, តិ> ទ្ធិ លុបទីបំផុតនៃធាតុ ] (ធម្មជាតិ) ជាគ្រឿងសម្រេច (ឫទ្ធិ); វិ. **ឥជ្ឈតិ ឯកាយាតិ> ឥទ្ធិ** ។ - **ប្បត្ត** គុ. អ្នកដល់ហើយនូវឫទ្ធិ, អ្នកមានឫទ្ធិដល់ហើយ; វិ. **ឥទ្ធិំ បត្តោ> ឥទ្ធិប្បត្តោ, ឥទ្ធិ បត្តា យស្ស សោ> ឥទ្ធិប្បត្តោ** ។ - **ប្បាដិហារិយា-នុសាសនី** ឥ. អនុសាសនីគឺឥទ្ធិប្បាដិហារ្យ, បាដិហារ្យគឺឫទ្ធិ និង



វាចាជាគ្រឿងប្រៀនប្រដៅតាម, វាចាជាគ្រឿងប្រដៅរឿយៗ ដោយបាដិហារ្យ ដែលសម្រេចដោយឫទ្ធិ ។ - **បាទ** ចុំ. ឥទ្ធិបាទ, ធម៌ជាទីតាំងប្រព្រឹត្តទៅនៃឫទ្ធិ, គុណជាគ្រឿងដល់នៃឫទ្ធិ, គុណជាគ្រឿងឱ្យដល់នូវសេចក្តីសម្រេច ។ - **ពល** នចុំ. កំឡាំងនៃឫទ្ធិ ។ - **វិសយ** ចុំ. វិស័យនៃឫទ្ធិ ។

**ឥទ្ធិម** គុ. [ ឥទ្ធិ+មន្តុ ] អ្នកមានឫទ្ធិ; វិ. **ឥទ្ធិ យស្ស អត្ថីតិ> ឥទ្ធិមា** ។

**ឥទ្ធិមន្ត** គុ. [ ឥទ្ធិ+មន្តុ ] អ្នកមានឫទ្ធិ; វិ. **ឥទ្ធិ យេសមត្ថីតិ >ឥទ្ធិមន្តោ** ។

**ឥទ្ធិមយ** គុ. [ ឥទ្ធិ+មយ ] ដ៏សម្រេចហើយដោយឫទ្ធិ, ជាវិការៈនៃឫទ្ធិ; វិ. **ឥទ្ធិយា និព្វត្តំ> ឥទ្ធិមយំ, ឥទ្ធិយា វិការោ> ឥទ្ធិមយោ** ។ - **បត្តចីវរ** នចុំ. បាត្រនិងចីវរដ៏សម្រេចហើយដោយឫទ្ធិ ។ - **បត្តចីវរាគមន** នចុំ. កិ.មកនៃបាត្រនិងចីវរដ៏សម្រេចហើយដោយឫទ្ធិ ។ - **បត្តចីវរធរ** គុ. អ្នកទ្រទ្រង់នូវបាត្រនិងចីវរជាវិការៈនៃឫទ្ធិ ។ - **រូប** នចុំ. រូបដ៏សម្រេចហើយដោយឫទ្ធិ ។

**ឥធ** អ.ស. [ ឥម+ធ ] ក្នុង...នេះ ។ - **លោកត្តភាវ** ចុំ. អត្តភាពក្នុងលោកនេះ ។ - **លោកត្ថ** ចុំ. ប្រយោជន៍ក្នុងលោកនេះ ។ - **លោកបរលោកត្ថ** ចុំ. ប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ ។ - **លោកបរលោកសុខាវហន** នចុំ. កិ.នាំមកនូវសុខក្នុងលោកនេះនិងលោកខាងមុខ ។ - **លោកសង្គហ** ចុំ. សេចក្តីសង្គ្រោះក្នុង

លោកនេះ ។ – **អាគតត្ថ** នបុំ. ភាវៈនៃ...ជាអ្នកមកហើយក្នុងទីនេះ ។

**ឥន្ទក** បុំ. [ ឥន្ទ+ណ្វុ ] បុគ្គលជាធំ, ទេវបុត្រឈ្មោះឥន្ទកៈ ។

**ឥន្ទខីល** បុំ. [ ឥន្ទ+ខីល ] សសរខឿន, សសរគោល (គោលរបស់ព្រះឥន្ទ) ។ – **សទិស** គុ. ប្រាកដស្មើដោយសសរខឿន ។ – **ឧបម** គុ. មានឧបមាដោយសសរខឿន, មានសសរខឿនជាគ្រឿងប្រៀប ។

**ឥន្ទគោបក** បុំ. [ ឥន្ទ+គោបក ] មេភ្លៀង ។ – **វណ្ណ** គុ. មានពណ៌ដូចជាពណ៌នៃមេភ្លៀង ។

**ឥន្ទប្បដិម** គុ. [ ឥន្ទ+បដិម ] ដូចជារូបនៃព្រះឥន្ទ្រ, មានរូបប្រៀបដោយរូបនៃព្រះឥន្ទ្រ (បដិម<បដិ+មា+អ=ដូច, ប្រហែល, ស្រដៀង) ។

**ឥន្ទបត្តនគរ** នបុំ. [ ឥន្ទបត្ត+នគរ ] នគរ (ក្រុង) ឈ្មោះឥន្ទបត្ត ។

**ឥន្ទសាលគុហា** ឥ. [ ឥន្ទសាល+គុហា ] គុហាឈ្មោះឥន្ទសាល, គុហាគឺបណ្ឌិតកំណត់ហើយដោយឥន្ទសាលព្រឹក្ស (ដើមដីប្រាំដក) ។

**ឥន្ទ្រិយ** នបុំ. [ ឥន្ទ+ណិយ, ផ្លាស់នៃឥន្ទ>ឥន្ទ្រ ] (ធម្មជាត) ធ្វើនូវភាពនៃខ្លួនជាធំក្រៃលែង (ឥន្ទ្រិយ); វិ. **ឥន្ទតិ បរមិស្សរិយំ ករោតីតិ> ឥន្ទ្រិយំ** ។ – **គុត្តិ** ឥ. កិ.គ្រប់គ្រងនូវឥន្ទ្រិយ ។ – **ទមន** នបុំ. កិ.ទូន្មាននូវឥន្ទ្រិយ ។ – **សំវរ** បុំ. កិ.សង្រួមនូវឥន្ទ្រិយ ។

**ឥនិម្មសេ** កិ. [ ឥន+អ+ឥ_អា+ម្ហ_អជ្ជ.+សេ_និ. ] សូមប្តូរ, សូមព្រះរាជទានប្តូរ ។



**ឥរិយ** នបុំ. [ ឥរ+ឥយ ] កិ.ប្រព្រឹត្តិទៅ, ដំណើរប្រព្រឹត្តិទៅ; វិ. **ឥរិយតេតិ> ឥរិយំ**; ធម្មជាតគឺបុគ្គលគប្បីឱ្យប្រព្រឹត្តទៅ; វិ. **ឥរិយកញ្ចំ បវត្តេតព្វន្តិ> ឥរិយំ** ។

**ឥរិយាបថ** បុំ. [ ឥរិយ+អាបថ ] គន្លងនៃកិ.ប្រព្រឹត្តិទៅ, គន្លងនៃកិ.ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ (ឥរិយាបថ) ។ – **ចារ** បុំ. កិ.ប្រព្រឹត្តិទៅនៃឥរិយាបថ, កិ.ត្រាច់ទៅដោយឥរិយាបថ ។ – **មត្ត** គុ. (អាការ) ត្រឹមតែឥរិយាបថ ។ – **សម្បត្តិ** ឥ. កិ.ដល់ព្រមដោយឥរិយាបថ, សម្បត្តិគឺឥរិយាបថ ។

**ឥល្លិសជាតក** នបុំ. [ ឥល្លិស+ជាតក ] ជាតកគឺបណ្ឌិតកំណត់ហើយដោយសេដ្ឋីឈ្មោះឥល្លិសៈ, ឥល្លិសជាតក ។

**ឥសិ** បុំ. [ ឥស+ឥ ] អ្នកស្វែងរកនូវគុណមានសីលគុណជាដើម (ឥសិ, ឫសិ) វិ. **សីលាទិគុណេ ឯសតីតិ> ឥសិ** ។ – **គណ** បុំ. ពួកនៃឥសី ។ – **គិលិបស្ស** គុ. ខាងនៃភ្នំឈ្មោះឥសិគិលិ (**ឥសិគិលិ**<ឥសិ+គិល+ឥ=ភ្នំលេបនូវឥសី; វិ. **ឥសយោ គិលតីតិ> ឥសិគិលិ**) ។ – **គិលិវេបុល្លវេភារាទិក** គុ. មានភ្នំឈ្មោះឥសិគិលិនិងភ្នំឈ្មោះវេបុល្លៈនិងភ្នំឈ្មោះវេភារៈជាដើម ។ – **បតន** នបុំ. (ព្រៃ) ឈ្មោះឥសិបតនៈ, ជាទីធ្លាក់ចុះនៃឥសី, ជាទីធ្លាក់ចុះនៃបុគ្គលអ្នកស្វែងរក ។ – **បព្វជ្ជា** ឥ. បួសនៃបុគ្គលអ្នកស្វែងរក, បួសដោយភាវៈនៃខ្លួនជាឥសី; វិ. **ឥសិភាវេន បព្វជ្ជា>**

**ឥសិបព្វជ្ជា** (បួសជាឥសី) ។ . **បវេទិត** គុ. គឺឥសីឲ្យដឹងទូទៅហើយ, គឺលោកអ្នកស្វែងរកនូវគុណប្រកាសហើយ (បវេទិត < ប+វិទ+ឥ.អា.+ត) ។

**ឥស្សរ** គុ. [ឦស>ឥស្ស+អរ] អ្នកគ្រប់សង្កត់ (នូវជនដទៃ) (អ្នកធំ, បុគ្គលជា ធំ, បុគ្គលជាឥស្សរៈ); វិ. **ឦសតិ អភិភវតីតិ> ឥស្សរោ** ។ . **កាល** បុំ. កាលនៃ...ជាឥស្សរៈ (ជាធំ) ។ . **កិច្ច** នបុំ. កិច្ចនៃបុគ្គលជាឥស្សរៈ ។ . **គេហ** នបុំ. ផ្ទះនៃបុគ្គលជាឥស្សរៈ ។ . **ជន** បុំ. ជនជាឥស្សរៈ ។ . **ជាតិក** គុ. ប្រកបដោយជាតិនៃបុគ្គលជាឥស្សរៈ, មានជាតិនៃបុគ្គលជាឥស្សរៈ ។ . **ញាតក** បុំ. ញាតិជាឥស្សរៈ ។ . **ទារិកា** ឥ. ទារិកានៃជនជាឥស្សរៈ, ក្មេងស្រីនៃជនជាឥស្សរៈ ។ . **អាធិបច្ច** នបុំ. ភាវៈនៃបុគ្គលជាឥស្សរៈនិងជាអធិបតី ។

**ឥស្សរិយ** នបុំ. [ឥស្សរ+ណិយ] ភាវៈនៃបុគ្គលជាឥស្សរៈ; វិ. **ឥស្សរស្ស ភាវោ> ឥស្សរិយំ** ។ . **ភយ** នបុំ. សេចក្ដីខ្លាចអំពីភាវៈនៃបុគ្គលជាឥស្សរៈ, ភ័យអំពីបុគ្គលមានភាពជាឥស្សរៈ ។ . **ភោគសម្មានសង្ខាត** គុ. ពោលគឺឥស្សរិយយសនិងភោគៈនិងសេចក្ដីរាប់អាន ។ . **ដ្ឋាន** នបុំ. ទីនៃភាវៈនៃបុគ្គលជាឥស្សរៈ, ទីគឺភាវៈនៃបុគ្គលជាឥស្សរៈ ។ . **វស** បុំ. អំណាចនៃភាវៈនៃបុគ្គលជាឥស្សរៈ ។ . **សម្បត្តិ** ឥ. សម្បត្តិគឺឥស្សរៈ ។ . **អាទិភាវ** បុំ. ភាវៈនៃគុណជាតមានឥស្សរិយយសជាដើម, ភាវៈនៃគុណជាតមានភាវៈនៃបុគ្គលជាឥស្សរៈជាដើម ។



**ឥស្សា** ឥ. [ឥស្ស++អ+អា.ឥ.] (ធម្មជាតិ) ច្រណែនគឺធ្វើនូវកិ.លើកឡើងនូវទោសដោយសំដី ឬ ដោយចិត្តក្នុងសត្វក្ដីក្នុងគុណក្ដី (ឫស្យា, ឈ្នានីស, ច្រណែន, ប្រច័ណ្ឌ); វិ. **ឥស្សតិ សត្តេសុបិ គុណេសុបិ វចសា មនសា វា ទោសារោបនំ ករោតីតិ> ឥស្សា** ។ . **អាទិ** គុ. មានសេចក្ដីច្រណែនជាដើម ។ . **អាទិទោសជាត** នបុំ. ទោសជាតមានសេចក្ដីឫស្យាជាដើម ។ . **បកតត្ថីវត្ថុ** នបុំ. រឿងនៃស្ត្រីគឺសេចក្ដីច្រណែនធ្វើទូទៅហើយ, គ្របសង្កត់ហើយ ។ . **បកត** គុ. គឺសេចក្ដីច្រណែនគ្របសង្កត់ហើយ ។ . **អាភិភូត** គុ. គឺសេចក្ដីច្រណែនគ្របសង្កត់ហើយ, គឺ សេចក្ដីប្រច័ណ្ឌគ្របសង្កត់ហើយ ។ . **មនក** គុ. អ្នកមានចិត្តឈ្នានីស, អ្នកមានចិត្តប្រកបដោយសេចក្ដីឫស្យា; វិ. **ឥស្សា**(១) **មនោ យស្ស សោ> ឥស្សាមនកោ, ឥស្សាយ សម្បយុត្តោ មនោ អស្សាតិ> ឥស្សាមនកោ** ។ . **មានាទិ** គុ. មានសេចក្ដីឫស្យានិងមានៈជាដើម ។

**ឥស្សុកី** បុំ. [ឥស្សុក+ឦ] អ្នកមានសេចក្ដីច្រណែន, ឈ្នានីស; វិ. **ឥស្សុកោ យស្ស អត្ថីតិ> ឥស្សុកី** ។ ម្យ៉ាងទៀតៈ **ឥស្សុកី** <ឥស្សុ+ណុក+ណី.ស=អ្នកមិនអត់ទ្រាំនូវសម្បត្តិនៃបុគ្គលដទៃ,

---

១ តែបទនេះមិនសូវបានប្រើទេព្រោះជាបទមានមាតច្នះគ្នា ។

(អ្នកណាំទិស, អ្នកច្រណែន); វិ. **ឥស្សតិ បរសម្បត្តឹ ន សហតីតិ> ឥស្សុកោ, ឥស្សុកោ ឯវ> ឥស្សុកី** ។

**ឦទិស** គុ. ( ឥម>ឦ+ទិស+ក្វិ ) ដូចនេះ, ប្រាកដដូចនេះ; វិ. **ឥមមិវ នំ បស្សតីតិ> ឦទិសោ** ។

---





**ឧក្កំស** បុំ. [ ឧ+កស+ណ, ចុះ.និ.រា. ] ការប្រព្រឹត្តិលើកឡើងគឺការប្រព្រឹត្តិទៅដោយសេចក្តីល្អក្រៃលែង (ឧក្រិដ្ឋ); វិ. **ឧក្កសិត្វា កសនំ អតិសយេន បវត្តនំ> ឧក្កំសោ** ។

**ឧក្កដ្ឋ** គុ. [ ឧ+កស+ត>ដ ដ្ឋ , លុប ស ] ដែលប្រព្រឹត្តទៅក្នុងខាងលើ (ឧក្រិដ្ឋ) ។ - **បំសុកូល** នបុំ. សំពត់បង្សុកូលដ៏ឧក្រិដ្ឋ បំសុកូល <បំសុ+កុ+ឧល+អ= សំពត់ដល់នូវភាពគឺបុគ្គលគួរខ្ពើមដូចជាអាចម៍ដី; វិ. **បំសុ វិយ កុច្ឆិតភាវំ ឧលតិ គច្ឆតីតិ> បំសុកូលំ** ។ - **សបទានចារិក** គុ. អ្នកមានកិ.ត្រាច់ទៅកាន់ផ្ទះជាលំដាប់ជាប្រក្រតីដ៏ឧក្រិដ្ឋ, ឬអ្នកមានកិ.ត្រាច់ទៅកាន់លំដាប់ច្រកជាវត្តដ៏ឧក្រិដ្ឋ, វិ. **សបទានំ ចរិតុំ សីលមស្សាតិ> សបទានចារី, សបទានំ ចរិតុំ វត្តមស្សាតិ វា> សបទានចារី, សបទានចារី ឯវ> សបទានចារិកោ, ឧក្កដ្ឋោ សបទានចារិកោ> ឧក្កដ្ឋសបទានចារិកោ** ។ ម្យ៉ាងទៀតថាៈអ្នកមានកិ.ត្រាច់ទៅមួយអន្លើដោយកិ.វៀរចាកការកាត់ផ្តាច់ជាប្រក្រតីដ៏ឧក្រិដ្ឋ, វិ. **ធិយតេ អវខណ្ឌិយតេតិ > ធានំ, អបេតំ ធានតោ > អបធានំ, សហ អបធានេន ចរិតុំ សីលម ស្សាតិ> សបធានចារី , សបធានចារី**

ឯវ> សបទានចារិកោ, ឧក្កដ្ឋោ សបទានចារិកោ> ឧក្កដ្ឋសបទានចារិកោ ។ - វស ចុំ. អំណាចនៃវត្តដ៏ឧក្រិដ្ឋ, អំណាចនៃ...ដ៏ឧក្រិដ្ឋ ។

**ឧក្កដ្ឋិសទ្ទ** ចុំ. [ ឧក្កដ្ឋិ+សទ្ទ ] សំឡេងគឺកិ.ហ៊ោ, សំឡេងហ៊ោ ។ កដ្ឋិ<កស+តិ, តិ>ដ្ឋិ, លុបទីបំផុតធាតុ=សទ្ទៈដែលជនពោល (សំឡេង), វិ. **កសិយតេតិ>កដ្ឋិ** ។ **ឧច្ចា កដ្ឋិ> ឧកដ្ឋិ**= សំឡេងដ៏ខ្ពស់ (ហ៊ោ) ។ **ឧក្កដ្ឋិ ឯវ សទ្ទោ> ឧក្កដ្ឋិសទ្ទោ** ។

**ឧក្កដ្ឋិសហស្ស** នចុំ. [ ឧក្កដ្ឋិ+សហស្ស ] ពាន់នៃសំឡេងហ៊ោ ។

**ឧក្កណ្ឋិ** គុ. [ ឧ+កឋ > ឧក្កណ្ឋ+ឥ+សិ_វ. ] រសាប់រសល់, អផ្សុក, ធុញទ្រាន់, សោក ។

**ឧក្កណ្ឋាបិត** គុ. [ ឧ+កឋ>ឧក្កណ្ឋ+ណេ ណាបេ+ឥ_អា+ត ] គឺ...ឱ្យអផ្សុកហើយ ។ - **ត្ត** នចុំ. ភាវៈនៃ...ជាអ្នក គឺ...ឱ្យអផ្សុកហើយ, ...ឱ្យធុញទ្រាន់ហើយ ។

**ឧក្កណ្ឋិត** គុ. [ ឧ+កឋ>ឧក្កណ្ឋ+ឥ_អា+ត ] អផ្សុកហើយ, ធុញទ្រាន់ហើយ ។ - **កាល** ចុំ. កាលនៃ...ជាអ្នកអផ្សុកហើយ ។ - **ភាវ** ចុំ. នៃ...ជាអ្នកអផ្សុកហើយ ។ - **ភិក្ខុ** ចុំ. ភិក្ខុអ្នកអផ្សុក ។ - **ភិក្ខុវត្ថុ** នចុំ. រឿងនៃភិក្ខុអ្នកអផ្សុក ។

**ឧក្កណ្ឋិតា** ឥ. [ ឧ+កឋ+ឥ_អា+តា ] អផ្សុកហើយ, ធុញទ្រាន់ហើយ ។

**ឧក្កណ្ឋិ** ឥ. [ ឧក្កណ្ឋ+ឥយ, ឥយ>ឥ ] សេចក្តីអផ្សុក, មានសេចក្តីអផ្សុក ។





**ឧក្កលាប** ចុំ. [ ឧ+កលាប ] សម្រាម, មានសម្រាម, មានសម្រាមដ៏ខ្ពស់, មានសម្រាមដ៏ច្រូបច្រាល ។ ប្រើជា «**ឧក្លាប**» ក៏មាន ។

**ឧក្កាមុខ** នចុំ. [ ឧក្កា+មុខ ] មាត់នៃបាវ ( ភាជន៍ម្យ៉ាងសំរាប់ដាំងរំលាយមាស ) ។

**ឧក្ការភូមិ** ឥ. [ ឧក្ការ+ភូមិ ] ផែនដីកខ្វក់, ផែនដីប្រកបដោយគូថ, ទីប្រឡាក់ដោយគូថ (**ឧក្ការ**<អវ>ឧ+កិរ+ណ=ណាមក, កខ្វក់) ។

**ឧក្កាសិតសទ្ទ** ចុំ. [ ឧក្កាសិត+សទ្ទ ] សំឡេងក្អក, សំឡេងគឺ...ក្អកហើយ ។

**ឧក្កា** ឥ. [ ឧស+ក+អា_ឥ. ] ( ធម្មជាត ) តែងឆេះ ( គប់ភ្លើង, ភ្លើងគប់); វិ. **ឧសតិ ឌហតីតិ> ឧក្កា** ។

**ឧក្កុដិក** គុ.វិ. ឬ គុ. [ ឧ+កុដ+ណិក ] ធ្វើនូវកិ.ពោងឡើង ឬចំពោងឡើង (ច្រហោង, អង្គុយច្រហោង, ខ្នងកណ្តាល ) ។ - **ប្បធាន** នចុំ. សេចក្តីព្យាយាមដោយភាវៈនៃបុគ្គលអ្នកអង្គុយច្រហោង, សេចក្តីព្យាយាមដោយកិ.អង្គុយច្រហោង ។

**ឧក្កុដិភាវ** ចុំ. [ ឧក្កុដិ+ភាវ ] ភាវៈជាអ្នកអង្គុយច្រហោង, ភាវៈនៃកិ.អង្គុយច្រហោង ។

**ឧក្ខលិកកាល** ចុំ. [ ឧក្ខលិក+កាល ] កាលនៃបាយបិតនៅក្នុងឆ្នាំង, កាលជាទីដាក់ចុះក្នុងឆ្នាំង, កាលនៃបាយគឺបុគ្គលចំអិនក្នុងឆ្នាំង ។

**ឧក្ខលិកត្ត** គុ. [ ឧក្ខលិក+អត្ត ] មានដំឡោងគឺបុគ្គលគប្បីឱ្យក្នុងកាលនៃបាយគឺបុគ្គលចំអិនក្នុងឆ្នាំង, មានដំឡោងគឺបុគ្គលគប្បីឱ្យក្នុងកាល

នៃបាយបិតនៅក្នុងឆ្នាំង; វៈ. **ឧក្ខលិយំ ឥជ្ជភិភិ> ឧក្ខលិកំ (ភត្តំ) , ឧក្ខលិកស្ស ការោ> ឧក្ខលិកការោ, ឧក្ខលិកការេ ជាកត្តុំ អត្ថ> ឧក្ខលិកត្តំ** ។

**ឧក្ខិត្ត** គុ. [ ឧ+ខិប+ត ] គឺ...លើកឡើងហើយ, ..ងាឡើងហើយ, ..ចើកឡើងហើយ, ..កើតឡើងហើយ, ..សើយឡើងហើយ ។ - **កាល** ចុំ. កាលនៃ...គឺ...លើកឡើងហើយ ។ - **ត្ត** នចុំ. ភាវៈនៃ... ជា... គឺ...លើកឡើងហើយ ។ - **បលិឃ** គុ. មានសសរខឿនលើកឡើងហើយ, មានសសរគោលលើកឡើងហើយ ។ - **ធជស្ស** គុ. មានប៉្វរថៅលើកឡើងហើយ, មានប៉្វរថៅយារឡើងហើយ ។ - **អានុវត្តក** ចុំ. ភិក្ខុ អ្នកប្រព្រឹត្តតាមនូវភិក្ខុជាធម្មកថិកដែលសង្ឃលើកវត្តហើយ, ភិក្ខុអ្នកប្រព្រឹត្តតាមនូវភិក្ខុដែលសង្ឃលើកទោសហើយ ឬលើកវត្តហើយ ។

**ឧក្ខិបតិ** កិ. [ ឧ+ខិប+អ+តិ.វ. ] លើកឡើង, ងើបឡើង ។

**ឧក្ខិបន** នចុំ. [ ឧ+ខិប+យុ ] កិ.លើកឡើង, កិ.ភាសទៅ ។ - **កាល** ចុំ. កាលនៃកិ.លើកឡើង, កាលជាទីលើកឡើង, ... ។

**ឧក្ខិបាបេត្វា** អ. [ ឧ+ខិប+ណាបេ+ត្វា ] ញុំាង...ឱ្យលើកឡើងហើយ,...។

**ឧក្ខិបិតុកាម** គុ. [ ឧក្ខិបិតុំ+កាម ] អ្នកចង់ដើម្បីលើកឡើង, ...។

**ឧក្ខិបិតុំ** អ. [ ឧ+ខិប+ឥ.អា+តុំ ] ដើម្បីលើកឡើង, ដើម្បីងើបឡើង, ...។

**ឧក្ខិបិត្វា** អ. [ ឧ+ខិប+ឥ.អា+ត្វា ] លើកឡើងហើយ, សើយឡើងហើយ, ... ។



**ឧក្ខិបិស្សុ** កិ. [ ឧ+ខិប+អ+ឧំ.អជ្ជ. ] លើកឡើងហើយ, បាចឡើងហើយ ។

**ឧក្ខេបក** ចុំ. [ ឧ+ខិប+ណ្វុ ] អ្នកលើកឡើង, ភិក្ខុអ្នកលើកវត្ត, ភិក្ខុអ្នកលើកទោស ។

**ឧក្ខេបទាយ** ចុំ. [ ឧក្ខេប+ទាយ ] រង្វាន់គឺបុគ្គលគប្បីលើកឡើង,អំណោយគឺបុគ្គលគប្បីលើកឡើង, វត្ថុគឺបុគ្គលគប្បីឱ្យគឺបុគ្គលគប្បីលើកឡើង ។

**ឧក្ខេបនីយកម្ម** នចុំ. [ ឧក្ខេបនីយ+កម្ម ] កម្មគឺសង្ឃគប្បីលើកឡើង, កម្មគឺសង្ឃគប្បីធ្វើដល់ភិក្ខុអ្នកមានអធិករណ៍ដែលសង្ឃគប្បីលើកឡើង ។

**ឧក្ខេបន** នចុំ. [ ឧ+ខិប+យុ ] កិ.លើកឡើង, កិ.លើកទោស, កិ.លើកវត្ត។

**ឧគ្គច្ឆតិ** គុ. [ ឧ+គម+អ+តិ.វ; ផ្លាស់ម>ច្ឆ ] ទៅក្នុងខាងលើ, រះឡើង, អណ្ដែតឡើង, ហោះឡើង, ផុះឡើង, ខ្ពុរឡើង ។

**ឧគ្គច្ឆន្ត** គុ. [ ឧ+គម+អន្ត ] កាលទៅក្នុងខាងលើ, កាលរះឡើង, ...។

**ឧគ្គច្ឆិ** កិ. [ ឧ+គម+អ+ឦ.អជ្ជ. ] ទៅក្នុងខាងលើហើយ, ខ្ពុរចេញហើយ, រះឡើងហើយ , ... ។ ប្រើជា **ឧគ្គញ្ឆិ** ក៏មាន ។

**ឧគ្គណ្ហាតិ** កិ. [ ឧ+គហ+ណ្ហា+តិ.វ. ] រៀន, កំពុងរៀន ។

**ឧគ្គណ្ហន្ត** គុ [ ឧ+គហ+ណ្ហ+អន្ត ] កាលរៀន, កំពុងរៀន ។

**ឧគ្គណ្ហាបេតុំ** អ. [ ឧ+គហ+ណ្ហ+ណាបេ+តុំ ] ដើម្បីញុំាង...ឱ្យរៀន ។

ឧគ្គណ្ហាបេត្វា អ. [ ឧ+គហ+ណ្ហា+ណាបេ+ត្វា ] ញ៉ាំង...ឱ្យរៀនហើយ។

ឧគ្គណ្ហាបេន្ត គុ. [ ឧ+គហ+ណ្ហា+ណាបេ+អន្ត ] កាលញ៉ាំង... ឱ្យរៀន, កំពុងឱ្យរៀន ។

ឧគ្គណ្ហិតព្វ គុ. [ ឧ+គហ+ណ្ហា+ឥ.អា+តព្វ ] គឺ...គប្បីរៀន ។

ឧគ្គណ្ហិតុំ អ. [ ឧ+គហ+ណ្ហា+ឥ.អា+តុំ ] ដើម្បីរៀន, វិកិ.រៀន ។

ឧគ្គណ្ហិត្វា អ. [ ឧ+គហ+ណ្ហា+ឥ.អា+ត្វា ] រៀនហើយ ។

ឧគ្គត គុ. [ ឧ+គម+ត ] ទៅហើយក្នុងខាងលើ, ឡើងទៅហើយ, រះឡើងហើយ, ខ្ពស់ ។ - តប គុ. មានតបៈទៅហើយក្នុងខាងលើ, មានតបៈដ៏ខ្ពស់។ - ធូម គុ. មានផ្សែងទៅហើយក្នុងខាងលើ, មានផ្សែងហុយឡើងហើយ ។

ឧគ្គ គុ. [ ឧច+គ ឬឧជ+អ,ជ>គ>គ្គ ] ខ្ពស់, ខ្ពង់ខ្ពស់, រុងរឿង ។ - តេជ គុ. មានតេជៈដ៏ខ្ពស់ ។ - នគរវាសី នថុំ. អ្នកមានកិ.នៅក្នុងក្រុងឈ្មោះ ឧគ្គៈជាប្រក្រតី ។ - នគរ នថុំ. ក្រុង ឈ្មោះឧគ្គៈ ។ - សេដ្ឋី ថុំ. សេដ្ឋីឈ្មោះឧគ្គៈ, សេដ្ឋីនៅក្នុងក្រុងឈ្មោះឧគ្គៈ ។ - សេនវត្ថុ នថុំ. រឿងនៃព្រះថេរៈឈ្មោះឧគ្គសេនៈ ។ - សេនសេដ្ឋិបុត្តវត្ថុ នថុំ. រឿងនៃសេដ្ឋីបុត្តឈ្មោះឧគ្គសេនៈ ។

ឧគ្គន្តុំ អ. [ ឧ+គម+តុំ ] ដើម្បីទៅក្នុងខាងលើ, ដើម្បីឡើងទៅ, ...។

ឧគ្គម្ម អ. [ ឧ+គម+ត្វា ] ទៅក្នុងខាងលើហើយ, ឡើងទៅហើយ, ហោះឡើងហើយ, អណ្តែតឡើងហើយ ។





ឧគ្គហណ នថុំ. [ ឧ+គហ+យុ ] កិ.រៀន ។ - ធារណវាចនាទិ គុ. មានកិ.រៀន និងកិ.ទ្រទ្រង់និងកិ.បង្ហាញជាដើម ។

ឧគ្គហ ថុំ. [ ឧ+គហ+អ ] កិ.រៀន; វិ. **ឧគ្គហណំ> ឧគ្គហោ** ។

ឧគ្គហិត គុ. [ ឧ+គហ+ឥ.អា+ត ] គឺ...រៀនហើយ ។ - បរិយត្តិ គុ. បរិយត្តិគឺ...រៀនហើយ, គុ. មានបរិយត្តិរៀនហើយ ។ - មត្ត គុ. គ្រាន់តែ ឬត្រឹមតែទីនៃ...គឺ...រៀនហើយ ។ - វត្ត គុ. មានវត្តរៀនហើយ ។ - សិប្ប នថុំ. សិល្បគឺ...រៀនហើយ, គុ. មានសិល្បសាស្ត្ររៀនហើយ ។

ឧគ្គរន្ត គុ. [ ឧ+គិរ>ឧគ្គរ+អ+អន្ត ] កាលរើឡើង, កាលងាឡើង ។

ឧគ្គីរិស្សុ កិ. [ ឧ+គិរ+អ+ឧំ.អជ្ជ.] រើឡើងហើយ, ងាឡើងហើយ, យារឡើងហើយ ។

ឧគ្ឃរន្ត គុ. [ ឧ+ឃរ+អ+អន្ត ] កាលខ្ចរឡើង, កាលហូរឡើង, កាលហូរចូល ។

ឧគ្ឃាដិតមត្ត គុ. [ ឧគ្ឃាដិត+មត្ត ] គ្រាន់តែគឺ...បើកឡើងហើយ, -កើចឡើងហើយ, -ដកឡើងហើយ (ឧគ្ឃាដិត<ឧ+ឃដ+ឥ.អា+ត) ។

ឧគ្ឃាដេត្វា អ. [ ឧ+ឃដ+ណេ+ត្វា ] បើកឡើងហើយ , កើចឡើងហើយ, ដកឡើងហើយ ។

ឧគ្ឃោសយមាន គុ. [ ឧ+ឃុស+ណយ+មាន ] កាលញ៉ាំងសំឡេងឱ្យគឹកកង, កាលឃោសនា ។

**ឧគ្ឃោសេត្វា** អ. [ ឧ+ឃុស+ណេ+ត្វា ] ញុំាងសំឡេងឲ្យឮកងហើយ, ឃោសនាហើយ, ស្រែកប្រកាសហើយ ។

**ឧគ្ឃោសេន្ត** គុ. [ ឧ+ឃុស+ណេ+អន្ត ] កាលញុំាងសំឡេងឲ្យឮកង, កាលឃោសនា, កាលស្រែកប្រកាស ។

**ឧគ្ឃោសេហិ** កិ. [ ឧ+ឃុស+ណេ+ហិ.ប. ] ចូរញុំាងសំឡេងឲ្យឮកង, ចូរឃោសនា, ចូរស្រែកប្រកាស ។

**ឧច្ចង្គ** បុំ. [ ឧច្ច+អង្គ ] គ្រឿងកំណត់ដ៏ខ្ពស់ ឬ អវយវៈដ៏ខ្ពស់ (ថ្ពក់, ចង្កេះ, ភ្លៅ) ។ ប្រើជា ឧច្ចង្គ ក៏មាន ។

**ឧច្ច** គុ. [ ឧ+ចិ+អ ] សភាវៈតែងសន្សំក្នុងខាងលើ (ខ្ពស់); វិ. **ឧចិនោតីតិ> ឧច្ចោ** ។ - **ដ្ឋាន** នបុំ. ទីខ្ពស់, ទីដ៏ខ្ពស់ ។ - **តរ** គុ. ខ្ពស់ជាង ។ - **នីចកុលប្បដិបាដិ** ឥ. លំដាប់នៃត្រកូលខ្ពស់និងត្រកូលទាប, លំដាប់នៃត្រកូលខ្ពស់និងទាប ។

**ឧច្ចយ** បុំ. [ ឧ+ចិ+ណ ] គឺ. សន្សំ, គឺ.គរួន ។

**ឧច្ចារ** បុំ. [ ឧ+ចរ+ណ ] អាហារចាស់ដែលគេបន្ទោបង់ ( ឧច្ចារៈ, អាចម៍); វិ. **ឧច្ចារិយតេ ឧហ្សតេតិ> ឧច្ចារោ** ។ -**ករណដ្ឋាន** នបុំ. ទីជាទីធ្វើនូវឧច្ចារៈ, ទីជាទីបន្ទោបង់នូវឧច្ចារៈ ។ -**បស្សាវដ្ឋាន** នបុំ. ទីជាទីបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ។

**ឧច្ចាវច** គុ. [ ឧច្ច+អវច ] ខ្ពស់និងទាប ។

**ឧច្ចាសទ្ទ** បុំ. [ ឧច្ច+សទ្ទ ] សំឡេងដ៏ខ្ពស់, សំឡេងឮ, វិ. **ឧច្ចោ**





**សទ្ទោ > ឧច្ចាសទ្ទោ** ។

**ឧច្ចាសន** នបុំ. [ ឧច្ច+អាសន ] ទីជាទីអង្គុយដ៏ខ្ពស់, អាសនៈដ៏ខ្ពស់; វិ. **ឧច្ចំ អាសនំ> ឧច្ចាសនំ** ។

**ឧច្ចិនាតិ** កិ. [ ឧ+ចិ+នា+តិ.វ. ] បេះ, ជ្រើសរើស ។

**ឧច្ចិនិត្វា** កិ. [ ឧ+ចិ+នា, នា>និ+ត្វា ] បេះហើយ, ជ្រើសរើសហើយ ។

**ឧច្ឆិជ្ជិស្សតិ** កិ. [ ឧ+ឆិទ+យ+ឥ.អា.+ស្សតិ.ក. ] នឹងសូន្យ, នឹងដាច់សូន្យ។

**ឧច្ឆិដ្ឋ** គុ. [ ឧ+ឆិទ+ត ] ជារបស់ដែល, ជាដែល, សល់, សំណល់ ។ - **អម្ពដ្ឋិ** នបុំ. គ្រាប់នៃស្វាយជាដែល ។ - **កសដ** បុំ. កាកជាដែល, កាកជារបស់ដែល ។ - **ខាទក** បុំ. អ្នកទំពាស៊ីនូវវត្ថុជាដែល ។ - **កញ្ជិក** នបុំ. បាយចុងអង្ករជាដែល, ទឹកបាយជាដែល ។ - **បាយាស** បុំ. បាយបាយាសជារបស់ដែល ។ - **ភត្ត** នបុំ. ភត្តជារបស់ដែល ។ - **ភោជន** នបុំ. ភោជនជារបស់ដែល ។ - **សេសក** គុ. វត្ថុដ៏សេសជារបស់ដែល, វត្ថុដ៏សេសចាកវត្ថុជារបស់ដែល ។ - **ឧទក** នបុំ. ទឹកជាដែល, ទឹកជារបស់ដែល, ទឹកសំណល់ ។

**ឧច្ឆិន្ទ** កិ. [ ឧ+ឆិទ+អ+ហិ.ប, លុបហិ ] ចូរកាត់, ចូរដកឡើង, ចូរផ្តាច់ផ្តិល ។

**ឧច្ឆុ** នបុំ. [ ឥស+ឧ, ឥ>ឧ, ស>ឆ ] វត្ថុដែលជនប្រាថ្នា (អំពៅ); វិ.**ឥសិយ-**

**កេតិ> ឧជ្ជុ** ។ - **ក្ខេត្ត** នចុំ. ស្រែនៃអំពៅ, ចំការនៃអំពៅ, ។ - **យដ្ឋិ** ៨. ដើមនៃអំពៅ ។ - **រស** នចុំ. រសនៃអំពៅ, ទឹកនៃអំពៅ ។

**ឧជុ** គុ. [ អជ+ឧ, អ នៃ អជ>ឧ ] ធម្មជាតប្រព្រឹត្តទៅដោយភាវៈមិនកោង ឬ មិនវៀច (ត្រង់), វិ. **អជតិ អកុដិលភាវេន បវត្តតីតិ> ឧជុ** ។ - **មគ្គ** ចុំ. ផ្លូវដ៏ត្រង់ ។ - **គត** គុ. ដែលទៅហើយដោយត្រង់ ។ - **ជាតិក** គុ. មានជាតិដ៏ត្រង់, ប្រកបដោយជាតិដ៏ត្រង់, វិ. **ឧជុ ជាតិ យស្សា សា> ឧជុជាតិកា, ឧជុ ជាតិ> ឧជុជាតិ, ឧជុជាតិយា និយុត្តា> ឧជុជាតិកា** ។ - **ទិដ្ឋិតា** ឥ. ភាវៈ...ជាអ្នកមានទិដ្ឋិដ៏ត្រង់; វិ. **ឧជុ ទិដ្ឋិ អស្សាតិ> ឧជុទិដ្ឋិ, តស្ស ភាវោ> ឧជុទិដ្ឋិតា** ។

**ឧជុក** គុ. [ ឧជុ+ក.ស. ] គិ.ប្រព្រឹត្តទៅដោយភាពមិនវៀច (ត្រង់), វិ. **អរណំ អកុដិលភាវេន បវត្តនំ> ឧជុ, ឧជុ ឯវ> ឧជុកំ** ។ - **សណ្ឋាន** នចុំ. សណ្ឋានដ៏ត្រង់, ទ្រង់ទ្រាយដ៏ត្រង់ ។ - **មគ្គ** ចុំ. ផ្លូវដ៏ត្រង់ ។

**ឧជ្ជង្គល** ចុំ. [ ឧ+ជង្គល ] ផែនដីដ៏ខ្ពស់, ទីទួល (ជង្គល<ជល+គល+អ = ប្រទេសជាទីលេបទូវទឹក (ផែនដី), វិ. **ជលំ គលតិ ឯត្ថាតិ> ជង្គលោ, ឧគ្គតោ ជង្គលោ> ឧជ្ជង្គលោ**) ។

**ឧជ្ជលន្តី** គុ. [ ឧ+ជល+អន្ត+ឦ ] កាលរុងរឿង, កាលភ្លឺឡើង ។



**ឧជ្ឈាន** នចុំ. [ ឧ+ឈេ+យុ ] គិ.សំឡឹង, គិ.ពិនិត្យ, គិ.លើកទោស, គិ.តិះដៀល, គិ.រអ៊ូរទាំ, វិ. **ឧជ្ឈាយតេតិ> ឧជ្ឈានំ** ។ - **ពហុល** គុ. ច្រើនដោយគិ.លើកទោស ។ - **សញ្ញិតា** ឥ. ភាវៈ នៃ... ជាអ្នកមានសេចក្ដីសំគាល់ក្នុងគិ.លើកទោស ។ - **សញ្ញិត្ថេរវត្ថុ** នចុំ. រឿងនៃព្រះថេរៈឈ្មោះឧជ្ឈានសញ្ញី (ព្រះថេរៈអ្នកមានសេចក្ដីសំគាល់ក្នុងគិ.លើកទោស) ។ - **សញ្ញី** ចុំ. អ្នកមានសេចក្ដីសំគាល់ក្នុងគិ.តិះដៀល; វិ. **ឧជ្ឈានេ សញ្ញា> ឧជ្ឈានសញ្ញា, សា យស្ស អត្ថីតិ> ឧជ្ឈានសញ្ញី** ។

**ឧជ្ឈាបយោថ** គិ. [ ឧ+ឈេ+ណាបយ+ថ.វ. ] ញុំាង...ឱ្យពិនិត្យ, ..ឱ្យសំឡឹង, ..ឱ្យលើកទោស ។

**ឧជ្ឈាបេយ្យាម** គិ. [ ឧ+ឈេ+ណាបយ+ឯយ្យាម.ក, លុប ឈ្ញ ] នឹងញុំាង...ឱ្យលើកទោស, នឹងប្រឹក្សា, នឹងញុំាង...ឱ្យជួយប្រឹក្សា ។

**ឧជ្ឈាយន្ត** គុ. [ ឧ+ឈេ+អន្ត ] កាលលើកទោស ។

**ឧជ្ឈាយិ** គិ. [ ឧ+ឈេ+អ+ឦ.អជ្ជ. ] លើកទោសហើយ, សំឡឹងហើយ ។

**ឧជ្ឈាយិត្វា** អ. [ ឧ+ឈេ+ឥ.អា+ត្វា ] លើកទោសហើយ, តិះដៀលហើយ ។

**ឧជ្ឈិត** គុ. [ ឧជ្ឈ+ឥ.អា+ត ] គឺ...លះហើយ, ..លះបង់ហើយ, ..ចោលហើយ ។

**ឧដ្ឋហតិ** គិ. [ ឧ+ឋា+អ+ឋា.អា+តិ.វ. ] តាំងឡើង, ក្រោកឡើង, រះឡើង ។

**ឧដ្ឋហតុ** កិ. [ ឧ+ឋា+អ+ហ.អា.+តុ.ប. ] ចូរតាំងឡើង, ចូរក្រោកឡើង ។

**ឧដ្ឋហថ** កិ. [ ឧ+ឋា+អ+ហ.អា.+ថ.ប. ] ចូរតាំងឡើង, ចូរក្រោកឡើង ។

**ឧដ្ឋហន្ត** គុ. [ ឧ+ឋា+អ+ហ.អា.+អន្ត ] កាលតាំងឡើង, កាលក្រោកឡើង ។

**ឧដ្ឋហិត្វា** អ. [ ឧ+ឋា+អ+ហ.អា.+ឥ.អា+ត្វា ] តាំងឡើងហើយ, ក្រោកឡើងហើយ ។

**ឧដ្ឋហិំសុ** កិ. [ ឧ+ឋា+អ+ហ.អា.+ឧំ.អជ្ជ. ] តាំងឡើងហើយ, ក្រោកឡើងហើយ ។

**ឧដ្ឋាតព្វ** គុ [ ឧ+ឋា+តព្វ ] គឺ...គប្បីតាំងឡើង, ..គប្បីក្រោកឡើង ។

**ឧដ្ឋាតិ** កិ. [ ឧ+ឋា+អ+តិ.វ. ] តាំងឡើង, ក្រោកឡើង, រះឡើង ។

**ឧដ្ឋាបិត** គុ. [ ឧ+ឋា+ណាបេ+ឥ.អា.+ត ] គឺ...ញុំាង...ឲ្យក្រោកឡើងហើយ, ..ឲ្យតាំងឡើងហើយ, ..ឲ្យងើបឡើងហើយ,

**ឧដ្ឋាតុំ** អ. [ ឧ+ឋា+តុំ ] ដើម្បីតាំងឡើង, ដើម្បីក្រោកឡើង ។

**ឧដ្ឋាន** នបុំ. [ ឧ+ឋា+យុ ] កិ.តាំងឡើង, កិ.ក្រោកឡើង, សេចក្ដីព្យាយាម, សេចក្ដីក្រពើនក្រតើន; វិ. **ឧដ្ឋហិយតេតិ>ឧដ្ឋានំ** ។ ..**ដ្ឋាន** នបុំ. ទីជាទីតាំងឡើង ។ ..**ដ្ឋានសង្ខាត** គុ. ពោលគឺទីជាទីតាំងឡើង, ។ ..**កាល** បុំ. កាលជាទីក្រោកឡើង, កាលជាទីក្រពើនក្រតើន ។ ..**វីរិយវន្ត** គុ. អ្នកមានព្យាយាមជាគ្រឿងតាំងឡើង, អ្នកមានព្យាយាមជាគ្រឿងក្រពើនក្រតើន ។





**ឧដ្ឋានវ** គុ. [ ឧដ្ឋាន+វន្តុ ] អ្នកមានព្យាយាមជាគ្រឿងតាំងឡើង, អ្នកមានសេចក្ដីខ្នះខ្នែង, វិ. **ឧដ្ឋានំ យស្ស អត្ថីតិ> ឧដ្ឋានវា** ។

**ឧដ្ឋិត** គុ. [ ឧ+ឋា+ត, អានៃឋា>ឥ ] តាំងឡើងហើយ, ក្រោកឡើងហើយ ។

**ឧណ្ហ** គុ. [ ឧស+ណ្ហ ] សភាវៈតែងក្ដៅ (ក្ដៅ, កំដៅ); វិ. **ឧសតិ ឌហ-តីតិ> ឧណ្ហោ** ។

**ឧណ្ណាលោម** បុំ. [ ឧណ្ណា+លោម ] រោមត្រង់ចិញ្ចើម ។

**ឧត្តមង្គ** នបុំ. [ ឧត្តម+អង្គ ] អវយវៈដ៏ឧត្តម (ក្បាល, អម្បែងក្បាល) ។

**ឧត្តរ** គុ. [ ឧ+តរ+អ ] ខាងលើ, ដ៏លើស, ដ៏ក្រៃលែង, ប្រសើរ, ទិសឧត្តរ, ទិសខាងជើង ។ ..**សាដក** បុំ. សាដកសម្រាប់ពាក់ត្ជួដ៏កាយខាងលើ (សំពត់បង់ក) ។

**ឧត្តរាសង្គ** បុំ. [ ឧត្តរ+អា+សញ្ជ+អ ] សំពត់ដែលបុគ្គលពាក់ត្ជួដ៏ចំណែកនៃកាយខាងលើ ( សំពត់បង់ក, ចីពរ ), វិ. **ឧត្តរស្មិំ ទេហភាគេ អាសញ្ជិយតិ ឋបិយតីតិ > ឧត្តរាសង្គោ** ។

**ឧត្តរិភង្គ** បុំ. [ឧត្តរិ+ភង្គ] សំឡដែលកាច់បង់នូវរសដ៏ក្រៃលែង (តាមទំលាប់នៃពោរាណាចារ្យដែលធ្លាប់ប្រែមកថា « សំឡកកូរ » ឬ «សំឡការី» បើតាមពិត ស័ព្ទនេះជាឈ្មោះសំឡអ្វីមួយ៉ាង ដែលគេនិយមប្រើក្នុងប្រទេសឥណ្ឌា) សំឡឈ្មោះឧត្តរិភង្គៈ ។

**ឧត្តរិត្វា** អ. [ ឧ+តរ+ឥ.អា.+ត្វា ] ឆ្លងឡើងហើយ, ឡើងហើយ, ឆ្លង

ហើយ ។

**ឧត្តាន** គុ. [ ឧ+តន+ណ ] ផ្ងារ, រាក់, រីករាយ ។ - **មុខ** គុ. មានមុខរីករាយ, មានមុខស្រស់ស្រាយ ។ - **ត្ត** គុ. មានសេចក្ដីរាក់ ។ - **សេយ្យក** បុំ. អ្នកដេកផ្ងារ; វិ. **ឧត្តានំ សយតីតិ > ឧត្តានសេយ្យកោ.** ( **សេយ្យក** < សី+ឯយ្យក ឬក ) ។

**ឧត្តាស** បុំ. [ ឧ+តស+ណ ] សេចក្ដីតក់ស្លុត, សេចក្ដីរន្ធត់, វិ. **ឧត្តសនំ> ឧត្តាសោ** ។

**ឧត្តិដ្ឋ** គុ. [ ឧ+ឋា, ឋា>តិដ្ឋ+អ ] បិណ្ឌបាតគឺបុគ្គលគប្បីក្រោកឡើងហើយឈរទៅ, ដុំនៃអាមិសគឺភិក្ខុគប្បីក្រោកឡើងហើយឈរទៅ ។

**ឧត្តិណ្ណ** គុ. [ ឧ+តរ+ត, ត>ឥណ្ណ, លុប រ ] ឆ្លងឡើងហើយ, ឡើងហើយ ។

**ឧទក** នបុំ. [ ឧទ្ទ+ក ] ធម្មជាតធ្វើនូវកិ.ជ្រួតជ្រាប (ទឹក), វិ. **ឧន្ទតិ ក្លេទំ ករោតីតិ> ឧទកំ** ។ - **កុម្ភ** បុំ., នបុំ. ល័ក្ខចាន់, ក្អមទឹក, ថូទឹក, (តាមទំលាប់ថា «ល័ក្ខចាន់សម្រាប់ដាក់នូវទឹក» ជាបរិក្ខារម៉្យាងរបស់វត្តជីតអ្នកកាន់ធុតង្គ) ជាវេវចនៈនៃកមណ្ឌលុ ។ - **ណ្ណវ** បុំ. ទន្លេដ៏ពេញដោយទឹក, សមុទ្រដ៏ពេញដោយទឹក ( **អណ្ណវ** <អណ>អណ្ណ+វ = ប្រទេសមានទឹក, ទន្លេ, សមុទ្រ) ។ - **និទ្ធមន** នបុំ. ទីជាទីកំចាត់បង់នូវទឹក, ប្រឡាយនៃទឹក, លូនៃទឹក, ផ្លូវនៃទឹក, ទីជាទីហូរទៅនៃទឹក (**និទ្ធមន**<និ+ធម+យុ) ។ - **មណិក** បុំ. ពាងនៃទឹក ។ - **ធារា** ឥ. ទនៃទឹក, ធ្លារនៃទឹក ។ - **បុព្ពុឡក**



បុំ. ពពុះនៃទឹក, ព្រពេញនៃទឹក ។ - **វាហ** បុំ. វេទជាទីដងនូវទឹក, វេទជាទីនាំនូវទឹក ។

**ឧទកុម្ភ** បុំ. [ ឧទ+កុម្ភ ] ក្អមនៃទឹក, ក្អមដ៏ពេញដោយទឹក ។

**ឧទគ្គភាវ** បុំ. [ ឧទគ្គ+ភាវ ] ភាវៈនៃសេចក្ដីត្រេកអរ (**ឧទគ្គ**<ឧ+អគ្គ ឬ ឧទ+អគ្គ) ។

**ឧទពិន្ទុ** នបុំ. [ ឧទ+ពិន្ទុ ] ដំណក់នៃទឹក ។

**ឧទពិន្ទុនិបាត** បុំ. [ ឧទពិន្ទុ+និបាត ] កិ.ធ្លាក់ចុះនៃដំណក់នៃទឹក, កិ.ស្រក់ចុះនៃដំណក់នៃទឹក, (**និបាត**<និ+បត+ណ) ។

**ឧទព្វហិ** កិ. [ ឧ+អ+វហ+អ+ឦ្ហ.អជ្ជ., ចុះម.អា. ] បានអូសឡើងហើយ, បានទាញឡើងហើយ ។

**ឧទរបដល** នបុំ. [ ឧទរ+បដល ] ដំបារនៃពោះ (ផ្ទៃនៃពោះ ) ។

**ឧទបាទិ** កិ. [ ឧ+អ+បទ+អ+ឦ្ហ.អជ្ជ. ចុះម.អា. ] បានកើតឡើងហើយ, កើតឡើងហើយ ។

**ឧទយន្ត** គុ. [ ឧទិ+អន្ត ] កាលរះឡើង, កាលកើតឡើង ។

**ឧទយព្វយ** បុំ. [ ឧទយ+វយ ] កិ.កើតឡើងនិងកិ.សូន្យទៅ ។

**ឧទាន** នបុំ. [ ឧទ+អន ] ពាក្យជាគ្រឿងបន្លឺឡើង, ( ពាក្យបន្លឺដោយសោមនស្ស) ឧទាន, វិ. **ឧទតិ ឯតេនាតិ> ឧទានំ** ។

**ឧទានេតិ** កិ. [ ឧទ+អា+អន+ណេ+តិ ] បន្លឺ, បន្លឺឡើង ។

**ឧទាហុ** និ. ឬថា, ឬក៏ ។

ឧទ្ទ ចុំ. ភេ ។

ឧទ្ទាន នចុំ. [ ឧ+ទេ+យុ ] វត្ថុសម្រាប់រួបរួមទុក ឬរក្សាទុក (ត្រណោត),
**វិ. ឧទ្ទាយតិ រក្ខតិ ឯតេនាតិ > ឧទ្ទានំ** ។

ឧទ្ទាម គុ. [ ឧ+ទាម ] មានគិ.ច្ចានរើឡើងហើយ (កញ្រោលឡើងហើយ);
**វិ. ឧទ្ធតោ ទាមា យេន សោ> ឧទ្ទាមោ** ( ទាម <ទម+ណ = គិ.បង្ហាត់, គិ.បង្វឹក; **វិ. ទមនំ> ទាមោ** ) ។

ឧទ្ទិក្ខតិ កិ. [ ឧ+ឥក្ខ+អ+តិ.វ. ចុះ ទ.អា. ] ងើបមើល, ក្រឡេកមើល ។

ឧទ្ទិស្ស អ. [ ឧ+ទិស+ត្វា ] ឧទ្ទិស , ចំពោះ , សំដៅ ។

ឧទ្ទីរយេ កិ. [ ឧ+ឦរ+ណយ+ឯយ្យ.ស, ចុះ ទ.អា. ] គប្បីពោល ។

ឧទុក្ខល ចុំ. ត្បាល់ ។

ឧទ្ទេស ចុំ. (ឧ+ទិស+ណ) ឧទ្ទេស, គិ.សំដែងឡើង, គឺបុគ្គលគប្បីសំដែងឡើង (បាលី) ។ - **ភត្ត** នចុំ. ភត្តគឺបុគ្គលគប្បីសំដែងឡើង, ភត្តគឺបុគ្គលគប្បីឧទ្ទិស, ឧទ្ទេសភត្ត ។

ឧទ្ធំ និ. ខាងលើ, ក្នុងខាងលើ, ជាន់ខាងលើ ។

ឧទ្ធគ្គ គុ. [ ឧទ្ធ+អគ្គ ] មានចុងក្នុងខាងលើ, មានចុងឡើងលើ, វិ. **ឧទ្ធំ អគ្គោ យេសន្តិ> ឧទ្ធគ្គា** ។

ឧទ្ធច្ច នចុំ. [ ឧទ្ធត+ណ្យ ] ភាវៈនៃចិត្តរាយមាយ; ភាវៈនៃចិត្តអណ្តែតអណ្តូង, ឬសេចក្តីរាយមាយ; វិ. **ឧទ្ធំ ធុនាតិ កម្បតីតិ >**



**ឧទ្ធតំ (ចិត្តំ), ឧទ្ធតស្ស ភាវោ > ឧទ្ធច្ចំ, ឧទ្ធតំ ឯវ តា > ឧទ្ធច្ចំ** ។

ឧទ្ធដ គុ. [ ឧ+ធរ+ត, ត>ដ ] សភាវៈដែលបុគ្គលរើឡើងហើយ, -ស្រង់ឡើងហើយ, ដកឡើងហើយ, វិ. **ឧទ្ធរិយិត្ថាតិ> ឧទ្ធដោ** ។

ឧទ្ធន នចុំ. [ ឧ+ធា+យុ ] ភាជនៈមានផ្លាំងជាជើងជាទីដែលជនដំកល់ឆ្នាំងខាងលើ (ជើងក្រាន); វិ. **ឧទ្ធំ ធីយតិ ថាលិយា ឯតស្មិន្តិ> ឧទ្ធនំ** ។ - **បន្តី** គ. របៀបនៃជើងក្រាន, ជួរនៃជើងក្រាន ។

ឧទ្ធរន្តី គុ. [ ឧ+ធរ+អន្ត+ឦ ] កំពុងរើឡើង , កំពុងបោចរោច ។

ឧទ្ធរិត្វា អ. [ ឧ+ធរ+ឥ.អា.+ត្វា ] រើឡើងហើយ, ស្រង់ឡើងហើយ, កកាយហើយ, បោចរោចហើយ ។

ឧន្នង្គល គុ. [ ឧ+នង្គល ] មាននង្គ័លក្នុងខាងលើ ឬមាននង្គ័លលើកឡើងហើយ, វិ. **ឧទ្ធំ នង្គលំ យស្ស សោ > ឧន្នង្គលោ, ឧក្ខិត្តំ នង្គលំ យេន សោ ចា> ឧន្នង្គលោ** ។

ឧន្នត គុ. [ ឧ+នម+ត ] ងើបឡើងហើយ, ប៉ោងឡើងហើយ ។

ឧន្នឡ គុ. [ ឧ+នឡ ] មានមានៈដូចជាបបុសលើកឡើងហើយ, វិ. **ឧក្ខិត្តោ មាននឡោ យេន សោ> ឧន្នឡោ** ។

ឧន្នាទន នចុំ. [ ឧ+នទ+យុ ] គិ.បន្លឺឡើង, គិ.គឹកកង ។

ឧបកដ្ឋ គុ. [ ឧប+កឌ្ឍ>ឧបកដ្ឋ ] ចូលទៅកាន់ទីជិត, ចូលទៅជិត, ( ជិត,

ជិតហើយ ), វិ. **គន្ត្វា សមីបំ ឧបគតោ > ឧបគន្ត្វា** ។

**ឧបកប្បតិ** កិ. [ ឧប+កប្ប+អ+តិ.វ. ] ឃើតចូលទៅ, មាញចូលទៅជិត ។

**ឧបកប្បនក** គុ. [ ឧប+កប្ប+យុ, យុ>អនក ] ដែលចូលទៅសម្រេច ។ បុំ. កាមដែលចូលទៅសម្រេច, សេចក្ដីប្រាថ្នាដែលចូលទៅសម្រេច ។

**ឧបករណ** នបុំ. [ ឧប+ករ+យុ ] (វត្ថុ) ជាគ្រឿងធ្វើនូវសេចក្ដីទំនុកបំរុង. គ្រឿងឧបករណ៍, វិ. **ឧបករោតិ ឯតេនាតិ > ឧបករណំ** ។ - **បដិពទ្ធ** គុ. ដែលជាប់ចំពោះដោយគ្រឿងឧបករណ៍ ។

**ឧបក** អស.ន. ឈ្មោះឧបកៈ ។ - **អាជីវកវត្ថុ** នបុំ.រឿងនៃអាជីវកឈ្មោះឧបកៈ ។

**ឧបការក** បុំ., នបុំ. [ ឧប+ករ+ណ្វុ ] អ្នកទំនុកបំរុង, អ្នកធ្វើនូវសេចក្ដីទំនុកបំរុង ( អ្នកមានឧបការៈ ); វិ. **ឧបករោតីតិ> ឧបការកោ** ។

**ឧបការ** បុំ. [ ឧប+ករ+ណ ] អ្នកធ្វើនូវសេចក្ដីទំនុកបំរុង, អ្នកមានឧបការៈ, កិ.ធ្វើនូវសេចក្ដីទំនុកបំរុង (ឧបការៈ) វិ. **ឧបករោតីតិ>ឧបការោ, ឧបការោ យស្ស អត្ថីតិ> ឧបការោ, ឧបករណំ> ឧបការោ** ។ - **មុខ** នបុំ. ឧបការៈ ជាប្រធាន, ឧបាយជាប្រធាននៃ កិ.ធ្វើនូវសេចក្ដីទំនុកបំរុង ។ - **វស** បុំ. អំណាចនៃឧបការៈ, អំណាចនៃគុណជាគ្រឿងធ្វើនូវសេចក្ដីទំនុកបំរុង ។

**ឧបការិកា** ឥ. [ ឧប+ករ+ណ្វុ+ឥ.ភា.+អា_ឥ. ] អ្នកធ្វើនូវសេចក្ដីទំនុកបំរុង,



អ្នកមានឧបការៈ ។

**ឧបក្កិលិដ្ឋ** គុ. [ ឧប+កិលិស+ត ] គឺ...ឱ្យចូលទៅសៅហ្មងហើយ, ..ចូលទៅឱ្យសៅហ្មងហើយ ។

**ឧបក្កិលេស** បុំ.[ ឧប+កិលិស+ណ ] ធម៌ជាគ្រឿងចូលទៅសៅហ្មង, ឧបក្កិលេស; វិ. **ឧបក្កិលិស្សតិ ឯតេនាតិ> ឧបក្កិលេសោ** ។

**ឧបកីតក** គុ. [ ឧប+កី+ត+ក.ស. ] ជាអ្នកគឺ...ចូលទៅទិញហើយ, ..ពោះហើយ ។ - **វាទ** បុំ. វាទៈថាភិក្ខុឈ្មោះនន្ទគឺព្រះមានព្រះភាគពោះហើយ ។

**ឧបក្កុបក្ក** គុ. [ ឧបក្ក+ឧបក្ក ] ឆ្អិនឡើងហើយៗ, ទុំឡើងហើយៗ, ដោរឡើងហើយៗ, ដោរឡើងក្រៃលែង (ឱបក្ក<ឧ+បច+ត) ។

**ឧបគច្ឆ** កិ. [ ឧប+គម+អ+ហិ_ក., លុក ហិ ] ចូរចូលទៅដល់, ចូរចូលទៅជិត ។

**ឧបគច្ឆន្ត** គុ. [ ឧប+គម+អន្ត ] កាលចូលទៅដល់, កាលចូលទៅជិត ។

**ឧបគច្ឆន្តិ** កិ. [ ឧប+គម+អ+អន្តិ_វ. ] ចូលទៅដល់, ចូលទៅជិត ។

**ឧបគញ្ឆិ** កិ. [ ឧប+គម+អ+ឦ.អជ្ជ. ] ចូលទៅដល់ហើយ, ចូលទៅជិតហើយ ។

**ឧបគត** គុ. [ ឧប+គម+ត ] ចូលទៅដល់ហើយ, ចូលទៅជិតហើយ, នៅហើយ, កើតហើយ ។

**ឧបគន្តុំ** អ. [ ឧប+គម+តុំ ] ដើម្បីចូលទៅដល់, ដើម្បីចូលទៅជិត, ចូលទៅរក ។

**ឧបគន្ត្វា** អ. [ ឧប+គម+ត្វា ] ចូលទៅដល់ហើយ, ចូលទៅជិតហើយ, ចូលទៅរកហើយ ។

**ឧបគមន** នពុំ. [ ឧប+គម+យុ ] កិ.ចូលទៅដល់, កិ.ចូលទៅជិត; វិ. **ឧប. គម្យតេតិ> ឧបគមនំ** ។ -**ការណ** នពុំ. ហេតុគឺកិ.ចូលទៅជិត, ហេតុនៃកិ.ចូលទៅជិត ។

**ឧបគមិស្សន្តិ** កិ.[ ឧប+គម+អ+ឥ.អា.+ស្សន្តិ-ភ. ] នឹងចូលទៅដល់, នឹងចូលទៅជិត, នឹងចូលទៅរក ។

**ឧបគុយ្ហិត្វា** អ. [ ឧប+គុហ+យ+ឥ.អា.+ត្វា ] ចូលទៅលាក់ហើយ, លាក់ទុកហើយ, បិទបាំងហើយ, ចូលទៅឱបហើយ, ឱបហើយ ។

**ឧបឃាត** ពុ. [ ឧប+ហន, ហន>ឃាត+ណ ] កិ.ចូលទៅបៀតបៀន, កិ.ចូលទៅសម្លាប់, កិ.ចូលទៅខ្ជប់; វិ. **ឧបហននំ> ឧបឃាតោ** ។

**ឧបចារ** ពុំ. [ ឧប+ចរ+ណ ] ធម៌ជាគ្រឿងប្រព្រឹត្តជិត ឬកិ.ប្រព្រឹត្តិទៅជិត (ឧបចារៈ); វិ. **ឧបចរតិ ឯតេនាតិ> ឧបចារោ, ឧបចរណំ វា> ឧបចារោ** ។ -**ជ្ឈាន** នពុំ. ឈានប្រព្រឹត្តទៅដោយអំណាចនៃធម៌ជាគ្រឿងប្រព្រឹត្តជិត, ឈានប្រព្រឹត្តទៅដោយអំណាចនៃឧបចារសមាធិ ។ -**ត្ថ** ពុំ. ប្រយោជន៍ដល់ឧបចារៈ, ត្រូវការដល់ឧបចារៈ ។ -**ប្បនាវស** ពុំ. អំណាចនៃឧបចារសមាធិ



និងអប្បនាសមាធិ ។ -**សមាធិ** ពុំ. សមាធិប្រព្រឹត្តទៅក្នុងឧបចារៈ, ឧបចារសមាធិ; វិ. **ឧបចារេ បវត្តោ សមាធិ> ឧបចារសមាធិ** ។

**ឧបចិក** ពុំ. [ ឧប+ចិ+ណក ] សត្វចូលទៅកូន (កណ្ដៀរ); វិ. **ឧបចិនាតីតិ> ឧបចិកោ** ។ -**អាទិ** គុ. (សត្វ) មានកណ្ដៀរជាដើម ។

**ឧប្បត្វា** អ. [ ឧ+បត+ត្វា ] អណ្ដែតទៅហើយ, ហោះឡើងហើយ, កន្លងហើយ ។

**ឧបច្ចគា** កិ. [ ឧប+អតិ>ឧបច្ច+អ+គម+អា.-ហ៊ា. ] បានចូលទៅកន្លងហើយ, កន្លងបង់ហើយ ។

**ឧបច្ឆិជ្ជិ** កិ. [ ឧប+ឆិទ+យ+ឦ-អជ្ជ. ] ចូលទៅកាត់ហើយ, ផ្ដាច់បង់ហើយ ។

**ឧបច្ឆិន្ទតិ** កិ. [ ឧប+ឆិទ+អ+តិ-វ, ចុះនិ-អា. ] ចូលទៅកាត់, កាត់ផ្ដាច់, ផ្ដាច់ ។

**ឧបច្ឆិន្ន** គុ. [ ឧប+ឆិទ+ត ] គឺ...ចូលទៅកាត់ហើយ, -ផ្ដាច់បង់ហើយ ។

**ឧបជ្ឈាយ** ពុំ. [ ឧប+ឈេប+ណ ] អ្នកចូលទៅសំឡឹងមើលនូវទោសតូចនិងទោសធំរបស់សិស្ស (ឧបជ្ឈាយ៍); វិ. **សិស្សានំ វជ្ជាវជ្ជំ ឧបនិជ្ឈាយតីតិ > ឧបជ្ឈាយោ** ។ -**វត្ត** នពុំ. វត្តគឺសទ្ធិវិហារិកគប្បីធ្វើដល់ឧបជ្ឈាយ៍ ។ -**អាទិវត្ត** នពុំ. វត្តមានឧបជ្ឈាយវត្តជាដើម ។ -**អាទិ** គុ. ( សហធម្មិក ) មានឧបជ្ឈាយ៍ជា

ដើម ។

**ឧបញ្ញាត** គុ. [ ឧប+ញា+ត ] គឺ...ចូលទៅដឹងហើយ ។

**ឧបដ្ឋបេតិ** កិ. [ ឧប+ឋប+ណេ+តិ.វ. ] ចូលទៅតាំងទុក, ញ៉ាំង...ឱ្យចូលទៅតាំងទុក, ..ឱ្យចូលទៅដំកល់ទុក ។

**ឧបដ្ឋបេត្វា** អ. [ ឧប+ឋប+ណេ+ត្វា ] ចូលទៅដំកល់ទុកហើយ, ញ៉ាំង...ឱ្យចូលទៅតាំងទុកហើយ ។

**ឧបដ្ឋហថ** កិ. [ ឧប+ឋា+អ+ហ.អា.+ថ.ប. ] ចូរបំរើ, ចូរទំនុកបំរុង, ចូរផ្គត់ផ្គង់ ។

**ឧបដ្ឋហន្តិ** កិ. [ ឧប+ឋា+អ+ហ.អា.+អន្តិ.វ. ] បំរើ, ទំនុកបំរុង, ផ្គត់ផ្គង់ ។

**ឧបដ្ឋហន្ត** គុ. [ ឧប+ឋា+ហ.អា.+អន្ត ] កាលបំរើ, កាលទំនុកបំរុង, កាលផ្គត់ផ្គង់ ។

**ឧបដ្ឋហិ** កិ. [ ឧប+ឋា+អ+ហ.អា.+ឦ.អជ្ជ. ] បំរើហើយ, ទំនុកបំរុងហើយ, ប្រាកដហើយ ។

**ឧបដ្ឋហិតុកាម** គុ. [ ឧបដ្ឋហិតុំ+កាម ] អ្នកចង់ដើម្បីបំរើ, អ្នកចង់ដើម្បីទំនុកបំរុង, អ្នកមានប្រាថ្នាដើម្បីបំរើ ។

**ឧបដ្ឋហឹសុ** កិ. [ ឧប+ឋា+អ+ហ.អា.+ឥំសុ.អជ្ជ. ] ចូលទៅតាំងទុកហើយ, បំរើហើយ, ប្រាកដហើយ ។

**ឧបដ្ឋាក** បុំ. [ ឧប+ឋា+ណ្វុ ] អ្នកបំរើ, អ្នកទំនុកបំរុង, អ្នកផ្គត់ផ្គង ; វិ. **ឧបដ្ឋាតីតិ> ឧបដ្ឋាកោ** ។ - **កុល** នបុំ. ត្រកូលនៃជនជា



ឧបដ្ឋាក។ - **មនុស្ស** បុំ. មនុស្សអ្នកទំនុកបំរុង, មនុស្សជាឧបដ្ឋាក។

**ឧបដ្ឋាតព្វ** គុ. [ ឧប+ឋា+តព្វ ] គឺ...គប្បីទំនុកបំរុង, ..គប្បីបំរើ, ..គប្បីផ្គត់ផ្គង់ ។

**ឧបដ្ឋាតិ** កិ. [ ឧប+ឋា+អ+តិ.វ. ] ទំនុកបំរុង, បំរើ, ប្រាកដ ។

**ឧបដ្ឋាន** នបុំ. [ ឧប+ឋា+យុ ] កិ.ទំនុកបំរុង, កិ.បំរើ, កិ.ផ្គត់ផ្គង់ ; វិ. **ឧបដ្ឋីយតេតិ> ឧបដ្ឋានំ** ។ ទីជាទីគាល់; វិ. **ឧបដ្ឋាតិ ឯត្ថាតិ> ឧបដ្ឋានំ** ។ -**ការិកា** ឥ. អ្នកធ្វើនូវសេចក្តីទំនុកបំរុង ។ - **បុប្ផ** នបុំ. ផ្កាសម្រាប់បំរើ ។ - **សាលា** ឥ. សាលាជាទីបំរើ, សាលាសម្រាប់បំរើ ។ - **វេលា** ឥ. វេលាជាទីបំរើ ។

**ឧបដ្ឋាបិត** គុ. [ ឧប+ឋា+ណាបេ+ត.អា.+ត ] គឺ ..... ឱ្យទំនុកបំរុងហើយ, ..ឱ្យបំរើហើយ ។

**ឧបដ្ឋាបេត្វា** អ. [ ឧប+ឋា+ណាបេ+ត្វា ] ញ៉ាំង ... ឱ្យទំនុកបំរុងហើយ, -ឱ្យចូលទៅតាំងទុកហើយ, . ឱ្យបំរើហើយ ។

**ឧបដ្ឋាយិកា** ឥ. [ ឧប+ឋា+ណ្វុ+ឥ.អា, ផ្លាស់អា របស់ឋា>អាយ+អា.ឥ. ] អ្នកបំរើ, ស្រ្តីជាឧបដ្ឋាយិកា ; វិ. **ឧបដ្ឋាតីតិ> ឧបដ្ឋាយិកា** ។

**ឧបដ្ឋិតស្សតិ** គុ. [ ឧបដ្ឋិត+សតិ ] អ្នកមានសតិចូលទៅតាំងទុកហើយ, អ្នកមានស្មារតីដំកល់មាំហើយ; វិ. **ឧបដ្ឋិតា សតិ យេន សោ> ឧបដ្ឋិតស្សតិ** ។ - **តា** ឥ. ភាវៈនៃ...នោះជាអ្នកមានសតិចូលទៅតាំងទុកហើយ, ..ដំកល់មាំហើយ ។

**ឧបដ្ឋិត** គុ. [ ឧប+ឋា+ត, អានៃឋា>ឥ ] ចូលទៅតាំងទុកហើយ, ដំកល់មាំហើយ ។

**ឧបដ្ឋិយមាន** គុ. [ ឧប+ឋា, អានៃឋា>ឥ+យ+មាន ] គឺ...កាលបំរើ, ...កាលទំនុកបំរុង ។

**ឧបឌ្ឍ** គុ. [ ឧប+អឌ្ឍ ] ពាក់កណ្ដាល, កន្លះ ។ - **កាយ** បុំ. កាយពាក់កណ្ដាល, ពាក់កណ្ដាលនៃកាយ ។ - **បថ** បុំ. ផ្លូវពាក់កណ្ដាល, ពាក់កណ្ដាលនៃផ្លូវ ។ - **ភត្ត** នបុំ. ភត្តពាក់កណ្ដាល ។ - **រជ្ជ** នបុំ. ភាវៈនៃខ្លួនជាស្ដេចពាក់កណ្ដាល, រាជ្យពាក់កណ្ដាល, ពាក់កណ្ដាលនៃរាជ្យ ។ - **សេសកាល** បុំ. កាលនៃ...ដ៏សេសពាក់កណ្ដាល ។ - **អាវសេស** គុ. ចំណែកដ៏សេសចុះពាក់កណ្ដាល, ដ៏សេសចុះចាក...ពាក់កណ្ដាល ។ - **ឧបឌ្ឍ** គុ. ពាក់កណ្ដាលនិងពាក់កណ្ដាល, ពាក់កណ្ដាលក្រៃពេក ។ - **ឧបោសថកម្ម** នបុំ. ឧបោសថកម្មពាក់កណ្ដាល ។

**ឧប្បណ្ឌុបណ្ឌុកជាត** គុ. ( ឧប្បណ្ឌុបណ្ឌុក+ជាត ) មានរោគលឿងឡើងលឿងឡើងកើតហើយ, មានរោគលឿងក្រៃពេកកើតហើយ (ឧប្បណ្ឌុ<ឧ+បឌិ+ឧ ) ។

**ឧបតិតុំ** អ. [ ឧ+បត+ឥ.អា.+តុំ ] ដើម្បីហោះឡើង, ...អណ្ដែតឡើង, ...ហើរឡើង, ដើម្បីងើបឡើង ។

**ឧបតិស្ស** អស.ន. ឈ្មោះឧបតិស្សៈ ។ - **គ្គាម** បុំ. ស្រុកឈ្មោះឧបតិស្សៈ ។ - **មាណវ** បុំ. មាណពឈ្មោះឧបតិស្សៈ ។ - **បរិព្វាជក** បុំ. បរិព្វាជកឈ្មោះឧបតិស្សៈ ។



**ឧបត្ថម្ភ** បុំ. [ ឧប+ថភ+អ, ចុះនិ.អា. ] ការឧបត្ថម្ភ,ការគាំទ្រ, សេចក្ដីទំនុកបំរុង; វិ. **ឧបត្ថម្ភិយតេតិ> ឧបត្ថម្ភនំ, ឧបត្ថម្ភនំ> ឧបត្ថម្ភោ** ។ - **ភូត** គុ. មានសេចក្ដីទំនុកបំរុងកើតហើយ; វិ. **ឧបត្ថម្ភោ ភូតោ យស្ស សោ> ឧបត្ថម្ភភូតោ** ។

**ឧបត្ថម្ភយមាន** គុ. [ ឧប+ថភ+ណយ+មាន, ចុះនិ.អា. ] កាលទំនុកបំរុង, កាលទល់ទ្រ, កាលគាំទ្រ ។

**ឧបថចារី** បុំ. [ ឧបថ+ចរ+ណី ] អ្នកប្រព្រឹត្តខុសផ្លូវ, អ្នកមានកិ.ប្រព្រឹត្តខុសផ្លូវជាប្រក្រតី ។

**ឧបទ្ទវ** បុំ. [ ឧប+ទុ+អ ] អន្តរាយជាហេតុចូលទៅបៀតបៀន ( ឧបទ្រព, អន្តរាយ); វិ. **ឧបគន្ត្វា ទវតិ ពិឡេតិ ឯតេនាតិ> ឧបទ្ទវោ** ។

**ឧបទ្ទុត** គុ. [ ឧប+ទុ+ត ] គឺ...ចូលទៅបៀតបៀនហើយ, ...ប្រទូស្តហើយ ។

**ឧបធារណ** នបុំ. [ ឧប+ធារ ឬ ធរ+យុ ] កិ.ពិចារណា; វិ. **ឧបធារិយតេតិ> ឧបធារណំ** ។

**ឧបធារិយមាន** គុ.[ ឧប+ធរ+ឥ.អា.+យ+មាន ] គឺ...កាលចូលទៅទ្រទ្រង់, ...កាលពិចារណា, ...កាលក្រោល, ...កាលចាំង ។

**ឧបធារេត្វា** អ. [ ឧប+ធរ+ណេ+ត្វា ] ពិចារណាហើយ, ពៃលកហើយ ។

**ឧបធារេន្ត** គុ. [ ឧប+ធរ+ណេ+អន្ត ] កាលចូលទៅទ្រទ្រង់, កាលត្រិតត្រា, កាលពិចារណា ។

**ឧបធារេតិ** កិ. [ ឧប+ធរ+ណេ+តិ.វ. ] ចូលទៅទ្រទ្រង់, ពិចារណា, ត្រិតត្រា, ពៃលក ។

**ឧបធាវមាន** គុ. [ ឧប+ធាវ+មាន ] កាលស្ទុះទៅ, កាលស្ទុះចូលទៅ, កាលលឿនចូលទៅ ។

**ឧបធាវិត្វា** អ. [ ឧប+ធាវ+ឥ.អា.+ត្វា ] ស្ទុះទៅហើយ, ស្ទុះចូលទៅហើយ, លឿនចូលទៅហើយ ។

**ឧបធាវឹសុ** កិ. [ ឧប+ធាវ+អ+ឧំ.អជ្ជ. ] ស្ទុះចូលទៅហើយ, លឿនចូលទៅហើយ ។

**ឧបធិ** ចុំ. [ ឧប+ធា+ឥ ] កិលេសជាគ្រឿងចូលទៅទ្រទ្រុក; វិ. **ឧបធាតិ ឯតេនាតិ> ឧបធិ**; ( ឧបធិ ស័ព្ទនេះ ជាឈ្មោះកិលេស ៤ យ៉ាងមាន **កាមុបធិ** ជាដើម) ។ - **ពន្ធន** គុ. អ្នកមានកិលេសឈ្មោះឧបធិជាគ្រឿងចង ។ - **វិវេក** ចុំ. សេចក្ដីស្ងាត់ចាកកិលេសឈ្មោះឧបធិ ។ - **សម្បទា** ឥ. កិ.ដល់ព្រមដោយឧបធិ ឬដោយឧបធិវិវេក ។ - **សំខយ** ចុំ. ធម៌ជាទីអស់ទៅព្រមនៃកិលេសឈ្មោះឧបធិ, (**សំខយ**<សំ+ខិ+ណ) ។

**ឧបនន្ទ** អស.ន. ភិក្ខុឈ្មោះឧបនន្ទ ។ - **សក្យបុត្តវត្ថុ** នចុំ. រឿងនៃភិក្ខុជាបុត្រនៃសក្យៈឈ្មោះឧបនន្ទ ។





**ឧបនយ្ហន្ត** គុ. [ ឧប+នហ+យ+អន្ត ] កាលចូលទៅចង, កាលចងមាំ ។

**ឧបនយ្ហតិ** កិ. [ ឧប+នហ+យ+អន្តិ.វ. ] ចូលទៅចង, ចងមាំ, ចងទុក ។

**ឧបនាមេត្វា** អ. [ ឧប+នម+ណេ+ត្វា ] បង្អោនចូលទៅជិតហើយ, ញុំាង...ឱ្យបង្អោនចូលទៅហើយ, ញុំាង...ឱ្យឱនចូលទៅហើយ ។

**ឧបនាមេន្ត** គុ. [ ឧប+នម+ណេ+អន្ត ] កាលបង្អោនចូលទៅ, កាលញុំាង...ឱ្យបង្អោនចូលទៅ, ..ឱ្យឱនចូលទៅ ។

**ឧបនាមេសិ** កិ. [ ឧប+នម+ណេ+ឦ.អជ្ជ.+ស.អា. ] បង្អោនចូលទៅហើយ, បង្អោនទៅជិតហើយ ។

**ឧបនិយំសន្តិ** គុ. [ ឧប+និ+យំស+អន្ត+ឦ ] កាលចូលទៅដុស, កាលចូលទៅជ្រៀតជ្រៀត ។

**ឧបនិធាយ** អ. [ ឧប+និ+ធា+ត្វា ] ចូលទៅតាំងទុកហើយ, ដឹកល់មាំហើយ, ប្រៀបធៀបហើយ, ប្រៀបផ្ទឹមហើយ ។

**ឧបនិសិន្នកថា** ឥ. [ ឧបនិសិន្ន+កថា ] វាចាជាហេតុពោលនៃបុគ្គលអ្នកអង្គុយជិត ( **ឧបនិសិន្ន**<ឧប+និ+សទ, សទ>សីទ+ត, ត>ន្ន) ។

**ឧបនិសីទន្តិ** កិ. [ ឧប+និ+សទ, សទ> សីទ+អ+អន្តិ.វ. ] អង្គុយជិត ។

**ឧបនិសីទិតុំ** អ. [ ឧប+និ+សទ, សទ>សីទ+ឥ.អា.+តុំ ] ដើម្បីអង្គុយជិត ។

**ឧបនិស្សយ** ចុំ. [ ឧប+និ+សិ+អ ] ធម៌ជាទីចូលទៅដេកអាស្រ័យ, ឧប.

និស្ស័យ; វិ. **ឧបនិស្សយតិ ឯកវាតិ> ឧបនិស្សយោ** ។
- **ការណ** នចុំ. ហេតុនៃឧបនិស្ស័យ ។ - **ធម្មសង្ខាត** គុ. សោល គឺធម៌ជាឧបនិស្ស័យ ។ - **ពល** នចុំ. កំលាំងនៃឧបនិស្ស័យ ។ - **ភាវ** ចុំ. ភាវៈនៃ...ជាឧបនិស្ស័យ ។ - **សម្បត្តិ** ឥ. កិ.ដល់ព្រមដោយ ឧបនិស្ស័យ, សម្បត្តិគឺឧបនិស្ស័យ ។ - **សម្បន្នត្ត** នចុំ. ភាវៈនៃ... ជាអ្នកមានឧបនិស្ស័យដល់ព្រមហើយ, ជាអ្នកដល់ព្រមហើយដោយ ឧបនិស្ស័យ ។

**ឧបនិស្សាយ** អ. [ ឧប+និ+សិ+ត្វា ] ចូលទៅអាស្រ័យហើយ ។

**ឧបនីត** គុ. [ ឧប+នី+ត ] គឺ...នាំចូលទៅហើយ ។ - **វយ** គុ. អ្នកមានវ័យគឺជរានាំចូលទៅហើយ ។

**ឧបនេតិ** កិ. [ ឧប+នី+អ+តិ.វ. ] នាំចូលទៅ, នាំចូលទៅជិត ។

**ឧបនេត្វា** អ. [ ឧប+នី+ត្វា ] នាំចូលទៅហើយ, នាំចូលទៅជិតហើយ ។

**ឧបនេន្ត** គុ. [ ឧប+នី+អន្ត ] កាលនាំចូលទៅ, កាលនាំចូលទៅជិត ។

**ឧបនេស្សាមិ** កិ. [ ឧប+នី+អ+ស្សាមិ.ភ. ] នឹងនាំចូលទៅ, នឹងនាំចូលទៅជិត ។

**ឧបបជ្ជតិ** កិ.[ ឧប+បទ+យ+តិ.វ. ] ចូលទៅដល់, ចូលទៅជិតដល់, កើត ។

**ឧប្បជ្ជតិ** កិ. [ ឧ+បទ+យ+តិ.វ. ] កើត, កើតឡើង ។

**ឧបបជ្ជមាន** គុ. [ ឧប+បទ+យ+មាន ] កាលចូលទៅជិតដល់, កាលកើត, កំពុងកើត ។



**ឧប្បជ្ជមាន** គុ. [ ឧ+បទ+យ+មាន ] កាលកើត, កាលកើតឡើង ។

**ឧបបជ្ជរេ** កិ. [ ឧប+បទ+យ+តិ ឬ អន្តិ[១] វ. ] ចូលទៅដល់, កើត ។

**ឧប្បជ្ជរេ** កិ. [ ឧ+បទ+យ+តិឬ អន្តិ (១)វ ] កើត, កើតឡើង ។

**ឧបបត្តិ** ឥ. [ ឧប+បទ+តិ ] កិ.ចូលទៅដល់, កិ.កើត, កំណើត; វិ. **ឧបបជ្ជនំ> ឧបបត្តិ** ។

**ឧប្បត្តិ** ឥ. [ ឧ+បទ+តិ ] កិ.កើត, កំណើត; វិ. **ឧប្បជ្ជនំ>ឧប្បត្តិ** ។

**ឧបបរិក្ខិត្វា** អ. [ ឧប+បរិ+ឥក្ខ+ឥ.អា.+ត្វា ] ចូលទៅឃើញជុំវិញហើយ, ពិចារណាហើយ ។

**ឧបបរិក្ខិស្សតិ** កិ. [ ឧប+បរិ+ឥក្ខ+អ+ឥ.អា.+ស្សតិ.ភ. ] នឹងចូលទៅឃើញជុំវិញ, នឹងពិចារណា ។

**ឧបបារមី** [ ឧប+បារ+ឥ+ឮ ] ធម្មជាតិជាហេតុចូលទៅជិតដល់នូវត្រើយ គឺនិព្វាន (ឧបបារមី); វិ. **ឧបគន្ត្វា និព្វានបារំ ឯតិ ឯកា-យាតិ> ឧបបារមី** ។

**ឧបព្វជន្ត** គុ. [ ឧប+វជ+អន្ត ] កាលសឹក (កាលចូលទៅវៀរ) ។

**ឧបព្វជិត** គុ. [ ឧប+វជ+ឥ.អា.+ត ] សឹកហើយ ។ - **បុព្វ** គុ. ធ្លាប់សឹកហើយ ។

**ឧបព្វជិត្វា** អ. [ ឧប+វជ+ឥ.អា.+ត្វា ] សឹកហើយ ។

---
១ ផ្លាស់ តិ ឬ អន្តិ.វ.> រេ ។

ឧបព្វជិស្សាមិ កិ. [ ឧប+វជ+អ+ឥ.អា.+ស្សាមិ.ក. ] នឹងសឹក ។

ឧបព្វជេតុំ អ. [ ឧប+វជ+ណេ+តុំ ] ដើម្បីញុំាង...ឱ្យសឹក ។

ឧបព្វាជេយ្យំ កិ. [ ឧប+វជ+ណេ+ឯយ្យំ.ស. ] គប្បីញុំាង... ឱ្យសឹក, គប្បីផ្សឹក ។

ឧបព្វាជេថ កិ. [ ឧប+វជ+ណេ+ថ.ប. ] ចូរញុំាង...ឱ្យសឹក, ចូរផ្សឹក ។

ឧបព្យាហរំ គុ. [ ឧប+វិ+អា+ហរ+អន្ត+សិ.វិ, ផ្លាស់ ន្ត+សិ.វិ.>អំ ] កាលចូលទៅជិតពេល, កំពុងចូលទៅពេល ។

ឧបភោគ បុំ. [ ឧប+ភុជ+ណ ] គ្រឿងប្រើប្រាស់ជិតខាង, គ្រឿងឧប-ភោគ ។ - ជាត នបុំ. វត្ថុជាគ្រឿងប្រើប្រាស់ជិតខាង, វត្ថុជាគ្រឿងឧបភោគ ។ - បរិភោគភណ្ឌ នបុំ. ភណ្ឌៈគឺគ្រឿងឧបភោគនិងគ្រឿងបរិភោគ ( ឧបភោគ = គ្រឿងប្រើប្រាស់, បរិភោគ = គ្រឿងស៊ី) ។

ឧបមា ឥ. [ ឧប+មា+ត្តិ ] វាចាជាគ្រឿងប្រៀបធៀប (សេចក្តីប្រៀបធៀប, ឧបមា); វិ. **ឧបមីយតិ ឯតាយាតិ > ឧបមា** ។

ឧបយោគ បុំ. [ ឧប+យុជ+ណ ] កិ.ចូលទៅប្រកប, កិ.ប្រកបចូល, កិ.ប្រើប្រាស់ ; វិ . **ឧបយុញ្ជិយតេតិ> ឧបយុញ្ជនំ, ឧប.យុញ្ជនំ> ឧបយោគោ** ។

ឧបរចិត គុ. [ ឧប+រច+ឥ.អា.+ត ] គឺ...ចូលទៅតាក់តែងហើយ, .រចនាហើយ ។



ឧបរមាម កិ. [ ឧប+រម+អ+ម.វ. ] លំបាក, ត្រជាបត្រដួស, វៀរលែង ។

ឧបរាជ បុំ. [ ឧប+រាជ ] ស្តេចជិត, ស្តេចបន្ទាប់, ឧបរាជ ។ - សេនា-បតិអាទិ គុ. ( ឥស្សរជន ) មានឧបរាជនិងសេនាបតីជាដើម ។ - អាទិ គុ. ( ឥស្សរជន ) មានស្តេចបន្ទាប់ជាដើម ។

ឧបរិ និ. [ ចុះក្នុងអត្ថនៃសត្តមី ] ក្នុងខាងលើ, ជាន់លើ, ឰដ៏ខាងលើ ។ - ឧម្មារ បុំ. ធរណីក្នុងខាងលើ, ខាងលើនៃធរណី ។ - តីរ នបុំ. ឆ្នេរ (ត្រើយ, ច្រាំង) ក្នុងខាងលើ, ខាងលើនៃឆ្នេរ ។ - បា្បសាទ បុំ. ប្រាសាទជាន់លើ, ខាងលើនៃប្រាសាទ ។ - បា្បសាទតល នបុំ. ផ្ទៃនៃប្រាសាទជាន់លើ ។ - ទេវលោកសម្បាបក គុ. ដែលញុំាងសត្វឱ្យដល់ព្រមនូវទេវលោកជាន់លើ ។ - ពន្ធវិចិត្រ-វិតាន នបុំ. ពិតានដ៏វិចិត្រដែលបុគ្គលចងឰដ៏ខាងលើ ។ - ភូមិ ឥ. ផែនដីក្នុងខាងលើ, ខាងលើនៃផែនដី, .ជាន់លើ ។ - មគ្គត្តយកិច្ច នបុំ. កិច្ចដោយប្រជុំនៃបីនៃមគ្គក្នុងខាងលើ (១) ។ - មគ្គវស បុំ. អំណាចនៃមគ្គក្នុងខាងលើ ។ - វិសេស បុំ. គុណវិសេសក្នុងខាងលើ ។ - មត្ថក បុំ. ទីចំផុតខាងលើ ។ - សីស នបុំ. ក្បាលក្នុងខាងលើ,ខាងលើនៃក្បាល ។

ឧបរិម គុ. [ ឧបរិ+ឥម ] មានក្នុងខាងលើ; វិ. **ឧបរិ ភវោ> ឧប.**

---

១. កិច្ចគឺប្រជុំនៃ បីនៃមគ្គជាន់លើ ។

**វិធោ** ។ - **កាយ** បុ. កាយមានក្នុងខាងលើ ។ - **កោដិ** ឥ. ទីចំផុតមានក្នុងខាងលើ ។ - **ផល** នបុ. ផ្លែមានក្នុងខាងលើ ។ - **បាទ** បុ. ជើងមានក្នុងខាងលើ ។

**ឧបរុន្ធតុ** កិ. [ ឧប+រុធ+អ+តុ_ប.+និ.អា. ] ចូរចូលទៅបិទ, ចូរឡោមទុក, ចូរខ្ទប់, ចូររាំង ។

**ឧបរុន្ធិ** កិ. [ ឧប+រុធ+អ+ឦ_អជ្ជ. ] ចូលទៅបិទហើយ, ឡោមទុកហើយ, ខ្ទប់ហើយ, រាំងហើយ ។

**ឧបរុន្ធិត្វា** អ. [ ឧប+រុធ+ឥ_អា+ត្វា ] ចូលទៅបិទហើយ, ឡោមទុកហើយ, ... ។

**ឧបរូបរិ** និ. ក្នុងខាងលើៗ ។ - **បទ** នបុ. បទក្នុងខាងលើៗ ។

**ឧបលិម្បតិ** កិ. [ ឧប+លិប+អ+តិ_វ+និ.អា ] ចូលទៅលាប, ចូលទៅប្រឡាក់, ប្រក, ជាប់, ទើរ ។

**ឧបលិម្បិត្វា** អ. [ ឧប+លិប+ឥ_អា+ត្វា ] ចូលទៅលាបហើយ, ចូលទៅប្រឡាក់ហើយ, ប្រកហើយ, ជាប់ហើយ ។

**ឧបវត្តន** នបុ. [ ឧប+វត្តុ+យុ ] ទីជាទីប្រព្រឹត្តចូលទៅជិត; វិ. **ឧបេច្ច វត្តន្តិ តច្ចន្តិ ឯត្ថាតិ> ឧបវត្តនំ** ។

**ឧបវន** នបុ. [ ឧប+វន ] ព្រៃជិត, ទីជិតនៃព្រៃ, ឬទីប្រព្រឹត្តទៅក្នុងទីជិតនៃព្រៃ; វិ. **វនស្ស សមីបំ> ឧបវនំ, វនស្ស សមីបេ វត្តតីតិ វា > ឧបវនំ** ។ សមីប> ឧប ។



**ឧបវសន្តិ** កិ. [ ឧប+វស+អ+អន្តិ.វ. ] ចូលទៅនៅ, នៅអាស្រ័យ, រក្សា ។

**ឧបវាណត្ថេរ** បុ. [ ឧបវាណ+ថេរ ] ព្រះថេរៈឈ្មោះឧបវាណៈ ។

**ឧបសគ្គ** បុ. [ ឧប+សជ+អ ] គ្រោះចូលទៅជិតជាប់ ឬកិ.ចូលទៅជិតជាប់ (អន្តរាយ, ការរឹបជាន់, ឧបស័គ្គ; វិ. **ឧបគន្ត្វា សជ្ជតិ បជា-សេតីតិ> ឧបសគ្គោ, ឧបសជ្ជនំ វា> ឧបសគ្គោ**) ។

**ឧបសង្កមន** នបុ. [ ឧប+សំ+កម+យុ ] កិ.ចូលទៅជិត, កិ.ចូលទៅរក, កិ.ចូលទៅគាល់; វិ. **ឧបសង្កមិយតេតិ> ឧបសង្កមនំ** ។ - **សៃ** បុ. អំណាចនៃកិ.ចូលទៅរក ។ - **អារហ** គុ. គួរដល់កិ.ចូលទៅរក, គួរដើម្បីកិ.ចូលទៅរក ។

**ឧបសង្កមន្ត** គុ. [ ឧប+សំ+កម+អន្ត ] កាលចូលទៅជិត, ...។

**ឧបសង្កមិ** កិ. [ ឧប+សំ+កម+អ+ឦ_អជ្ជ. ] ចូលទៅជិតហើយ, ចូលទៅរកហើយ ។

**ឧបសង្កមិតុំ** អ. [ ឧប+សំ+កម+ឥ_អា+តុំ ] ដើម្បីចូលទៅជិត, ... ។

**ឧបសង្កមិត្វា** អ. [ ឧប+សំ+កម+ឥ_អា.+ត្វា ] ចូលទៅជិតហើយ, ចូលទៅរកហើយ, ចូលទៅគាល់ហើយ ។

**ឧបសង្កមិស្សតិ** កិ. [ ឧប+សំ+កម+អ+ឥ_អា.+ស្សតិ_ភ. ] នឹងចូលទៅជិត, ... ។

**ឧបសន្ត** គុ. [ ឧប+សម+ត, ត>ន្ត, លុប ម ] ចូលទៅរម្ងាប់ហើយ ។ - **តា**

ឥ. ភាវៈនៃ...ជា...ចូលទៅរំងាប់ហើយ ។ - **រាគាទិក្កិលេស** ចុំ. អ្នកមានកិលេសមានរាគៈជាដើមចូលទៅរំងាប់ហើយ, អ្នកមានរាគាទិក្កិលេសចូលទៅរំងាប់ហើយ ។ - **រូប** នចុំ. អ្នកមានរូបចូលទៅរំងាប់ហើយ , មានសភាពចូលទៅរំងាប់ហើយ ។

**ឧបសម** ចុំ. [ ឧប+សម+អ ] ធម៌ជាទីចូលទៅរំងាប់, ធម៌ជាគ្រឿងចូលទៅរំងាប់, កិ.ចូលទៅរំងាប់ ឬសេចក្ដីស្ងប់; វិ. **ឧបសម្មតិ ឯត្ថាតិ> ឧបសមោ, ឧបសម្មតិ ឯតេនាតិ> ឧបសមោ, ឧបសមនំ> ឧបសមោ** ។

**ឧបសម្បជ្ជ** អ. [ ឧប+សំ+បទ+ត្វា ] ចូលទៅដល់ព្រមហើយ ។

**ឧបសម្បទា** ឥ. [ ឧបរិ+សំ+បទ+អ+អា.ឥ. ] ( ធម្មជាតិ ) ជាហេតុដល់ព្រមនូវភាវៈក្នុងខាងលើ, កិ. ដល់ព្រមនូវភាវៈក្នុងខាងលើ (ឧបសម្បទ); វិ. **ឧបរិភាវំ សម្បជ្ជតិ ឯតាយាតិ> ឧបសម្បទា, ឧបរិភាវស្ស សម្បជ្ជនំ> ឧបសម្បទា** ។ - **កាល** ចុំ. កាលនៃឧបសម្បទ ។

**ឧបសម្បន្ន** គុ. [ ឧបរិ+សំ+បទ+ត ] ដល់ព្រមក្នុងខាងលើហើយ, ឧបសម្បទហើយ ។

**ឧបសម្បាទេត្វា** អ. [ ឧបរិ+សំ+បទ+ណេ+ត្វា ] ញុំាង...ឱ្យឧបសម្បទហើយ ។

**ឧបសម្មតិ** កិ. [ ឧប+សម+យ+តិ.វ. ] ចូលទៅរំងាប់ ។



**ឧបសំវសេ** កិ. [ ឧប+សំ+វស+អ+ឯយ្យ.ស. ] គប្បីចូលទៅនៅរួម ។

**ឧបសាឡ្ហកជាតក** នចុំ. [ ឧបសាឡ្ហក+ជាតក ] ជាតកគឺបណ្ឌិតកំណត់ហើយដោយព្រាហ្មណ៍ឈ្មោះឧបសាឡ្ហកៈ ។

**ឧបសាឡ្ហកនាម** គុ. [ ឧបសាឡ្ហក+នាម ] (ព្រាហ្មណ៍)ឈ្មោះឧបសាឡ្ហកៈ, មានឈ្មោះថាឧបសាឡ្ហកៈ ។

**ឧបសេចន** នចុំ. [ ឧប+សិច+យុ ] កិ.ចូលទៅស្រោច, កិ.លាយ, ជាគ្រឿងលាយ ។

**ឧបសេន** អស.ន. ឈ្មោះឧបសេនៈ ។

**ឧបសេវន្ត** គុ. [ ឧប+សេវ+អន្ត ] កាលចូលទៅសេព, កាលចូលទៅសេពគប់ ។

**ឧបហត** គុ. [ ឧប+ហន+ត ] គឺ...ចូលទៅបៀតបៀនហើយ, - ចូលទៅកំចាត់ហើយ (-គោះហើយ) ។

**ឧបហនន្ត** គុ. [ ឧប+ហន+អន្ត ] កាលចូលទៅបៀតបៀន ។

**ឧបាគមិ** កិ. [ ឧប+អា+គម+អ+ឦ.អជ្ជ. ] ចូលទៅជិតហើយ, ចូលមកជិតដល់ហើយ, ចូលមកដល់ហើយ ។

**ឧបាទាន** នចុំ. [ ឧប+អា+ទា+យុ ] ធម្មជាតដែលជនចូលទៅជិតកាន់យក, សេចក្ដីប្រកាន់មាំ ( ឧបាទាន ) ; វិ. **ឧបាទិយតេតិ> ឧបាទានំ** ។ (វត្ថុ)ដែលភ្លើងចូលទៅកាន់យក (កំពូម); វិ. **ឧបាទិយតេ អគ្គិនាតិ> ឧបាទានំ** ។

**ឧបាទាយ** អ. [ឧប+អា+ទា+ត្វា] ព្រោះចូលទៅកាន់យក, ព្រោះប្រកាន់មាំ, ប្រៀបធៀប, អាស្រ័យ, ត្រឹមតែ (ប្រែជាបុព្វកាលក៏បាន) ។

**ឧបាទិន្នក** គុ. [ឧប+អា+ទា+ត, ត> ឥន្ន+ក.ស.] (សង្ខារ) គឺវិញ្ញាណចូលទៅកាន់យកហើយ (សត្វមានវិញ្ញាណ) ។

**ឧបាយ** ពុំ. [ឧប+អយ+អ ឬឧប+ឥ+ណ] ហេតុជាគ្រឿងចូលទៅដល់នូវកិ.ផ្ចាញ់នូវសត្រូវ ឬ ហេតុជាគ្រឿងចូលទៅដល់ (ឧបាយ); វិ. **សត្តុវិជយំ ឧបគច្ឆន្តិ ឯតេហីតិ>ឧបាយោ, ឧបេតិ ឯតេនាតិ វា> ឧបាយោ** ។

**ឧបាលិ** អស.ន. ភិក្ខុឈ្មោះឧបាលិ, ខ្ទាន់ប្រកេសឈ្មោះឧបាលិ ។ - **កប្បកសត្តម** គុ. មានខ្ទាន់ប្រកេសឈ្មោះឧបាលិជាទី៧ ឬ ជាគំរប់៧ ។ - **ត្ថេរ** ពុំ. ព្រះថេរៈឈ្មោះឧបាលិ ។

**ឧបាសក** ពុំ. [ឧប+អាស+ណ្វុ] អ្នកចូលទៅអង្គុយជិតនូវព្រះរត្នត្រ័យ (ឧបាសក); វិ. **រតនត្តយំ ឧបាសតីតិ> ឧបាសកោ** ។ - **បរិសា** ឥ. បរិស័ទជាឧបាសក, បរិស័ទគឺឧបាសក ។ ឥ. **ឧបាសិកា**<ឧប+អាស+ណ្វុ+ឥ.អក+អា.ឥ ។

**ឧបាហនមណ្ឌន** នពុំ.( ឧបាហន+មណ្ឌន ) គឺ.ប្រដាប់នូវទ្រនាប់ជើង ឬ ស្បែកជើង ។

**ឧបេក្ខក** ពុំ. [ ឧប+ឥក្ខ+ណ្វុ ] អ្នកចូលទៅសំឡឹងមើល, អ្នកចូលទៅពិនិត្យមើល, អ្នកព្រងើយកន្តើយ, អ្នកសោះអង្គើយ; វិ. **ឧបេក្ខតីតិ > ឧបេក្ខកោ** ។





**ឧបេតិ** កិ. [ ឧប+ឥ+អ+តិ.វ. ] ចូលទៅដល់, ចូលទៅជិត, នៅ ។

**ឧបេត** គុ. [ ឧប+ឥ+ត ] ចូលទៅដល់ហើយ, ចូលទៅជិតហើយ, ប្រកបហើយ ។

**ឧបេថ** កិ. [ ឧប+ឥ+អ+ថ.ប. ] ចូរចូលទៅដល់, ចូរចូលទៅជិត ។

**ឧបេន្តិ** កិ. [ ឧប+ឥ+អ+អន្តិ.វ. ] ចូលទៅដល់, ចូលទៅជិត, នៅ ។

**ឧបេមិ** កិ. [ ឧប+ឥ+អ+មិ.វ. ] ចូលទៅដល់, ចូលទៅជិត, នៅ ។

**ឧបេហិសិ** កិ. [ ឧប+ឥ+អ+ហ.អក+ឥ.អក+ស្សសិ.ភ., លុបស្ស ] នឹងចូលទៅដល់, នឹងចូលទៅជិត, នឹងទៅ ។

**ឧបោសថ** (១) ពុំ. [ ឧប+វស+ថ, ផ្លាស់វ>ឧ ] ធម៌ជាទីនៅអាស្រ័យ ឬ ជាទីរក្សា (ឧបោសថ); វិ. **ឧបវសន្តិ ឯត្ថាតិ> ឧបោសថោ** ។ - **កម្មវត្ថុ** នពុំ. រឿងនៃឧបោសថកម្ម ។ - **កម្ម** នពុំ. កម្មគឺកិ.រក្សានូវឧបោសថ ។ - **កិច្ចាទិ** គុ. (កិច្ច) មានកិច្ចគឺកិ.ធ្វើនូវឧបោសថជាដើម ។ - **កុល** នពុំ. ត្រកូលនៃដំរីឈ្មោះ ឧបោសថ ។ - **ង្គ** នពុំ. អង្គនៃឧបោសថ ។ - **ត្ថ** ពុំ. ប្រយោជន៍ ដល់ឧបោសថ, ត្រូវការដល់ឧបោសថ, ប្រយោជន៍ដល់កិ.រក្សានូវឧបោសថ ។ - **ទិវសភាវ** ពុំ. ភាវៈនៃថ្ងៃជាទីរក្សានូវឧបោសថ ។ - **ទិវស** ពុំ; នពុំ.

(១) ឧបោសថ <ឧប+ឧស+ថ= ធម៌ជាទីកំចាត់បង់នូវអកុសល ។

ថ្ងៃនៃឧបោសថ, ថ្ងៃជាទីរក្សានូវឧបោសថ ។ - **វាស** បុំ. នៅ ឬ កិ.នៅដោយអំណាចនៃឧបោសថ, នៅដោយអំណាចនៃកិ.រក្សានូវឧបោសថ, រក្សានូវឧបោសថ ។

**ឧបោសថាគារ** បុំ., នបុំ. [ ឧបោសថ+អគារ ] រោងនៃឧបោសថ ។ - **វត្ត** នបុំ. វត្តគឺសង្ឃគប្បីធ្វើក្នុងរោងនៃឧបោសថ; វិ. **ឧបោសថាគារេ កត្តព្វំ វត្តំ> ឧបោសថាគារវត្តំ** ។ - **អាទិករណ-វសេ** បុំ. អំណាចនៃកិ.ធ្វើនូវទីមានរោងនៃឧបោសថជាដើម ។

**ឧបោសថិក** គុ. [ ឧបោសថ+ណិក ] អ្នករក្សានូវឧបោសថ; វិ. **ឧបោសថំ រក្ខតីតិ> ឧបោសថិកោ** ។ - **ភត្ត** នបុំ. ភត្តគឺបុគ្គលគប្បីឲ្យក្នុងថ្ងៃឧបោសថ; វិ. **ឧបោសថេ ទាតព្វន្តិ> ឧបោសថិកំ, ឧបោសថិកំ ភត្តំ> ឧបោសថិកភត្តំ** ។ - **ភាវ** បុំ. ភាវៈនៃ... ជាអ្នករក្សានូវឧបោសថ ។

**ឧប្បជ្ជ** កិ. [ ឧ+បទ+យ+ហិ.ប., លុបហិ ] ចូរកើត, ចូរកើតឡើង ។

**ឧប្បជ្ជនក** [ ឧ+បទ+យ+យុ+ក.ស. ឬ ណុ ] ដែលកើតឡើង, កិ.កើតឡើង, ជាទីកើតឡើង ។ - **តណ្ហា** ឥ. តណ្ហាដែលកើតឡើង ។ - **លោភ** បុំ. លោភដែលកើតឡើង ។

**ឧប្បជ្ជន្ត** គុ. [ ឧ+បទ+យ+អន្ត ] កាលកើតឡើង, កំពុងកើត ។

**ឧប្បជ្ជន** នបុំ. [ ឧ+បទ+យ+យុ ] កិ.កើតឡើង, ជាទីកើតឡើង; វិ. **ឧប្បជ្ជិយតេតិ> ឧប្បជ្ជនំ, ឧប្បជ្ជតិ ឯត្ថាតិ> ឧប្ប-**



**ជ្ជនំ** ។ - **ភិជ្ជនសភាវ** គុ. មានកិ.កើតឡើងនិងកិ.បែកធ្លាយជាសភាវៈ ឬជាធម្មតា ។

**ឧប្បជ្ជន្តិ** កិ. [ ឧ+បទ+យ+អន្តិ.វ. ] កើតឡើង ។

**ឧប្បជ្ជិត្វា** អ. [ ឧ+បទ+យ+ឥ.អា+ត្វា ] កើតឡើងហើយ ។

**ឧប្បជ្ជេយ្យ** កិ. [ ឧ+បទ+យ+ឯយ្យ.ស. ] គប្បីកើតឡើង ។

**ឧប្បតន** នបុំ. [ ឧ+បត+យុ ] កិ.លោតឡើង, កិ.ហោះឡើង, កិ.អណ្តែតឡើង ។

**ឧប្បតមាន** គុ. [ ឧ+បត+មាន ] កាលហោះឡើង, កាលអណ្តែតឡើង ។

**ឧប្បតិត** គុ. [ ឧ+បត+ឥ.អា+ត ] លោតឡើងហើយ, កើតឡើងហើយ, ហោះឡើងហើយ, អណ្តែតឡើងហើយ ។

**ឧប្បតិតុកាម** គុ. [ ឧប្បតិតុំ+កាម ] ចង់ដើម្បីហោះឡើង, ហើរឡើង ។

**ឧប្បតិតុំ** អ. [ ឧ+បត+ឥ.អា+តុំ ] ដើម្បីហោះឡើង, ...។

**ឧប្បតិត្វា** អ. [ ឧ+បត+ឥ.អា+ត្វា ] ហោះឡើងហើយ, លោតឡើងហើយ, ហើរឡើងហើយ ។

**ឧប្បតិស្សាមិ** កិ. [ ឧ+បត+អ+ឥ.អា.+ស្សាមិ.ភ. ] នឹងហោះឡើង, នឹងលោតឡើង, នឹងហើរឡើង ។

**ឧប្បត្តិ** ឥ. [ ឧ+បទ+តិ ] កិ.កើតឡើង, ហេតុជាគ្រឿងកើតឡើង ។ - **កាល** បុំ. កាលនៃកិ.កើតឡើង, កាលជាទីកើតឡើង ។ - **ក្ខណ** បុំ. ខណៈនៃកិ.កើតឡើង, ខណៈជាទីកើតឡើង ។ - **ដ្ឋាន** នបុំ.

ទីនៃកិ.កើតឡើង, ទីជាទីកើតឡើង ។ - **វត្ថុ** នថុំ. រឿងនៃកិ.កើតឡើង, រឿងគឺហេតុជាគ្រឿងកើតឡើង ។

**ឧប្បត្តិត** គុ. [ ឧ+បទ+តិ+ត.ស. ] ដែលកើតឡើងហើយ, គឺ...ឲ្យកើតឡើងហើយ ។

**ឧប្បថចារ** ថុំ. [ ឧប្បថ+ចរ+ណ ] កិ.ប្រព្រឹត្តខុសផ្លូវ, កិ.ប្រព្រឹត្តខុសចាកផ្លូវ, កិ.ប្រព្រឹត្តខុសគន្លង ។

